# កម្រងរូបភាពសម្រាប់គម្រោងដើមដំបូង

## កូនសៀវភៅព្រះគម្ពីរ ភាគ២

## មេរៀន១៤ពីដល់២៦

## គម្រោងរបស់ អេ អេស អាយ (ASI)

ការចាប់ផ្ដើមដំបូង - គម្រោងកម្រងរូបភាព

ប្រវត្តិ

គម្រោងកម្រងរូបភាពត្រូវបានចាប់ផ្តើមធ្វើដំបូង នៅពេលដែលគម្រោងជាប់ទាក់ទងទៅនឹង សមាជិកទាំងអស់ (Total Member Involvement – TMI) នៅប្រទេសវ៉ូវ៉ាន់ដា បានបង្ហាញថា នៅតាមតំបន់ដែលផ្សព្វផ្សាយដំណឹងជាច្រើន កន្លែងមិនមានភ្លើងអគ្គិសនី ហេតុដូច្នេះហើយទើបគ្មានគំនូររូបភាពសម្រាប់ជួយក្នុងការបង្រៀនមេរៀន(តាមបែបទំនើប)។

គម្រោងលំអិត

ការកើតមានគម្រោងកម្រងរូបភាព ត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដោយ អេ អេស អាយ ហើយនិងក្រុមជំនុំដែលជឿថា ដំណឹងល្អត្រូវតែផ្សព្វផ្សាយដល់ចុងបំផុតនៃផែនដី។ កម្រងរូបភាពទាំងនេះ គឺមិនត្រូវបានអនុញ្ញាតឲ្យផ្លោះប្តូរជាមួយនឹងទំនិញផ្សេងៗ ឬលក់ដូរឡើយ ព្រោះវាគឺជាអំណោយផ្តល់ឲ្យពី អេ អេស អាយ។

សេចក្តីណែនាំ

មេរៀនទាំងអស់មាន២៦។ មេរៀននីមួយៗមានបីផ្នែក។ ផ្នែកទី១-មេរៀនអំពីសុខភាព។ ផ្នែកទី២-មេរៀនព្រះគម្ពីរ។ ផ្នែកទី៣-សំណួរពិភាក្សាជាក្រុមតូចៗ។

មេរៀននីមួយៗ គឺចាប់ផ្តើមដោយមេរៀនអំពីសុខភាព បន្ទាប់មកគឺមានមេរៀនព្រះគម្ពីរ ហើយបន្ទាប់ពីនោះក៏មានពេលវេលាខ្លះសម្រាប់ពិភាក្សានូវសំណួរត្រិះរិះ។

**មាតិកា**


មេរៀនសុខភាពទី១៤ - ហាត់ប្រាណដើម្បីឲ្យមានកំលាំងពលំ .......... 3

មេរៀនសុខភាពទី១៥ - ភេសជ្ជៈ (ប្រើជំនួសទឹក) .......... 12

មេរៀនសុខភាពទី១៦ - ការព្យាបាលដោយប្រើទឹក .......... 21

មេរៀនសុខភាពទី១៧ - កិត្តិយស និងការគោរព (ជំងឺដែលឆ្លងតាមរយៈការរួមភេទ -STIs) .......... 31

មេរៀនសុខភាពទី១៨ - ជំងឺអេដស៍ ជាជំងឺឆ្លងរាតត្បាតដែលអាចបង្កាមិនឲ្យកើតឡើងបាន .......... 40

មេរៀនសុខភាពទី១៩ - ជីវិត គឺរស់នៅក្នុងឈាម .......... 49

មេរៀនសុខភាពទី២០ - ជំងឺបេះដូង គឺជាឃាតករលេខ១ក្នុងពិភពលោក .......... 59

មេរៀនសុខភាពទី២១ - ជំងឺដែលកើតឡើងដោយសារសត្វមូស .......... 67

មេរៀនសុខភាពទី២២ - អនាម័យនៅតាមផ្ទះសម្បែង .......... 78

មេរៀនសុខភាពទី២៣ - ជំងឺទឹកនោមផ្អែម គឺជាជំងឺដែលបំផ្លាញ .......... 89

មេរៀនសុខភាពទី២៤: អាហារជាតិម្សៅ - អាហារដែលមានថាមពលខ្ពស់ .......... 100

មេរៀនសុខភាពទី២៥ - ជំងឺបាក់ទឹកចិត្ត (អន្លង់ជ្រៅ) .......... 110

មេរៀនសុខភាពទី២៦: ដានីញ៉ែល - របៀបរស់នៅរបស់ព្រះសម្រាប់សុខភាពល្អ .......... 119

# មេរៀនសុខភាពទី១៤ - ហាត់ប្រាណដើម្បីឲ្យមានកំលាំងពលំ



១. ព្រះគម្ពីរនិយាយមកកាន់ពួកយើងអំពីសុខភាព។ វាប្រាប់យើងថា ព្រះជាម្ចាស់បានបង្កើតអាដាម និងអេវ៉ា ហើយដាក់ពួកគេឲ្យរស់នៅ និងធ្វើការនៅក្នុងសួនអេដែន។ ការដាំដំណាំនៅទីនោះងាយស្រួល ហើយវាជាការងារដែលល្អ ដែលសប្បាយរីករាយ។ តែគួរឲ្យស្តាយ ពួកគេបានប្រព្រឹត្តអំពើបាប ហើយត្រូវចាកចេញពីសួនដែលជាលំនៅរបស់ពួកគេ។

នៅទីកន្លែងថ្មី ការងារធ្ងន់ជាងមុនសម្រាប់អាដាម។ ថ្ងៃក្តៅ ហើយគាត់ហត់នឿយ និងបែកញើស។ ប៉ុន្តែព្រះ ទ្រង់បានជ្រាបថា ការងារនៅក្រោមពន្លឺថ្ងៃ និងខ្យល់បរិសុទ្ធរក្សារាងកាយឲ្យមានសុខភាពល្អ និងស្រឡះខួរក្បាល ហើយព្រះបានប្រទានពរដល់ការងាររបស់គាត់។

ព្រះគម្ពីរមិនបាននិយាយអ្វីអំពីអេវ៉ាធ្វើការនៅក្នុងសួនឡើយ។ តែបាននិយាយអំពីអេវ៉ាបង្កើតកូនចៅ ហើយមើលថែពួកគេទៅវិញ។

..............................................................................................................................

២. ការរត់ធ្វើឲ្យអ្នកខំប្រឹងដកដង្ហើម ហើយបេះដូងរបស់អ្នកលោតកាន់តែលឿន។ អ្នកបែកញើស។ ក្រោយមកអ្នកមានអារម្មណ៍ថាអស់កំលាំង តែស្រួលខ្លួន។ ខួរក្បាលរបស់អ្នកធ្វើការលឿន អ្នកស្រេកឃ្លាន អ្នកញុំាទឹកច្រើន ហើយអ្នកគេងលក់ស្រួល។ រាងកាយរបស់អ្នកអាចប្រយុទ្ធទប់ទល់នឹងជំងឺបានល្អប្រសើរ។ ហើយអ្នកសប្បាយចិត្តជាងមុន។

ការហាត់ប្រាណអាចនឿយហត់ ប៉ុន្តែ វាមានផលប្រយោជន៍ច្រើន ហើយត្រូវហាត់ប្រាណជារៀងរាល់ថ្ងៃ។ ការហាត់ប្រាណរបស់អ្នកអាចរាប់បញ្ចូលទាំងការជិះកង់ ឬក៏ការងារដោយប្រើផ្នែករាងកាយ ដូចជាធ្វើសួនដំណាំ។ ការដើរគឺជាការហាត់ប្រាណដែលល្អបំផុត។ វាមិនធ្ងន់ចំពោះរាងកាយ។ ការហាត់ប្រាណនោះល្អ បើហាត់នៅខាងក្រៅនៅក្រោមពន្លឺថ្ងៃ មានខ្យល់បរិសុទ្ធ និងនៅក្នុងធម្មជាតិ។ វានឹងជួយស្តារទាំងរាងកាយ ហើយ និងចិត្តគំនិត ហើយជួយប្រយុទ្ធទប់ទល់នឹងជំងឺ។

ការហាត់ប្រាណជួយពង្រឹងសាច់ដុំបេះដូងរបស់អ្នក ដើម្បីឲ្យវាអាចផ្តល់អាហារល្អ និងខ្យល់ល្អ ដែលចាំបាច់សម្រាប់ឲ្យមានសុខភាពល្អ ហើយរក្សាអ្នកឲ្យមានជីវិតរស់នៅ។

ការអង្គុយច្រើន ឬយូរពេក និងការគេងលេង ឬលក់យូរពេក អាចធ្វើឲ្យបេះដូងអ្នកចុះខ្សោយ ធ្វើឲ្យវាលោតញាប់ ហើយបណ្តាលឲ្យអ្នកឆាប់ហត់។ បេះដូងរបស់អ្នក គឺជាសាច់ដុំហើយសាច់ដុំត្រូវការធ្វើការដើម្បីឲ្យវានៅរឹងមាំល្អ។

..............................................................................................................................

៣. តើបេះដូងរបស់អ្នកត្រូវការការហាត់ប្រាណច្រើនប៉ុណ្ណា?

ការហាត់ប្រាណពង្រឹងបេះដូង យ៉ាងហោចណាស់ឲ្យបានសាមសិបនាទីក្នុងមួយថ្ងៃ គឺល្អសម្រាប់ទាំងមនុស្សប្រុស និងមនុស្សស្រី។ កូនតូចៗក៏ត្រូវហាត់ប្រាណដែរ។ ការរត់ លោត និងលេងនៅខាងក្រៅជួយបង្កើនថាមពលនៃការរៀនសូត្រ ក៏ដូចជាកំលាំងសាច់ដុំរបស់ពួកគេដែរ។

សួតរបស់អ្នកធ្វើការជុំគ្នាជាមួយនឹងបេះដូងរបស់អ្នក។ សួតទាំងនេះស្រូបយកខ្យល់បរិសុទ្ធ ហើយដកយកខ្យល់ដែលបានប្រើប្រាស់រួចហើយចេញ។ សួតរបស់អ្នកអាចរមូល ហើយមិនអាចធ្វើការងាររបស់វាបានល្អបំផុតនោះឡើយ បើសិនជារបៀបឈរ ឬអង្គុយរបស់អ្នកមិនបានល្អ។

តើអ្នកដឹងដោយរបៀបណា ថារបៀបឈរឬអង្គុយរបស់អ្នកល្អឬមិនល្អនោះ? ចូរចងខ្សែ ហើយដាក់ទម្ងន់ចងនៅខាងចុង ហើយឈរពីចំហៀងនៅក្បែរវា។ បើសិនជារបៀបឈរនឹងអង្គុយរបស់អ្នកល្អ ខ្សែនោះនឹងស្របជាមួយនឹងត្រចៀក ស្មារ និងនៅកណ្តាលជង្គង់ ហើយនិងកជើងរបស់អ្នក។ បើមិនល្អទេ ត្រូវហាត់ឈរឲ្យត្រង់រហូតទាល់តែរបៀបឈរ ឬអង្គុយរបស់អ្នកត្រឹមត្រូវល្អ។

............................................................................................................................................

៤. សួតមានទម្ងន់១.៣ គ.ក. (៣ផោន) មានផ្ទៃខ្យល់២៤០០គ.ម. (១៥០០ ម៉ាលស៍) និងមានកោសិកានៃផ្នែកក្រអូមមាត់នៅក្រោយធ្មេញចំនួន៤០០លាន ដែលកោសិកាទាំងអស់នោះត្រូវការជាតិសំណើមដើម្បីដំណើរការ។ បើគ្មានទឹកគ្រប់គ្រាន់ជារៀងរាល់ថ្ងៃនោះទេ ការបញ្ចេញចោលរបស់សួត ហើយនិងឈាមឡើងខាប់ ហើយហូរយឺត។ ដូចនេះ វាកាត់បន្ថយការផ្តល់អុកស៊ីហ្សែនទៅកាន់កោសិកា ហើយនិងការដកយកចេញនូវខ្យល់ដែលប្រើប្រាស់រួច និងកាកសំណល់ឧស្ម័ន និងឧស្ម័នកាបូនិច។

ដើម្បីឲ្យមានសុខភាពល្អបំផុត អ្នកត្រូវការដកដង្ហើមស្រូបយកខ្យល់ល្អឲ្យចូលពេញសួត។ ដើម្បីសាកល្បងខ្លួនឯង ចូរគេងនៅលើទីដែលមានផ្ទៃរាប ហើយដាក់របស់ដែលសំប៉ែតដូចជាឆ្នាំងនៅលើពោះរបស់អ្នក។ ដកដង្ហើមតាមធម្មតា។ បើសិនជាពោះរបស់អ្នកប៉ោងឡើងនៅពេលដែលអ្នកដកដង្ហើមចូល នោះមានន័យថា អ្នកប្រើប្រាស់សួតរបស់អ្នកបានត្រឹមត្រូវហើយ។ បើសិនជាឆ្នាំងនោះនៅនឹង ហើយមានតែដើមទ្រូងរបស់អ្នកមានចលនា នោះបានន័យថា អ្នកប្រើប្រាស់តែសួតនៅផ្នែកខាងលើប៉ុណ្ណោះ។ ចូរហាត់រៀនដកដង្ហើមឲ្យបានត្រឹមត្រូវដើម្បីហ្វឹកហាត់ខ្លួនឯងឡើងវិញ។ បើសិនជាអ្នកមើលទៅកូនង៉ែតដកដង្ហើម អ្នកនឹងឃើញពួកគេដកដង្ហើមតាមធម្មជាតិ។

............................................................................................................................................

៥. ដោយសារតែបេះដូង និងសួតរបស់អ្នកអាចនឹងមានការខូចខាត អ្នកនឹងត្រូវតែការពារពួកវាឲ្យផុតពី ៖

ក. ផ្សែង - ផ្សែងបារីមានផ្ទុកជាតិពុលលើសពី៥០០០ប្រភេទ ដែលប៉ះពាល់ដល់សុខភាពរាងកាយ។

ខ. ខ្យល់កខ្វក់ - ផ្សែងលាយអ័ព្ទពីឧស្សាហកម្ម ហើយនិងផ្សែងចេញពីភ្លើងដែលនៅចំហ ការដុតដំណាំ និងបារី ធ្វើឲ្យខូចសួត បេះដូង និងខួរក្បាល។ កុមារដែលត្រូវនឹងផ្សែង ច្រើនតែរៀនយឺតយ៉ាវ (មិនសូវចាប់មេរៀនបានលឿន) ការលូតលាស់ថយចុះ និងជំងឺផ្លូវដង្ហើម។

គ. អាហារសាច់សត្វ - ខ្លាញ់នៅក្នុងសាច់ ស៊ុត(ពងមាន់ ពងទា...) និងទឹកដោះគោ អាចធ្វើឲ្យស្ទះសរសៃឈាមបាន។ កោសិកាមិនអាចទទួលបានខ្យល់ ឬអាហារគ្រប់គ្រាន់ ហើយវាស្លាប់ ធ្វើឲ្យគាំងបេះដូង ឬក៏ដាច់សរសៃឈាមខួរក្បាល។

ឃ. ខ្វះទឹក - ជារៀងរាល់ថ្ងៃ បើរាងកាយគ្មានទឹកគ្រប់គ្រាន់ទេ ឈាមនឹងឡើងខាប់ ហើយហូរយឺត បណ្តាលឲ្យសរសៃឈាមស្ទះ និងធ្វើឲ្យខូចបេះដូង ខួរក្បាល និងសួត។ តើអ្នកត្រូវញ៉ាំទឹកប៉ុន្មានលីត? មនុស្សធំត្រូវការ

ពី២-៣លីតជារៀងរាល់ថ្ងៃ។

ង. លើសទម្ងន់ - ខ្លាញ់ឥតប្រយោជន៍បន្ថែមលើរាងកាយ ត្រូវការធ្វើឲ្យសរសៃឈាមយឺតវែង។ បេះដូង និងសួត ត្រូវខំធ្វើការកាន់តែខ្លាំង ដើម្បីផ្ដល់អុកស៊ីហ្សែនដល់រាងកាយ។ ការហាត់ប្រាណអាចជួយកំចាត់ខ្លាញ់ឥតប្រយោជន៍ ហើយនិងធ្វើឲ្យរាងកាយស្រកទម្ងន់។

........................................................................................................................................................................

៦. អាហារធ្វើអំពីរុក្ខជាតិ - ជាពិសេស អាហារបន្លែបៃតង និងពណ៌ស្វាយ ជួយការពារសុខភាពបេះដូង សួត និងខួរក្បាល។ វាសម្រួលដល់សរសៃឈាម ហើយធ្វើឲ្យវាយឺត ដើម្បីឲ្យឈាមអាចហូរបានលឿន ហើយនាំខ្យល់បរិសុទ្ធ និងអាហារទៅកាន់រាងកាយទាំងមូល។

លោកុប្បត្តិ ១:២៩ ចែងថា ព្រះជាម្ចាស់បានផ្ដល់រុក្ខជាតិនៅក្នុងសួនអេដែនឲ្យអាដាម និងអេវ៉ាសម្រាប់ញ៉ាំជាអាហារ។ ទ្រង់ផ្ដល់គ្រាប់ផ្លែឈើ សណ្ដែក និងផ្លែឈើ ហើយក្រោយមកបន្ថែមគ្រាប់ធញ្ញជាតិ បន្លែបៃតង និងបន្លែផ្សេងៗទៀត។

អាហារទាំងនេះ គឺជាអាហារដែលមានសុខភាពល្អបំផុតសម្រាប់រាងកាយរបស់អ្នក។ ចូរញ៉ាំវា នោះព្រះជាម្ចាស់នឹងប្រទានពរដល់អ្នក។

## ការសុគត និងរស់ឡើងវិញ



យើងម្នាក់ៗសុទ្ធតែមានរឿងរបស់ខ្លួន ហើយគ្មានរឿងពីរណាដូចគ្នាបេះបិទ។ រឿងទាំងនេះខ្លះវែងតែគួរឲ្យស្ដាយ រឿងខ្លះមានលក្ខណៈខ្លីបន្តិចៗ គ្មានអ្នកណាមានរឿងសប្បាយគ្រប់រឿងនោះឡើយ ហើយក៏គ្មានអ្នកដែលមានរឿងជីវិតដែលអាក្រក់ទាំងអស់នោះដែរ។ ប៉ុន្តែ រឿងទាំងអស់នេះ បញ្ចប់តាមរបៀបដូចគ្នា។ មុននឹងក្រោយ យើងទាំងអស់គ្នាគង់តែស្លាប់។

ខ្ញុំដឹងថា នេះគឺជារឿងដែលយើងមិនត្រូវគិត ឬនិយាយឡើយ។ ប៉ុន្តែ ខ្ញុំបានទន្ទឹងរង់ចាំនិយាយអំពីវាជាមួយនឹងអ្នក។ ហេតុអ្វី? ពីព្រោះខ្ញុំចង់ចែករំលែកដំណឹងល្អខ្លះៗចេញពីព្រះគម្ពីរត្រង់តែម្ដង។ បើសិនជាអ្នកជឿនូវអ្វីដែលខ្ញុំនឹងប្រាប់ដល់អ្នក អ្នកនឹងមិនដែលគិតអំពីការស្លាប់ក្នុងរបៀបដូចគ្នាទៀតឡើយ។

មនុស្សជាច្រើនគិតថា ការស្លាប់គឺត្រូវបានគ្រប់គ្រងដោយអារក្ស និងខ្មោចបិសាច ហើយនិងបិសាចដែលគួរឲ្យខ្លាចដទៃទៀត។ ពួកគេខ្លាចការស្លាប់ ពីព្រោះពួកគេគិតថាវាមានន័យថាជាទារុណកម្ម ឬក៏ភ្លើង ឬក៏ភាពខ្មៅងងឹតជារៀងរហូត។ តែនេះមិនមែនជាអ្វីដែលព្រះគម្ពីរបង្រៀននោះទេ។ ព្រះគម្ពីរយល់ឃើញការស្លាប់ គឺខុសគ្នាច្រើនណាស់។

........................................................................................................................................................................
.



ខ្ញុំសូមប្រាប់អ្នកអំពីលោក ស្ទេផាន ជាមេដឹកនាំម្នាក់នៅក្នុងចំណោមមេដឹកនាំដទៃទៀតនៅក្នុងព្រះវិហារគ្រីស្ទានដើមដំបូង។ គាត់ជាអ្នកអធិប្បាយដ៏ល្អម្នាក់ ហើយសត្រូវនៃសេចក្ដីពិតស្អប់គាត់។ មានថ្ងៃមួយ ពួកគេបានបណ្ដេញគាត់ចេញពីទីក្រុងយេរូសា

ឡើម ហើយគប់ដុំថ្មដាក់គាត់ រហូតដល់គាត់ស្លាប់។ សូមស្តាប់នូវអ្វីដែលបានកើតឡើង ៖

“នោះគាត់លុតជង្គង់ចុះរួចឡើងជាសំលេងខ្លាំងថា “ឱព្រះអម្ចាស់អើយ សូមកុំរាប់បាបនេះដល់គេឡើយ” ។ កាលគាត់បានពោលដូច្នោះហើយ នោះក៏ដេកលក់ទៅ ...” (កិច្ចការ ៧:៦០)។

កាលលោកស្ទេផានស្លាប់ គាត់ “គេងលក់” ។ នោះគឺជាអ្វីដែលព្រះគម្ពីរបានចែង។

នេះ គឺជាឧទាហរណ៍មួយទៀត ៖ ព្រះយេស៊ូ ហើយនិងសាវ័ករបស់ទ្រង់បានឮថា មានមិត្តសម្លាញ់ម្នាក់ឈ្មោះថាឡាសារ មានជំងឺជាទម្ងន់។ ព្រះយេស៊ូរវល់បង្រៀន និងព្យាបាល រហូតទាល់តែពីរថ្ងៃក្រោយមកទើបទ្រង់ មានបន្ទូលទៅកាន់មនុស្សដទៃទៀត

“ឡាសារ ជាសម្លាញ់យើង គាត់បានដេកលក់ទៅហើយ ខ្ញុំទៅដើម្បីនឹងដាស់គាត់ឡើង។”

“ដូច្នេះ ពួកសិស្សទូលថា “ព្រះអម្ចាស់អើយ បើគាត់ដេកលក់ នោះគាត់នឹងបានជាវិញ។”

“ឯព្រះយេស៊ូ ទ្រង់មានព្រះបន្ទូលពីគាត់ស្លាប់ទេ តែគេស្មានថាទ្រង់មានព្រះបន្ទូលអំពីគាត់គ្រាន់តែដេកសម្រាកប៉ុណ្ណោះ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេ ជាយ៉ាងច្បាស់ថា “ឡាសារស្លាប់ហើយ”(យ៉ូហាន ១១:១១-១៤)។

មែន “ដេក” គឺជាពាក្យដែលព្រះគម្ពីរចូលចិត្តប្រើសម្រាប់ការស្លាប់។ ហើយការដេកមិនមែនជារឿងគួរឲ្យខ្លាចទេ មែនទេ?

ប៉ុន្តែ ព្រះគម្ពីរប្រាប់យើងច្រើនទៀតអំពីការស្លាប់។ សូមស្តាប់ ៖

“ដ្បិតមនុស្សដែលរស់ គេដឹងថាខ្លួននឹងស្លាប់ជាមិនខាន តែមនុស្សស្លាប់ឥតដឹងអ្វីឡើយ” (សាស្តា ៩:៥)។

មានទៀត ៖

“ទោះទាំងសេចក្តីស្រឡាញ់ សេចក្តីសំអប់ និងសេចក្តីឈ្នានីសរបស់គេវិនាសសូន្យបាត់ទៅហើយ គេក៏ឥតមានចំណែកណាក្នុងការអ្វីដែលធ្វើនៅក្រោមថ្ងៃជាដរាបតទៅមុខដែរ” (សាស្តា ៩:៦)។

មានន័យថា នៅពេលដែលខ្ញុំស្លាប់ ខ្ញុំនឹងមិនខ្វល់អំពីកង្វល់នៃជីវិតជារៀងរាល់ថ្ងៃ។ ខ្ញុំនឹងមិនខ្វល់អំពីអនាគតរបស់ខ្ញុំឡើយ។ ខ្ញុំនឹងមិនដឹងអ្វីឡើយ ពីព្រោះតាមរយៈព្រះគម្ពីរបានប្រាប់ថា ខ្ញុំនឹងមិនភ្ញាក់ឡើយ។ ការស្លាប់ គឺជាការដេកលក់យ៉ាងស្ងប់។

……………………………………………………………………………………………………………
.



តើអ្នកបានគេងទេកាលពីយប់មិញ? ខ្ញុំបានគេង។ ខ្ញុំគេងលក់ដូចកូនង៉ែតនៅក្នុងដៃរបស់ម្តាយ។ ខ្ញុំគេងលក់ ហើយខ្ញុំមិនដឹងអ្វីទាំងអស់រហូតដល់ខ្ញុំក្រោកនៅព្រឹកនេះ។ បើមានរឿងអ្វីសំខាន់បានកើតឡើងនៅក្នុងកំឡុងពេលយប់ ខ្ញុំក៏មិនបានដឹងដែរ។ ខ្ញុំមិនដឹងថា ខ្ញុំគេងបានប៉ុន្មានម៉ោងទេ រហូតទាល់តែខ្ញុំភ្ញាក់ ហើយមើលឃើញម៉ោង។ សេចក្តីស្លាប់ គឺដូច្នោះឯង។

មានមនុស្សខ្លះអាចនិយាយថា “ទេ។ នោះមិនត្រូវទេ។ ពេលអ្នកស្លាប់ ព្រលឹងរបស់អ្នកនឹងបន្តរស់នៅ។ អ្នកនឹងទៅកាន់ភពវិញ្ញាណ ឬក៏ទៅឋានសួគ៌ ឬក៏ទៅឋាន នរក។”

នោះគឺជាការជឿទូទៅ តែតើព្រះគម្ពីរយល់ស្របជាមួយដែរឬទេ? ប្រាកដណាស់ អត់ទេ។ ព្រះគម្ពីរមិនបានបង្រៀនថា យើងមានព្រលឹងដែលបន្តរស់នៅបន្ទាប់ពីយើងស្លាប់នោះទេ។

តើខ្ញុំអាចប្រាកដអំពីរឿងនោះបានដោយរបៀបណាដែរ? តាមពិតទៅ វាងាយស្រួលទេ។ តោះ ត្រឡប់ទៅសាច់រឿងអំពីការបង្កើត ហើយអាននូវអ្វីដែលវាបានប្រាប់។

“ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង” (លោកុប្បត្តិ ២:៧)។

ធូលីដី ហើយនិងដង្ហើមជីវិត។ យើងត្រូវបានបង្កើតពីរបស់អស់ទាំងនោះឯង។ របស់អស់ទាំងនោះហើយ ដែលធ្វើឲ្យយើងក្លាយជាមនុស្សដែលមានជីវិត។ ធូលី ហើយ និងខ្យល់ដង្ហើមត្រូវញែកចេញពីគ្នានៅពេលដែលយើងស្លាប់។ រាងកាយយើងរលួយ ពុកផុយ ហើយនៅទីបំផុតក៏ត្រឡប់ទៅធូលីដីវិញ។ ខ្យល់ដង្ហើម ដែលពេលខ្លះហៅថា “វិញ្ញាណ” ត្រឡប់ទៅឯព្រះជាម្ចាស់។

ព្រះគម្ពីរនិយាយត្រូវ។ ការស្លាប់ គឺមិនមែនជាសណ្ឋានផ្សេងនៃជីវិតឡើយ។ អ្នកស្លាប់មិនដឹងអ្វីឡើយ។ ពួកគេមិនមានជីវិតរស់នៅជាមួយនឹងព្រះនោះទេ។

“មនុស្សស្លាប់រមែងមិនសរសើរដល់ព្រះយេហូវ៉ាទេ ព្រមទាំងមនុស្សដែលចុះទៅនៅឯស្ថានស្ងាត់ឈឹងផង”(ទំនុកតម្កើង ១១៥:១៧)។

ទោះបីជាយើងគ្មានអ្វីដែលត្រូវខ្លាចចំពោះសេចក្តីស្លាប់ក៏ដោយ ក៏យើងនៅ តែឃើញថាធាតុពិតសេចក្តីស្លាប់ គឺជារឿងដែលយើងមិនចង់បាននោះទេ។ សេចក្តីស្លាប់បង្កើតឲ្យមានភាពទទេនៅក្នុងជីវិតរបស់យើង។ គឺសត្រូវដែលលួចឆក់យកមនុស្សជាទីស្រឡាញ់របស់យើង ហើយប្លន់យកមិត្តភាពពីយើងទៅ។ ប៉ុន្តែ ព្រះជាម្ចាស់មានដំណោះស្រាយចំពោះបញ្ហានៃអំពើបាប។ គ្មានអ្វីដែលទាក់ទងជាមួយនឹងព្រលឹងទៅនគរឋានសួគ៌ ឬក៏ជីវិតនៅក្នុងពិភពវិញ្ញាណ។ គឺល្អប្រសើរជាងនោះទៅទៀត។

តែឥឡូវ មិត្តអើយ ខ្ញុំត្រូវធ្វើការសារភាព។ ខ្ញុំខុស នៅពេលដែលខ្ញុំនិយាយថា រឿងជីវិតរបស់យើងទាំងអស់បញ្ចប់ទៅដូចគ្នា គឺក្នុងសេចក្តីស្លាប់។ នោះមិនចំជា ត្រឹមត្រូវទេ។ ហេតុអ្វីបានជាខ្ញុំនិយាយដូច្នោះ? ពីព្រោះថា សេចក្តីស្លាប់មិនមែនជាទីបញ្ចប់ឡើយ។

កាលពី ២ឬ៣នាទីកន្លងទៅ ខ្ញុំបានប្រាប់អ្នកថា ខ្ញុំបានគេងកាលពីយប់មិញ។ ខ្ញុំក៏បានប្រាប់អ្នកដែរថា ព្រឹកញនេះ ខ្ញុំបានក្រោកឡើង។ ហើយព្រះគម្ពីរប្រាប់យើងថា រឿងដូចគ្នានឹងកើតឡើងបន្ទាប់ពីយើងស្លាប់។ យើងនឹងក្រោកចេញពីសេចក្តីស្លាប់។ តើរឿងនេះអាចទៅរួចបានដោយរបៀបណា?



តើអ្នកចាំទេថា តើសេចក្តីស្លាប់មកកាន់គ្រួសាររបស់មនុស្សបានដោយរបៀបណា? ឪពុកម្តាយដើមដំបូងរបស់យើង គឺអាដាម និងអេវ៉ាញ៉ាំផ្លែឈើដឹងខុសត្រូវ។ ពួកគេបានប្រព្រឹត្តអំពើបាប ដោយការមិនស្តាប់បង្គាប់ព្រះ។ ព្រះគម្ពីរថែងប្រាប់យើងថា ៖

“ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់”(រ៉ូម ៦:២៣)។

ព្រះគម្ពីរក៏បានថែងដែរថា ៖

“ដ្បិតដែលសេចក្តីស្លាប់បានមកដោយសារមនុស្ស នោះសេចក្តីដែលមនុស្សស្លាប់បាន រស់ឡើងវិញ ក៏មកដោយសារមនុស្សដែរ”(កូរិនថូសទី១ ១៥:២១)។

មិត្តទាំងឡាយអើយ រឿងនេះគឺចំលើយរបស់ព្រះចំពោះបញ្ហានៃសេចក្តីស្លាប់។ ទ្រង់នឹងមិនបណ្តោយឲ្យសេចក្តីស្លាប់ចាប់យើងទុកជាឈ្លើយរហូតទេ។ យើងនឹងរស់ឡើងវិញ។ ហើយបុរសដែលធ្វើឲ្យការនេះកើតឡើងបានគឺជាព្រះយេស៊ូ ជាព្រះរាជបុត្រារបស់ព្រះ។ ទ្រង់បានបំបាក់ច្រវ៉ាក់នៃសេចក្តីស្លាប់ឲ្យយើង។ នេះគឺជាសាច់រឿង ៖

…………………………………………………………………………………………………………….



ក្រោយព្រះយេស៊ូបានសុគត់នៅលើឈើឆ្កាង មិត្តរបស់ទ្រង់បានបញ្ចុះព្រះកាយទ្រង់នៅក្នុងផ្នូរ ហើយប្រមៀលផ្ទាំងថ្មធំមួយបិទមាត់ផ្នូរ។ ទេសាភិបាលរ៉ូម៉ាំង គឺលោកពីឡាត់ បានបញ្ជូនទាហានឲ្យទៅយាមផ្នូរ ដើម្បីកុំឲ្យមានអ្នកណាមកលួចព្រះកាយព្រះយេស៊ូចេញទៅ។ គ្រប់យ៉ាងស្ងាត់ជ្រងំនៅពេលថ្ងៃបរិសុទ្ធ។ ប៉ុន្តែ នៅព្រឹកថ្ងៃបន្ទាប់ មានហេតុការណ៍អស្ចារ្យបានកើតឡើង។ សូមស្តាប់ពាក្យនៅក្នុងព្រះគម្ពីរ ៖

“ក្រោយថ្ងៃឈប់សម្រាក កាលរៀបនឹងចូលថ្ងៃទី១ក្នុងអាទិត្យនោះ ម៉ារាជាអ្នកស្រុកម៉ាក់ដាឡា និងម៉ារា១ទៀត ក៏នាំគ្នាទៅមើលផ្នូរ។ នោះមានកក្រើកដីជាខ្លាំង ដ្បិតមានទេវតានៃព្រះអម្ចាស់ ចុះពីលើមេឃមកប្រមៀលថ្មចេញពីផ្នូរ ហើយក៏អង្គុយលើ។ សណ្ឋានរបស់ទេវតានោះដូចផ្លេកបន្ទោរ ហើយសម្លៀកបំពាក់ក៏សស្គុសដូច ហិមៈ។ ពួកយាមល្បាតក៏ញ័ររន្ធត់ ដោយភ័យខ្លាចទេវតា ហើយត្រឡប់ដូចជាមនុស្ស ស្លាប់។”

“តែទេវតានិយាយនឹងស្ត្រីពីរនាក់ កុំឲ្យភ័យអី ដ្បិតខ្ញុំដឹងហើយថានាងរកព្រះយេស៊ូដែលត្រូវឆ្កាង។ តែទ្រង់មិនគង់នៅទីនេះទេ ដ្បិតទ្រង់មានព្រះជន្មរស់ឡើងវិញ ...” (ម៉ាថាយ ២៨:១-៧)។

…………………………………………………………………………………………………………….



ត្រឹមត្រូវហើយ។ ទ្រង់មានព្រះជន្មរស់ពីសុគត់ឡើងវិញ។ ផ្នូរមិនអាចទប់ទ្រង់បានទេ។ មិត្តរបស់ផងទ្រង់មានអំណរជាខ្លាំង នៅពេលដែលពួកគាត់ឃើញទ្រង់ជាថ្មី។

តាមរយៈព្រះគម្ពីរ “ហើយកាលទ្រង់បានរងទុក្ខរួចហើយ នោះក៏បានសម្តែងអង្គទ្រង់មកទាំងអស់ ឲ្យពួកសាវ័កនោះឃើញ ដោយសារភស្តុតាងជាច្រើន ព្រមទាំងលេចមកឯគេ ក៏សម្តែងពីអស់ទាំងសេចក្តីខាងឯនគរព្រះក្នុងរវាង៤០ថ្ងៃ”(កិច្ចការ ១:៣)។

នៅចុងបញ្ចប់នៃរយៈពេល៤០ថ្ងៃ សាវ័ករបស់ទ្រង់បានឃើញព្រះយេស៊ូត្រូវបានលើកឡើងទៅឯនគរឋានសួគ៌។ ទេវតាពីរនាក់នៅក្នុងសណ្ឋានជាមនុស្សបាននិយាយទៅកាន់ពួកគេ។ នេះគឺជាអ្វីដែលពួកគេបាននិយាយ ៖

“ព្រះយេស៊ូនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នាឡើងទៅលើស្ថានសួគ៌ ទ្រង់នឹងយាងមកវិញតាមបែបដដែល ដូចអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ” (កិច្ចការ ១:១១)។

…………………………………………………………………………………………………………….



ឥឡូវសូមស្តាប់ពីរបៀបដែលព្រះគម្ពីរពិពណ៌នាអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូ៖

"ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំលេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់ជាដរាបទៅ" ថែស្សាឡូនិចទី១ ៤១៦,១៧"។

នេះគឺជាទស្សនៈមួយទៀតអំពីព្រឹត្តិការណ៍ដូចគ្នា៖

"នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ។ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១ប៉ប្រិចភ្នែក ប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ" (កូរិនថូសទី១ ១៥:៥១,៥២)។

តើនោះមិនមែនជារូបភាពអស្ចារ្យទេឬអី? អ្នកដែលជឿព្រះយេស៊ូគ្រីស្ទទាំងអស់ដែលបានទទួលទ្រង់ជាព្រះអង្គសង្គ្រោះរបស់ពួកគេ អាចប្រឈមនឹងសេចក្តីស្លាប់ជាមួយនឹងសេចក្តីសន្យាដ៏អស្ចារ្យនេះ។ ពេលដែលព្រះយេស៊ូយាងត្រឡប់មកវិញ ទ្រង់នឹងប្រោសពួកគេចេញពីស្លាប់ ហើយផ្តល់រាងកាយថ្មី ល្អឥតខ្ចោះ ដែលមិនពុករលួយដល់ពួកគេ។

អស់អ្នកដែលមិនបានស្លាប់ តែបន្តរស់នៅរហូតដល់ថ្ងៃនោះ ក៏នឹងត្រូវបានផ្លាស់ប្តូរដែរ។ ពួកគេនឹងចាប់ផ្តើមជីវិតថ្មីទាំងអស់គ្នា នៅក្នុងនគរដ៏អស់កល្បរបស់ព្រះ។

ព្រះគម្ពីរចែងថា៖

"... នោះទើបនឹងបានសម្រេចតាមពាក្យ ដែលចែងទុកមកថា សេចក្តីជ័យជំនះបានលេបសេចក្តីស្លាប់បាត់ហើយ" (កូរិនថូសទី១ ១៥:៥៤)។

មិត្តអើយ យើងអាចរស់នៅដោយមិនខ្លាចអំពីសេចក្តីស្លាប់ដែលមកបន្លាចមនុស្សជាច្រើន។ ជីវិតរបស់យើងអាចផ្លាស់ប្រែដោយការទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់យើង ហើយដោយការជឿលើសេចក្តីសន្យានៅក្នុងព្រះបន្ទូលបរិសុទ្ធរបស់ទ្រង់ នៅក្នុងព្រះគម្ពីរ។ បើសិនអ្នកនៅមិនទាន់បានទទួលយកទ្រង់ជាព្រះអង្គសង្គ្រោះនៅឡើយ តើអ្នកអាចទទួលយកនៅពេលឥឡូវនេះបានដែរឬទេ? ឈ្នួលនៃអំពើបាប គឺជាសេចក្តីស្លាប់ តែអំណោយរបស់ព្រះ គឺជាជីវិតអស់កល្បតាម រយៈព្រះយេស៊ូគ្រីស្ទ ជាព្រះអម្ចាស់របស់យើង។ សូមទទួលយកអំណោយនេះ នៅថ្ងៃនេះ។ សូមអធិស្ឋានជុំគ្នាឥឡូវនេះ។

(សំណើអធិស្ឋាន)

ព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ អរព្រះគុណទ្រង់ចំពោះសេចក្តីស្រឡាញ់ដ៏អស្ចារ្យ និងចំពោះអំណោយនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូ។ អរព្រះគុណទ្រង់ដែលបានបញ្ជូនទ្រង់មកកាន់ពិភពលោកនេះ ដើម្បីសុគត់ជំនួសពួកទូលបង្គំ ដើម្បីនឹង

អភ័យទោសចំពោះអំពើបាបរបស់ពួកទូលបង្គំ ហើយពួកទូលបង្គំអាចបានសង្គ្រោះ។ ព្រះវរបិតា នៅថ្ងៃនេះ បើសិនជាមានបុរស ឬស្ត្រី ឬក៏ក្មេងៗនៅទីនេះ មិនបានទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់ពួកគេទេ សូមទ្រង់មេត្តាបញ្ជូនព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់និយាយទៅកាន់ចិត្តរបស់ពួកគេ ដើម្បីអង្វរពួកគេ ជាប្រយោជន៍ឲ្យពួកគេទទួលបានជីវិតអស់កល្ប។ ហើយសូមឲ្យពួកទូលបង្គំរស់នៅដោយមានទំនុកចិត្ត នៅក្នុងសេចក្តីសន្យានៃព្រះបន្ទូលរបស់ទ្រង់។ នៅពេលដែលព្រះយេស៊ូយាងមក ម្តងទៀត សូមឲ្យយើងទាំងអស់គ្នា បានរស់នៅរួមគ្នាជាមួយនឹងទ្រង់នៅឯនគរ អស់កល្បរបស់ទ្រង់ជារៀងរហូត។ ទូលបង្គំយើងខ្ញុំអធិស្ឋានសូមគ្រប់កិច្ចការទាំងអស់នេះ នៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ</u>

| | | |
|---|---|---|
| លោកុប្បត្តិ ៣:១៨,១៩ | ទំនុកតម្កើង ១៤៦:៣,៤ | យ៉ូហាន ១១:១៥ |
| យ៉ូហាន ២០:១៧ | សាំយ៉ូអែលទី២ ៧:១២ | សាស្តា ១២:៧ |
| យ៉ូហាន ១១:២១,២៣,២៤ | កូរិនថូសទី១ ១៥:១៦-១៨ | យ៉ូប ១៤:១០-១៥ |
| ដានីញ៉ែល ១២:២ | យ៉ូហាន ១១:២៥ | កូរិនថូសទី១ ១៥:៥៣-៥៥ |
| យ៉ូប ១៧:១៣ | លូកា ២៣:៤២,៤៣ | យ៉ូហាន ១១:៣៥ |
| ថែស្សាឡូនិចទី១ ៤:១៣ | យ៉ូប ២៧:៣ | យ៉ូហាន ៥:២៨,២៩ |
| យ៉ូហាន ១១:៣៩ | វិវរណៈ ១:១៨ | ទំនុកតម្កើង ១៣:៣ |
| យ៉ូហាន ១១:៥ | យ៉ូហាន ១៩:៣១-៣៣ | វិវរណៈ ២២:១២ |

## លំនាំពិភាក្សា

ហាត់ប្រាណដើម្បីឲ្យមានកំលាំងពលំ

១. តើការហាត់ប្រាណជួយដល់បេះដូងអ្នកដោយរបៀបណា?
២. តើការហាត់ប្រាណជួយដល់សួតអ្នកដោយរបៀបណា?
៣. តើទំលាប់រស់នៅជីវិតបែបណា ដែលអាចបំផ្លាញបេះដូង និងសួតរបស់អ្នក?

ការសុគត និងរស់ឡើងវិញ

១. តើពាក្យមួយទៀតដែលព្រះគម្ពីរប្រើសម្រាប់ពាក្យ “សេចក្តីស្លាប់” គឺពាក្យអ្វី?
   - កិច្ចការ ៧:៦០ - យ៉ូហាន ១១:១១-១៤
២. តើអ្នកចងចាំរឿងអ្វីខ្លះដែលបានកើតឡើងពីយប់មិញ ពេលអ្នកកំពុងតែគេងលក់?
៣. តើសេចក្តីស្លាប់ គឺជាសណ្ឋាននៃជីវិតមួយទៀត? តើមនុស្សដឹងខ្លួនទេ នៅក្នុងសេចក្តីស្លាប់?
   - ទំនុកតម្កើង ១១៥:១៧

៤. តើមានអ្វីមកបន្ទាប់ពីសេចក្តីស្លាប់?

- កូរិនថូសទី១ ១៥:២១ - ម៉ាថាយ ២៨:១-៧

៥. តើនឹងមានអ្វីកើតឡើងចំពោះអ្នកស្លាប់នៅពេលដែលព្រះយេស៊ូយាងត្រឡប់មកវិញ?

- ថែស្សាឡូនិចទី១ ៤:១៦,១៧ - កូរិនថូសទី១ ១៥:៥១,៥២,៥៤

# មេរៀនសុខភាពទី១៥ - ភេសជ្ជៈ (ប្រើជំនួសទឹក)



១. មនុស្សជុំវិញពិភពលោក ចាប់ផ្តើមថ្ងៃរបស់ពួកគេជាមួយនឹងទឹកកាហ្វេ ឬតែក្តៅ១ពែង។ ពួកគេត្រូវការថាមពលនោះដើម្បីកុំឲ្យងងុយគេង។ ក្រោយមក ពេលថាមពលនោះអស់ទៅ ពួកគេក៏ងាកទៅរកទឹកកូកាកូឡា។ ពួកគេមិនត្រឹមតែត្រូវការវាសម្រាប់ប៉ូវកំលាំងប៉ុណ្ណោះទេ តែដើម្បីឲ្យមានអារម្មណ៍ធម្មតា។ ពួកគេមិនអាចធ្វើអ្វីបានដោយគ្មានវាឡើយ តែពួកគេកម្រឈប់វាយតម្លៃពីសារសំខាន់នៃជម្រើសរបស់ពួកគេ។

កាហ្វេអ៊ីន គឺជាថ្នាំញៀនដែលមនុស្សពាសពេញពិភពលោកប្រើប្រាស់ច្រើនជាងគេបំផុត។ វាមាននៅក្នុងតែ កាហ្វេ ទឹកសូដា សូកូឡា និងថ្នាំពេទ្យ។ វាពេញនិយម ពីព្រោះវាជួយលើកកំលាំង និងបង្កើនថាមពល។ ពួកគេមានអារម្មណ៍ល្អប្រសើរ និងគិតបានលឿន។ តែវាមានផលប៉ះពាល់តបស្នងមកវិញ។

..........................................................................................................................................
.

២. ការបង្កើនថាមពល គឺខ្ចីមកពីថាមពលដែលរាងកាយរក្សាទុក។ គឺដូចជាដកយកលុយដែលឲ្យខ្ចី ដែលត្រូវសងវិញ។ អ្នកមានអារម្មណ៍ល្អពីដំបូង តែនៅពេលដែលជាតិកាហ្វេអ៊ីនសាប ថាមពលធ្លាក់ចុះ វាពិតជាធ្វើឲ្យអ្នកកាន់តែអស់កំលាំងជាងពេលអ្នកមិនមានជាតិកាហ្វេអ៊ីនទៅទៀត។

សកម្មភាពក្នុងខួរក្បាលអាចនឹងមានមែន តែបាត់បង់នូវភាពត្រឹមត្រូវ(ខុសប្រក្រតី)។ អ្នកអាចធ្វើការបានលឿន តែមិនបានល្អប្រសើរ ហើយអ្នកនឹងធ្វើខុសកាន់តែច្រើនថែមទៀត។

កាហ្វេអ៊ីន គឺជាសារធាតុចម្លែកដែលបំផ្លាញរាងកាយ - សារធាតុពុល។ ហើយវាញៀនទៀតផង។ ជាតិកាហ្វេអ៊ីននៅក្នុងកាហ្វេ។

កាហ្វេអ៊ីនអាចធ្វើឲ្យប្រព័ន្ធសរសៃប្រសាទធ្វើការហួសកម្រិត។ មនុស្សខ្លះអាចជម្រះជាតិកាហ្វេអ៊ីនចេញពីក្នុងខ្លួនបានលឿន ប៉ុន្តែ ភាគច្រើនមិនអាច។ លទ្ធផលនោះគឺ “បញ្ហាសរសៃប្រសាទដោយសារកាហ្វេ” អារម្មណ៍ភ័យញ័រ ញ័រដៃ អារម្មណ៍មិននឹងនរ រសោប់រសល់ ឆាប់អាក់អន់ចិត្ត ឈឺក្បាល និងស្រាលក្បាល។

ជាតិកាហ្វេអ៊ីនធ្វើឲ្យគេងមិនលក់។ ការគេងមិនគ្រប់គ្រាន់ធ្វើឲ្យអស់កំលាំង។ វាក្លាយទៅជាទម្លាប់ដែលមានគ្រោះថ្នាក់។ ពេលព្រឹក អ្នកក្រោកឡើងអស់កំលាំង ដូច្នេះ អ្នកញ៉ាំកាហ្វេមួយពែង ហើយប្រើសារធាតុដែលមានជាតិកាហ្វេអ៊ីនដើម្បីបង្កើនថាមពលនៅក្នុងពេលថ្ងៃ។ បន្ទាប់មក នៅពេលយប់ អ្នកគេងមិនលក់ ហើយពេលព្រឹកបន្ទាប់ អ្នកក្រោកឡើងអស់កំលាំងទៀត។

ជាតិ៖ ធ្វើឲ្យអារម្មណ៍ប្រែប្រួល។ វាគឺជាមូលហេតុដែលបណ្តាលឲ្យកើតជំងឺបាក់ទឹកចិត្តខ្លាំងជាងគេ បំផុត។ កាលណាប្រើប្រាស់វារយៈពេលយូរ វាប៉ះពាល់ដល់អាកប្បកិរិយារបស់ខួរក្បាល ការរៀនសូត្រ និងការចងចាំ។

ជាតិកាហ្វេអ៊ីនធ្វើឲ្យរាងកាយធ្វើការហួសកម្រិត។ ការបង្កើនសារធាតុនេះ បណ្ដាលឲ្យមានផលប៉ះពាល់រយៈពេលយូរ។ អាសុីតក្រពះកើនឡើង បណ្ដាលឲ្យឆ្អល់ចុងដង្ហើម ឬចុកក្រពះ និងដំបៅ។ ជីពចរដែលធ្វើការហួសកម្រិត បណ្ដាលឲ្យបេះដូងលោតឌឹបឌាក់ៗ សម្ពាធឈាមឡើងខ្ពស់ បេះដូង និងប្រព័ន្ធដកដង្ហើមមិនដំណើរការ ឬក៏ដាច់សរសៃឈាមខួរក្បាល។ តម្រងនោមធ្វើការធ្ងន់ហួសកម្រិត។ វានាំឲ្យកើតជំងឺមហារីកមួយចំនួន។

………………………………………………………………………………………………………………

៣. ជាតិកាហ្វេអ៊ីន អាចបណ្ដាលឲ្យប្រឈមនឹងការរលូតកូនកម្រិតខ្ពស់ និងកូនកើតមិនគ្រប់ទម្ងន់សម្រាប់ស្ត្រីមានផ្ទៃពោះ។ កាហ្វេអ៊ីនស្ថិតនៅក្នុងទឹកដោះម្ដាយយូរជាងនៅក្នុងឈាមរបស់ម្ដាយ។ ម្ដាយសំអាតវាចេញពីសរសៃឈាមនៅក្នុងរយៈពេលប្រាំមួយម៉ោង ប៉ុន្ដែ វានៅក្នុងខ្លួនកូនង៉ែតដល់ទៅ១០០ម៉ោង។ នេះនាំឲ្យកូនង៉ែត មិនសប្បាយចិត្ត និងញៀនជាតិកាហ្វេអ៊ីន។

ទម្លាប់ញ៉ាំកាហ្វេអាចកំចាត់បាន។ តែការបញ្ឈប់អាចធ្វើឲ្យឈឺក្បាល អស់កំលាំង ការសោះអង្គើយ រសាប់រសល់ និងរោគសរសៃប្រសាទ រហូតដល់ទៅមួយអាទិត្យ។ បន្ទាប់មក នឹងបានផលល្អ គេងលក់ មានថាមពលពិត មានអារម្មណ៍ល្អប្រសើរ ហើយនិងជួយសន្សំសំចៃលុយកាក់។

ដើម្បីប្ដូរទម្លាប់ពីការញ៉ាំភេសជ្ជៈដែលមានជាតិកាហ្វេអ៊ីនត្រូវៈ

ប្ដូរទៅញ៉ាំទឹកក្ដៅឧណ្ហៗ ឬក៏តែរុក្ខជាតិ។

ប្ដូរទម្លាប់ពេលព្រឹករបស់អ្នក។

ទៅស្រូបយកខ្យល់ល្អបរិសុទ្ធ និងហាត់ប្រាណនៅក្នុងកំឡុងពេលថ្ងៃ នៅពេលដែលអ្នកឃ្លានកាហ្វេ ឬក៏កូកាកូឡា។ ហាត់ប្រាណធ្វើឲ្យមានកំលាំងពលំ។ ការហាត់ប្រាណ៣០នាទី ជារៀងរាល់ថ្ងៃជួយធ្វើឲ្យខួរក្បាលលូតលាស់ បង្កើតអរម៉ូនដែលសប្បាយ ហើយផ្ដល់កំលាំងផ្នែកសតិបញ្ញា និងមានកំលាំងថាមពលពិតប្រាកដ។

សម្រាក។ មនុស្សធំពេញវ័យត្រូវការគេងពី៧-៨ម៉ោង ដើម្បីកសាងកោសិកាឡើងវិញ ហើយផលិតរក្សាទុកថាមពលពិត។ ការសម្រាក មានសារសំខាន់ដើម្បីយកឈ្នះលើការញៀន និងស្ដាររាងកាយ ជាពិសេស បើសិនជាអ្នកធ្វើការដោយប្រើកំលាំងខ្លាំង។

………………………………………………………………………………………………………………

៤. ទឹកសូដា

ដូចកាហ្វេដែរ ទឹកសូដាមិនមែនជាអាហារនោះទេ។ វាគឺជារបស់ចម្លែកចំពោះរាងកាយ។ ទឹកសូដាភាគច្រើនមានផ្ទុកជាតិកាហ្វេអ៊ីន។ លើសពីនេះ វាមានជាតិគីមី សម្រាប់រសជាតិ ហើយក៏អាចមានស្ករសប្បនិមិត្ត ឬក៏ស្ករចម្រាញ់។ វាមិនមានជីវជាតិសម្រាប់ប៉ូវសាច់ឈាមឡើយ ហើយកោសិការបស់រាងកាយ ត្រូវខំប្រឹងធ្វើការយ៉ាងខ្លាំងដើម្បីកែច្នៃស្ករ និងសារធាតុគីមី។

ទាំងកាហ្វេ និងភេសជ្ជៈវាទាញយកជាតិកាល់ស្យូមចេញពីឆ្អឹង ធ្វើឲ្យឆ្អឹងចុះខ្សោយ។

ស្ករ

តោះ និយាយអំពីស្ករ។ ទឹកសូដា មានស្ករច្រើនណាស់។ តាមពិតទៅ ស្ករដែលផលិតបានភាគច្រើន គេយកទៅដាក់នៅក្នុងភេសជ្ជៈ។ នៅក្នុងរាល់កំប៉ុងទឹកសូដា មានស្ករចំនួន១០ស្លាបព្រាតែ នៅក្នុងទឹកសូដា១លីតមានស្ករ២៧ស្លាបព្រាតែ ឬក៏ស្ករ១០៨ក្រាម!

ស្ករជួយបង្កើនថាមពលបន្តិច ហើយធ្វើឲ្យអ្នកមានអារម្មណ៍ប្រសើរមួយរយៈពេលខ្លី ដូចកាហ្វេអ៊ីនដែរ ក្រោយពីញ៉ាំវាមិនបានយូរប៉ុន្មាន វាក៏ធ្វើឲ្យអ្នកអស់កំលាំង ហើយធ្វើឲ្យអ្នកចង់ញ៉ាំ ហើយញ៉ាំទៀត ដើម្បីឲ្យមានអារម្មណ៍ធម្មតា។

ការឃ្លានស្ករ គឺជាការញៀន។ កាលណាអ្នកកាន់តែញ៉ាំ អ្នកកាន់តែចង់ញ៉ាំទៀត ហើយអ្នកនឹងមិនចេះឆ្អែត ឬស្កប់ឡើយ។

ស្ករ ធ្វើឲ្យឈាមស្វះ ធ្វើឲ្យវាឡើងខាប់ និងហូរយឺត។ ស្ករបំផ្លាញប្រព័ន្ធការពារ។ ទោះបីជាស្ករចំនួនតិច ក៏វាសន្ធប់លើកោសិកាឈាមសដែលជាអ្នកប្រយុទ្ធនៃប្រព័ន្ធការពាររបស់រាងកាយ ធ្វើឲ្យវាប្រយុទ្ធនឹងមេរោគដែលលុកលុយដ៏គ្រោះថ្នាក់មិនកើត។ ដោយគ្មានការការពារពីកោសិកាឈាមសទេ មេរោគផ្តាសាយ ផ្តាសាយធំ និងសួតចូលលុកលុយ ហើយដំបៅក្រជា។

បាក់តេរីដែលមិនល្អនៅក្នុងពោះវៀនរីកចម្រើនយ៉ាងលឿនដោយសារស្ករ។ វាបំផ្លាញបាក់តេរីដែលល្អ ដែល ផលិតវីតាមីនប៊ី ដែលចាំបាច់សម្រាប់ដំណើរការ និងការលូតលាស់របស់ខួរក្បាល ហើយនិងការដែលធ្វើឲ្យមានអារម្មណ៍សប្បាយ។

ជាតិស្ករហួសកម្រិត ប្រែក្លាយទៅជាខ្លាញ់ ហើយស្តុកទុកនៅក្នុងរាងកាយ។ កាលណាបេះដូង និងតម្រងនោមច្រោះជាតិខ្លាញ់ ពួកវាក៏បន្ថយល្បឿន ហើយប៉ះពាល់ដល់ដំណើរឈាមរត់។ ថ្លើម ដែលជាប្រព័ន្ធច្រោះរបស់រាងកាយ ហើម និងឈឺ។ លំពែងនឿយហត់ នាំឲ្យកើតជំងឺទឹកនោមផ្អែម។

ជាតិស្ករច្រើនហួសកម្រិត ធ្វើការដូចជាថ្នាំពុល បំផ្លាញមុខងាររបស់រាងកាយ។

.................................................................................................................................................

**៥. ធ្វើការសម្រេចចិត្តដែលត្រឹមត្រូវ និងមានសុខភាពល្អ**

ស្ករមានរសជាតិឆ្ងាញ់ តែវាធ្វើឲ្យអ្នកខាតលុយ។ តែអ្នកអាចញ៉ាំស៊ុត (ពងមាន់/ទា...) ផ្លែឈើ១ចំណិត ឬក៏សណ្តែកដី ដែលជួយធ្វើឲ្យអ្នកមានសុខភាពល្អ ជាជាងបំផ្លាញវា។

ទឹកសុទ្ធ គឺជាជម្រើសរបស់ព្រះសម្រាប់ទឹកផ្សេងៗដែលល្អឥតខ្ចោះ។ វាមិនលួចអាហារពីរាងកាយទេ។ វាជួយធ្វើឲ្យឈាមរាវ ហើយរត់បានលឿន។ វាជួយបំពេញជាតិទឹកអ្នក។ វាធ្វើឲ្យខួរក្បាលរបស់អ្នកស្រឡះ និងផ្តល់ថាមពល។

ព្រះជាម្ចាស់ជ្រាបពីសេចក្តីត្រូវការរបស់យើង ហើយទ្រង់បានផ្តល់ឲ្យយើងនូវដំបូន្មានដ៏ល្អនៅក្នុងព្រះគម្ពីរ អេសាយ ៥៥:២។ នេះ គឺជាសំណួររបស់ទ្រង់ ៖

“ហេតុអ្វីបានជាចំណាយលុយកាក់ទៅលើអ្វីដែលមិនមែនជានំប៉័ង និងការងាររបស់អ្នកទៅលើអ្វីដែលមិនពេញចិត្ត? សូមស្តាប់ សូមស្តាប់ខ្ញុំចុះ ហើយញ៉ាំនូវអ្វីដែលល្អ នោះអ្នកនឹងរីករាយផ្សេងៗអាហារដែលល្អៗ។”

## សុខភាព



មួយពាន់ឆ្នាំមុនព្រះយេស៊ូប្រសូត ស្តេចដាវីឌបានគ្រប់គ្រងប្រទេសអ៊ីស្រាអែល។ ទ្រង់គឺជាអ្នកចម្បាំងដ៏ខ្លាំងពូកែ ប៉ុន្តែទ្រង់ក៏ជាអ្នកតែងកំណាព្យ និងជាអ្នកលេងភ្លេងយ៉ាងល្អអស្ចារ្យ។ កំណាព្យ និងចម្រៀងជាច្រើននេះ គឺមាននៅក្នុងព្រះគម្ពីរតែម្តង។ ព្រះគម្ពីរនោះ គឺមានឈ្មោះថា “ទំនុកតម្កើង”។ សូមស្តាប់កំណាព្យមួយនេះ ៖

“ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង។ ទ្រង់ជ្រាបការដែលទូលបង្គំក្រោកឡើងផង ទ្រង់ក៏យល់គំនិតរបស់ទូលបង្គំពីចំងាយដែរ” (ទំនុកតម្កើង ១៣៩:១,២)។

ស្តេចដេវីឌយល់ជ្រាបថា ព្រះអង្គម្ចាស់បានដឹងគ្រប់យ៉ាងទាំងអស់អំពីទ្រង់។ គឺគ្រប់យ៉ាងដែលទ្រង់បានប្រព្រឹត្ត។ សូម្បីតែគំនិតរបស់ទ្រង់។ នៅមានទៀត ៖

“ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ។ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ” (ទំនុកតម្កើង ១៣៩:១៣,១៤)។

ស្តេចដេវីឌ ទទួលស្គាល់ថា ទ្រង់ត្រូវបានព្រះអទិករបង្កើតមក។ ព្រះកាយរបស់ទ្រង់ដូចជារូបកាយរបស់ពួកយើង គឺជារឿងដ៏អស្ចារ្យ។ បេះដូង សួត ភ្នែក និងខួរក្បាលរបស់ទ្រង់ គឺគ្រប់ផ្នែកទាំងអស់របស់ទ្រង់ ត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់អង្គឯង។

គម្ពីរទំនុកតម្កើងមួយទៀតចែងថា ៖

“ត្រូវឲ្យដឹងថា ព្រះយេហូវ៉ាទ្រង់ជាព្រះ គឺទ្រង់ដែលបានបង្កើតយើងខ្ញុំ យើងខ្ញុំជារបស់ផងទ្រង់ យើងខ្ញុំជារាស្ត្ររបស់ទ្រង់ ហើយជាហ្វូងចៀម នៅទីគង្វាលរបស់ទ្រង់” (ទំនុកតម្កើង ១០០:៣)។

បើសិនជាព្រះបានបង្កើតយើង ទ្រង់ដឹងគ្រប់យ៉ាងអំពីយើង។ ទ្រង់ជ្រាបអំពីរបៀបដែលរាងកាយរបស់យើងធ្វើការ។ ទ្រង់ដឹងនូវអ្វីដែលល្អបំផុតសម្រាប់ឲ្យយើងញុាំ និងផឹក។ ទ្រង់ដឹងពីផ្លូវដែលល្អបំផុតសម្រាប់ឲ្យយើងថែរក្សារាងកាយរបស់យើង។

.........................................................................................................................................



កាលដើមដំបូងឡើយ ព្រះជាម្ចាស់បានមានបន្ទូលប្រាប់អាដាម និងអេវ៉ាថា “មើលអញឲ្យគ្រប់ទាំងតិណជាតិមានគ្រាប់ពូជដែលដុះនៅលើផែនដី និងគ្រប់ទាំងរុក្ខជាតិទាំងឡាយដែលកើតផ្លែមានគ្រាប់ពូជ ទុកជាអាហារដល់ឯង” (លោកុប្បត្តិ ១:២៩)។

គឺមានតែគ្រាប់ធញ្ញជាតិ គ្រាប់ផ្លែឈើ និងផ្លែឈើ។ តែត្រូវចងចាំថា ពួកគេរស់នៅក្នុងសួនអេដែន។ មានដើមរុក្ខជាតិ និងដើមឈើប្រភេទខុសៗគ្នានៅក្នុងសួន ដូច្នេះ គឺមានច្រើនប្រភេទដែលអាចជ្រើសរើសបាន។

.........................................................................................................................................



បន្ទាប់ពីពួកគេបានប្រព្រឹត្តអំពើបាប អាដាម និងអេវ៉ា លែងអាចរស់នៅក្នុងសួន។ ពួកគេត្រូវទៅរស់នៅជាមួយនឹងផលបាបដែលពួកគេបានប្រព្រឹត្ត។ នៅខាងក្រៅសួន ពួកគេត្រូវដាំដំណាំសម្រាប់ធ្វើជាអាហារដោយខ្លួនឯង។ អាហាររបស់ពួកគេបានផ្លាស់ប្តូរ។ សូមស្តាប់នូវអ្វីដែលព្រះជាម្ចាស់បានមាន បន្ទូលប្រាប់ទៅពួកគេ ៖

“ឯងត្រូវស៊ីអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ” (លោកុប្បត្តិ ៣:១៨)។

ដូច្នេះ ឥឡូវនេះពួកគេមានបន្លែញុាំ បន្ថែមពីលើអ្វីដែលពួកគេអាចដាំបាន។

វាប្រហែលជាអាហារដែលល្អចំពោះសុខភាព។ មនុស្សមានជីវិតរស់នៅបានរាប់រយឆ្នាំ។ ព្រះគម្ពីរប្រាប់យើងថា អាដាមខ្លួនឯងបានរស់នៅដល់អាយុ ៩៣០ឆ្នាំ។ មាន

មនុស្សផ្សេងទៀត ដែលរស់នៅបានដល់អាយុយ៉ាងហោចណាស់៩០០ឆ្នាំ ហើយបុរសម្នាក់ឈ្មោះមេទូសិលា ស្លាប់នៅអាយុ៩៦៩ឆ្នាំ។ មនុស្សសម័យនោះមានអាយុវែង រហូតទាល់តែដល់សម័យកាលលោកណូអេ ហើយនិងទឹកជំនន់ដ៏ធំ។

.



គឺពេលនោះហើយដែលព្រះជាម្ចាស់បានបែងចែកសត្វទៅជាពីរក្រុម ៖ ស្អាត និងមិនស្អាត។ ទ្រង់អាចធ្វើដូច្នោះបាន ពីព្រោះទ្រង់គឺជាព្រះអទិកររបស់ពួកគេផងដែរ។ ទ្រង់បានបង្កើតពួកគេម្នាក់ៗ ហើយទ្រង់ជ្រាបដឹងថា សត្វខ្លះអាចញ៉ាំជាអាហារ បាន ហើយខ្លះទៀតមិនអាចញ៉ាំបាន។

ទ្រង់បានប្រាប់លោកណូអេ ឲ្យយកសត្វចូលទៅក្នុងទូក។ នេះគឺជាអ្វីដែលទ្រង់បានមានបន្ទូលប្រាប់ ៖

“ខាងឯសត្វជើង៤ដែលស្អាត នោះឯងត្រូវយក៧គូ ហើយសត្វជើង៤មិនស្អាត នោះឲ្យយកតែ១គូវិញ គឺទាំងឈ្មោលទាំងញីផង” (លោកុប្បត្តិ ៧:២)។

អ្នកច្បាស់ជាឆ្ងល់ហើយ ថាសត្វណាដែលស្អាត ហើយសត្វណាដែលមិនស្អាត។ នេះគឺជាអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលប្រាប់រាស្ត្ររបស់ទ្រង់ ៖

“ហើយគ្រប់ទាំងសត្វដែលមានក្រចកឆែក គឺក្រចកឆែកដាច់ជា២ ហើយដែលទំពារអៀងផង ក្នុងអស់ទាំងពួកសត្វនោះនឹងបរិភោគបាន” (ចោទិយកថា ១៤:៦)។

ដូច្នេះ មានន័យថាសត្វដែលស្អាត គឺរាប់បញ្ចូលទាំងសត្វគោ ចៀម ពពែ ក្តាន់ ប្រើស និងពពួកឈ្លូស។

ចុះសត្វដែលមិនស្អាតវិញ? សូមស្តាប់ ៖

“ប៉ុន្តែ ក្នុងបណ្តាសត្វដែលទំពាអៀង ឬដែលមានក្រចកឆែកនោះ មិនត្រូវឲ្យបរិភោគសត្វទាំងនេះឡើយ គឺសត្វអូដ្ឋ ទន្សាយគល់ ទន្សាយថ្ម ពីព្រោះសត្វទាំងនោះទំពាអៀង តែគ្មានក្រចកឆែកទេ ជាសត្វមិនស្អាតទាំងអស់ដល់ឯងរាល់គ្នា។ ហើយជ្រូកដែរ ពីព្រោះ មានក្រចកឆែក តែមិនទំពាអៀងទេ នោះមិនស្អាតដល់ឯងរាល់គ្នា មិនត្រូវឲ្យបរិភោគ សាច់វាឡើយ ក៏មិនត្រូវទាំងពាល់ខ្មោចវាផង” (ចោទិយកថា ១៤:៧,៨)។



ព្រះជាម្ចាស់ចង់ការពារពួកគេពីជំងឺដែលពួកគេអាចឆ្លងបានមកពីការញ៉ាំអាហារដែលខុស។ ទ្រង់បានចង្អុលបង្ហាញពីចំណុចពិសេសនៃការហាមប្រាមពួកគេមិនឲ្យញ៉ាំសត្វជ្រូក។ ហេតុអ្វី? នេះគឺជាហេតុផលមួយដែលល្អ ៖

សាច់សត្វជ្រូក គឺច្រើនតែមានព្រូនតូចៗ។ កាលណាអ្នកញ៉ាំសាច់វា សត្វព្រូនទាំងនោះចូលទៅក្នុងរាងកាយរបស់អ្នក ហើយធ្វើសំបុកវានៅទីនោះ។ វាចូលទៅក្នុងឈាមរបស់អ្នក ហើយធ្វើដំណើរទៅផ្នែកផ្សេងទៀតនៃរាងកាយរបស់អ្នក។ ពួកវាលូតលាស់ ហើយកើតកូនចៅ។ ហើយនៅទីបំផុត ពួកវាអាចសម្លាប់អ្នកបាន។

ព្រះជាម្ចាស់ស្គាល់រាងកាយរបស់អ្នកច្បាស់បំផុត ហើយទ្រង់ក៏ស្គាល់សត្វជ្រូកដែរ។ បើទ្រង់មានបន្ទូលប្រាប់ថា ពួកវាជាសត្វមិនស្អាតហើយយក ល្អកុំញ៉ាំសាច់ពួកវាអី។ តើខ្ញុំនិយាយត្រូវទេ?

ចុះសត្វត្រីវិញ? តើពួកវាជាសត្វស្អាត ឬក៏មិនស្អាត? នេះគឺជាអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់រាស្ត្ររបស់ទ្រង់ ៖

"ឯបណ្តាសត្វទាំងប៉ុន្មានដែលនៅក្នុងទឹក នោះឯងនឹងបរិភោគសត្វទាំងនេះបាន គឺសត្វណាដែលមានព្រុយ ហើយមានស្រកាផង។ តែមិនត្រូវឲ្យបរិភោគសត្វណាដែលគ្មានព្រុយ និងស្រកាទេ ដ្បិតជាសត្វមិនស្អាតទាំងអស់ដល់ឯងរាល់គ្នា"
(ចោទិយកថា ១៤:៩,១០)។

ដូច្នេះ ត្រីអាចញ៉ាំបាន បើសិនជាពួកវាមានទាំងព្រុយ និងស្រកា។

ចុះសត្វស្លាបដែលហើរ? តើវាល្អសម្រាប់ធ្វើជាអាហារដែរឬទេ? សូមស្តាប់ ៖

"ឯបណ្តាសត្វហើរដែលស្អាត នោះឯងរាល់គ្នានឹងបរិភោគបានគ្រប់យ៉ាង។ តែសត្វហើរទាំងនេះ នោះមិនត្រូវបរិភោគឡើយ គឺខ្លែង ស្ទាំង ប្រមង់ ល្អួត អាត និងត្មាត តាមពូជវា។ អូសទ្រិច ខ្លែងស្រាក រំពេ និងអកតាមពូជវា។ មៀម គូក ទីទុយ ទុង ក្រៀល ស្មោញ កុក និងក្រសារ តាមពូជវា កំប៉ោយ ហើយជ្រឹង និងអស់ទាំងសត្វដែលវារ ហើយហើរផង នោះជាសត្វមិនស្អាតដល់ឯង មិនត្រូវបរិភោគឡើយ"
(ចោទិយកថា ១៤:១១-១៩)។

ព្រះជាម្ចាស់ក៏បានមានបន្ទូលប្រាប់រាស្ត្ររបស់ទ្រង់ថា មានផ្នែកខ្លះនៃរាងកាយរបស់សត្វដែលស្អាត នោះក៏មិនត្រូវញ៉ាំដែរ។ សូមស្តាប់ ៖

"គឺថាមិនត្រូវឲ្យឯងរាល់គ្នាបរិភោគខ្លាញ់ ឬឈាមឡើយ" (លេវីវិន័យ ៣:១៧)។

កាលនៅក្នុងសម័យព្រះគម្ពីរ ប្រជារាស្ត្រអាចមិនយល់ពីមូលហេតុដែលពួកគេមិនត្រូវញ៉ាំឈាម ឬខ្លាញ់របស់សត្វដែលស្អាត។ សព្វថ្ងៃនេះយើងដឹងថា សូម្បីតែឈាមរបស់សត្វដែលស្អាតក៏អាចមានផ្ទុកជំងឺដែរ។ ហើយខ្លាញ់សត្វអាចចូលទៅក្នុងឈាមរបស់យើង ហើយបណ្តាលឲ្យកើតបញ្ហាធ្ងន់ធ្ងរដល់ បេះដូង និងសរសៃឈាមរបស់យើង។

ហេតុអ្វីបានជាព្រះជាម្ចាស់ផ្តល់ការណែនាំបែបនោះ អំពីអ្វីដែលត្រូវញ៉ាំនិងអ្វីដែលមិនត្រូវញ៉ាំ? គឺដោយសារសេចក្តីស្រឡាញ់ដ៏ធំរបស់ទ្រង់ចំពោះពួកគេ។ ទ្រង់ចង់ឲ្យពួកគេក្លាយជាមនុស្សដែលមានសុភមង្គល និងមានសុខភាពល្អបំផុតនៅក្នុងពិភពលោក។ នោះគឺជាអ្វីដែលទ្រង់ចង់បានឲ្យពួកយើងដូចគ្នាដែរ។

..................................................................................................................................



ចុះបើខ្ញុំនិយាយថា "រាងកាយរបស់ខ្ញុំ ជាកម្មសិទ្ធរបស់ខ្ញុំ។ គ្មានអ្នកណាម្នាក់អាចប្រាប់ខ្ញុំថាត្រូវធ្វើអ្វីចំពោះវាឡើយ។"

ព្រះគម្ពីរសួរសំណួរនេះដល់ខ្ញុំ ៖

"តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ។ ដ្បិតព្រះ

ទ្រង់បានចេញថ្លៃលោះអ្នករាល់គ្នាហើយ ដូច្នេះ ចូរតម្កើងព្រះនៅក្នុងរូបកាយ ហើយក្នុងវិញ្ញាណនៃអ្នករាល់គ្នា ដែលជារបស់ផងទ្រង់ចុះ”(កូរិនថូសទី១ ៦:១៩,២០)។

នេះមានន័យថា រាងកាយរបស់ខ្ញុំ គឺមិនមែនជារបស់ខ្ញុំឡើយ។ វាជារបស់ផងព្រះជាម្ចាស់ ដែលបានបង្កើតវា។ ហើយខ្ញុំជារបស់ផងទ្រង់ ពីព្រោះទ្រង់បានចេញថ្លៃលោះឲ្យខ្ញុំដោយសារព្រះលោហិតនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូគ្រីស្ទដែលបានសុគត់ដើម្បីសង្គ្រោះខ្ញុំចេញពីអំណាចនៃអំពើបាប និងសេចក្តីស្លាប់។ ព្រះគម្ពីរថែងបែបនេះ ៖

“ដូច្នេះ ទោះបើសុី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សម្រាប់ចម្រើនសិរីល្អដល់ព្រះចុះ” (កូរិនថូសទី១ ១០:៣១)។

អ្វីដែលយើងញ៉ាំ ឬផឹក ឬក៏អ្វីដែលយើងធ្វើចំពោះរាងកាយយើង គឺសំខាន់ចំពោះព្រះ។ ទ្រង់ចង់ឲ្យយើងមានសុខភាពល្អពេលឥឡូវនេះ ហើយត្រៀមខ្លួនទៅរស់នៅជាមួយនឹងទ្រង់នៅក្នុងនគរដ៏អស់កល្បរបស់ទ្រង់។ សូមស្តាប់ ៖

“តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរដកទេឬអី កុំឲ្យច្រឡំឡើយ ដ្បិតពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសាហាយស្មន់ ពួកអ្នកសម្រេចកិច្ចដោយខ្លួនឯង ពួកលេងកូនជឹង ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះដៀល និងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរព្រះទុកជាមរដកឡើយ” (កូរិនថូសទី១ ៦:៩,១០)។

ព្រះគម្ពីររាប់បញ្ចូលទាំងអសីលធម៌ខាងផ្នែកផ្លូវភេទ និងអំពើខុសប្រក្រតី នៅក្នុងចំណោមអ្វីដែលធ្វើឲ្យរាងកាយខូច។ ការស្រវឹងស្រា គឺជារឿងមួយ ទៀតដែលធ្វើឲ្យខូច និងបំផ្លាញជីវិត។ ការប្រើប្រាស់ស្រា នៅក្នុងលក្ខណៈបែបណាក៏ដោយ គឺជាបណ្តាសាដ៏ធំបំផុតនៅក្នុងពិភពលោករបស់យើង នាសព្វថ្ងៃនេះ។



ស្រា គឺជាភេសជ្ជៈជាតិអាល់កុលដែលមានគ្រប់ទីកន្លែងនៅក្នុងសម័យព្រះគម្ពីរ តែដំបូន្មាននៅក្នុងព្រះគម្ពីរត្រូវនឹងសម័យកាលរបស់យើងដែរ។ នេះគឺជាអ្វីដែលគម្ពីរបានថែងប្រាប់យើង ៖

“ឯស្រាទំពាំងបាយជូរ ជារបស់បញ្ឆោតមើលងាយ ហើយគ្រឿងស្រវឹងបង្កើតការឡូឡា អ្នកណាដែលវង្វេងដោយគ្រឿងទាំង២នោះ ឈ្មោះថាគ្មានប្រាជ្ញា” (សុភាសិត ២០:១)។

“កុំឲ្យមើលស្រាទំពាំងបាយជូរក្នុងកាលដែលមានពណ៌ក្រហម គឺក្នុងកាលដែលព្រួចពពុះនៅក្នុងកែវ ហើយហូរចុះទៅដោយស្រួលនោះឡើយ។ ដ្បិតដល់ចុងបំផុតនឹងចឹកដូចជាពស់វិញ ហើយអុចដូចជាពស់ហានុមានផង។ ភ្នែកឯងនឹងឃើញស្រីដទៃ ហើយចិត្តឯងនឹងពោលសេចក្តីខូចអាក្រក់ដែរ”(សុភាសិត ២៣: ៣១-៣៣)។

ការញ៉ាំស្រា នាំឲ្យមានការបែកបាក់គ្រួសារ មានគ្រោះថ្នាក់ដល់អាយុជីវិត និងបទឧក្រិដ្ឋហិង្សា។ មនុស្សញៀនស្រា ប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ចំពោះការកើត ជំងឺថ្លើម ខួរក្បាលរបស់ពួកគេខូច ហើយអាយុកាលថយចុះយ៉ាងហោចណាស់១២ឆ្នាំ។

ឪពុកម្តាយប្រមឹកផ្តល់កំណើតឲ្យកូនង៉ែត កើតមកខូចខួរក្បាល។ កូនង៉ែតទាំងនេះរងទុក្ខរាប់ឆ្នាំ ដោយសារតែរបៀបរស់នៅរបស់ឪពុកម្តាយ។

ការប្រើប្រាស់ថ្នាំជក់ គឺជាការញាំញីបែបទំនើបមួយបែបទៀត ដែលជះឥទ្ធិពលទៅលើមនុស្សជាតិ។ វាគឺជាមូលហេតុបង្កឲ្យមានសេចក្តីស្លាប់លេខមួយ ដែលអាចការពារបាន។ វាបានសម្លាប់មនុស្សជិតប្រាំមួយលាននាក់ជារៀងរាល់ឆ្នាំ។ អ្នកជក់ប្រឈមខ្ពស់នឹងជំងឺមហារីកសួត បន្ថែមពីលើជំងឺបេះដូង និងជំងឺសួត និងជំងឺសរសៃឈាមផ្សេងៗទៀត។

កូនង៉ែតដែលកើតចេញពីម្តាយដែលជក់បារី អាចស្លាប់នៅក្នុងវ័យនៅជាកូនង៉ែតច្រើនជាងកូនង៉ែតដែលកើតពីម្តាយដែលមិនជក់បារី។

តើមិនមានអ្វីឆ្ងល់ទេឬ ដែលថា ព្រះជាម្ចាស់ប្រាប់ឲ្យយើងថែរក្សារាងកាយរបស់យើងទុកជាព្រះវិហាររបស់ទ្រង់នោះ?

មិត្តអើយ បើអ្នករស់នៅក្នុងផ្លូវខុស ចូរសូមឲ្យព្រះអភ័យទោសឲ្យទៅ។ ទ្រង់នឹងអភ័យទោសឲ្យ។ ទ្រង់នឹងទទួលយកអ្នក ហាក់ដូចជាអ្នកមិនបានប្រព្រឹត្តរឿងទាំងអស់នោះឡើយ។ ហើយបើអ្នកទូលសូមដល់ទ្រង់ ទ្រង់នឹងផ្តល់កំលាំងឲ្យអ្នក ឲ្យមានជីវិតរស់នៅតាមបែបត្រឹមត្រូវ។ ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើជាអ្នកជួយដល់យើង ដើម្បីឲ្យយើងអាចយកឈ្នះលើទម្លាប់អាក្រក់ និងរស់នៅតាមបែបដែលនឹងផ្តល់ការគោរព ឬកិត្តិយសដល់ព្រះអទិកររបស់យើង។

តើមានចំនួនប៉ុន្មាននាក់ ចង់ឲ្យខ្ញុំអធិស្ឋានឲ្យអ្នកពេលឥឡូវនេះ សុំឲ្យទ្រង់ជួយសង្គ្រោះចេញពីទម្លាប់បាប និងសម្រាប់កំលាំងថាមពលដើម្បីរស់នៅស្របទៅតាមដំបូន្មានដ៏ល្អរបស់ព្រះជាម្ចាស់?

សូមអធិស្ឋានជាមួយគ្នា។

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ ទ្រង់គឺជាព្រះអទិកររបស់ពួកទូលបង្គំ។ ពួកទូលបង្គំជារបស់ផងទ្រង់។ ហើយទ្រង់បានសង្គ្រោះពួកទូលបង្គំដោយព្រះលោហិតរបស់ព្រះយេស៊ូ ដែលបានសុគត់ជំនួសបាបរបស់ពួកទូលបង្គំ។ អរព្រះគុណទ្រង់ចំពោះការបង្កើតរាងកាយដ៏អស្ចារ្យទាំងនេះ។ អរព្រះគុណទ្រង់ចំពោះការរចនាគ្រប់ផ្នែកនៃរាងកាយរបស់ពួកទូលបង្គំបានយ៉ាងល្អឥតខ្ចោះ។ អរព្រះគុណទ្រង់ដែលបានប្រទានឲ្យពួកទូលបង្គំនូវដំបូន្មានអំពីរបៀបដែលយើងត្រូវរស់នៅ ហើយនិងអ្វីដែលយើងត្រូវញ៉ាំ ឬត្រូវផឹក។ សូមទ្រង់អភ័យទោសឲ្យពួកទូលបង្គំ ដែលពួកទូលបង្គំប្រព្រឹត្តមិនល្អចំពោះរាងកាយទាំងនេះ ដែលជាព្រះវិហាររបស់ទ្រង់។ សូមផ្តល់កំលាំងឲ្យពួកទូលបង្គំកំចាត់នូវទម្លាប់មិនត្រឹមត្រូវ ហើយជួយឲ្យពួកទូលបង្គំរស់នៅស្របទៅតាមគម្រោងរបស់ទ្រង់សម្រាប់ពួកទូលបង្គំ។ ពួកទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ ៖

| | | |
|---|---|---|
| លោកុប្បត្តិ ២:១៥ | និក្ខមនំ ២៣:២៥ | ម៉ាកុស ៦:៣១ |
| កូរិនថូសទី១ ៣:១៧ | លោកុប្បត្តិ ៣:១៩ | លេវីវិន័យ ១១:៧,៨ |
| យ៉ូហាន ១០:១០ | ភីលីព ៤:១៣ | លោកុប្បត្តិ ៥:២៧ |
| ទំនុកតម្កើង ៨៤:១១ | យ៉ូហាន ១៥:៥ | យ៉ូហានទី៣ ២ |
| និក្ខមនំ ១៥:២៦ | ទំនុកតម្កើង ១០៥: ៣៧ | កិច្ចការ ៧:២២ |

## លំនាំពិភាក្សា

ភេសជ្ជៈ – ប្រើជំនួសទឹក

១. តើគ្រឿងញៀនដែលពេញនិយមជាងគេបំផុតរបស់ពិភពលោក គឺជាអ្វី?
២. តើជាតិកាហ្វេអ៊ីនបំផ្លាញរាងកាយរបស់អ្នកបានដោយរបៀបណា?
៣. តើស្ករបំផ្លាញរាងកាយរបស់អ្នកតាមវិធីណា?

សុខភាព

១. តើព្រះជាម្ចាស់បានផ្តល់អ្វីឲ្យអាដាម និងអេវ៉ា ញុំានៅក្នុងសួនច្បារ?
- លោកុប្បត្តិ ១:២៩

២. តើមានអ្វីបន្ថែមចំពោះអាហាររបស់ពួកគេ ក្រោយពីពួកគេបានប្រព្រឹត្តអំពើបាប?
- លោកុប្បត្តិ ៣:១៨

៣. ព្រះជាម្ចាស់បានរាប់សត្វខ្លះថាជា “សត្វស្អាត” និងសត្វខ្លះទៀតថា “មិនស្អាត” សត្វណាដែលអាចញុំាបាន ហើយផ្នែកណានៃ “សត្វដែលស្អាត” មិនអាចញុំាបាន?
- ចោទិយកថា ១៤:៧,៨, ១១-១៩ - លេវីវិន័យ ៣:១៧

៤. ហេតុអ្វីបានជាញុំាអាហារដែលមានសុខភាពល្អ ជារឿងសំខាន់?
- កូរិនថូសទី១ ៦:១៩,២០ - កូរិនថូសទី១ ១០:៣១

៥. តើមានអ្វីទៀតដែលបង្ខូចព្រះវិហារព្រះជាម្ចាស់ - រាងកាយរបស់ពួកយើង?
- កូរិនថូសទី១ ៦:៩,១០ - សុភាសិត ២០:១ - សុភាសិត ២៣:៣១-៣៣

# មេរៀនសុខភាពទី១៦ - ការព្យាបាលដោយប្រើទឹក



១. ព្រះជាម្ចាស់បានប្រទានឲ្យយើងនូវព្រះពរពីធម្មជាតិជាច្រើន ហើយទឹកគឺជាព្រះពរមួយប្រភេទ។ ទឹក គឺមិនត្រឹមតែប្រើសម្រាប់ញ៉ាំ និងលាងសំអាត ឬបោកគក់នោះទេ។ វាអាចប្រើសម្រាប់ព្យាបាលដោយសុវត្ថិភាព និងងាយស្រួលចំពោះការឈឺចាប់។

**ការងូតទឹកក្តៅ ឆ្លាស់ជាមួយនឹងទឹកត្រជាក់**

ការព្យាបាលដោយប្រើទឹកដែលមានប្រយោជន៍ គឺការងូតទឹកក្តៅ ឆ្លាស់ជាមួយនឹងទឹកត្រជាក់។ ការព្យាបាលនេះ អាចប្រើសម្រាប់រាងកាយទាំងមូល ឬក៏គ្រាន់តែមួយផ្នែក ដូចជាដៃ ជើង ឬក៏ប្រអប់ជើង។

ហេតុអ្វីទឹកក្តៅ និងទឹកត្រជាក់?

បើសិនជាអ្នកដាក់ដៃនៅក្នុងទឹកក្តៅដំបូង ហើយបន្ទាប់មកដាក់នៅក្នុងទឹកត្រជាក់ពីរឬបីនាទី អ្នកនឹងឃើញពណ៌ស្បែកប្រែទៅជាពណ៌ផ្កាឈូក ឬក៏ក្រហម ក្នុងពេលដែលឈាមធ្វើដំណើរចូល និងចេញពីដៃរបស់អ្នក។ កាលណាឈាមបង្កើនការធ្វើដំណើរទៅកាន់ផ្នែកនៃរាងកាយដែលឈឺ អុកស៊ីហ្សែន និងសារធាតុចិញ្ចឹមធ្វើដំណើរចូលទៅ ហើយកាកសំណល់ត្រូវបានបញ្ចេញចោលយ៉ាងលឿន។ ទឹកក្តៅទាញឈាមទៅកាន់តំបន់ដែលទឹកក្តៅនោះប៉ះ ក៏បើកសរសៃឈាម ហើយបង្កើនការផ្គត់ផ្គង់ឈាម។ បន្ទាប់មក ទឹកត្រជាក់បញ្ជូនឈាមចេញទៅ នៅពេលដែលសរសៃឈាមរួមទៅវិញដោយសារទឹកត្រជាក់។ ការធ្វើរបៀបនេះដដែលៗបីដង បង្កើនលំហូរឈាមទៅកាន់ផ្នែកនៃរាងកាយនោះ ហើយជួយឲ្យឆាប់ជាសះស្បើយ។

---

**២. របៀបព្យាបាលដោយប្រើចានធំជ្រៅ**

ប្រើចានធំជ្រៅចំនួនពីរ ចាក់ទឹកឲ្យល្មមលិចប្រអប់ជើងពីលើកជើង។ ចាក់ទឹកទៅក្តៅល្មមក្នុងចានធំជ្រៅ អ្នកអាចប្រើកែងដៃវាស់កម្តៅក្នុងទឹកដែលអ្នកចាក់ចូលទៅក្នុងចានធំជ្រៅ។ ចូរបន្ថែមទឹកក្តៅចូលទៅតាមតម្រូវការ ដើម្បីរក្សាកម្តៅឲ្យក្តៅល្មម ត្រូវប្រើកែងដៃវាស់កម្តៅទឹក។ ចូរចាក់ទឹកត្រជាក់ចូលទៅក្នុងចានធំជ្រៅមួយទៀត។ ត្រូវត្រាំជើងក្នុងទឹកក្តៅចំនួនបីនាទី រួចប្តូរទៅត្រាំជើងទៅក្នុងទឹកត្រជាក់ចំនួនកន្លះនាទី។ ចូរធ្វើបែបនេះបីដង ហើយត្រូវបញ្ចប់ជាមួយនឹងទឹកត្រជាក់ជានិច្ច។ បន្ទាប់មក អ្នកជំងឺអាចសម្រាកមួយរយៈ។

<u>សម្រាប់ឈឺក្បាល</u> - ឆ្លាស់ត្រាំជើងនៅក្នុងទឹកក្តៅ និងទឹកត្រជាក់។ ធ្វើបែបនេះ ទាញឈាមចេញឆ្ងាយពីក្បាល។ <u>របួសសាច់ដុំ ដូចរមួលកជើង</u> - ត្រូវត្រាំផ្នែកដែលរងរបួសនៅក្នុងទឹកត្រជាក់ចំនួនពីរថ្ងៃដំបូង បន្ទាប់មកប្តូរពីទឹកក្តៅ និងទឹកត្រជាក់ចុះឡើង ដើម្បីជួយឲ្យឆាប់ជាបានលឿន។

<u>របួសដៃ ឬជើង</u> - ត្រាំដៃ ឬជើងដែលរបួសឆ្លាស់គ្នានៅក្នុងទឹកក្តៅ ឬទឹកត្រជាក់នៅក្នុងចានធំជ្រៅ។

………………………………………………………………………………………………………………

៣. របៀបព្យាបាលដោយប្រើកន្សែងពោះគោ:

ចូរជ្រលក់កន្សែងពោះគោនៅក្នុងទឹកក្តៅ។ ពូតកន្សែងពោះគោ ហើយដាក់វាស្អំនៅត្រង់កន្លែងដែលត្រូវព្យាបាល។ បើសិនជាក្តៅពេក ត្រូវដាក់កន្សែងពោះគោស្ងួតនៅពីលើស្បែក បន្ទាប់មកដាក់កន្សែងពោះគោដែលជ្រលក់ទឹកក្តៅ។ ចូរប្រយ័ត្នឲ្យមែនទែន កុំឲ្យរលាកស្បែក។ ត្រូវឆែកមើល កុំឲ្យស្បែកឡើងក្រហមពេក។ ត្រូវរុំកន្សែងពោះគោដែលក្តៅជាមួយនឹងក្រណាត់ក្រាស់។ នៅពេលដែលកន្សែងពោះគោក្តៅនោះចុះត្រជាក់ ចូរដកវាចេញ ហើយដាក់កន្សែងពោះគោត្រជាក់ស្អំពីលើជំនួសវិញ។ ពេលអ្នកស្អំកន្សែងពោះគោត្រជាក់ អ្នកត្រូវរាប់ឲ្យដល់សាមសិប ដោយយឺតៗ។ ចូរធ្វើរបៀបនេះដដែលៗបីដង ដំបូងក្តៅ បន្ទាប់មកត្រជាក់។ បញ្ចប់ការព្យាបាលជាមួយនឹងកន្សែងត្រជាក់ ហើយសំងួតផ្នែករាងកាយ។

<u>សម្រាប់ផ្តាសាយដើមទ្រូង ឬក្អក</u> - ឆ្លាស់កន្សែងពោះគោក្តៅ និងត្រជាក់ ស្អំនៅផ្នែកខ្នងបីដង និងនៅលើដើមទ្រូងបីដង។

<u>សម្រាប់ឈឺខ្នង/របួស ឬក៏ពោះ/ក្រពះ</u> - ឆ្លាស់ស្អំកន្សែងពោះគោក្តៅ និងត្រជាក់នៅលើកន្លែងដែលឈឺបីដង។

………………………………………………………………………………………………………………

៤. របៀបព្យាបាលជំងឺគ្រុនក្តៅ

សម្រាប់ជំងឺគ្រុនក្តៅ ជូតខ្លួនជាមួយនឹងក្រណាត់សើម ដោយប្រើទឹកត្រជាក់ល្មម មិនមែនត្រជាក់ខ្លាំង។ អាចយកក្រណាត់ត្រជាក់សើមដាក់ពីលើថ្ងាស ឬនៅកផ្នែកខាងក្រោយ។ ជ្រលក់ស្រោមជើងជាមួយនឹងទឹកត្រជាក់ ពូតទឹកចេញរួចពាក់នៅពីលើជើងចំនួន១០នាទី។

<u>សម្រាប់កុមារដែលគ្រុនក្តៅខ្លាំង</u> - ត្រូវដាក់កុមារចូលទៅក្នុងចានធំជ្រៅដែលមានទឹកក្តៅឧណ្ហៗរួចហើយជ្រលក់អេប៉ុងទៅក្នុងទឹកយកមកស្បេតនៅលើស្បែករបស់ពួកគេ។ ឬក៏យកក្រណាត់សើមដែលក្តៅឧណ្ហៗដណ្តប់ពីលើដងខ្លួនរបស់ពួកគេរួចហើយប្តូរពេលដែលក្រណាត់នោះចាប់ផ្តើមត្រជាក់។ មិនត្រូវឲ្យកុមារ មានអាការៈរងារ ឬញ័រញាក់នោះឡើយ។ ព្យាបាលចំនួន២០នាទី ហើយបន្ទាប់មក ដណ្តប់ដោយក្រណាត់ស្តើង។ ចូរធ្វើបែបនេះ ពីរ ឬបីដងក្នុងមួយថ្ងៃ រហូតទាល់តែកម្តៅថយចុះ។ ចូរកុំប្រើអាល់កុលជូតខ្លួន ឬក៏ចាក់វាចូលទៅក្នុងទឹក។

………………………………………………………………………………………………………………

៥. តើត្រូវផ្តល់ការព្យាបាលញឹកញាប់ប៉ុណ្ណា?

ការព្យាបាលដោយងូតទឹកក្តៅ និងត្រជាក់ ត្រូវផ្តល់ឲ្យពី៣-៥ដងក្នុងមួយថ្ងៃ បើអាចធ្វើទៅបាន។ អ្នកជំងឺត្រូវញ៉ាំទឹកបន្ថែម ហើយសម្រាករយៈពេលមួយម៉ោងកន្លះ បន្ទាប់ពីការព្យាបាលនីមួយៗ ដើម្បីជួយឲ្យរាងកាយជាសះស្បើយ។

ពេលណាដែលមិនត្រូវប្រើការព្យាបាលដោយទឹក :

មិនត្រូវប្រើចំពោះមនុស្សណាដែលមិនអាចញាណដឹងពីសីតុណ្ហភាពទឹកឡើយ។
មិនត្រូវប្រើចំពោះមនុស្សដែលកើតជំងឺទឹកនោមផ្អែមឡើយ។
មិនត្រូវប្រើចំពោះមនុស្សដែលគ្រុនក្តៅខ្លាំង។
មិនត្រូវប្រើចំពោះកូនង៉ែត ឬក៏កុមារដែលខ្សោយឡើយ។

………………………………………………………………………………………………………………………

៦. ព្រះជាម្ចាស់បានប្រទានឲ្យយើងនូវវិធីព្យាបាលសាមញ្ញដោយប្រើទឹកតាមបែបធម្មជាតិ ហើយទ្រង់គឺជាអ្នកព្យាបាលដ៏អស្ចារ្យ ដូច្នេះ ចូរចាប់ផ្តើមការព្យាបាលដោយការអធិស្ឋានសុំពរ និងជំនួយពីព្រះជាមុនសិន។

## ពិធីបុណ្យជ្រមុជទឹក

*(គោលបំណងចំបងនៃមេរៀនអធិប្បាយនេះ គឺដើម្បីស្វែងរកមនុស្សដែលបានត្រៀមខ្លួនរៀនមេរៀនពិធីបុណ្យជ្រមុជទឹក។)*



លោកចិន្តា ចូលចិត្តសេពគ្រឿងស្រវឹង ហើយជក់បារី។ គាត់ដឹងថា វាមិនល្អសម្រាប់គាត់ឡើយ ប៉ុន្តែ គាត់នៅក្មេង ហើយគិតថាគាត់នឹងមិនមានបញ្ហាអ្វីឡើយ។ លោកចិន្តាខំធ្វើការដើម្បីចិញ្ចឹមបីបាច់ក្រុមគ្រួសាររបស់គាត់ដែលមានចំនួនច្រើននាក់។ គាត់ស្រឡាញ់ប្រពន្ធគាត់ឈ្មោះមុន្នីណាស់ ប៉ុន្តែ ពេលគាត់ស្រវឹងស្រា គាត់នៅខាងក្រៅរយៈពេលយូរលេងល្បែងស៊ីសង។ នៅពេលដែលគាត់ត្រឡប់មកផ្ទះវិញ អ្នកស្រីមុន្នីបន្ទោសគាត់អំពីរឿងអស់លុយ។ គាត់ខឹងខ្លាំង គាត់ស្រែកឲ្យ ហើយវាយអ្នកស្រី។ អ្នកស្រីខ្លាចក្រុមគ្រួសារគាត់ត្រូវបាក់បែកដោយសារការផឹកស្រារបស់គាត់។

ថ្ងៃមួយ លោកចិន្តាកើតជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ។ គាត់កាន់តែស្គមទៅៗ។ អ្នកស្រីមុន្នីបារម្ភអំពីគាត់ជាខ្លាំង។ មានគ្រីស្ទជនចិត្តសប្បុរសខ្លះបានមកជួយមើលថែគាត់រហូតដល់គាត់បានជាសះស្បើយ។ គាត់បានសម្រេចចិត្តទៅមើលព្រះវិហាររបស់ពួកគេ។ រឿងអំពីព្រះអទិករ និងការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាងបានទាក់ទាញចិត្តរបស់គាត់។ លោកចិន្តាដឹងខ្លួនថា ការផឹកស្រា ការជក់បារី និងការលេងល្បែងស៊ីសងរបស់គាត់ គឺជារឿងអាត្មានិយម។ គាត់គិតតែអំពីការសប្បាយរបស់ខ្លួនឯង ហើយមកបំផ្លាញសុភមង្គលក្នុងគ្រួសារទៅវិញ។ លោកចិន្តា បានសុំឲ្យព្រះកែប្រែចិត្តរបស់គាត់ ហើយជួយឲ្យគាត់ឈប់ផឹកស្រា និងជក់បារី។

នៅពេលដែលលោកចិន្តា ត្រឡប់មកពីព្រះវិហារវិញ អ្នកស្រីមុន្នីកំពុងតែកាប់អុស ហើយបានសួរថា "តើបងទៅណា ខាតតែពេលរឹងខ្ញុំវិញ ធ្វើការងារផ្ទះសព្វបែបយ៉ាង?"

គាត់បានឆ្លើយថា "បងទៅព្រះវិហារ"។

អ្នកស្រីបានស្រែកថា "ខ្ញុំស្អប់សាសនាគ្រីស្ទ"។ អ្នកស្រីបានលើកពូថៅគប់ទៅលោកចិន្តា។ តាមធម្មតា គាត់តែងតែខឹងខ្លាំង ហើយវាយផ្តួលអ្នកស្រីទៅនឹងដី។ តែគាត់បែរជាឈរស្ងៀមនៅទីនោះ ញញឹមដាក់អ្នកស្រី។ អ្នកស្រីមានការភ្ញាក់ផ្អើលចំពោះការកែប្រែនេះ។

នៅព្រឹកថ្ងៃសៅរ៍បន្ទាប់ អ្នកស្រីមុន្នីបានស្លៀកពាក់ស្អាតបាតរង់ចាំទៅព្រះវិហារជាមួយនឹងលោកចិន្តា។ "ខ្ញុំចង់ដឹងអំពីព្រះដែលបានកែប្រែប្តីរបស់ខ្ញុំ ពីប្តីដែលប្រមឹក ខឹងសម្បារ មកជាប្តីដែលល្អ និងស្មោះត្រង់។"

ពួកគាត់ទាំងពីរបានធ្វើបុណ្យជ្រមុជទឹក ជាគ្រីស្ទជនសេវេនដេយអាត់វេនទីស្ទ ហើយបម្រើការងារព្រះអស់រយៈពេលជាច្រើនឆ្នាំ។ កូនៗរបស់គាត់ជាច្រើនក៏ធំឡើង ហើយបានធ្វើការបម្រើព្រះដែរ។

នេះហើយ គឺជាអំណាច និងសេចក្តីស្រឡាញ់របស់ព្រះ ទ្រង់អាចកែប្រែអ្នកណាដែលយល់ព្រមឲ្យទ្រង់កែប្រែ។

តើអ្នកដឹងដែរឬទេ ថាព្រះយេស៊ូបានមានបន្ទូលអំពីការកើតជាថ្មី? ទ្រង់មិនបានមានបន្ទូលថា មនុស្សដែលមានច្រមុះធំអាចកើតជាថ្មី ហើយច្រមុះនោះរួមតូចនោះទេ។ ទ្រង់មិនបានមានបន្ទូលថា មនុស្សដែលមានត្រចៀកកំប៉ាងអាចកើតជាថ្មី ហើយមានត្រចៀកសំប៉ែតឡើយ។ គឺអត់ទេ។ ទ្រង់មានបន្ទូលអំពីមនុស្សផ្លាស់ប្តូរ ពីខាងក្នុងចិត្ត ជារឿងដែលសំខាន់ជាងគេបំផុត។

…………………………………………………………………………………………………………………………
.



នៅយប់មួយ មានបុរសម្នាក់ឈ្មោះនីកូឌេម បានមកគាល់ព្រះយេស៊ូ។ លោកនីកូឌេម គឺជាមេដឹកនាំដ៏សំខាន់នៅក្នុងព្រះវិហារជនជាតិយូដា។ អ្នករំពឹងថា គាត់ជាមនុស្សដែលទៀងទាត់ គួរឲ្យគោរព និងសុចរិត។ ព្រះយេស៊ូមានសារសម្រាប់គាត់៖

"ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ" (យ៉ូហាន ៣:៣)។

ឥឡូវ លោកនីកូឌេម គឺជាមនុស្សដែលមានអំណួត។ គាត់ប្រហែលជាគិតថា គាត់បានធ្វើអ្វីដែលចាំបាច់ដើម្បីធ្វើជាផ្នែកមួយនៃនគររបស់ព្រះរួចរាល់ហើយ។ គាត់ប្រហែលជាមិនបានគិតថាគាត់ត្រូវកែប្រែឡើយ។ ដូច្នេះ គាត់ក៏បាននិយាយ រឿងផ្តេសផ្តាស។ គាត់បាននិយាយថា៖

"ធ្វើដូចម្តេចនឹងកើតឡើងបាន ក្នុងកាលដែលចាស់ហើយ តើអាចនឹងចូលទៅក្នុងពោះម្តាយម្តងទៀត ហើយកើតឡើងវិញបានឬ?" (យ៉ូហាន ៣:៤)។

ប្រាកដណាស់ មិនអាចទេ!

ព្រះយេស៊ូបានមានបន្ទូលអំពីការផ្លាស់ប្រែដែលកើតឡើង នៅពេលដែលយើងទទួលយកទ្រង់ធ្វើជាព្រះអង្គសង្គ្រោះ។ វាគឺជាជីវិតថ្មី។ យើងអាចមើលទៅមានលក្ខណៈដូចគ្នាពីខាងក្រៅ ប៉ុន្តែខាងក្នុងចិត្តយើងមានលក្ខណៈខុសគ្នា។ ការផ្លាស់ប្រែគឺជារឿងដ៏អស្ចារ្យ។ គឺដូចជាស្លាប់ ហើយកើតជាថ្មីដូច្នោះឯង។

ព្រះយេស៊ូបានបន្តមានបន្ទូលជាមួយនឹងលោកនីកូឌេម។

"ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ" (យ៉ូហាន ៣:៥)។

..................................................................................................................................................
.



តើការកើតអំពីទឹក និងអំពីព្រះវិញ្ញាណមានន័យដូចម្តេច? ព្រះយេស៊ូបានផ្តល់ឲ្យយើងនូវគំរូរបស់ទ្រង់ មុននឹងទ្រង់ចាប់ផ្តើមធ្វើការងារព្យាបាលនិងបង្រៀនរបស់ទ្រង់។ ទ្រង់បានយាងទៅទន្លេយ័រដាន់ ដើម្បីទទួលបុណ្យជ្រមុជទឹកពីហោរាដ៏អស្ចារ្យ គឺលោកយ៉ូហានបាទីស្ទ ដែលបានជ្រមុជទ្រង់ចូលទៅក្នុងទឹក នោះហើយជាអត្ថន័យនៃពាក្យថា "បុណ្យជ្រមុជទឹក"នោះ។ បន្ទាប់មក លោកយ៉ូហានបានលើកទ្រង់ចេញពីទឹក។

ព្រះវរបិតារបស់ព្រះយេស៊ូដែលគង់នៅឯនគរឋានសួគ៌ មានព្រះទ័យរីករាយជាខ្លាំង។ សូមស្តាប់ ៖

"កាលព្រះយេស៊ូបានទទួលបុណ្យជ្រមុជហើយ នោះទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃក៏បើកឡើង ឲ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះ យាងចុះមកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់។ នោះមានឮសំលេងចេញពីមេឃថា "នេះជាកូនស្ងួនភ្ងាររបស់អញ ជាទីពេញចិត្តអញណាស់" " (ម៉ាថាយ ៣:១៦,១៧)។

មុននឹងទ្រង់យាងត្រឡប់ទៅនគរឋានសួគ៌វិញ ព្រះយេស៊ូបានប្រទានការណែនាំដល់អ្នកដើរតាមទ្រង់ថា ៖

"ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង..." (ម៉ាថាយ ២៨:១៩,២០)។

ព្រះគម្ពីរពន្យល់អំពីបុណ្យជ្រមុជទឹកបែបនេះ ៖

"តើអ្នករាល់គ្នាមិនដឹងទេឬអី ថាយើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្តីសុគតនៃទ្រង់ដែរ។ ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ" (រ៉ូម ៦:៣,៤)។

ដូច្នេះ អ្នកអាចដឹងហើយថា ពេលដែលយើងបានធ្វើបុណ្យជ្រមុជទឹក នោះយើងចូលរួមក្នុងការសុគតរបស់ព្រះយេស៊ូ ស្លាប់ទៅក្នុងជីវិតនៃអំពើបាបរបស់យើង។ ហើយយើងក៏ចូលរួមនៅក្នុងការរស់ឡើងវិញទៅកាន់ជីវិតបែបថ្មីដែរ។

---



លោក ភីលីព គឺជាចាស់ទុំនៅក្នុងព្រះវិហារគ្រីស្ទាន។ ព្រះវិញ្ញាណរបស់ព្រះបាននាំគាត់ទៅឯផ្លូវទីរហោឋានដែលនាំពីក្រុងយេរូសាឡិមឆ្ពោះទៅប្រទេសអេហ្ស៊ីប។ មានបុរសម្នាក់មកពីដំណាក់នៃប្រទេសអេត្យូពី បានធ្វើដំណើរតាមផ្លូវនោះដោយ រទេះ(រថ) ពីក្រុងយេរូសាឡិម ត្រឡប់ទៅផ្ទះរបស់គាត់វិញ។ គាត់អានព្រះគម្ពីរ ពេលដែលគាត់កំពុងជិះរទេះនៅតាមផ្លូវ។

នេះគឺជារបៀបដែលព្រះគម្ពីរពិពណ៌នាប្រាប់អំពីរឿងនេះ ៖

“ខណៈនោះ ព្រះវិញ្ញាណទ្រង់មានព្រះបន្ទូលទៅភីលីពថា ឲ្យចូលទៅប្រកៀកនឹងរថនោះទៅ។

ភីលីពក៏រត់ទៅតាម ឮលោកកំពុងតែអានមើលគម្ពីរហោរាអេសាយរួចសួរថា លោកមើលយល់ឬទេ?

ឯលោកក៏ឆ្លើយឡើងថា បើគ្មានអ្នកណាដឹកនាំខ្ញុំ នោះធ្វើដូចម្តេចឲ្យយល់បានរួចលោកក៏សូមឲ្យភីលីពឡើងជិះរថជាមួយគ្នា”(កិច្ចការ ៨:២៩,៣១)។

“នោះភីលីពបើកមាត់សម្តែងប្រាប់ដំណឹងល្អពីព្រះយេស៊ូ ចាប់តាំងពីបទគម្ពីរនោះរៀងទៅ។ កាលកំពុងតែទៅតាមផ្លូវ នោះឃើញមានទីទឹក ហើយអ្នកកំរៀរនិយាយថា មើលនុះន៏ទឹក តើមានអ្វីឃាត់មិនឲ្យខ្ញុំទទួលបុណ្យជ្រមុជទឹកបាន?”
(កិច្ចការ ៨:៣៥,៣៦)។

លោកភីលីព បានដឹងថាព្រះយេស៊ូបានមានព្រះបន្ទូល ៖

“អ្នកណាដែលជឿ ហើយទទួលបានបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ ...”
(ម៉ាកុស ១៦:១៦)។

ដូច្នេះ គាត់ក៏ប្រាប់ទៅបុរសជនជាតិអេត្យូពីថា ៖

“បើលោកជឿអស់ពីចិត្ត នោះទទួលបាន” (កិច្ចការ ៨:៣៧)។

---



លោកភីលីពយល់ថា បុណ្យជ្រមុជទឹករបស់គ្រីស្ទាន គឺសម្រាប់តែអ្នកដែលជឿដល់ព្រះយេស៊ូពិតប្រាកដតែប៉ុណ្ណោះ។ បុរសជនជាតិអេត្យូពីមិនបានយល់ដឹងរឿងគ្រប់យ៉ាងដែលព្រះគម្ពីរបង្រៀននោះទេ។ ដូចយើងភាគច្រើនដែរ គាត់កំពុងតែរៀនសូត្រ។ តែគាត់បានធ្វើការសម្រេចចិត្តអំពីព្រះយេស៊ូរួចទៅហើយ។

“នោះលោកបង្គាប់ឲ្យបញ្ឈប់រថ រួចភីលីព និងអ្នកកំរៀរ ក៏ចុះទៅក្នុងទឹកទាំង២នាក់ ហើយភីលីពគាត់ធ្វើបុណ្យជ្រមុជទឹកឲ្យ។ លុះឡើងពីទឹកមក នោះព្រះវិញ្ញាណនៃព្រះ

អម្ចាស់ ទ្រង់ឆក់យកភីលីពបាត់ទៅ ហើយអ្នក កំរៀវមិនបានឃើញគាត់ទៀតទេ ក៏ទៅតាមផ្លូវទៅដោយអរសប្បាយ” (កិច្ចការ ៨:៣៨-៣៩)។

ដូចព្រះយេស៊ូដែរ បុរសជនជាតិអេត្យូពីត្រូវបានកប់ទៅក្នុងទឹក ហើយត្រូវបានលើកឡើងមកវិញម្តងទៀត។ នេះគឺជារបៀបដែលមនុស្សគេធ្វើពិធីបុណ្យជ្រមុជទឹកកាលពីសម័យនោះ ហើយយើងបន្តធ្វើពិធីបុណ្យជ្រមុជទឹកនេះតាមរបៀបដូចគ្នានៅក្នុងសម័យនេះ។ ប្រភេទនៃបុណ្យជ្រមុជទឹកតាមបែបផ្សេងទៀត គឺទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់មនុស្ស ហើយវាមិនដូចពិធីបុណ្យជ្រមុជទឹកត្រឹមត្រូវ ដែលចែងនៅក្នុងព្រះគម្ពីរឡើយ។

---



យើងរៀនបន្ថែមអំពីបុណ្យជ្រមុជទឹកពីរឿងរបស់លោកសូល ជាអ្នកផ្សព្វផ្សាយដំណឹងល្អដ៏ល្បីល្បាញបំផុតនៃព្រះវិហារគ្រីស្ទានសម័យមុន។ មានពេលមួយនោះ គាត់ធ្លាប់ជាសត្រូវដែលអាក្រក់បំផុតរបស់គ្រីស្ទានសម័យមុន។ ការស្អប់ និងការកាប់សំលាប់ គឺមាននៅក្នុងចិត្តរបស់គាត់។ ប៉ុន្តែ ជីវិតរបស់គាត់ត្រូវបានផ្លាស់ប្រែ នៅពេលដែលគាត់បានទៅទីក្រុង ដាម៉ាស្កា នៅក្នុងប្រទេសស៊ីរី ដើម្បីសំលាប់ពួកគ្រីស្ទាននៅទីនោះ។ ពេលដែលគាត់ធ្វើដំណើរទៅជិតដល់ទីក្រុង គាត់ត្រូវបានខ្វាក់ភ្នែកដោយពន្លឺយ៉ាងខ្លាំងពីឋានសួគ៌។ ក្រោយមកគាត់បានប្រាប់អំពីរឿងនេះ។ សូមស្តាប់៖

“ខ្ញុំក៏ដួលដល់ដី ហើយឮសំលេងមានព្រះបន្ទូលមកខ្ញុំថា សុល នែ សុល ហេតុអ្វីបានជាធ្វើទុក្ខដល់ខ្ញុំ? ខ្ញុំបានឆ្លើយថា ឱព្រះអម្ចាស់អើយ តើព្រះអង្គណានុះ រួចទ្រង់មានព្រះបន្ទូលមកខ្ញុំថា ខ្ញុំជាព្រះយេស៊ូ ពីភូមិណាសារ៉ែត ដែលអ្នកបៀតបៀន” (កិច្ចការ ២២:៧,៨)។

---



លោក សុល បានឮព្រះយេស៊ូមានបន្ទូលប្រាប់គាត់ឲ្យទៅទីក្រុងដាម៉ាស្កា ហើយរង់ចាំការណែនាំ។ គូកនរបស់គាត់បាននាំគាត់ទៅទីក្រុង។ គាត់រង់ចាំនៅទីនោះ ចំនួនបីថ្ងៃ មិនអាចមើលឃើញ ហើយបដិសេធមិនព្រមញុំាអាហារ ឬទឹកឡើយ។ បន្ទាប់មកព្រះបានបញ្ជូនហោរាម្នាក់ឈ្មោះ អាណានៀសមកជួបគាត់។ ហោរាបាន និយាយថា៖

“អ្នកសុលអើយ សូមឲ្យភ្នែកអ្នកបានភ្លឺឡើង” (កិច្ចការ ២២:១៣)។

ភ្លាមនោះ ភ្នែករបស់គាត់ក៏បានបើកឡើង។

លោក អាណានៀស បានប្រាប់លោកសុលថា គាត់ត្រូវបានជ្រើសរើសឲ្យធ្វើការងារពិសេសសម្រាប់ព្រះជាម្ចាស់។ គាត់បាននិយាយថា៖

“ដ្បិតអ្នកត្រូវធ្វើជាស្មរបន្ទាល់ពីទ្រង់ ដល់មនុស្សទាំងអស់ពីគ្រប់ការដែលអ្នកបានឃើញ បានឮ។ ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត ចូរក្រោកឡើងទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ ដោយការអំពាវនាវដល់ព្រះនាមព្រះអម្ចាស់”

(កិច្ចការ ២២:១៥,១៦)។

លោក សុល ត្រូវការធ្វើការចាប់ផ្តើមជីវិតជាថ្មី។ គាត់ត្រូវការលាងសំអាតឲ្យជ្រះអស់ពីទង្វើអាក្រក់ទាំងប៉ុន្មានដែលគាត់បានប្រព្រឹត្ត។ គាត់ត្រូវការព្រះគុណអស្ចារ្យរបស់ព្រះ ហើយនិងការអភ័យទោស។ បុណ្យជ្រមុជទឹក គឺជាច្រកទ្វារទៅកាន់ជីវិតថ្មី សម្រាប់លោកសុល។ គាត់បានទទួលបុណ្យជ្រមុជទឹក ហើយបន្តក្លាយទៅជាអ្នកដឹកនាំ ដ៏អស្ចារ្យនៅក្នុងព្រះវិហារគ្រីស្ទាន។

មិត្តអើយ ខ្ញុំគិតថាគ្មាននរណាម្នាក់នៅទីនេះធ្លាប់បានខ្វាក់ដោយសារពន្លឺយ៉ាងខ្លាំងមកពីឋានសួគ៌នៅក្នុងកំឡុងពេលរៀនមេរៀនទាំងនេះឡើយ។ តែខ្ញុំពិតជាជឿជាក់ថា ព្រះយេស៊ូធ្លាប់បានមានបន្ទូលទៅកាន់ចិត្តរបស់អ្នក ពីព្រោះថា យើងទាំងអស់គ្នាមានចំណុចខ្លះដូចលោកសុលដែរ។ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យចាកចេញពីជីវិតនៃអំពើបាប ហើយធ្វើតាមគម្រោងការរបស់ទ្រង់សម្រាប់ជីវិតរបស់ពួកយើង។

ថ្ងៃនេះ ព្រះយេស៊ូមានបន្ទូលមកក្នុងចិត្ត ហើយមានបន្ទូលដូចគ្នាទៅនឹងអ្វីដែលទ្រង់មានបន្ទូលទៅកាន់លោកនីកូឌេមដែរ។

"ត្រូវតែកើតជាថ្មី" (យ៉ូហាន ៣:៧)។

ហើយពាក្យសម្ដីរបស់លោកហោរាក៏បានមកដល់យើងសព្វថ្ងៃនេះដែរថា៖

"ចូរក្រោកឡើង ទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ" (កិច្ចការ ២២:១៦)។

តើអ្នកចង់កើតជាថ្មីដែរ ឬទេ? សំអាតឲ្យស្អាតចេញពីអំពើបាបរបស់អ្នក? តើអ្នកចង់ធ្វើអ្វីដូចដែលព្រះយេស៊ូបានធ្វើ ហើយធ្វើបុណ្យជ្រមុជទឹក ដែរឬទេ? ពេលដែលរៀនមេរៀននេះចប់ភ្លាម ខ្ញុំចង់ទៅជួបអស់អ្នកដែលចង់រៀបចំខ្លួនសម្រាប់បុណ្យជ្រមុជទឹក។ បើសិនជាអ្នកចង់ចូលរួមជាផ្នែក មួយក្នុងក្រុម សូមមេត្តាមកពេលឥឡូវនេះ ហើយចូលរួមជាមួយខ្ញុំនៅទីនេះ មុននឹងយើងអធិស្ឋានបិទ។ ខ្ញុំចង់ឲ្យយើងនៅទីនេះជុំគ្នា នៅពេលដែលយើងអធិស្ឋាន។ (ផ្អាកបន្តិច រួចបន្តទៅកថាខណ្ឌបន្ទាប់)

នៅក្នុងជីវិតនេះ គ្មានអ្វីសំខាន់ជាងការរៀបចំត្រៀមខ្លួនសម្រាប់ជីវិតនាពេលខាងមុខឡើយ។ ការទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះ គឺជាក្ដីសង្ឃឹមតែមួយគត់របស់យើង បើសិនជាយើងចង់មានកន្លែងនៅក្នុងនគរដ៏អស់កល្បរបស់ព្រះ។ ទ្រង់បានត្រាស់ហៅយើងម្នាក់ៗឲ្យងាកទៅរកទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើង។

មនុស្សខ្លះនៅទីនេះ មិនទាន់បានធ្វើការសម្រេចចិត្តនៅឡើយ។ បើសិនជាអ្នកជាផ្នែកមួយនៃក្រុមនោះ សូមអ្នកលើកដៃឡើង ក្នុងពេលឥឡូវនេះបានទេ? ខ្ញុំចង់អធិស្ឋានសូមឲ្យព្រះវិញ្ញាណរបស់ព្រះនិយាយទៅកាន់អ្នក និងដឹកនាំអ្នក ហើយបង្ហាញដល់អ្នកអំពីអ្វីដែលអ្នកត្រូវធ្វើ។ ព្រះសូរសៀងរបស់ទ្រង់ ហើយនិងការដឹកនាំរបស់ទ្រង់ គឺសំខាន់ខ្លាំងជាងសំលេង និងការដឹកនាំរបស់ខ្ញុំទៅទៀត។

ឥឡូវ សូមយើងអធិស្ឋាន។

ឱព្រះវរបិតា ដែលគង់នៅឯនគរឋានសួគ៌ ទ្រង់អាចទតមើលក្នុងចិត្តរបស់ពួកទូលបង្គំ ហើយឃើញពីសេចក្តីត្រូវការដ៏ធំបំផុតរបស់ពួកទូលបង្គំ។ ពួកទូលបង្គំទាំងអស់គ្នា សុទ្ធតែជាមនុស្សមានអំពើបាប កំពុងតែត្រូវការព្រះអង្គសង្គ្រោះ។ ទ្រង់ទតឃើញអស់អ្នក

ដែលបានមកខាងមុខ ពួកគាត់ចង់រៀបចំត្រៀមខ្លួនសម្រាប់ពិធីបុណ្យជ្រមុជទឹក។ សូមទ្រង់ប្រទានពរ ឲ្យពួកគាត់មានទឹកចិត្ត និងជួយពង្រឹងពួកគាត់ក្នុងការធ្វើការសម្រេចចិត្ត។ សូមផ្តល់សេចក្តីសុខសាន្តនៅក្នុងចិត្ត និងសេចក្តីជំនឿដ៏រឹងមាំដល់ពួកគាត់នៅក្នុងសេចក្តីសន្យារបស់ទ្រង់។

ហើយព្រះវរបិតា ទ្រង់ជ្រាបដឹងអំពីមនុស្សម្នាក់ៗនៅទីនេះ ដែលមិនទាន់បានសម្រេចចិត្តទទួលយកព្រះយេស៊ូ ហើយដើរតាមទ្រង់ដោយធ្វើពិធីបុណ្យជ្រមុជទឹកនៅឡើយ។ សូមទ្រង់មេត្តា បញ្ជូនព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់មកដឹកនាំពួកគាត់ឲ្យនិយាយទៅកាន់ចិត្តពួកគាត់ ហើយជួយពួកគាត់ឲ្យយល់អំពីគម្រោងការរបស់ទ្រង់សម្រាប់ពួកគាត់។

អរព្រះគុណទ្រង់ចំពោះការបញ្ជូនព្រះយេស៊ូមកធ្វើជាព្រះអង្គសង្គ្រោះរបស់ពួកទូលបង្គំ។ បើគ្មានទ្រង់ទេ ពួកទូលបង្គំនឹងគ្មានក្តីសង្ឃឹមសម្រាប់ជីវិតអស់កល្ប។ ដោយសារក្តីស្រឡាញ់ដ៏ធំធេង និងការលះបង់របស់ទ្រង់ ដើម្បីពួកទូលបង្គំ ពួកទូលបង្គំអាចទន្ទឹងរង់ចាំទៅនៅជាមួយនឹងទ្រង់នៅក្នុងនគររបស់ទ្រង់។ សូមឲ្យទូលបង្គំយើងខ្ញុំគ្រប់គ្នាដែលនៅទីនេះ ត្រៀមខ្លួនទៅគាល់ទ្រង់នៅទីនោះ។ ទូលបង្គំយើងខ្ញុំសូមគ្រប់កិច្ចការទាំងនេះនៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ</u>

| | | |
|---|---|---|
| ម៉ាថាយ ៣:៥,៦ | យ៉ូហាន ៣:២-៥ | កិច្ចការ ១៦:២៨-៣៣ |
| យ៉ូហានទី១ ១:៩ | ម៉ាថាយ ៣:១៤-១៧ | កិច្ចការ ២:៤១,៤២ |
| កូរិនថូសទី១ ១២:១៣ | យ៉ូហាន ១:២៩ | កិច្ចការ ១០:៣៨ |
| អេភេសូរ ៤:៥ | | |

## លំនាំពិភាក្សា

**ការព្យាបាលដោយប្រើទឹក**

១. តើទឹកក្តៅ និងទឹកត្រជាក់ជួយព្យាបាលដោយរបៀបណា?
២. តើមានជំងឺណាខ្លះ ដែលអាចព្យាបាលដោយប្រើទឹកបាន?
៣. តើអ្នកណាដែលជាអ្នកព្យាបាលដ៏អស្ចារ្យ?

**ពិធីបុណ្យជ្រមុជទឹក**

១. ហេតុអ្វីបានជាចាំបាច់ត្រូវកើតជាថ្មី?
 - យ៉ូហាន ៣:៣
២. តើមានអ្វីកើតឡើងចំពោះមនុស្សដែលកើតជាថ្មី?
៣. តើពាក្យ "បុណ្យជ្រមុជទឹក" មានន័យដូចម្តេច?
៤. តើអត្ថន័យខាងព្រលឹងវិញ្ញាណនៃពិធីបុណ្យជ្រមុជទឹកជាអ្វី?
 -រ៉ូម ៦:៣,៤

៥. តើយើងដឹងបានដោយរបៀបណាថា បុរសជនជាតិអេត្យូពីបានត្រៀមខ្លួនធ្វើបុណ្យជ្រមុជទឹក?

- កិច្ចការ ៨:៣៥-៣៨

៦. តើមានអ្វីកើតឡើងចំពោះអំពើបាបរបស់យើង នៅពេលដែលយើងបានធ្វើបុណ្យជ្រមុជទឹក?

- កិច្ចការ ២២:១៦

## មេរៀនសុខភាពទី១៧ - កិត្តិយស និងការគោរព (ជំងឺដែលឆ្លងតាមរយៈការរួមភេទ -STIs)




១. ស្តេចដាវីឌ គឺជាស្តេចដែលគេគោរពជាងគេនៅក្នុងព្រះគម្ពីរ។ កាលពីនៅវ័យជំទង់ ទ្រង់បានមើលថែសត្វចៀមរបស់ឪពុកទ្រង់ ស្តេចដាវីឌបានរៀនស្រឡាញ់ និងជឿទុកចិត្តដល់ព្រះជាម្ចាស់។ ទ្រង់បានសំលាប់សត្វតោ និងខ្លាឃ្មុំដោយព្រះហស្ត(ដៃ)ទទេរបស់ទ្រង់ ពេលដែលទ្រង់ក្លាយជាយុវជន ទ្រង់បានសំលាប់យក្សកូលីយ៉ា ដើម្បីការពារព្រះនាមព្រះ។ ពេលដែលទ្រង់ក្លាយជាស្តេចអុីស្រាអែល ស្តេចដាវីឌ បានដឹកនាំទ័ព និងដណ្តើមបានជ័យ ជំនះពីសត្រូវ។ ទ្រង់ត្រូវបានរាស្ត្រពេញមួយនគរស្រឡាញ់ និងគោរព។ ព្រះជាម្ចាស់បានប្រទានពរដល់បុរសដែលភាពស្មោះត្រង់ ក្លាហានមោះមុត ហើយមានបន្ទូលសរសើរអំពីទ្រង់ថា “អញរកបានដាវីឌ កូនអ៊ីសាយជាទី គាប់ចិត្តដល់អញ ដែលនឹងធ្វើតាមចិត្តអញគ្រប់ជំពូក”(កិច្ចការ ១៣:២២)។

គួរឲ្យស្តាយ ពេលដែលស្តេចដាវីឌ មានវ័យចាស់ជរាទៅ ទ្រង់ក៏បានវង្វេងចេញពីព្រះ ហើយបានប្រព្រឹត្តអំពើបាបយ៉ាងធំធេង។

.............................................................................................................................................

២. បញ្ញត្ត១០ប្រការរបស់ព្រះជាម្ចាស់ គឺជារបងការពារ។ វាជួយការពារយើងឲ្យមានសុវត្ថិភាព។ តែស្តេចដាវីឌបដិសេធមិនទទួលយកការការពារពីព្រះ មិនយកចិត្តទុកដាក់ជាមួយនឹងក្រុមគ្រួសារ ហើយនិងអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់ទ្រង់។ គាត់វក់នឹងប្រពន្ធកូនទាហានដ៏ស្មោះត្រង់ ក្លាហាន និងសុចរិតរបស់ទ្រង់ម្នាក់ ដែលមានវ័យក្មេង ហើយស្អាត។

ស្តេចដាវីឌ បានប្រព្រឹត្តរំលងបញ្ញត្តទី១ ដោយផ្តល់កិត្តិយសឲ្យខ្លួនឯងជាជាងព្រះ។ ទ្រង់បានប្រព្រឹត្តរំលងបញ្ញត្តទី១០ ដោយសារទ្រង់លោភលួចយកប្រពន្ធវ័យក្មេង ស្រស់ស្អាត ដែលជាប្រពន្ធរបស់បុរសម្នាក់ទៀត។ ទ្រង់បានប្រព្រឹត្តរំលងបញ្ញត្តទី៧ នៅពេលដែលទ្រង់បានបញ្ចុះបញ្ចូលនាងឲ្យរួមដំណេកជាមួយ។ ទ្រង់ក៏បានប្រព្រឹត្តរំលងបញ្ញត្តទី៦ នៅពេលដែលទ្រង់បានបញ្ជូនប្តីដែលមានវ័យក្មេងរបស់នាងឲ្យទៅស្លាប់ក្នុងសមរភូមិ ដើម្បីឲ្យទ្រង់អាចរៀបការជាមួយនាងបាន។

.............................................................................................................................................

៣. ហោរាបានមកជួបស្តេចដាវីឌ ជាមួយនឹងសារនៃការស្តីបន្ទោសពីឋានសួគ៌។ ស្តេចដាវីឌ បានទទួលយកការស្តីបន្ទោស ហើយបានលន់តួទោសយ៉ាងអស់ពីចិត្ត។ ព្រះជាម្ចាស់បានអភ័យទោសឲ្យទ្រង់។ ប៉ុន្តែ គាត់ត្រូវបានបាត់បង់ការទុកចិត្តពីក្រុមគ្រួសារ ហើយនិងអ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទ្រង់ ហើយចាប់តាំងពីពេលនោះមក ជីវិតរបស់ទ្រង់ជួបតែបញ្ហា។ ព្រះគម្ពីរចែងថា “តែផ្លូវរបស់មនុស្សដែលរំលងច្បាប់ នោះពិបាកវិញ” (សុភាសិត ១៣:១៥) ហើយវាពិបាកសម្រាប់ស្តេចដាវីឌ។ អំពើបាបរបស់ទ្រង់បានបំផ្លាញព្រលឹងរបស់ទ្រង់

ហើយធ្វើឲ្យឥទ្ធិពល និងអំណាចរបស់ទ្រង់ទៅលើកូនចៅ ហើយនិងប្រទេសជាតិរបស់ទ្រង់ចុះខ្សោយ។ សីលធម៌ផ្នែកអាកប្បកិរិយានៃក្រុមគ្រួសារ និងនគររបស់ទ្រង់កាន់តែអាក្រក់។

អាមនុន ដែលជាបុត្រាច្បងរបស់ស្តេចដាវីឌ បានរំលោភប្អូនស្រីចុងរបស់ខ្លួន។ ស្តេចដាវីឌ មិនបានរកខុសត្រូវអ្វីឡើយ ដោយសារតែវាជាកំហុសរបស់ទ្រង់។ បងប្រុសបង្កើតរបស់ប្អូនស្រី ដែលមានឈ្មោះថា អាប់សា-ឡោម ខឹងជាខ្លាំង ក៏បានសំលាប់អាមនុន។ ម្តងនេះទៀត ស្តេចដាវីឌ ក៏មិនបានធ្វើអ្វីដែរ។ អាប់សាឡោម មិនគោរពបិតារបស់ទ្រង់ឡើយ ហើយបានព្យាយាមលួចរាជបល្ល័ង្ករបស់ទ្រង់ទៀត។ ស្តេចដាវីឌ ក៏មិនបានធ្វើអ្វីឡើយ។ នៅទីបំផុត អាប់សាឡោម ដែលស្តេចដាវីឌស្រឡាញ់ជាទីបំផុត ត្រូវបានសំលាប់។

នេះគឺជារឿងសោកនាដកម្មមួយ តែវានៅកើតមានឡើងនៅសម័យកាលនេះដែរ។ ពួកមនុស្សប្រុស និងមនុស្សស្រីឈ្លក់នឹងកាមតណ្ហាពីមួយទៅមួយ ហើយប្រព្រឹត្តរំលងបញ្ញត្តរបស់ព្រះទាំងក្នុងចិត្ត និងទាំងទង្វើរបស់ពួកគេ។ ហើយដូចស្តេចដាវីឌដែរ ពួកគេនឹងទទួលផលវិបាក។ ទំនាក់ទំនងគ្រួសារត្រូវបានបាក់បែក កើតជំងឺឆ្លងរាលដាល (អេដស៍ ស្វាយ និងជំងឺផ្សេងៗទៀត) មានកូនដែលមិនចង់បានកើតមក ហើយត្រូវវងទុក្ខ អ្នកដែលមានទោស ត្រូវបានគេលែងជឿទុកចិត្ត គេលែងគោរព និងលែងឲ្យតម្លៃ។ ដូចព្រះគម្ពីរបានចែងថា "តែឯអ្នកណាដែលលួចប្រពន្ធគេ នោះជាអ្នកឥតមានគំនិតឡើយ អ្នកណាដែលប្រព្រឹត្តអំពើយ៉ាងនោះ ឈ្មោះថាចង់បំផ្លាញជីវិតខ្លួនហើយ" (សុភាសិត ៦:៣២)។

---

៤. កាលព្រះបង្កើតពិភពលោក ទ្រង់បានបង្កើតអាដាម និងអេវ៉ា សម្រាប់ជាដៃគូនឹងគ្នា។ ពេញមួយព្រះគម្ពីរ គម្រោងការរបស់ព្រះជាម្ចាស់ គឺច្បាស់លាស់ណាស់៖ អាពាហ៍ពិពាហ៍ គឺរវាងបុរសម្នាក់ និងស្ត្រីម្នាក់ ចំណងនេះ គឺមួយជីវិត។ ព្រះជាម្ចាស់ស្អប់ការផិតក្បត់ ពីព្រោះទ្រង់ស្រឡាញ់មនុស្សលោក ហើយចង់ជួយឲ្យគេរួចចាកផុតពីផលវិបាក និងបញ្ហាទុក្ខកង្វល់។

បញ្ញត្តទី៧របស់ព្រះចែងថា "កុំឲ្យប្រព្រឹត្តអំពើផិតក្បត់ឡើយ"។ ច្បាប់នេះជួយការពារ ដោយការដាក់កម្រិតព្រំដែនទំនាក់ទំនងផ្លូវភេទចំពោះដៃគូដែលបានរៀបការហើយ។ អ្នកដែលនៅលីវ ត្រូវបានរក្សាសុវត្ថិភាពដោយការរង់ចាំទំនាក់ទំនងផ្លូវភេទរហូតទាល់តែរៀបការរួច បន្ទាប់មកត្រូវមានភាពស្មោះត្រង់ចំពោះប្រពន្ធ/ប្តី។

តែគួរឲ្យស្តាយ មានមនុស្សប្រុសគ្រប់ជាតិសាសន៍ និងវប្បធម៌មួយចំនួន ដែលចង់មានទំនាក់ទំនងផ្លូវភេទដោយសេរី រាប់បញ្ចូលទាំងទំនាក់ទំនងផ្លូវភេទជាមួយនឹងស្ត្រីវ័យក្មេងដែលនៅលីវផងដែរ។ នៅកន្លែងខ្លះ ក្មេងស្រីនៅលីវ ដែលមិនមានដៃគូផ្លូវភេទជាបុរសនោះ គឺមិនមានឋានៈ (មុខមាត់) ក្នុងសង្គមទេ ដូច្នេះ ពួកគេច្រើនតែបណ្តោយខ្លួនឲ្យមានទំនាក់ទំនងផ្លូវភេទជាមួយនឹងបុរសជាច្រើន។ ការធ្វើបែបនេះ នាំឲ្យពួកគេប្រឈមនឹងការឆ្លងជំងឺ និងចំលងជំងឺ។ គម្រោងការរបស់ព្រះ ជួយការពារស្ត្រីក្មេងៗពីការ កេងប្រវ័ញ្ចផ្នែកផ្លូវភេទ ហើយនិងផលវិបាកនានារបស់វា។ ការរួមភេទមិនរើសមុខ ឬដៃគូច្រើន ត្រូវបានព្រះដាក់បណ្តាសា។

គុណវិបត្តិមួយនៃការរួមភេទមិនរើសមុខ ឬមានដៃគូច្រើន គឺជាជំងឺឆ្លងតាមរយៈការរួមភេទ ឬជំងឺកាមរោគ (STDs – Sexual Transmitted Diseases)។

មានមេរោគដែលគ្រោះថ្នាក់យ៉ាងហោចណាស់៣០ប្រភេទខុសៗគ្នា ដែលឆ្លងតាមការរួមភេទ និងតាមឈាម។ បាក់តេរីវីរុស និងបរាសិតទាំងនេះបណ្តាលឲ្យកើតជំងឺដែលគ្រោះថ្នាក់ជាច្រើន។ មានតែជំងឺផ្លូវភេទ៤ប្រភេទតែប៉ុណ្ណោះដែលអាចព្យាបាលឲ្យជាបានដោយប្រើថ្នាំផ្សះ ឬអង់ទីប៊ីយ៉ូទិក៖ ជំងឺស្វាយ ជំងឺប្រមេះ (រលាកហើមប្រដាប់ភេទ) ជំងឺក្លាមីឌា និងជំងឺទ្រីខូម៉ូនីអាសុីស។ ជំងឺពីរប្រភេទអាចបង្កាបានដោយការចាក់ថ្នាំការពារ៖ ជំងឺរលាកថ្លើមប្រភេទប៊ី ឬបេ និងជំងឺរលាកមាត់ស្បូន (HPV-Human papillomavirus)។

រោគសញ្ញាឬអាការៈនៃជំងឺកាមរោគ

ជំងឺកាមរោគភាគច្រើន មានចេញរោគសញ្ញាភ្លាមៗ ហើយរោគសញ្ញាខ្លះដូចជាជំងឺអេដស៍ និងទ្រីខូម៉ូនីអាស៊ីស អាចប្រើរយៈពេលអស់ជាច្រើនឆ្នាំទើបរោគសញ្ញាលេចចេញ។ ទាំងបុរស និងស្រ្តី អាចមានអាការៈឈឺពេលបត់ជើងតូច ហៀរទឹករងៃ/ធ្លាក់ស កន្ទួលនៅលើរាងកាយ ក្រហម រមាស់ខ្លាំង ដំបៅ និងដុំ ឬក៏ដំបៅមាត់ ឬក៏នៅលើប្រដាប់បន្តពូជ។ ជំងឺកាមរោគដែលច្រើនកើតជាងគេ គឺជំងឺស្វាយ អាចបណ្តាលឲ្យកើតជំងឺបេះដូង ខ្វិន ខូចខួរក្បាល និងស្លាប់បាន។ រាល់ជំងឺឆ្លងដោយសារការរួមភេទ វាធ្វើឲ្យប្រព័ន្ធការពារចុះខ្សោយ ធ្វើឲ្យងាយស្រួលឆ្លងជំងឺផ្លូវភេទផ្សេងទៀត ជាពិសេស គឺជំងឺអេដស៍។

វាជាការចាំបាច់ដែលត្រូវឲ្យក្រុមគ្រូពេទ្យវិនិច្ឆ័យអាការៈរោគ ឬរោគសញ្ញា ដើម្បីធ្វើការព្យាបាល។

..............................................................................................................................................

៥. ម្តាយដែលឆ្លងរោគនេះ អាចមានអាករៈឈឺស្បូន ហើយមិនអាចបង្កកំណើតបាន។ មេរោគ អាចបណ្តាលឲ្យកូនក្នុងផ្ទៃស្លាប់ កូនងាប់កើតមកស្លាប់ កូនកើតមិនគ្រប់ទម្ងន់ និងកើតមិនគ្រប់ខែ។ មេរោគអាចចម្លងពីម្តាយទៅកូនក្នុងកំឡុងពេលមានផ្ទៃពោះ ពេលឆ្លងទន្លេ និងពេលដែលបំបៅកូន ហើយអាចបណ្តាលឲ្យកើតជំងឺហើមស្ងួត ធ្វើឲ្យខូចឆ្អឹង ខូចខួរក្បាល និងសរសៃប្រសាទ ខ្វាក់ និងពិការ។ បើស្រ្តីមានផ្ទៃពោះមានមេរោគនេះ ត្រូវទទួលការពិនិត្យ ប្រឹក្សានិងព្យាបាលពីសំណាក់គ្រូពេទ្យ។

..............................................................................................................................................

៦. អ្នកដែលមានទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍ គឺប្រឈមនឹងការឆ្លងជំងឺកាមរោគ ហើយត្រូវឲ្យគ្រូពេទ្យវិនិច្ឆ័យរោគ ទោះបីជាគ្មានរោគសញ្ញាក៏ដោយ។ ការព្យាបាលបានឆាប់រហ័សជួយបង្កាកុំឲ្យមានការខូចខាត។

ជំងឺទាំងអស់នេះអាចជៀសផុតបាន បើសិនជារក្សាទំនាក់ទំនងផ្លូវភេទសម្រាប់ពេលរៀបការ។ ព្រះបានបង្កើតទំនាក់ទំនងផ្លូវភេទនេះឡើង ដើម្បីឲ្យបុរស និងស្រ្តីដែលបានសន្យារក្សាភាពស្មោះត្រង់ជាមួយគ្នានោះបានរីករាយជាមួយគ្នាអស់មួយជីវិត។ បើសិនជាគ្មានដៃគូណាម្នាក់មានជំងឺផ្លូវភេទទេ ហើយបើសិនជាពួកគេស្រឡាញ់គ្នា ហើយនៅតែស្មោះត្រង់នឹងគ្នា ពួកគេនឹងមិនចាំបាច់ត្រូវខ្លាចជំងឺទាំងនេះឡើយ! ពួកគេ និងកូនៗត្រូវបានការពារ ដោយការធ្វើតាមគម្រោងការរបស់ព្រះ។

## ដានីញ៉ែល ជំពូក ៧



ឧបមាថា អ្នកជាក្មេងតូច ហើយយាយរបស់អ្នកនិយាយរឿងដ៏អស្ចារ្យមួយប្រាប់អ្នក។ គាត់ប្រាប់អ្នកពីដំណើររឿងដំបូង ហើយនិងពាក់កណ្តាលផ្ទៃរឿង តែបន្ទាប់មកមុននឹងគាត់និយាយទៅដល់ចុងបញ្ចប់ គាត់ក៏ឈប់។ អ្នកមុខជានិយាយថា “យាយសូមកុំឈប់។ សូមប្រាប់សាច់រឿងដែលនៅសេសសល់ឲ្យខ្ញុំស្តាប់។”

ចុះបើគាត់និយាយថា “យាយសុំទោស។ យាយអត់ដឹងសាច់រឿងទាំងអស់ទេ។ ដូច្នេះ យាយមិនអាចប្រាប់ពីចុងបញ្ចប់នៃសាច់រឿងបានទេ។” ក្មេងភាគច្រើននឹងមិនស្កប់ចិត្តជាមួយនឹងសាច់រឿងត្រឹមតែសាច់រឿងដំបូង និងកណ្តាលសាច់រឿងប៉ុណ្ណោះទេ តើមែនទេ? ពួកគេចង់ដឹងចុងបញ្ចប់នៃសាច់រឿងដែរ។

មនុស្សធំក៏ដូចគ្នាដែរ។ យើងទាំងអស់គ្នាចង់ដឹងពីសាច់រឿងបញ្ចប់ទៅយ៉ាងណា។ ខ្ញុំគិតថា ហោរាដានីញ៉ែល ក៏មិនខុសគ្នាដែរ។ គាត់បានគិតអំពីការតស៊ូប្រយុទ្ធយ៉ាងធំធេងរវាងល្អ និងអាក្រក់នៅក្នុងពិភពលោក ហើយគាត់ចង់ដឹងចុងបញ្ចប់នៃរឿង។

ប្រាកដណាស់ ព្រះជាម្ចាស់ជ្រាបដឹងផ្ទៃរឿងទាំងមូល។ ទ្រង់បានបញ្ជូនសុបិននិមិត្តអំពីអនាគតកាលទៅឲ្យលោកដានីញ៉ែល ហើយនិងទេវតាមួយរូបជួយពន្យល់ឲ្យគាត់យល់។ សូមស្តាប់ ៖

“ខ្ញុំបានឃើញការជាក់ស្តែងនៅពេលយប់ដូច្នេះ ខ្យល់ទាំង៤នៅលើអាកាសធ្លាក់ចុះមកលើមហាសមុទ្រ។ រួចមានសត្វធំ៤ឡើងចេញពីសមុទ្រមក មានសណ្ឋានផ្សេងៗគ្នា។ សត្វទី១ដូចជាសិង្ហ ហើយមានស្លាបជាស្លាបឥន្ទ្រី ...

រួចឃើញសត្វ១ទៀត ជាសត្វទី២មានសណ្ឋានជាខ្លាឃ្មុំ ក៏ឈរចំខែងពាំឆ្អឹងជំនីរ៣នៅក្នុងមាត់ ខាំដោយធ្មេញ ...

ក្រោយមក ខ្ញុំគន់មើលទៅឃើញសត្វ១ទៀតមានសណ្ឋានជាខ្លារខិន ឯនៅលើខ្នងវាមានស្លាប៤នៃសត្វហើរ ក៏មានក្បាល៤ដែរ...

លំដាប់នោះ ក្នុងការជាក់ស្តែងពេលយប់ ខ្ញុំក៏ឃើញសត្វទី៤ដែលគួរស្ញើម គួរស្ញែងខ្លាច ហើយមានកំលាំងយ៉ាងក្រៃលែង មានធ្មេញដែកធំៗ វាត្របាក់លេប លំអិត កំទេចហើយជាន់ឈ្លីសំណល់ដោយជើង សត្វនោះផ្សេងពីអស់ទាំងសត្វដែលមក ជាមុននោះ ក៏មានស្នែង១០”(ដានីញ៉ែល ៧:២-៧)។

នេះគឺជាសុបិននិមិត្តដែលគួរឲ្យខ្លាច។ តើសត្វធំទាំងនេះ មានអត្ថន័យដូចម្តេច?វាគឺជាអាថិកំបាំង។ លោកដានីញ៉ែលបានសរសេរ ៖

“ឯខ្ញុំដានីញ៉ែល  ចិត្តខ្ញុំកើតមានសេចក្តីតប់ប្រមល់នៅក្នុងខ្លួន ហើយការជាក់ស្តែងក្នុងខួរខ្ញុំ ក៏នាំឲ្យខ្ញុំវិតក្កព្រួយ”(ដានីញ៉ែល ៧:១៥)។

ព្រះបានបញ្ជូនទេវតាមួយរូបទៅជួយដល់ហោរា។ ទេវតាបាននិយាយថា ៖

“ឯសត្វធំទាំង៤នោះ គឺជាស្តេច៤អង្គដែលនឹងកើតឡើងនៅផែនដី”(ដានីញ៉ែល ៧:១៧)។

---



លោកដានីញ៉ែលបានដឹងថា ស្តេចនៃបាប៊ីឡូន បានប្រើប្រាស់រូបសិង្ហជាតំណាងឲ្យអាណាចក្រដ៏អស្ចារ្យរបស់ពួកទ្រង់(ស្តេច)។ គាត់យល់ថា ក្បាលដែលធ្វើអំពីមាស និងសិង្ហដែលមានស្លាបឥន្ទ្រីទាំងពីរនេះ គឺជានិមិត្តរូបនៃក្រុងបាប៊ីឡូន។

នៅក្នុងសុបិននិមិត្តអំពីសត្វទាំង៤នេះ លោកដានីញ៉ែលបានឃើញមានការប្រែប្រួលយ៉ាងធំចំពោះសត្វសិង្ហ។ សូមស្តាប់ ៖

“ខ្ញុំបានគន់មើលដរាបដល់ចំអេងស្លាបវាត្រូវដកចេញ ហើយវាត្រូវលើកឡើងផុតពីដី ក៏ដាក់ឲ្យឈរជើង២ដូចជាមនុស្ស ហើយបានឲ្យវាមានចិត្តរបស់មនុស្សដែរ”(ដានីញ៉ែល ៧:៤)។

លោកហោរាបានដឹងអំពីរឿងនោះ។ គាត់ខ្លួនឯងបានដឹងអំពីរឿងនោះ។ គាត់ខ្លួនឯងបានឃើញនូវការដួលរលំនៃក្រុងបាប៊ីឡូន។ ពីមុនដូចជាសិង្ហ ដែលមានឫទ្ធិអំណាច

ស្តេចនៃសត្វទីក្រុងបាប៊ីឡូនបានបាត់បង់អំណាចដ៏ធំធេង ហើយធ្លាក់ខ្លួនមកជាបុរសសាមញ្ញធម្មតាវិញ។

..................................................................................................................................................



លោកដានីញ៉ែលបានមើលហេតុការណ៍នោះកើតឡើង។ គាត់នៅទីនោះ នៅពេលដែលទីក្រុងបាប៊ីឡូនត្រូវបានដួលរលំនៅក្នុងឆ្នាំ៥៣៩ មុន គ.ស.។ នគរមីឌា និងពើស៊ីបានរួបរួមគ្នា ដើម្បីជំនួសទីក្រុងបាប៊ីឡូននៅលើវេទិកាពិភពលោក។ លោកដានីញ៉ែលបានដឹងអំពីអាណាចក្រមីដូពើស៊ីជាខ្លាឃ្មុំដ៏ធំ។

នៅក្នុងសុបិននិមិត្តរបស់គាត់ គាត់បានឃើញសត្វខ្លាឃ្មុំក្រោកឡើងនៅម្ខាង។ គាត់ដឹងហើយថា នៅម្ខាងអាណាចក្រគឺខ្លាំងជាងនៅម្ខាងទៀត។ ខាងពើស៊ី គឺខ្លាំងជាងគេបំផុត។ ក៏ប៉ុន្តែវាមិនខ្លាំងគ្រប់គ្រាន់នឹងនៅជាប់បានជារៀងរហូតនោះទេ។ អាណាចក្រនេះត្រូវបានដួលរលំនៅក្នុងឆ្នាំ៣៣១ មុនគ.ស.។

..................................................................................................................................................
.



សត្វខ្លារខិនដែលមានស្លាបបួន និងក្បាលបួន អាចធ្វើជាតំណាងបានសម្រាប់តែអាណាចក្ររបស់ស្តេចអាឡិកសែ◌៊ានដឺរ ដឺ ហ្គ្រេត តែប៉ុណ្ណោះ។ ទ័ពរបស់ទ្រង់ធ្វើសកម្មភាពលឿនខ្លាំងណាស់ ហើយវាយដណ្តើមបានតំបន់ត្រួតត្រារបស់ពួកពើស៊ី។ អាណាចក្ររបស់គាត់ធំជាងគេបំផុតនៅក្នុងពិភពលោកដែលគេធ្លាប់ដឹង។

តែលោកអាឡិកស៊ែនដឺរ មិនបានរស់នៅឲ្យជីវិតបានសប្បាយក្នុងនាមជាព្រះចៅអធិរាជនោះឡើយ។ ទ្រង់បានសុគតទាំងនៅក្មេងវ័យ ហើយអាណាចក្រដ៏ធំធេងរបស់ទ្រង់ត្រូវបានបែងចែកទៅជានគរ៤ដាច់ដោយឡែកពីគ្នា។ នគរនីមួយៗត្រូវបានគ្រប់គ្រងដោយមេទ័ពរបស់ស្តេចអាឡិកស៊ែនដឺរ។

..................................................................................................................................................



កាលដែលលោកដានីញ៉ែលបានសរសេរអំពីរឿងសុបិននិមិត្ត គាត់គិតមិនឃើញអំពីឈ្មោះសត្វកំណាចទី៤នោះឡើយ។ គឺវាមិនដូចសត្វកំណាចផ្សេងទៀត។ វាមិនដូចអ្វីដែលគាត់ធ្លាប់បានឃើញពីមុនមកនោះទេ។ គាត់ដឹងថា វាតំណាងឲ្យពិភពអាណាចក្រទី៤ គឺជាអាណាចក្រមួយដែលរឹងមាំជាងអាណាចក្រផ្សេងៗទៀត។ ប្រវត្តិសាស្ត្រប្រាប់យើងថា នេះគឺជាអាណាចក្ររ៉ូម។ ទ័ពរបស់វាមានអំណាចខ្លាំងក្លា ហើយគ្មានមេត្តាឡើយ។ វាគ្រប់គ្រងដោយដៃដែក។

..................................................................................................................................................
.



លោកដានីញ៉ែលជាពិសេស បានចាប់អារម្មណ៍ចំពោះស្នែង១០នៅលើក្បាលរបស់សត្វកំណាចទី៤នេះ។ ស្នែងទាំង១០ តំណាងឲ្យកុលសម្ព័ន្ធធំៗ នៅក្នុងតំបន់ត្រួតត្រារបស់អាណាចក្ររ៉ូម។ ប៉ុន្តែ វាមានទៀត។ សូមស្តាប់ ៖

“ខ្ញុំបានពិចារណាមើលស្នែងទាំងនោះក៏ឃើញមានស្នែង១ទៀត ជាស្នែងតូច ដុះឡើងនៅជាកណ្តាល...ស្នែង១នោះមានភ្នែក ដូចជាភ្នែកនៃមនុស្ស ក៏មានមាត់កំពុងតែពោលយ៉ាងធំ” (ដានីញ៉ែល ៧:៨)។

ទេវតាបានពន្យល់ “ស្តេចនោះនឹងពោលពាក្យទាស់នឹងព្រះដ៏ខ្ពស់បំផុត ហើយនឹងធ្វើទុក្ខបៀតបៀនដល់ពួកបរិសុទ្ធនៃព្រះដ៏ខ្ពស់បំផុតដែរ ព្រមទាំងគិតបំផ្លាស់ពេលកំណត់ និងច្បាប់ផង” (ដានីញ៉ែល ៧:២៥)។

តើអ្នកធ្លាប់ដឹង ឬឮ ដែរឬទេ? ប៉ុន្មានថ្ងៃមុន យើងបាននិយាយអំពីស្នែងចម្លែកនេះ។ ខ្ញុំបានប្រាប់អ្នកថា វាតំណាងឲ្យសាសនាក្លែងក្លាយ ពីព្រោះវានិយាយពាក្យទាស់នឹងព្រះដ៏ខ្ពស់បំផុត។ ការផ្លាស់ប្តូរពេលវេលា និងច្បាប់ សំដៅទៅលើច្បាប់របស់ព្រះអំពីពេលវេលា : បញ្ញត្តថ្ងៃបរិសុទ្ធ។

ដូច្នេះ មិត្តអើយ កូនស្នែងតូចនេះដែលបានរីកចម្រើនឡើងនៅក្នុងអាណាចក្ររ៉ូម គឺសាសនាដែលរីកចម្រើនកាន់តែខ្លាំង ដល់ថ្នាក់វាក្លាយទៅជាផ្នែកមួយនៃអាណាចក្រខ្លួនឯង។ មេដឹកនាំរបស់វា សង្ឃនាយករ៉ូម ដែលជាសម្តេចប៉ាប។ នៅទីបំផុត ពួកគេមានអំណាចលើស្តេចនានា និងព្រះចៅអធិរាជ។

ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា ស្នែងចម្លែកនៅក្នុងសុបិននិមិត្តរបស់លោកដានីញ៉ែល មិនមែនតំណាងឲ្យមនុស្សណាម្នាក់ ឬក្រុមមនុស្សណាឡើយ។ តែវាតំណាងឲ្យប្រព័ន្ធសាសនាក្លែងក្លាយ ដែលទុកចំណេះដឹង និងទំនៀមទម្លាប់ប្រពៃណីរបស់មនុស្សសំខាន់ជាងព្រះបន្ទូលរបស់ព្រះ។ ប្រព័ន្ធសាសនានេះ គឺជាព្រះវិហាររ៉ូម៉ាំង ដែលអះអាងថាមានអំណាចកែប្រែថ្ងៃបរិសុទ្ធរបស់ព្រះពីថ្ងៃសៅរ៍ទៅថ្ងៃអាទិត្យ។

ទេវតាបានប្រាប់លោកដានីញ៉ែលបន្ថែមទៀតអំពីស្នែងចម្លែកនោះ និងការធ្វើទុក្ខបុកម្នេញដែលវានឹងធ្វើទៅលើរាស្ត្ររបស់ព្រះ។ “ហើយគេនឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចនោះ នៅ១ខួប ២ខួប ហើយកន្លះខួប”។ នេះគឺជានិមិត្តសញ្ញាដែលមានន័យថា ១ឆ្នាំ បូក២ឆ្នាំ បូកកន្លះឆ្នាំ។ នោះស្មើរនឹង ៣ឆ្នាំកន្លះ។ នោះស្មើនឹង១២៦០ថ្ងៃនៅក្នុងទំនាយពេលវេលា និង១២៦០ឆ្នាំក្នុងពេលវេលាពិតប្រាកដ។ នៅក្នុងកំឡុងពេលនោះ ស្តេចប៉ាបនៃព្រះវិហាររ៉ូមុាំងកាតូលិកបានគ្រប់គ្រងពិភពរបស់គ្រីស្ទាន។

នៅក្នុងកំឡុងពេលនោះ នឹងមានសង្គ្រាមប្រយុទ្ធគ្នាដោយសារតែសាសនា។ កុលសម្ព័ន្ធទាំងអស់ដែលមិនបានទទួលយកការដឹកនាំរបស់ព្រះវិហាររ៉ូម៉ាំងត្រូវបានកំចាត់ចោល។ មានគ្រីស្ទានរាប់ពាន់នាក់ដែលមិនក្រាបបង្គំចំពោះអំណាចនៃស្តេចប៉ាប ត្រូវបានជាប់គុក ធ្វើទារុណកម្ម ឬក៏ត្រូវបានសំលាប់។ នៅទីបំផុត រយៈពេល១២៦០ឆ្នាំក៏ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ១៧៩៨ នៅពេលដែលស្តេចប៉ាបរូម៉ាំងត្រូវបានចាប់ខ្លួន ហើយនិរទេសចេញ។

.............................................................................................................................................
.



តែនោះ មិនមែនជាទីបញ្ចប់នៃរឿងឡើយ។ លោកដានីញ៉ែលបានឃើញហួសឆ្ងាយពីសត្វកំណាចទាំង៤នោះទៅទៀត។ គាត់បានឃើញព្រះអង្គឯង ជាព្រះនៃសម័យបុរាណ គង់នៅលើបល្ល័ង្កកាត់ក្តី។ ស្នែងចម្លែកដែលបាននិយាយពាក្យទាស់នឹងព្រះនោះ ត្រូវបានកាត់ទោស។ ទេវតាបានប្រាប់លោកដានីញ៉ែលថា៖

"គេនឹងដកអំណាចវាចេញ ឲ្យត្រូវបំផ្លាញ ហើយសាបសូន្យទៅដរាបដល់ចុងបំផុត" (ដានីញ៉ែល ៧:២៦)។

បន្ទាប់មក លោកដានីញ៉ែលបានឃើញផ្នែកសំខាន់បំផុតនៃសុបិននិមិត្តនោះ គឺមានរឿងល្អអស្ចារ្យកំពុងតែកើតមានឡើង។ សូមស្តាប់៖

"ខ្ញុំក៏ឃើញក្នុងការជាក់ស្តែងពេលយប់នោះ មាន១អង្គដូចជាមនុស្សជាតិ (កូនមនុស្ស) ទ្រង់យាងមកក្នុងពពកឰដ៏អាកាស!"

តើអ្នកណាទៅជាកូនមនុស្ស? គឺព្រះយេស៊ូ ពិតប្រាកដណាស់ "កូនមនុស្ស" គឺជាឈ្មោះដែលទ្រង់សព្វព្រះទ័យសម្រាប់ទ្រង់អង្គឯង។ លោកដានីញ៉ែលនិយាយថា៖

"ទ្រង់យាងមកឯព្រះដ៏មានព្រះជន្មពីបុរាណនោះ ហើយមានគេនាំចូលទៅចំពោះព្រះអង្គ។ នោះបានប្រទានឲ្យទ្រង់មានអំណាចគ្រប់គ្រង និងសិរីល្អ ព្រមទាំងឲ្យមានរាជ្យផង ដើម្បីឲ្យបណ្តាជនទាំងឡាយ សាសន៍ដទៃ និងមនុស្សគ្រប់ភាសា បានគោរពដល់ទ្រង់ ឯអំណាចគ្រប់គ្រងរបស់ទ្រង់ នោះក៏ស្ថិតស្ថេរនៅអស់កល្ប ឥតដែលកន្លងបាត់ឡើយ ហើយរាជ្យរបស់ទ្រង់នឹងបំផ្លាញមិនបានផង" (ដានីញ៉ែល ៧:១៣,១៤)។

មិត្តទាំងឡាយ នេះគឺជាចុងបញ្ចប់នៃសាច់រឿង។ ចុងបញ្ចប់រវាងការតស៊ូ ប្រយុទ្ធនៃសេចក្តីល្អ និងសេចក្តីអាក្រក់។

មែន ពិភពលោកនេះ គឺជាសមរភូមិប្រយុទ្ធ ដែលនគររបស់មនុស្សនៅតែបន្តប្រយុទ្ធប្រឆាំងគ្នាទៅវិញទៅមក។

មែន យើងនៅតែបន្តមើលលទ្ធផលនៃអំពើបាបនៅជុំវិញខ្លួនយើង: ជំងឺ ក្តីវេទនា ភាពក្រីក្រ ការស្អប់ខ្ពើម ការឈឺចាប់ និងសេចក្តីស្លាប់។

សាសនាក្លែងក្លាយបន្តដឹកនាំមនុស្សចេញឆ្ងាយពីព្រះ ហើយចេញឆ្ងាយពីសេចក្តីពិត។ តែព្រះជាម្ចាស់នឹងបញ្ចប់ហេតុការណ៍ទាំងអស់នេះ។

ព្រះយេស៊ូ ជាព្រះអង្គសង្គ្រោះ និងជាស្តេចរបស់យើងនឹងគ្រប់គ្រង។ អ្នកដើរតាមទ្រង់ អ្នកដែលស្រឡាញ់ទ្រង់មកពីគ្រប់ទាំងសាសន៍ និងភាសា នឹងត្រូវបានស្វាគមន៍ឲ្យចូលទៅក្នុងនគររបស់ទ្រង់។ មិនដូចអាណាចក្ររបស់មនុស្សឡើយ នគររបស់ទ្រង់នឹងមិនត្រូវបានបំផ្លាញទេ។

ព្រះយេស៊ូគង់នៅទីនោះ នៅក្នុងសាច់រឿងដើមដំបូង មុនការបង្កើតផែនដី។

ទ្រង់ក៏នៅទីនោះ នៅក្នុងពាក់កណ្តាលសាច់រឿង នៅពេលលដែលទ្រង់បានយាងមកកាន់ពិភពលោករបស់យើង ដើម្បីសុគតជួសបាបយើង។

ទ្រង់នឹងនៅទីនោះ ខណៈពេលដែលសង្គ្រាមរវាងសេចក្តីល្អ និងសេចក្តីអាក្រក់នឹងមកដល់ទីបញ្ចប់។

ហើយនោះគឺជាដំណើររឿងដំបូងនៃជីវិតថ្មី ដែលនឹងមិនដែលមានទីបញ្ចប់។ ខ្ញុំចង់ធ្វើជាចំណែកនៃរឿងនោះ ចុះអ្នកវិញ?

មិត្តអើយ ខ្ញុំចង់ឲ្យព្រះយេស៊ូស្ថិតនៅក្នុងរឿងនៃជីវិតរបស់ខ្ញុំនៅពេលឥឡូវនេះ។ ខ្ញុំចង់ឲ្យទ្រង់ធ្វើជាព្រះអង្គសង្គ្រោះ និងធ្វើជាស្តេចរបស់ខ្ញុំនៅថ្ងៃនេះ ដើម្បីឲ្យទ្រង់អាចជួយខ្ញុំរៀបចំត្រៀមសម្រាប់ជីវិតនៅក្នុងនគរដ៏អស់កល្បរបស់ទ្រង់។ ចុះអ្នកវិញ? តើអ្នកចង់ចូលរួមជាមួយនឹងខ្ញុំទេ? បើសិនជាចង់មែន សូមអញ្ជើញមកខាងមុខ ហើយឈរជាមួយនឹងខ្ញុំនៅទីនេះ ពេលដែលយើងអធិស្ឋាន។

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ ពួកទូលបង្គំកំពុងឈរជុំគ្នានៅទីនេះ ពីព្រោះពួកទូលបង្គំត្រូវការព្រះយេស៊ូគង់នៅក្នុងរឿងនៃជីវិតរបស់ពួកទូលបង្គំ។ ពួកទូលបង្គំត្រូវការទ្រង់ជាព្រះអង្គសង្គ្រោះរបស់ពួកទូលបង្គំ។ ពួកទូលបង្គំត្រូវការ ទ្រង់ធ្វើជាស្តេចនៃជីវិត របស់ពួកទូលបង្គំ។ ពួកទូលបង្គំត្រូវការទ្រង់នៅក្នុងជីវិតរបស់ ពួកទូលបង្គំនៅថ្ងៃនេះ ថ្ងៃស្អែក និងថ្ងៃខានស្អែកជាបន្តរហូតទៅ។ ហើយនៅពេលដែលសង្គ្រាមរវាងសេចក្តីល្អ និងសេចក្តីអាក្រក់ចប់ហើយ ពួកទូលបង្គំចង់រស់នៅជាមួយនឹងទ្រង់ជារៀងរហូត។ សូមជួយពួកទូលបង្គំទទួលយកទ្រង់មកគង់នៅក្នុងចិត្ត និងក្នុងជីវិតរបស់ពួកទូលបង្គំនៅថ្ងៃនេះ ដើម្បីឲ្យទ្រង់អាចទទួលយកពួកទូលបង្គំចូលទៅក្នុងនគរដ៏អស់កល្បរបស់ផងទ្រង់។ នេះគឺជាការអធិស្ឋានរបស់ពួកទូលបង្គំនៅក្នុង ព្រះនាមព្រះយេស៊ូ។ អាម៉ែន។

ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ

| | | |
|---|---|---|
| យេរេមា ៩:៧ | លូកា ២២:៤៨ | អេសេគាល ៩:៦ |
| វិវរណៈ ១៧:១៥ | ដានីញ៉ែល ៨:២២ | |

## លំនាំពិភាក្សា

**កិត្តិយស និងការគោរព (ជំងឺដែលឆ្លងតាមរយៈការរួមភេទ –STIs)**

១. ចូរពន្យល់អំពីរបៀបដែលបញ្ញត្ត១០ប្រការរបស់ព្រះអាចជួយការពារអ្នកពីជំងឺដែលឆ្លងតាមរយៈការរួមភេទដែលឆ្លងបាន។
២. តើរោគសញ្ញាខ្លះៗនៃជំងឺដែលឆ្លងតាមរយៈការរួមភេទមានអ្វីខ្លះ?
៣. តើគ្រោះថ្នាក់នៃជំងឺដែលឆ្លងតាមរយៈការរួមភេទដែលមិនបានទទួលការព្យាបាលនោះមានអ្វីខ្លះ?

**ដានីញ៉ែល ជំពូក៧**

១. តើសត្វកំណាចទាំង៤នៃគម្ពីរដានីញ៉ែលជំពូក៧នោះជាអ្វី? ហើយវាតំណាងឲ្យអ្វី?
   - ដានីញ៉ែល ៧:២-២៧

២. សត្វកំណាចទី៤ដែលមានស្នែង១០ បន្ទាប់មក ស្នែងដែលចេះនិយាយបានដុះលូតលាស់។ តើវាបានធ្វើអ្វី?

- ដានីញ៉ែល ៧:២៥

៣. អ្នកបរិសុទ្ធស្ថិតនៅក្រោមអំណាចរបស់ស្នែងដែលចេះនិយាយរយៈពេលយូរប៉ុណ្ណា?

- ដានីញ៉ែល ៧:២១,២៥

៤. តើមានហេតុការណ៍អ្វីកើតឡើងចំពោះអំណាចរបស់ស្នែងតូច?

- ដានីញ៉ែល ៧:២៦

៥. តើនគរណាមកជំនួសនគរទាំង៤ ហើយតើវានៅបានយូរប៉ុណ្ណា?

- ដានីញ៉ែល ៧:១៣,១៤,២៧

## មេរៀនសុខភាពទី១៨ - ជំងឺអេដស៍
## ជាជំងឺឆ្លងរាតត្បាតដែលអាចបង្ការមិនឲ្យកើតឡើងបាន




១. ប្រព័ន្ធការពាររបស់យើង គឺមានលក្ខណៈស្មុគស្មាញជាងមហិទ្ធិឫទ្ធិដ៏ខ្លាំងពូកែនៃអាវុធរបស់ទាហានទៅទៀត។ កោសិកាដែលប្រយុទ្ធប្រឆាំងនឹងមេរោគ ត្រូវបានបង្កើតឡើងនៅក្នុងឆ្អឹង ហើយបន្ទាប់មក ត្រូវបានបង្វឹកឲ្យកំចាត់មេរោគដូចជាពពួកបាក់តេរី និងវីរុសដែលចូលមកលុកលុយរាងកាយ។ នៅពេលដែលវាចូលលុកលុយ កោសិកាប្រព័ន្ធការពារក៏ចាប់ផ្តើមបង្កើតកូនចៅភ្លាម បង្កើតជាពលទ័ពកោសិកាសម្រាប់ប្រយុទ្ធ និងបំផ្លាញមេរោគដែលចំលងរោគ។ បើសិនជារាងកាយរបស់មនុស្សមានសុខភាពល្អ កោសិកាប្រព័ន្ធការពារឈ្នះមេរោគនោះ។

ថ្នាំវ៉ាក់សាំងការពារ ត្រូវបានបង្កើតឡើងដើម្បីជួយបង្វឹកដល់កោសិកាការពារឲ្យចងចាំ និងសំលាប់ជំងឺជាក់លាក់នានា ដូចជាជំងឺប៉ូលីយ៉ូ ជំងឺសាឡាទែន ឬក៏ជំងឺរលាកថ្លើម។

........................................................................................................................................................

២. ហ៊ីវ – **HIV** (វីរុសដែលធ្វើឲ្យប្រព័ន្ធរាងកាយរបស់មនុស្សចុះខ្សោយ **Human Immunodeficiency Virus**)
ភេរវករដែលជាវីរុសហ៊ីវ ចូលក្នុងរាងកាយបានតាមរយៈឈាម តាមរយៈការប្រើប្រាស់ម្ជុលចាក់ថ្នាំដែលប្រើរួចហើយ ឬក៏តាមទឹករំអិលពេលរួមភេទ។ ពួកវាបំបែកខ្លួនវាទៅជាកោសិកាថ្មីចំនួនរាប់លាន ដោយវាបំផ្លាញកោសិកា លីមហ្វូស៊ីត ស៊ីឌីបួន (CD4 lymphocyte cells)។ វាប្រើពេលដល់ទៅប្រាំមួយខែសម្រាប់ឲ្យអង់ទីករខាងប្រយុទ្ធនឹងវីរុសអេដស៍វិវត្តទៅជាទ័ពប្រយុទ្ធ។ រហូតដល់ពេលនោះ មិនធ្វើតេស្តឈាមឃើញមេរោគអេដស៍ឡើយ។

នៅក្នុងកំឡុងពេលនេះ អ្នកដែលទើបនឹងឆ្លងមេរោគនេះ អាចមានអាការៈដូចជាផ្តាសាយ និងគ្រុនក្តៅចំនួនពីមួយទៅពីរសប្តាហ៍។ កោសិកាការពារប្រមូលផ្តុំគ្នាប្រយុទ្ធ បណ្តាលឲ្យកូនកណ្តុរនៅក្រោមក្លៀក នៅសងខាងក និងក្រលៀនឡើងហើម ហើយឡើងរឹង និងឈឺ។ រោគសញ្ញាប្រភេទនេះងាយនឹងកើតដំបៅដែលបង្កដោយវីរុស ដូច្នេះ អ្នកដែលឆ្លងមេរោគនេះ មិនចាប់អារម្មណ៍ ឬសង្ស័យថាខ្លួនមានមេរោគហ៊ីវឡើយ។

........................................................................................................................................................

៣. ចំនួនពី១០-១៥ឆ្នាំ អាស្រ័យទៅលើសុខភាព និងរបៀបរស់នៅ អ្នកផ្ទុកមេរោគអាចមើលទៅមានសុខភាពល្អខណៈពេលដែលមេរោគអេដស៍កំពុងតែបំផ្លាញកោសិកាការពាររបស់គេ។ ប៉ុន្តែ ពួកគេកាន់តែចុះខ្សោយ ហើយឈឺ ងាយនឹងឆ្លងជំងឺផ្សេងៗ នៅពេលដែលកោសិកា លីមហ្វូស៊ីត ស៊ីឌីបួន របស់គេថយចំនួន។ គេនឹងស្រកទម្ងន់ បន្តិចម្តងៗ រាគរូសមិនឈប់ឈររយៈពេលជាងមួយខែ គ្រុនក្តៅ ក្អក មានស្នាមអុចខ្មៅចំលែក មានកន្ទួល

នៅលើស្បែក (ធ្វើឲ្យឈឺ) និងកើតមហារីកស្បែក។ ដោយសារប្រព័ន្ធរាងកាយចុះខ្សោយ ពួកគេងាយនឹងកើតដំបៅមាត់ និងមានជំងឺសួតធ្ងន់ធ្ងរដែលអាចបណ្តាលឲ្យស្លាប់បាន ដូចជាជំងឺហើមសួត ឬក៏ជំងឺរបេង។

នៅពេលណាដែលរាងកាយលែងអាចផលិតកោសិកា លីមហ្វូស៊ីត ស៊ីឌីបួនបានគ្រប់គ្រាន់ដើម្បីប្រយុទ្ធជាមួយនឹងមេរោគហ៊ីវហើយ នោះអ្នកដែលរងគ្រោះដោយសាររោគសញ្ញា និងជំងឺទាំងនេះ មេរោគហ៊ីវក៏ក្លាយទៅជាមេរោគអេដស៍(AIDs – Aquired Immune Deficiency Syndrome)។ ជំងឺអេដស៍ គឺជាជំងឺដែលធ្ងន់ធ្ងរ។

កាលណារាងកាយឆ្លងវីរុសហ៊ីវហើយ បើសិនជាឈាមមានមេរោគនេះត្រូវបានចែករំលែក ឬក៏អ្នកមានមេរោគនេះទៅរួមភេទជាមួយនឹងមនុស្សម្នាក់ទៀត មេរោគនេះនឹងឆ្លងទៅអ្នកនោះ។ សព្វថ្ងៃនេះ មានមនុស្សជាង៣៨លាននាក់នៅក្នុងពិភពលោកយើងនេះ មានមេរោគអេដស៍។ ៣៧លាននាក់ទៀតបានស្លាប់ដោយសារជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍។ លទ្ធផលចុងបញ្ចប់ គឺក្តីទុក្ខវេទនា ការឈឺចាប់ ភាពក្រីក្រ បែកបាក់គ្រួសារ និងមានមនុស្សឈឺរាប់លាននាក់ ក្មេងៗដែលមិនដឹងអីកំព្រាឪពុកម្តាយ។

ការស្លាប់ និងក្តីវេទនាទាំងអស់នេះ អាចបង្ការកុំឲ្យកើតមានឡើងបាន បើសិនជាគេយល់អំពីគម្រោងការរបស់ព្រះ ហើយគោរពប្រតិបត្តិតាម។

---

៤. ព្រះបានប្រទានគម្រោងការរបស់ទ្រង់ឲ្យ នៅពេលដែលទ្រង់បានបង្កើតបុរស និងស្ត្រីនៅក្នុងសួនអេដែន ៖ ប្តីមួយ និងប្រពន្ធមួយអស់មួយជីវិត។ បើសិនជាគ្រប់គ្នាដែលមានមេរោគអេដស៍មានទំនាក់ទំនងផ្លូវភេទជាមួយតែប្តីនិងប្រពន្ធរបស់ខ្លួន ហើយគ្មានអ្នកដទៃទៀតនៅក្រៅចំណងអាពាហ៍ពិពាហ៍របស់ខ្លួន ជំងឺដែលឆ្លងរាលដាលពាសពេញពិភពលោកនេះនឹងត្រូវបញ្ចប់។ អ្វីដែលពិភពលោកនេះត្រូវការ មិនមែនជាថ្នាំពេទ្យច្រើនជាងនេះទេ ទោះបីជាថ្នាំពេទ្យទាំងនោះសំខាន់សម្រាប់គ្រានេះក៏ដោយ។ អ្វីដែលពិភពលោកនេះត្រូវការ គឺត្រឡប់ទៅរកព្រះជាម្ចាស់ ហើយនិងស្តង់ដារសីលធម៌របស់ទ្រង់វិញ។

ចោទិយកថា ២៨:១៥,២២ គឺចំៗ ហើយច្បាស់លាស់ណាស់ ៖ "ប៉ុន្តែ បើឯងមិនព្រមស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃឯង ហើយមិនប្រយ័ត្ននឹងប្រព្រឹត្តតាមគ្រប់ទាំងសេចក្តីបញ្ញត្ត និងច្បាប់ទាំងប៉ុន្មានរបស់ទ្រង់ ដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះទេ នោះអស់ទាំងសេចក្តីបណ្តាសាទាំងនេះនឹងផ្សាយមកលើឯង ហើយរត់មករកឯងផង។ ព្រះយេហូវ៉ានឹងវាយឯងដោយជំងឺរីងរៃ និងគ្រុនរងារ ហើយដោយកើតហើមពិស និងក្តៅខ្លួនដូចភ្លើង ដោយដារ និងស្រូវស្កក ហើយក្រាជង សេចក្តីវេទនាទាំងនោះនឹងដេញតាមផង ទាល់តែវិនាសបាត់អស់រលីងទៅ។" តើរឿងនេះ អាចនិយាយអំពីជំងឺអេដស៍ដែរឬទេ?

**ការព្យាបាល**

មានថ្នាំព្យាបាលសម្រាប់ជំងឺអេដស៍/ហ៊ីវ។ ថ្នាំមិនបានបំផ្លាញមេរោគអេដស៍នោះទេ តែវាធ្វើឲ្យមេរោគនោះពិការ។ មេរោគ ឬវីរុសនោះស៊ាំ ហើយថយចំនួន ប៉ុន្តែ នៅតែបន្តកកើតកូនចៅ។

**ការការពារ**

១. ស្រោមអនាម័យ ប្រើតាមរបៀបត្រឹមត្រូវ ជួយកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ហើយនិងជំងឺផ្លូវភេទនានា។ បើសិនជាអ្នកដែលរៀបការហើយ សង្ស័យថាដៃគូរបស់ខ្លួនមិនស្មោះត្រង់ ពួកគេត្រូវទាមទារឲ្យប្រើស្រោមអនាម័យដើម្បីការពារកុំជំងឺឆ្លង។

២. ការកាត់ចុងស្បែកលិង្គរបស់បុរស ជួយកំចាត់កន្លែងដែលមេរោគលាក់ខ្លួនបាន។ ការកាត់ស្បែកនៅត្រង់ប្រដាប់ភេទរបស់ស្ត្រីមិនបានជួយផ្តល់ការការពារអ្វីឡើយ វាមានតែបំផ្លាញរាងកាយរបស់ស្ត្រី ហើយធ្វើឲ្យប្តី និងប្រពន្ធមិនមានក្តីសុខពេញលេញជាមួយគ្នានៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ពួកគេ។

៣. ស្ត្រីមានផ្ទៃពោះ ដែលផ្ទុកមេរោគអេដស៍ ត្រូវប្រើថ្នាំព្យាបាលដើម្បីជួយឲ្យមានសុខភាពល្អប្រសើរ ហើយនិងជួយការពារដល់កូនង៉ែត ដែលអាចឆ្លងមេរោគក្នុងកំឡុងពេលកើតបាន។

…………………………………………………………………………………………………………………………….......

.

៥. របៀបរស់នៅដែលស្អាត ជារឿងដែលសំខាន់នៅក្នុងការពន្យឺតនូវការលុកលុយរបស់មេរោគអេដស៍។

អាហាររុក្ខជាតិដែលមានផ្លែឈើ និងបន្លែ គ្រាប់ធញ្ញជាតិ គ្រាប់ពូជ និងសណ្តែក ផ្តល់វីតាមីន និងរ៉ែខនិជ ហើយនិងសារធាតុដែលជួយប្រយុទ្ធប្រឆាំងនឹងជំងឺ។ ផលិតផលកាហ្វេ តែ និងស្ករ គ្រាប់ធញ្ញជាតិ និងស្ករដែលចម្រាញ់ វាលួចជីវជាតិទាំងនេះពីរាងកាយ។ តែខ្មៅ កាហ្វេ ស្រា និងថ្នាំជក់ ធ្វើឲ្យកោសិកាខូច និងប្រព័ន្ធការពារចុះខ្សោយ។

ពន្លឺថ្ងៃ ខ្យល់បរិសុទ្ធ ហើយនិងការគេងបានពី៧-៨ម៉ោងជារៀងរាល់យប់ជួយស្តារថាមពល និងពង្រឹងប្រព័ន្ធការពារ។ ទឹកសុទ្ធជួយលាងសំអាតកាកសំណល់ចេញពីរាងកាយ ហើយនិងធ្វើឲ្យកោសិកាមានភាពស្រស់ស្រាយ។

…………………………………………………………………………………………………………………………….......

៦. កាលព្រះយេស៊ូគង់នៅលើផែនដីនេះ ទ្រង់បានចំណាយពេលព្យាបាលជំងឺរបស់មនុស្សច្រើនជាងអធិប្បាយ ឬបង្រៀន។ មានពេលមួយ ព្រះយេស៊ូបានព្យាបាលបុរសម្នាក់ដែលពិការដៃជើង ដោយសារតែអំពើបាបរបស់គាត់។ ព្រះគម្ពីរយ៉ូហាន ៥:១៤ ចែងថា ក្រោយនោះមក "ព្រះយេស៊ូឃើញគាត់នៅក្នុងព្រះវិហារ ក៏មានព្រះបន្ទូលទៅថា មើល ឥឡូវអ្នកបានជាហើយ កុំឲ្យធ្វើបាបទៀត ក្រែងអ្នកកើតមានសេចក្តីអាក្រក់ជាងនេះទៅទៀត"។

ការព្យាបាលផ្នែករាងកាយ និងខាងព្រលឹងវិញ្ញាណដើរទន្ទឹមគ្នា។ ព្រះជាម្ចាស់ព្យាបាលរាងកាយរបស់យើងពេលដែលយើងសហការជាមួយនឹងច្បាប់របស់ទ្រង់ ហើយការអភ័យទោសរបស់ទ្រង់នាំសេចក្តីសុខសាន្តហើយនិងដើរកាន់តែជិតជាមួយនឹងទ្រង់។ ពេលដែលព្រះយេស៊ូយាងមក ទ្រង់នឹងផ្តល់រាងកាយថ្មី និងសុខភាពល្អឥតខ្ចោះឲ្យដល់យើង។ តោះ រៀបចំត្រៀមខ្លួនឲ្យរួចរាល់ ដើម្បីជួបទ្រង់!

## សញ្ញាសំគាល់របស់សត្វសាហាវ



ខ្ញុំប្រាកដថា មានអ្នកខ្លះចងចាំរឿងស្តេចនេប៊ូក្នេសារ និងសុបិននិមិត្តរបស់ទ្រង់ អំពីរូបសំណាកដ៏ធំ។ ក្បាលរូបសំណាកធ្វើអំពីមាស ហើយវាជាសញ្ញាតំណាងឲ្យអាណាចក្ររបស់ស្តេចនេប៊ូក្នេសារ គឺក្រុងបាប៊ីឡូន។

ស្តេចមានព្រះទ័យរីករាយអំពីក្បាលធ្វើអំពីមាសនោះ រហូតទាល់តែទ្រង់បានជ្រាបថា អាណាចក្ររបស់ទ្រង់នឹងនៅមិនគង់វង្សរហូតទេ។ ដើមទ្រូង និងដៃរបស់រូបសំណាកនោះធ្វើអំពីប្រាក់ ហើយនោះមានន័យថា អាណាចក្រមួយទៀតនឹងដើរតាមទ្រង់។ ស្តេចចង់ជឿថា សុបិនរបស់ទ្រង់ខុស។ ទ្រង់ចង់បង្ហាញថា ទីក្រុងរបស់ទ្រង់នឹងមិនមានទីបញ្ចប់ឡើយ។

ដូច្នេះ ទ្រង់ក៏បានបញ្ជាឲ្យសិប្បករបស់ទ្រង់សាងរូបសំណាកដ៏ធំអំពីមាស។ ក្បាលធ្វើអំពីមាស ដៃក៏ធ្វើអំពីមាស។ គ្រប់ផ្នែកទាំងអស់នៃរូបនោះ ចាប់ពីក្បាលដល់ជើង គឺធ្វើអំពីមាស។ ទ្រង់បានបញ្ជាសិប្បកររបស់ទ្រង់ឲ្យដាក់រូបសំណាកនោះនៅខាងក្រៅទី

ក្រុង។ ស្តេចនេប៊ូក្នេសារបញ្ជាថា ឲ្យគ្រប់គ្នាមកមើលរូបសំណាកធ្វើអំពីមាសនេះ។ លោកដានីញ៉ែលដែលជាហោរា បានសរសេររឿងសម្រាប់ឲ្យយើងអាន។ សូមស្តាប់ ៖

“រួចមានអ្នក១ស្រែកប៉ាវប្រកាស ជាសំលេងយ៉ាងខ្លាំងថា ម្នាលជនទាំងឡាយព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសាអើយ មានសេចក្ដីបង្គាប់ដល់អ្នករាល់គ្នាដូច្នេះថា វេលាណាដែលអ្នករាល់គ្នាឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងប៉ី ហើយតន្ត្រីគ្រប់យ៉ាងនោះត្រូវក្រាបថ្វាយបង្គំដល់រូបមាស ដែលព្រះករុណាទ្រង់បានតាំងឡើងទៅ។ បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះនឹងត្រូវបោះទៅកណ្ដាលគុកភ្លើង ដែលកំពុងឆេះយ៉ាងសន្ធៅនៅវេលានោះឯង” (ដានីញ៉ែល ៣:៤-៦)។

នៅក្នុងហ្វូងមនុស្សដ៏ធំ ដែលគេបានប្រមូលផ្ដុំ មានបុរសវ័យក្មេង៣ នាក់ឈ្មោះ សាដ្រាក់ មែសាក់ និងអ័បេឌនេកោ។ ពួកគាត់បានថ្វាយបង្គំ ព្រះពិត។ ពួកគាត់បានចងចាំនូវបញ្ញត្តរបស់ទ្រង់អំពីរូបសំណាក ៖

“កុំឲ្យឆ្លាក់ធ្វើរូបណាសម្រាប់ឯងឲ្យសោះ ក៏កុំឲ្យធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង។ ក៏កុំឲ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាមនោះឡើយ។ ដ្បិតអញដែលជាយេហូវ៉ាជាព្រះនៃឯង អញមានសេចក្ដីប្រចណ្ឌ ក៏ទំលាក់ការទុច្ចរិតរបស់ឪពុកទៅលើកូនចៅរហូតដល់៣ហើយ៤តំណផង ចំពោះអស់អ្នកណាដែលស្អប់អញ” (និក្ខមនំ ២០:៤,៥)។

ពួកគេមិនព្រមក្រាបថ្វាយបង្គំរូបសំណាកធ្វើអំពីមាសរបស់ស្តេចនេប៊ូក្នេសារឡើយ។ ស្តេចក្រោធជាខ្លាំង។ ទ្រង់បានប្រាប់ពួកគេថា ៖

“តែបើមិនថ្វាយបង្គំទេ នោះនឹងត្រូវបោះឯងទៅក្នុងគុកភ្លើង ដែលឆេះយ៉ាងសន្ធៅនៅវេលានោះឯង តើមានព្រះឯណាដែលអាចនឹងដោះឯងរាល់គ្នា ឲ្យរួចពីកណ្ដាប់ដៃយើងបាន?” (ដានីញ៉ែល ៣:១៥)។

បុរសទាំង៣នាក់មិនស្ទាក់ស្ទើរចិត្តឡើយ។ សូមស្តាប់នូវអ្វីដែលពួកគាត់បាននិយាយ ៖

“បើជាយ៉ាងនោះមែន នោះព្រះនៃយើងខ្ញុំ ដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយឲ្យខ្ញុំរួចពីគុកភ្លើង ដែលឆេះយ៉ាងសន្ធៅបានហើយ បរពិត្រព្រះករុណា ព្រះអង្គនោះក៏នឹងជួយឲ្យយើងរួចពីព្រះហស្តទ្រង់ដែរ” (ដានីញ៉ែល ៣:១៧)។

.........................................................................................................................



ស្តេចនេប៊ូក្នេសារបានចេញបញ្ជាឲ្យទាហានដែលមាំមួនមួយចំនួន ចាប់ពួកគាត់ចងហើយបោះពួកគាត់ចូលទៅក្នុងគុកភ្លើង។ ភ្លើងនោះក្ដៅខ្លាំងណាស់ដល់ថ្នាក់ធ្វើឲ្យពួកទាហានទាំងនោះស្លាប់ តែសាដ្រាក់ មែសាក់ និងអ័បេឌនេកោ មិនបានរងផលប៉ះពាល់អ្វីឡើយ។ ស្តេចនោះ ភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលបានឃើញពួកគាត់ដើរចុះឡើងនៅក្នុងភ្លើង។ ហើយក៏បានឃើញមានម្នាក់ទៀតនៅជាមួយនឹងពួកគាត់ដែរ។

“ហើយក៏ក្រោកឡើងជាប្រញាប់ មានព្រះបន្ទូលនឹងពួកជំនិតរបស់ទ្រង់ថា តើមិនមែន៣នាក់ ដែលយើងបោះទៅក្នុងភ្លើងទាំងជាប់ចំណងផងទេឬអី?

គេក៏ទូលតបថា បរពិត្រព្រះកុរណាអើយ ពិតហើយដូច្នោះ។

រួចទ្រង់មានព្រះបន្ទូលថា មើល យើងឃើញ៤នាក់ ឥតជាប់ចំណងសោះ កំពុងដើរនៅកណ្តាលភ្លើង ឥតមានអ្វីសោះ ឯអ្នកទី៤ក៏មានភាពដូចជាកូនព្រះ”
(ដានីញ៉ែល ៣:២៤,២៥)។

អ្នកឃើញទេ ព្រះជាម្ចាស់មិនបានបោះបង់អ្នកដើរតាមទ្រង់ដែលស្មោះត្រង់នោះទេ ពេលដែលពួកគេក្រោកឈរប្រឆាំងនឹងសាសនាក្លែងក្លាយ។ ទ្រង់គង់នៅទីនោះជាមួយនឹងពួកគេ នៅក្នុងពេលដែលពួកគេត្រូវការទ្រង់។ ទ្រង់តែងតែគង់នៅជាមួយនឹងអស់អ្នកដែលស្មោះត្រង់ចំពោះទ្រង់ក្នុងពេលដែលជួប ឬប្រឈមនឹងគ្រោះថ្នាក់ និងសេចក្តីស្លាប់ផង។ ដូចដែលយើងនឹងឃើញនៅថ្ងៃនេះ សាតាំងបានព្យាយាមបំផ្លាញរាស្ត្ររបស់ព្រះ ប៉ុន្តែព្រះនៅតែគ្រប់គ្រងបាន។

---



នៅក្នុងមេរៀនមុន យើងបាននិយាយអំពីសុបិននិមិត្តរបស់លោកដានីញ៉ែល អំពីសត្វសាហាវដ៏ធំទាំង៤ ហើយស្នែងចម្លែកដែលមានភ្នែកដូចជាបុរស ហើយមាត់និយាយពាក្យទាស់នឹងព្រះដ៏ខ្ពស់បំផុត។ យើងបានដឹងថា សត្វសាហាវតំណាងឲ្យពិភពអាណាចក្រធំទាំង៤ ៖ ទីក្រុង បាប៊ីឡូន ពើស៊ី ក្រិក និងរ៉ូម។ ហើយស្នែង គឺជាសញ្ញានៃប្រព័ន្ធសាសនាដែលលើកតម្កើងទំនៀមទំលាប់ប្រពៃណី ខ្ពស់ជាងព្រះបន្ទូលរបស់ព្រះ គឺព្រះគម្ពីរ។ ទេវតាបានប្រាប់ដានីញ៉ែលថា ស្នែងនោះនឹងគៀបសង្កត់រាស្ត្ររបស់ព្រះរយៈពេល១២៦០ឆ្នាំ។

---



ហោរាយ៉ូហានក៏បានសុបិននិមិត្តឃើញសត្វសាហាវ ឬសត្វកំណាចដែរ។ គាត់និយាយអំពីសត្វទាំងនោះនៅក្នុងព្រះគម្ពីរវិវរណៈ ជាសៀវភៅចុងក្រោយនៅក្នុងព្រះគម្ពីរ។ នៅក្នុងសុបិននិមិត្តរបស់គាត់ សាតាំងបានបង្ហាញខ្លួនជាសត្វនាគដ៏ធំ ដែលផ្តល់អំណាច និងសិទ្ធិទៅឲ្យសត្វសាហាវដែលចេញពីសមុទ្រ។ សត្វសាហាវនេះ មានក្បាល៧ និងស្នែង១០។ លោកយ៉ូហាន បានសរសេរថា ៖

“ក៏មានអំណាចបានប្រគល់ដល់វាឲ្យច្បាំងឈ្នះពួកបរិសុទ្ធបាន”(វិវរណៈ ១៣:៧)។

សត្វសាហាវនេះមានមាត់ចេះនិយាយជាពាក្យសម្តីធំ និងពាក្យប្រមាថ ក៏ឲ្យមានអំណាចនឹងធ្វើការវាក្នុងរវាង៤២ខែ” (វិវរណៈ ១៣:៥)។

តោះ សូមគិតអំពីពេលវេលានោះបន្តិច។ សែសិបពីរខែ គឺស្មើនឹង ៣ឆ្នាំកន្លះ។ សែសិបពីរខែ ឬបីឆ្នាំកន្លះ ស្មើនឹងចំនួនថ្ងៃដែលបានទាយទុកមុន គឺ១២៦០ថ្ងៃ។ ហើយនោះ ១២៦០ឆ្នាំ ក្នុងពេលវេលាពិត ប្រាកដ។ ដូច្នេះ ទាំងលោកដានីញ៉ែល និងលោកយ៉ូហាន បានយល់ឃើញដែរថា រាស្ត្ររបស់ព្រះនឹងត្រូវទទួលរងនូវការសង្កត់សង្កិន ចំនួន ១២៦០ឆ្នាំ។ នោះគឺជាពេលវេលា ដែលព្រះវិហាររ៉ូម និងស្តេចប៉ាប គ្របដណ្តប់ពិភពរបស់គ្រីស្ទាន។ ១២៦០ឆ្នាំបានបញ្ចប់ នៅក្នុងឆ្នាំ១៧៩៨ គឺកាលពីជាង២០០ឆ្នាំកន្លងទៅ។

វាជាការចាំបាច់សម្រាប់ឲ្យយើងឃើញថា មានពេលវេលាកំណត់ទៅលើប្រព័ន្ធសាសនាក្លែងក្លាយនេះ។ ប៉ុន្តែ វាមិនរលត់ ឬក៏បាត់រូបរាងឡើយ។ សូមស្តាប់នូវអ្វីដែលបានកើតឡើងនៅក្នុងសុបិននិមិត្តរបស់លោកយ៉ូហាន ៖

…………………………………………………………………………………………………………………........

.



“ខ្ញុំក៏ឃើញសត្វសាហាវ១ទៀត ឡើងចេញពីដីមក វាមានស្នែង២ ដូចជាកូនចៀម តែពោលពាក្យដូចជានាគវិញ។ ក៏ប្រព្រឹត្តដោយនូវគ្រប់ទាំងអំណាចរបស់សត្វទី១ នៅមុខនាគនោះ ទាំងបណ្តាលឲ្យផែនដី និងអស់អ្នកដែលនៅផែនដីបានក្រាបថ្វាយបង្គំដល់សត្វទី១....” (វិវរណៈ ១៣:១១, ១២)។

សត្វសាហាវថ្មីនេះចង់ស្តារសាសនារបស់សត្វសាហាវដែលមានក្បាល៧។ ជាមួយនឹងសំលេងដូចសត្វនាគរបស់វា វាប្រាប់គ្រប់គ្នាឲ្យធ្វើរូបសំណាក ឲ្យដូចសត្វសាហាវដែលមានក្បាល៧។ តាមរយៈហោរា យ៉ូហាន ៖

“ក៏មានអំណាចបានប្រគល់ឲ្យវា និងធ្វើឲ្យរូបសត្វនោះមានខ្យល់ដង្ហើម ដើម្បីឲ្យបានចេះនិយាយ ហើយអំណាចនឹងធ្វើឲ្យពួកអ្នកដែលមិនព្រមក្រាបថ្វាយបង្គំរូបសត្វនោះត្រូវស្លាប់ផង” (វិវរណៈ ១៣:១៥)។

តើនេះមានន័យដូចម្តេច? នេះប្រាប់យើងយ៉ាងច្បាស់ថា អំណាចពិភពលោកថ្មីនឹងមានសិទ្ធិបង្ខំមនុស្សឲ្យចូលជឿសាសនាក្លែងក្លាយ។

សាច់រឿងអំពីសុបិននិមិត្តរបស់លោកយ៉ូហានបន្តទៅទៀត គាត់បានឃើញសត្វសាហាវនេះ បង្ខំគ្រប់គ្នាឲ្យដាក់សញ្ញាសំគាល់នៅលើដៃ ខាងស្តាំ ឬក៏នៅលើថ្ងាស ដើម្បីបញ្ជាក់ថាពួកគេបានទទួលយកសាសនារបស់សត្វកំណាច និងរូបសំណាករបស់វា។ អ្នកណាដែរមិនបានទទួលយកសញ្ញាសំគាល់ នឹងមិនត្រូវបានអនុញ្ញាតឲ្យទិញ ឬលក់ឡើយ។ បែបនោះ ពួកគេនឹងត្រូវដាក់ឲ្យនៅដាច់ពីគេ ឬកាត់ផ្តាច់ចេញពីមនុស្សម្នា ទាំងអស់។

តើសញ្ញាសំគាល់នៃសត្វសាហាវនេះអាចជាអ្វីទៅ?

មុននឹងខ្ញុំឆ្លើយសំណួរនោះ ខ្ញុំសុំសួរអ្នកពីរឿងផ្សេងទៀត ៖ តើអ្នកដឹងទេថា ព្រះជាម្ចាស់នៃនគរឋានសួគ៌មានសញ្ញាសំគាល់? សូមស្តាប់ព្រះបន្ទូលរបស់ព្រះ ៖

“អញក៏តាំងថ្ងៃឈប់សម្រាករបស់អញឲ្យគេដែរ ទុកសម្រាប់ជាទីសំគាល់ដល់អញហើយនិងគេ...” (អេសេគាល ២០:១២)។

នៅមានតទៅទៀត ៖

“ត្រូវឲ្យឯងរាល់គ្នាកាន់អស់ទាំងថ្ងៃឈប់សម្រាករបស់អញជាកុំខាន ដ្បិតនោះជាទីសំគាល់ដល់អញ...” (និក្ខមនំ ៣១:១៣)។

អ្នកឃើញទេ ថ្ងៃសម្រាកពិត គឺជាសញ្ញាសំគាល់ដែលបង្ហាញពីភាពស្មោះត្រង់របស់យើងចំពោះព្រះវរបិតានៅឯនគរឋានសួគ៌របស់យើង។ វាគូសសំគាល់យើងថា ជាអ្នកដើរតាមទ្រង់។

ឥឡូវ ខ្ញុំនឹងសួរម្តងទៀត តើអ្វីទៅជាសញ្ញាសំគាល់របស់សត្វសាហាវ?

យើងបានដឹងហើយថា សត្វសាហាវដែលមានក្បាល៧ ហើយនិងរូបរបស់វាតំណាងឲ្យសាសនាក្លែងក្លាយ ដឹកនាំដោយសម្តេចប៉ាបនៃទីក្រុងរ៉ូម។ នេះគឺជាប្រព័ន្ធសាសនាដែលគ្របដណ្តប់ទៅលើពិភពរបស់គ្រីស្ទានចំនួន១២៦០ឆ្នាំ។ តើសញ្ញា ឬទីសំគាល់អ្វីដែលបង្ហាញពីភាពស្មោះត្រង់ចំពោះសាសនាក្លែងក្លាយនេះ?

បើថ្ងៃបរិសុទ្ធជាសញ្ញា ឬទីសំគាល់របស់ព្រះ តើវាអាចទេដែលថ្ងៃ អាទិត្យ ជាថ្ងៃប្រកួតប្រជែងថ្វាយបង្គំ គឺជាទីសំគាល់ ឬជាសញ្ញានៃសាសនារបស់សត្វសាហាវនោះ?

ព្រះវិហាររ៉ូម ក៏មានឈ្មោះថា ព្រះវិហាររ៉ូមុាំង កាតូលិកដែរ។ វាអះអាងថា មានសិទ្ធិអំណាចផ្លាស់ប្តូរថ្ងៃបរិសុទ្ធពីថ្ងៃមួយទៅថ្ងៃមួយទៀតបាន។ ពីថ្ងៃសៅរ៍ទៅថ្ងៃអាទិត្យ។ មេដឹកនាំព្រះវិហាររ៉ូម៉ាំងកាតូលិកអួតថា ការផ្លាស់ប្តូរនេះ គឺជាសញ្ញាសំគាល់នៃអំណាច និងសិទ្ធិនៃព្រះវិហារ របស់ពួកគេ។

ដូច្នេះ មិត្តអើយ យើងមានសញ្ញា និងទីសំគាល់ពីរខុសគ្នា។ មួយ គឺថ្ងៃបរិសុទ្ធរបស់ព្រះ ហើយមួយទៀត គឺថ្ងៃអាទិត្យ ជាថ្ងៃថ្វាយបង្គំក្លែងក្លាយ។

……………………………………………………………………………………………………........

.



សុបិននិមិត្តរបស់លោកយ៉ូហានអំពីសត្វសាហាវ និងរូបសំណាក ហើយនិងទីសំគាល់របស់សត្វសាហាវទាយថា ថ្ងៃណាមួយ គ្រប់គ្នានឹងត្រូវបានបង្ខំឲ្យទទួលយកសាសនាក្លែងក្លាយ ដែលតម្រូវឲ្យពួកគេថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យជំនួសឲ្យថ្ងៃបរិសុទ្ធពិត ដែលជាថ្ងៃសៅរ៍។

ប៉ុន្តែ ដូចបុរសវ័យក្មេងទាំង៣នាក់នៅក្នុងរឿងរូបសំណាករបស់ស្តេចនេប៊ូក្នេសារ នឹងមានមនុស្សដែលសម្រេចចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់នៃនគរឋានសួគ៌។ ពួកគេនឹងមិនក្រាបថ្វាយបង្គំចំពោះសាសនាក្លែងក្លាយឡើយ។ ពួកគេនឹងបន្តរក្សាថ្ងៃបរិសុទ្ធពិតឲ្យបរិសុទ្ធ។ ពួកគេនឹងជឿទុកចិត្តលើព្រះឲ្យថែរក្សពួកគេ។ ពួកគេនឹងមិនព្រមទទួលយកទីសំគាល់របស់សត្វសាហាវឡើយ។

តើមានអ្នកណាមានទីសំគាល់របស់សត្វសាហាវដែរឬទេ សព្វថ្ងៃនេះ?

អត់ទេ ការនោះនឹងមិនទាន់កើតឡើង រហូតទាល់តែរដ្ឋាភិបាលនៃពិភពលោកនេះ ចេញច្បាប់ តម្រូវឲ្យយើងគោរពប្រតិបត្តិថ្ងៃអាទិត្យជំនួសថ្ងៃបរិសុទ្ធ។ ការនោះមិនទាន់កើតឡើងនៅឡើយទេ វៀរលែងតែមានករណីលើកលែងមួយចំនួន។ តែមេដឹកនាំព្រះវិហាររ៉ូម៉ាំង កាតូលិក មិនខ្មាស់អៀនក្នុងការស្នើរសុំឲ្យអនុវត្តច្បាប់នោះឡើយ។

មិត្តអើយ អ្វីដែលសំខាន់បំផុតសម្រាប់យើងគឺថា យើងធ្វើការសម្រេចចិត្តរបស់យើងគោរពតាមព្រះបន្ទូលរបស់ព្រះ ជាជាងគោរពតាមច្បាប់របស់មនុស្ស។ យើងត្រូវធ្វើការសម្រេចចិត្តពេលឥឡូវនេះ ដូចសាដ្រាក់ មែសាក់ និងអ័បេឌនេកោ ហើយបដិសេធមិនក្រាបថ្វាយបង្គំចំពោះប្រព័ន្ធសាសនាក្លែងក្លាយ។

……………………………………………………………………………………………………........

.



នៅក្នុងសុបិននិមិត្តមួយផ្សេងទៀត ហោរាយ៉ូហានបានឃើញនគរឋានសួគ៌។ នៅទីនោះ គាត់បានឃើញអស់អ្នកដែលទទួលបានជ័យជំនះលើសត្វសាហាវ និងរូបសំណាក ហើយនិងទីសំគាល់របស់វា។ គាត់បានឮពួកគេច្រៀងចម្រៀង។ សូមស្តាប់ពាក្យក្នុងចម្រៀងរបស់ពួកគេ៖

“ឱព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ ការទ្រង់សុទ្ធតែធំ ហើយអស្ចារ្យ ឱស្តេចនៃសាសន៍អើយ ផ្លូវទ្រង់សុទ្ធតែសុចរិត ហើយពិតត្រង់” (វិវរណៈ ១៥:៣)។

ខ្ញុំចង់នៅទីនោះច្រៀងចម្រៀងជាមួយនឹងពួកគេ។ ចុះអ្នកវិញចង់ដែរឬទេ? ខ្ញុំចង់ឈរនៅជាមួយអស់អ្នកដែលបានទទួលជោគជ័យលើសត្វសាហាវ លើរូបសំណាករបស់វា ហើយនិងលើទីសំគាល់របស់វា។ ខ្ញុំចង់មានភាពស្មោះត្រង់ជាមួយនឹងព្រះ។ ខ្ញុំចង់បង្ហាញក្តីស្រឡាញ់របស់ខ្ញុំចំពោះទ្រង់ដោយការគោរពថ្ងៃបរិសុទ្ធរបស់ទ្រង់។

ខ្ញុំនឹងលុតជង្គង់នៅត្រង់នេះ នៅពេលឥឡូវនេះ ហើយសុំជំនួយពីទ្រង់ ដើម្បីឲ្យខ្ញុំអាចឈរបាន នៅពេលដែលមនុស្សដទៃទៀតគោរពតាមទំនៀមទម្លាប់និងប្រពៃណីរបស់មនុស្ស។ ចុះអ្នកវិញ? បើសិនជាអ្នកចង់ចូលរួមជាមួយនឹងខ្ញុំ សូមលុតជង្គង់នៅនឹងកន្លែងរបស់អ្នក ពេលដែលយើងអធិស្ឋានជាមួយគ្នា។

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ ថ្ងៃនេះពួកទូលបង្គំបាននិយាយអំពីសត្វសាហាវ រូបសំណាក និងទីសំគាល់របស់វា ប៉ុន្តែឥឡូវនេះ ពួកទូលបង្គំត្រូវនិយាយជាមួយនឹងទ្រង់អំពីពួកទូលបង្គំ។ ពួកទូលបង្គំត្រូវការអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីជួយពួកទូលបង្គំឲ្យធ្វើការសម្រេចចិត្តឲ្យបានម៉ឺងម៉ាត់អំពីការបម្រើទ្រង់។ ពួកទូលបង្គំត្រូវការអំណាចរបស់ព្រះ ដើម្បីជួយពួកទូលបង្គំឲ្យធ្វើតាមព្រះបន្ទូលរបស់ទ្រង់ ហើយនិងរក្សាថ្ងៃបរិសុទ្ធរបស់ទ្រង់។ ពួកទូលបង្គំ ចង់បានទីសំគាល់សញ្ញា ហើយនិងត្រារបស់ទ្រង់នៅលើចិត្តពួកទូលបង្គំ។ ពួកទូលបង្គំចង់ធ្វើជារបស់ផងទ្រង់ទាំងស្រុង។ សូមរៀបចំពួកទូលបង្គំសម្រាប់ការជំនុំជំរះនាពេលខាងមុខ ហើយសូមថែរក្សាពួកទូលបង្គំ ដូចដែលទ្រង់បានធ្វើសម្រាប់សាដ្រាក់ មែសាក់ និងអ័បេឌនេកោ នៅទីក្រុងបាប៊ីឡូនកាលពីសម័យយូរលង់ណាស់មកហើយដែរ។ សូមធ្វើឲ្យពួកទូលបង្គំធ្វើជាអ្នកមានជ័យជំនះលើសត្វសាហាវ ហើយរូបសំណាក និងទីសំគាល់របស់វា។ ពួកទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ ៖</u>

| | | |
|---|---|---|
| ទំនុកតម្កើង ៩១:៥-៨,៩-១១ | ដានីញ៉ែល ៧:២៥ | រ៉ូម ៦:១៦ |
| វិវរណៈ ១៤:៩,១០,១២ | អេសាយ ៣៣:១៦ | ដានីញ៉ែល ៨:១២ |
| វិវរណៈ ៧:២,៣ | អេសេគាល ២០:១២ | ដានីញ៉ែល ១២:១ |
| វិវរណៈ ១៨:៤ | | |

# លំនាំពិភាក្សា

**ជំងឺអេដស៍ ជាជំងឺឆ្លងរាតត្បាតដែលអាចបង្ការមិនឲ្យកើតឡើងបាន**

១. តើរោគសញ្ញាខ្លះៗនៃមេរោគហ្ីវ/អេដស៍នោះគឺមានអ្វីខ្លះ?
២. តើជំងឺអេដស៍ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរបៀបណា?
៣. តើអ្វីទៅជាផែនការដែលល្អបំផុតដើម្បីការពារកុំឲ្យឆ្លងជំងឺអេដស៍? តើវិធីផ្សេងៗទៀតដើម្បីបង្ការជំងឺនេះគឺមានអ្វីខ្លះ?

**សញ្ញាសំគាល់របស់សត្វសាហាវ**

១. តើស្តេចនេប៊ូក្នេសារកសាងអ្វី ហើយតើទ្រង់បានធ្វើអ្វីជាមួយនឹងវត្ថុនោះ?
- ដានីញ៉ែល ៣:១-៦
២. តើមានទារុណកម្មអ្វីខ្លះសម្រាប់អស់អ្នកដែលបដិសេធមិនព្រមក្រាបថ្វាយបង្គំរូបសំណាក?
- ដានីញ៉ែល ៣:១៥
៣. នៅពេលដែលស្តេចទតមើលទៅក្នុងភ្លើង ទ្រង់បានទតឃើញរូបភាពគួរឲ្យភ្ញាក់ផ្អើល? តើស្តេចបានទតឃើញអ្វី?
- ដានីញ៉ែល ៣:២៤,២៥
៤. ហោរាយ៉ូហាន ជាច្រើនឆ្នាំក្រោយមក ក៏មានសុបិននិមិត្តអំពីសត្វសាហាវដែលមានស្នែង១០។ តើសត្វសាហាវនេះធ្វើអ្វីប្រឆាំងជំទាស់នឹងរាស្ត្ររបស់ព្រះ ហើយរយៈយូរប៉ុណ្ណា?
-វិវរណៈ ១៣:៥-៧
៥. តើអ្វីនឹងជាសញ្ញា ឬក៏ទីសំគាល់នៃសិទ្ធិអំណាចរបស់សត្វសាហាវនេះ? តើអ្វីដែលនឹងជាសញ្ញា ឬក៏ជាទីសំគាល់នៃព្រះវិហារពិត?
- ដានីញ៉ែល ៧:២៥ -វិវរណៈ ១២:១៧

# មេរៀនសុខភាពទី១៩ - ជីវិត គឺរស់នៅក្នុងឈាម



១. មនុស្សអាចជួបគ្រោះថ្នាក់ធ្ងន់ធ្ងរ បាក់ដៃ ឬប៉ះទង្គិចក្បាល អាចបាក់ធ្មេញ ឈឺចាប់ ហើយនៅតែមានជីវិតរស់នៅ។ យ៉ាងណាមិញ របួសដែលអាចបណ្តាលឲ្យហូរឈាមដែលមិនអាចទប់ស្កាត់បាន នឹងនាំឲ្យស្លាប់។ ជីវិត គឺមាននៅក្នុងឈាម។

…………………………………………………………………………………………………………………........
.

២. ឈាមមួយដំណក់មើលឃើញនៅក្រោមមីក្រូទស្សន៍ គឺមានជីវិតជាមួយនឹងកោសិការាងកាយ ដែលមានរូបរាង និងទំហំខុសគ្នា ហើយកោសិកានីមួយៗមានការងារធ្វើ។

តើកោសិកាទាំងនេះជាអ្វី ហើយតើវាមានមុខងារធ្វើអ្វីខ្លះ?

កោសិកាឈាមស បំផ្លាញមេរោគ ឬមីក្រុបដែលបង្កគ្រោះថ្នាក់ និងវាយកំចាត់ជំងឺ។

កោសិកាឈាមក្រហម មានផ្ទុកអេម៉ូក្លូប៊ីន ដែលប្រើជាតិដែកដើម្បីនាំអុកស៊ីហ្សែនពីសួតទៅកោសិការាងកាយ ហើយយកខ្យល់ដែលប្រើប្រាស់ហើយត្រឡប់ទៅសួតវិញ។

ផ្លាស្មានាំអាហារដែលមានជីវជាតិ ដូចជាជាតិម្សៅ គ្លុយកូសដែលមានថាមពលខ្ពស់ ប្រូតេអ៊ីនសម្រាប់ជួសជុល និងការលូតលាស់វីតាមីនជំនួយ សារធាតុរ៉ែខនិជ សារធាតុគីមីនៅក្នុងរុក្ខជាតិ ហើយនិងការដុតរំលាយខ្លាញ់យឺតៗទៅកោសិកា។ វាក៏នាំយកកាកសំណល់របស់កោសិកាទៅតម្រងនោម និងថ្លើមបញ្ចេញចោលទៅតាមទឹកនោម និងលាមក។

អ្វីដែលរំខានដល់ការងាររបស់កោសិកាទាំងនេះ បណ្តាលឲ្យកើតជំងឺ ហើយក៏អាចស្លាប់បានដែរ។

…………………………………………………………………………………………………………………........
.

៣. នៅពេលដែលបរាសិត ឬមេរោគនៃជំងឺគ្រុនចាញ់ ត្រូវបានសត្វមូសចាក់បញ្ចូលទៅក្នុងខ្លួនមនុស្ស ពួកគេបំបែកខ្លួនទៅជាមេរោគរាប់លាន ដែលបំផ្លាញកោសិកាឈាមក្រហមដែលដឹកនាំអុកស៊ីហ្សែន។ បើគ្មានអុកស៊ីហ្សែនទេ កោសិកា គឺប្រៀបដូចជាទៀនកំពុងតែឆេះ ដែលមានកែវគ្របពីលើវាដូច្នោះឯង គឺភ្លើងចាប់ផ្តើមរលត់ទៅដោយយឺតៗ។ កោសិការាងកាយ ក៏ស្លាប់ បើគ្មានកោសិកាឈាមក្រហមផ្តល់អុកស៊ីហ្សែនទៅឲ្យវា។

ការខ្វះកោសិកាឈាមក្រហមដែលមានសុខភាពល្អ ហៅថាជំងឺខ្វះឈាមក្រហម។

ជំងឺខ្វះឈាមក្រហម បណ្តាលឲ្យសាច់ដុំចុះខ្សោយ អស់កំលាំងខ្លាំង គ្មានកំលាំងថាមពលធ្វើការងារ ក្រចកដៃ បបូរមាត់ ស្បែក និងអញ្ចាញធ្មេញដែលស្លេកស្លាំង ជីពចរដើរញាប់ ហើយពិបាកដកដង្ហើម។

ខួរក្បាល ធ្វើការមានកម្រិត នៅពេលដែលវាខ្វះអុកស៊ីហ្សែន។ កុមារដែលមានជំងឺខ្វះឈាមក្រហម មានការពិបាកក្នុងការរៀនសូត្រ និងមានបញ្ហាផ្នែកអាកប្បកិរិយារីឯមនុស្សធំពេញវ័យវិញមានបញ្ហាក្នុងការផ្ចង់អារម្មណ៍ និងការចងចាំ។

អ្នកណាក៏អាចមានជំងឺខ្វះឈាមក្រហមដែរ ប៉ុន្តែ ស្ត្រីដែលបាត់បង់ឈាមពេលមានរដូវ និងកុមារ គឺមានការប្រឈមខ្ពស់បំផុត។ ជំងឺខ្វះឈាមក្រហមអាចបណ្តាលមកពី ៖

១. ជំងឺគ្រុនចាញ់ បំផ្លាញកោសិកាឈាមក្រហម
២. ការញ៉ាំអាហារដែលមានជាតិដែកមិនគ្រប់គ្រាន់
៣. ជំងឺរាគរូសរ៉ាំរ៉ៃ
៤. ព្រូនទំពក់ដែលឆ្លងមកពីដី
៥. ព្រូនស៊ីស្ទូសូម៉ាយអាស៊ីស ដែលឆ្លងមកពីទឹកមិនស្អាត។ ព្រូនទាំងនេះវាស៊ីចំណីអាហារដែលមានជីវជាតិរបស់ពោះវៀន ហើយបឺតជញ្ជក់ឈាម។ កាលណាមានព្រូនច្រើន មានន័យថាបាត់បង់ឈាមកាន់តែច្រើន ហើយមានជំងឺខ្វះឈាមក្រហមកាន់តែខ្លាំង។ អាចប្រើថ្នាំពេទ្យព្យាបាលបាន។

………………………………………………………………………………………………........

.

៤. ព្រះគម្ពីរចែងប្រាប់យើងថា “មានពេលវេលាសម្រាប់គ្រប់ទាំងអស់” (សាស្តា ៣:១)។ សម្រាប់កុមារីដែលពេញវ័យ ហើយនិងស្ត្រី គឺមានគោលបំណង និងមានពេលវេលាសម្រាប់រដូវកាលនៃការមករដូវជារៀងរាល់ខែ។ វាគឺជារឿងធម្មតា ព្រោះវាជាផ្នែកមួយនៃការលូតលាស់ ហើយវាជារឿងចាំបាច់ដែលព្រះបានប្រទានសមត្ថភាពនៃការបង្កើតកូនចៅ។ នៅក្នុងកំឡុងពេលមានរដូវក្នុងរយៈពេលខ្លី ត្រូវមានអនាម័យនៅក្នុងការគ្រប់គ្រងរដូវ គឺជាការចាំបាច់ ដើម្បីឲ្យក្មេងស្រីអាចនៅរៀន ទទួលបានការសិក្សាអប់រំ ហើយក្លាយជាម្តាយ និងប្រពន្ធដ៏ល្អ។ រៀងរាល់ការខំប្រឹងប្រែងដើម្បីរក្សានូវសេចក្តីថ្លៃថ្នូរសម្រាប់ពេលវេលានេះ នឹងត្រូវបានពរជ័យ។

ត្រូវគោរព និងការពារមនុស្សស្រី។ ពួកគេត្រូវតែទទួលបានការយកចិត្តទុកដាក់ និងអាហារដែលមានជីវជាតិបំប៉នរាងកាយឲ្យមានសុខភាពល្អ។ មនុស្សស្រីនៅក្នុងវ័យជំទង់ មិនត្រូវមានផ្ទៃពោះទេ ពីព្រោះពួកគេនៅក្នុងវ័យដែលកំពុងលូតលាស់ទៅជាមនុស្សធំពេញវ័យ។ ពួកគេត្រូវការអាហារដែលមានជីវជាតិល្អៗដើម្បីបង្គ្រប់ដល់ការលូតលាស់ និងការអភិវឌ្ឍន៍របស់ពួកគេ ហើយរាងកាយរបស់ពួកគេមិនទាន់ពេញលក្ខណៈគ្រប់គ្រាន់ដើម្បីរក្សាទុកអាហារបម្រុងដែលមានជីវជាតិល្អៗសម្រាប់ជីវិតកូនង៉ែតថ្មីនោះឡើយ។ ការរៀបការត្រូវរង់ចាំរហូតទាល់តែមនុស្សស្រីនោះមានវ័យល្មមគ្រប់គ្រាន់ ហើយរាងកាយរបស់ពួកគេអាចទទួលភាពជាម្តាយបាន។

ស្ត្រីមិនគួរមានកូនង៉ែតញឹកជាប់គ្នាពេកទេ។ ការមានផ្ទៃពោះក្នុងពេលកូនមុនមានអាយុមិនទាន់គ្រប់ពីរឆ្នាំ នោះគឺឆាប់ពេកហើយ។ ម្តាយនឹងខ្វះជីវជាតិល្អៗ ដែលចាំបាច់សម្រាប់សុខភាពរបស់នាង។ នាងមិនអាចរក្សាទុកជីវជាតិល្អៗដែលចាំបាច់ដើម្បីចិញ្ចឹមខ្លួនឯង បំបៅកូន ហើយមានកូនង៉ែតមួយទៀត។ ជាលទ្ធផលនាំឲ្យកើតជំងឺខ្វះអាហារូបត្ថម្ភ និងជំងឺខ្វះឈាមក្រហម។

ជំងឺខ្វះឈាមក្រហម ធ្វើឲ្យមានបញ្ហានៅក្នុងការឆ្លងទន្លេធ្ងន់ធ្ងរ ហើយថែមទាំងអាចស្លាប់ផង បើសិនជាមានឈាមហូរច្រើនពេក។ កូនដែលកើតពីម្តាយដែលមានជំងឺខ្វះឈាមក្រហម មានទំហំខ្លួនតូច មានឱកាសរស់នៅតិចតួច។ កូនដែលលូតលាស់មិនបានល្អទាំងនេះ រៀនខ្សោយ ហើយធ្វើការមិនស្វាហាប់ពេលដែលគេចម្រើនវ័យឡើង។

ពេលកើត ជាតិដែក និងអាហារដែលមានជីវជាតិបន្ថែមទៀតអាចហូរចូលទៅកូនង៉ែតដោយការ

ដាក់កូននៅលើពោះរបស់ម្តាយ ហើយរង់ចាំរហូតទាល់តែទងផ្ចិតឈប់លោតមុននឹងចងវា។

ការបំបៅដោះកូន ផ្តល់អាហារដែលមានជីវជាតិល្អបំផុតសម្រាប់កូនង៉ែត។ នៅពេលដែលកូនង៉ែតមានអាយុបាន៦ខែ ត្រូវបន្ថែមអាហាររុក្ខជាតិដែលកិនម៉ត់។ ការបំបៅកូនដោយទឹកដោះ ត្រូវបន្តយ៉ាងហោចណាស់រហូតទាល់តែកូនមានអាយុ២ឆ្នាំ។ មិនត្រូវប្រើទឹកដោះសត្វទេ ពីព្រោះវាអាចបណ្តាលឲ្យមានបញ្ហាពោះវៀន កើតជំងឺខ្វះឈាមក្រហម និងជំងឺទឹកនោមផ្អែម។

**អាចមានឈាមដែលមានសុខភាពល្អបាន!**

ត្រូវសំអាតឈាម។ ព្យាបាលព្រូន រាគរូស គ្រុនចាញ់ ឬក៏ជំងឺផ្សេងៗទៀតជាមួយនឹងថ្នាំពេទ្យ ហើយនិងថ្នាំបំប៉ន ដើម្បីឲ្យរាងកាយអាចជាសះស្បើយ។

៥. ឈាមកើតឡើងពីអាហារដែលយើងបានញុាំ។ អាហារមានផ្ទុកជាតិដែក បង្កើតជាឈាមដែលរឹងមាំល្អ។ សាច់ក៏មានជាតិដែកខ្ពស់ដែរ ប៉ុន្តែ វាមានតម្លៃថ្លៃ ហើយមានជាតិខ្លាញ់ដែលគ្រោះថ្នាក់ ហើយជូនកាលមានបរាសិត (ព្រូន គេនញ៉ា)ទៀតផង។ អាហាររុក្ខជាតិអាចផ្តល់ជាតិដែកដែលចាំបាច់បាន។ ពពួកសណ្តែករួមទាំងបន្លែក្រៀម និងសណ្តែកបារាំង បន្លែស្លឹកពណ៌បៃតងចាស់ ហើយនិងគ្រាប់ពូជមកពី ល្ពៅ ល្ង ឬក៏ល្ពៅក្អមគឺសម្បូរទៅដោយជាតិដែក និងអាហារដែលមានជីវជាតិផ្សេងទៀត។

វីតាមីនស៊ី ឬសេ ជួយឲ្យឈាមស្រូបជាតិដែក។ វាមាននៅក្នុងដើមរុក្ខជាតិដែលមានពណ៌ចម្រុះដូចជាពពួកត្រសក់ ឬឪឡឹក ត្របែក ពពួកក្រូច យីរី ប៊ីរី បន្លែដែលមានស្លឹកពណ៌បៃតងចាស់ ស្ពៃក្តោប ម្ទេស និងប៉េងប៉ោះ ក៏ដូចជាផ្លែឈើ និងបន្លែជាច្រើនមុខប្លែកៗពីគ្នាផ្សេងទៀត។ ការដាំដើមឈើហូបផ្លែ និងបន្លែ ជាពិសេស បន្លែដែលមានពណ៌បៃតងចាស់ ជាវិធីដែលផ្តល់នូវសុខភាពល្អក្នុងការចិញ្ចឹមគ្រួសាររបស់អ្នក។

ការត្រាំគ្រាប់ធញ្ញជាតិ និងសណ្តែកពេញមួយយប់មុននឹងចំអិន ជួយបង្កើនជាតិដែក និងជាតិស័ង្កសីសម្រាប់ឲ្យដល់ឈាម។ នេះគឺជាវិធីសាស្ត្រដែលមិនអស់លុយកាក់ សម្រាប់បង្កើនជីវជាតិនៅក្នុងអាហាររបស់អ្នក។

តែ និងកាហ្វេ រារាំងមិនឲ្យឈាមស្រូបជាតិដែកបាន។ ការចំណាយលុយកាក់លើ តែនិងកាហ្វេ គឺជាការឥតប្រយោជន៍។ តែគួរតែប្រើលុយកាក់សម្រាប់អាហារដែលមានគុណភាពល្អ ហើយមានសារធាតុចិញ្ចឹម។ កាលណារាងកាយមានអាហារល្អគ្រប់គ្រាន់ ធ្វើឲ្យមានកំលាំងថាមពលបរិបូរ ហើយមិនចាំបាច់យកកំលាំងថាមពលក្លែងក្លាយមកពីភេសជ្ជៈដែលមានជាតិកាហ្វេអ៊ីនឡើយ។

---

៦. ព្រះយេស៊ូបានសុគត ហើយលះបង់ព្រះលោហិតរបស់ទ្រង់ ដើម្បីអំពើបាបរបស់យើង។ ទ្រង់ជ្រាបពីសារសំខាន់របស់ឈាម ដើម្បីមានជីវិត និងសុខភាពល្អ។ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ" (យ៉ូហាន ៣:១៦)។

ចូរជឿ ថាទ្រង់រស់។ ចូរអធិស្ឋាន។ ចូរប្រាប់ទ្រង់អំពីបញ្ហារបស់អ្នក។ ទ្រង់បានលះបង់ព្រះលោហិតរបស់ទ្រង់ ហើយបានសុគតជួសអ្នក ពីព្រោះទ្រង់ស្រឡាញ់អ្នក។

# ព្រះវិហារពិត (ភាគ១)



ឧបមាថា ខ្ញុំមកជួបអ្នកជាមួយនឹងប្រអប់បីស្អាតៗ ហើយបានប្រាប់អ្នកថា មានមួយប្រអប់មានពេជ្រដែលមានតម្លៃមិនអាចកាត់ថ្លៃបាន។ ប្រអប់ពីរផ្សេងទៀតមានដុំថ្ម។ តើអ្នកចង់បានមួយណា?

បើសិនជាអ្នក ដូចជាមនុស្សភាគច្រើន អ្នកច្បាស់ជាចង់បានប្រអប់ដែលមានពេជ្រ។ ប៉ុន្តែ តើប្រអប់មួយណាដែលមានពេជ្រនោះ? ប្រអប់ ពណ៌ខៀវ ពណ៌ក្រហម ពណ៌បៃតង? អ្នកអាចយកបានតែមួយទេ ដូច្នេះអ្នកត្រូវជ្រើសរើសដោយយកចិត្តទុកដាក់។

អ្នកប្រហែលជាត្រូវមក ហើយពិនិត្យប្រអប់ទាំងនេះឲ្យជិត ថាតើមានសញ្ញាសំគាល់ពិសេសដែលអាចប្រាប់អ្នកថាមានអ្វីនៅក្នុងប្រអប់នីមួយៗ។ ប៉ុន្តែ គ្មានសញ្ញាសំគាល់ឡើយ។

ខ្ញុំអាចស្រមើស្រមៃថា មិត្តភក្តិរបស់អ្នកនឹងមកផ្តល់ដំបូន្មានឲ្យអ្នកបាន។ មិត្តម្នាក់និយាយថា “ជ្រើសរើសយកប្រអប់ពណ៌បៃតងទៅ។ ខ្ញុំគិតថាពណ៌បៃតងស្អាត។ ប្រអប់នោះប្រហែលជាត្រូវហើយ។”

អ្នកផ្សេងទៀតថា “អូ ពណ៌ក្រហម គឺជាពណ៌ដែលខ្ញុំចូលចិត្ត។ រើស យកពណ៌ក្រហមទៅ។”

មិត្តភក្តិម្នាក់ទៀតថា “ពេជ្រ គឺច្បាស់ជានៅក្នុងប្រអប់ពណ៌ខៀវ។ រើសមួយហ្នឹងទៅ។”

មានមិត្តកាន់តែច្រើនមក បានផ្តល់យោបល់ឲ្យ។ វាច្របូកច្របល់ណាស់។ ខ្ញុំស្ទើរតែឮអ្នកនិយាយទៅកាន់មិត្តភក្តិរបស់អ្នកថា “ឈប់សិន។ អ្នកទាំងអស់គ្នា មិនអាចទាយត្រូវទាំងអស់ទេ។ មានពេជ្រតែមួយប្រអប់ទេ ដូច្នេះខ្ញុំមិនចង់សម្រេចចិត្តខុសទេ។ ខ្ញុំមិនចង់បានដុំថ្មធម្មតានោះទេ។ ខ្ញុំចង់បានពេជ្រនោះ។”

នៅទីបំផុត អ្នកសម្រេចចិត្តមកជួបខ្ញុំ ហើយសុំយោបល់។ “អ្នកដឹងថាអ្វីនៅក្នុងប្រអប់ទាំងនោះ សូមមេត្តាប្រាប់ខ្ញុំ ថាជ្រើសរើសយកមួយណា។”

ប្រាកដហើយ ខ្ញុំនឹងប្រាប់អ្នក ពីព្រោះខ្ញុំចង់ឲ្យអ្នកសប្បាយចិត្ត ហើយទទួលបានរបស់ដែលល្អបំផុត។ នោះអ្នកនឹងបើកប្រអប់ ហើយទទួលយករង្វាន់របស់អ្នកដោយក្តីរីករាយ។

---



មានព្រះវិហារជាច្រើនស្អាតៗដូចរង្វាន់ស្អាតទាំងនោះដែរ ។ តែរឿងដែលសំខាន់នោះគឺ អ្វីដែលនៅក្នុងព្រះវិហារ។ ព្រះជាម្ចាស់ចង់ជួយយើងឲ្យដឹងពីទីកន្លែងដែលត្រូវទៅព្រះវិហារ។ ព្រះគម្ពីរប្រាប់យើងអំពីរឿងសំខាន់ៗជាច្រើន។ វាប្រាប់យើងពីរបៀបជ្រើសរើសយកសាសនាដែលត្រឹមត្រូវ។ វាជួយយើងឲ្យជ្រើសរើសយកព្រះវិហារពិតប្រាកដ។

បើសិនជាអ្នកចង់ជ្រើសរើសអ្វីដែលត្រឹមត្រូវ អ្នកត្រូវមើលដោយយកចិត្តទុកដាក់។ អ្នកត្រូវមើលថា មានសញ្ញាសំគាល់ពិសេសណាមួយដែលបង្ហាញពីភាពខុសគ្នារវាងរបស់ក្លែងក្លាយ ហើយនិងរបស់ពិតឬអត់។ រួច សឹមធ្វើការសម្រេចចិត្ត។

អ្នកផ្សេងទៀតអាចនិយាយទៅកាន់អ្នកថា “នេះគឺជាសាសនាដែលត្រឹមត្រូវ” ឬថា “អត់ទេ សាសនានោះមិនត្រឹមត្រូវទេ។ នៅទីនោះ មានព្រះវិហារដែលត្រឹមត្រូវ។” អ្នកឮកាន់តែច្រើន ទាំងអស់គ្នាសុទ្ធតែអះអាង ថាត្រឹមត្រូវ។ វាអាចច្របូកច្របល់។ ដូច្នេះ អ្នកក៏និយាយថា “អ្នកមិនអាចត្រូវទាំងអស់នោះទេ។ គឺអាចមានសាសនាពិតតែមួយប៉ុណ្ណោះ។ អាចមានព្រះវិហារត្រឹមត្រូវតែមួយ។ ខ្ញុំមិនចេះ តែចង់ទៅព្រះវិហារណាមួយនោះទេ។ ខ្ញុំចង់ទៅព្រះវិហាររបស់ព្រះពិតប្រាកដ។”

បើសិនជាអ្នកមកឯខ្ញុំ ហើយសុំយោបល់ពីខ្ញុំ អ្នកដឹងហើយថា ខ្ញុំនឹងធ្វើអ្វី តើមែនដែរឬទេ? (លើកព្រះគម្ពីរឡើង) អ្នកនិយាយត្រូវហើយ។ ខ្ញុំនឹងលើកព្រះគម្ពីរខ្ញុំឡើង ហើយនិយាយថា “ចម្លើយសម្រាប់សំណួររបស់អ្នក គឺនៅទីនេះ នៅក្នុងព្រះបន្ទូលបរិសុទ្ធ របស់ព្រះ។ នៅទីនេះ គឺជាកន្លែងដែលយើងអាចរៀនសូត្រអំពីព្រះវិហារពិតរបស់ព្រះ។”

បទទំនាយព្រះគម្ពីរ ប្រើសញ្ញាដើម្បីបង្រៀនយើងអំពីព្រះវិហារពិត និងក្លែងក្លាយ។ នេះគឺជាអ្វីដែលហោរាយ៉ូហានបានឃើញនៅក្នុងសុបិននិមិត្តអំពីព្រះវិហារពិត ៖

---



“រួចមានទីសំគាល់១យ៉ាងធំ នៅលើមេឃ គឺជាស្ត្រីម្នាក់ប្រដាប់ខ្លួនដោយព្រះអាទិត្យ មានព្រះច័ន្ទនៅក្រោមជើង ក៏មានមកុដធ្វើពីផ្កាយ១២ នៅលើក្បាលដែរ។ នាងមានគភ៌ ក៏ស្រែកដោយរៀបនឹងសម្រាលចេញ ទាំងឈឺចាប់នឹងបង្កើតកូនមក...

នាគនោះក៏ស្ថិតនៅត្រង់មុខស្ត្រីដែលរៀបនឹងសម្រាលកូននោះ ដើម្បីលេបកូននាងក្នុងកាលដែលសំរាលចេញមក។ នាងសំរាលបានកូនប្រុស ដែលត្រូវឃ្វាលគ្រប់អស់ទាំងសាសន៍ដោយដំបងដែក តែព្រះទ្រង់លើកកូននាងទៅឯទ្រង់ នឹងដល់បល្ល័ង្កទ្រង់វិញ។” (វិវរណៈ ១២:១,២,៤,៥)។

នៅក្នុងសុបិននិមិត្តនេះ ស្ត្រីតំណាងឲ្យព្រះវិហារពិត។ នាងមានសម្រស់ស្រស់ស្អាត ស្លៀកសម្លៀកបំពាក់ព្រះអាទិត្យមានពន្លឺភ្លឺចែងចាំង មានព្រះច័ន្ទនៅពីក្រោមជើង។ នាងពាក់ផ្កាយ១២ ដូចជាមកុដនៅលើក្បាល។

ចុះសត្វនាគវិញ? តើវាជានរណា? ហោរាហៅវាថា ៖

“គឺជាពស់ពីបុរាណ ដែលឈ្មោះហៅថា អារក្ស ហើយសាតាំងផង ដែលបាននាំលោកិយទាំងមូលវង្វេងចេញ” (វិវរណៈ ១២:៩)។

កូនរបស់ស្ត្រី គឺពិតជាព្រះយេស៊ូវអង្គឯងនោះហើយ។ ទ្រង់ត្រូវបានបញ្ជូនមកដោយព្រះវរបិតារបស់យើងនៅឯនគរឋានសួគ៌ ឲ្យមករស់នៅក្នុងចំណោមមនុស្ស ហើយសុគតជួសអំពើបាបរបស់យើង។ ទ្រង់ត្រូវបានប្រោសឲ្យរស់ពីសុគត ហើយបានយាងត្រឡប់ទៅឯព្រះវរបិតាទ្រង់វិញ។ ទ្រង់នឹងគ្រប់គ្រងពិភពលោកទាំងមូល នៅពេលដែលនគររបស់មនុស្សបានដល់ទីបញ្ចប់។

---



នៅក្នុងសុបិននិមិត្តរបស់លោកយ៉ូហាន គាត់បានឃើញសត្វនាគធ្វើទុក្ខបុកម្នេញដល់ស្ត្រី ដែលជាព្រះវិហារពិត។ លោកយូ៉ហានបានសរសេរថា៖

“រួចស្ត្រីនោះក៏រត់ទៅឯទីរហោស្ថាន នៅទីនោះព្រះបានរៀបកន្លែងឲ្យនាង ដើម្បីនឹងចិញ្ចឹមនាងនៅទីនោះ អស់រវាង១២៦០ថ្ងៃ” (វិវរណៈ ១២:៦)។

ពេលវេលាដែលបានទាយទុកនោះ តំណាងឲ្យ១២៦០ឆ្នាំ។ យើងបាននិយាយអំពីរយៈកាលនៃពេលវេលានោះពីមុនមក តើមែនទេ? តើចាំពីសត្វសាហាវដែលមានក្បាល ៧ ដែលបានធ្វើសង្គ្រាមប្រយុទ្ធជាមួយនឹងរាស្ត្ររបស់ព្រះដែរឬទេ? សត្វសាហាវ នោះតំណាងឲ្យប្រព័ន្ធសាសនារបស់ទីក្រុងរ៉ូម ហើយនិងស្តេចប៉ាបរបស់គេ។ ពួកវាគាបសង្កត់ពិភពលោករបស់គ្រីស្ទាន។ ពួកគេបានព្យាយាមបង្ខំឲ្យគ្រប់គ្នាទទួលយកសាសនារបស់ពួកគេ ដោយផ្អែកទៅលើទំនៀមទំលាប់ និងប្រពៃណីរបស់មនុស្សជំនួសឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់។

យោងតាមសុបិននិមិត្ត ស្ត្រីនឹងមានជីវិតរស់នៅក្នុងទីរហោស្ថានពេញ១២៦០ឆ្នាំនោះ។ នោះជាហេតុការណ៍ដែលបានកើតឡើង។

ទំរាំដល់ពេល១២៦០ឆ្នាំបានដល់ទីបញ្ចប់ មានគ្រីស្ទានរាប់លាននាក់បានស្លាប់ ពីព្រោះពួកគេមិនយកការបង្រៀនក្លែងក្លាយរបស់ព្រះវិហារទីក្រុងរ៉ូម។ ប៉ុន្តែ ព្រះបានការពារសេចក្តីពិតរបស់ទ្រង់ ដើម្បីឲ្យវាមានជីវិតរស់នៅបានយូរនៅក្នុងពេលដែលត្រូវបានគេធ្វើទុកបុកម្នេញ។

…………………………………………………………………………………………………………….......

.



មានព្រឹត្តិការណ៍មួយទៀតនៅក្នុងសុបិននិមិត្តរបស់ហោរា។ សូមស្តាប់៖

“នាគក៏ខឹងនឹងស្ត្រីនោះ ហើយចេញទៅច្បាំងនឹងសំណល់ពូជនាងទាំងប៉ុន្មាន ជាពួកអ្នកដែលកាន់តាមបញ្ញត្តព្រះ ហើយមានសេចក្តីបន្ទាល់ពីព្រះយេស៊ូ” (វិវរណៈ ១២:១៧)។

រឿងរបស់ព្រះវិហារពិត គឺមិនចប់នៅត្រឹម១២៦០ឆ្នាំនោះទេ។ លោកយ៉ូហាន បានឃើញការប្រយុទ្ធដ៏ធំមួយបន្តកើតមានឡើងរហូតដល់ចុងបញ្ចប់នៃប្រវត្តិសាស្ត្រនៃពិភពលោកចាស់នេះ។ គាត់បានឃើញសត្វនាគ កំពុងធ្វើសង្គ្រាមប្រឆាំងនឹងពូជចុងក្រោយរបស់ស្ត្រី។

បន្ទាប់មក ហោរាបានផ្តល់ឲ្យយើងនូវអ្វីដែលយើងត្រូវការ ដើម្បីរកឲ្យឃើញពីព្រះវិហារពិតនៅក្នុងសម័យកាលរបស់យើង - ព្រះវិហារពិត បង្រៀនអំពីការស្តាប់បង្គាប់ (គោរពប្រតិបត្តិតាមបញ្ញត្ត)ទាំងអស់របស់ព្រះ។ ហើយព្រះវិហារពិតជឿលើទីបន្ទាល់របស់ព្រះយេស៊ូ សារដែល បានផ្តល់ឲ្យតាមរយៈហោរារបស់ទ្រង់ដូចជាលោកដានីញ៉ែល លោកយ៉ូហាន ហើយនិងហោរាដទៃទៀត។

មានគ្រីស្ទានដែលស្មោះត្រង់ជាច្រើននាក់នៅតាមព្រះវិហារគ្រីស្ទានខុសៗគ្នាជាច្រើន។ ពួកគេទាំងអស់គ្នាចង់ប្រតិបត្តិតាមការបង្រៀននៃព្រះបន្ទូលរបស់ព្រះ។ ប៉ុន្តែ សង្ឃ និងគ្រូគង្វាល ហើយនិងគ្រូបង្រៀនរបស់ពួកគេបានបង្រៀនពួកគេឲ្យប្រព្រឹត្តរំលងបញ្ញត្តខ្លះរបស់ព្រះ។

ឧទាហរណ៍ :




នៅក្នុងបញ្ញត្តិទី៤ ព្រះមានបន្ទូលថា៖

"ចូរនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ។ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ"(និក្ខមនំ ២០:៨,៩)។

ហេតុអ្វីបានជាថ្ងៃបរិសុទ្ធសំខាន់ចំពោះព្រះជាម្ចាស់ម្ល៉េះ? សូមស្ដាប់៖

"ដ្បិតក្នុង៦ថ្ងៃ ព្រះយេហូវ៉ា ទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនិងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែររួចដល់ថ្ងៃទី៧ទ្រង់ឈប់សម្រាក ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សម្រាក ហើយក៏ញែកចេញជាបរិសុទ្ធ" (និក្ខមនំ ២០:១១)។

ថ្ងៃសាប្ប័ត គឺជាថ្ងៃបរិសុទ្ធ។ វាជាការរំឭកប្រចាំសប្ដាហ៍អំពីអ្នកដែលបានបង្កើតលោកិយ អ្នកដែលបានបង្កើតយើងពីដំបូង និងអ្នកដែលបានផ្ដល់ជីវិតឲ្យយើង។ វាគឺជាថ្ងៃសម្រាប់រាស្ត្ររបស់ព្រះបានទៅជិតទ្រង់ តាមរយៈការថ្វាយបង្គំ និងការអធិស្ឋាន។ ដោយការសម្រាកពីការងារធម្មតានៅថ្ងៃបរិសុទ្ធ រាស្ត្រពិតរបស់ទ្រង់ទទួលបានភាពស្រស់ស្រាយ និងមិត្តភាពរបស់ពួកគេជាមួយនឹងទ្រង់ត្រូវបានកើតមានជាថ្មី។ ពិតជាថ្ងៃដ៏អស្ចារ្យមែន!

ប៉ុន្តែ ពិភពរបស់គ្រីស្ទានជាច្រើនបានងាកបែរប្រឆាំងនឹងថ្ងៃបរិសុទ្ធរបស់ព្រះ គឺជាថ្ងៃសាប្ប័ត ដែលព្រះបានបង្កើត។ ព្រះវិហារភាគច្រើន គោរពថ្វាយបង្គំនៅថ្ងៃអាទិត្យ ជំនួសឲ្យថ្ងៃសៅរ៍ ជាថ្ងៃទី៧នៃសប្ដាហ៍វិញ។ ព្រះវិហារនៃរ៉ូមបានអះអាងថា ខ្លួនមានសិទ្ធិអំណាចកែប្រែថ្ងៃថ្វាយបង្គំបាន។ ប៉ុន្តែ នេះមិនមែនជាអ្វីដែលព្រះគម្ពីរបានបង្រៀននោះទេ។

ព្រះវិហារពិត គឺខុសគ្នា។ សុបិននិមិត្តរបស់លោកយ៉ូហានប្រាប់យើងថា ព្រះវិហារពិតគឺត្រូវបានរក្សាទុកដោយការគោរពប្រតិបត្តិតាមបញ្ញត្តទាំងអស់របស់ព្រះ។

.



នៅក្នុងសុបិននិមិត្តមួយទៀត ហោរាយ៉ូហានបានឃើញព្រះវិហារពិតរបស់ព្រះតំណាងដោយទេវតានាំសារហោះកាត់ផ្ទៃមេឃ។ ពួកគេកំពុងតែយកព្រះបន្ទូលរបស់ព្រះទៅកាន់ពិភពលោក។ ខ្ញុំសូមអានសារនេះឲ្យអ្នកស្ដាប់៖

"ខ្ញុំក៏ឃើញទេវតា១ទៀត កំពុងហោះកាត់កណ្ដាលមេឃ ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សម្រាប់នឹងថ្លែងប្រាប់ដល់មនុស្សនៅផែនដី គឺដល់គ្រប់អស់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារដែរ។ ទេវតានោះបន្លឺសំលេងយ៉ាងខ្លាំងថា ចូរកោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អរបស់ផងទ្រង់ចុះ ដ្បិតពេលដែលទ្រង់ត្រូវជំនុំជំរះ នោះបានមកដល់ហើយ ចូរក្រាបថ្វាយបង្គំដល់ព្រះដ៏បង្កើតផ្ទៃមេឃ ផែនដី សមុទ្រ និងរន្ធទឹកទាំងប៉ុន្មានចុះ" (វិវរណៈ ១៤:៦,៧)។

សូមចងចាំថា ទេវតា គឺជាសញ្ញា។ ទេវតានោះតំណាងឲ្យព្រះវិហាររបស់ព្រះ។ ព្រះវិហារពិត។ គឺព្រះវិហារនោះហើយ ដែលរក្សាបញ្ញត្តរបស់ព្រះ រាប់ទាំងបញ្ញត្តថ្ងៃបរិសុទ្ធផងដែរ។

សុបិននិមិត្តរបស់លោកយ៉ូហានអំពីទេវតា មានន័យថាព្រះវិហារពិតរបស់ព្រះនឹងប្រាប់ពិភពលោកថា ពេលវេលាចុងបញ្ចប់នឹងមកដល់។ សុបិននិមិត្តប្រាប់ថា ព្រះវិហារពិតនឹងហៅរាស្ត្ររបស់ព្រះពីគ្រប់សាសន៍ គ្រប់កុលសម្ព័ន្ធ និងគ្រប់ភាសា។

រាស្ត្រពិតរបស់ព្រះ សមាជិកនៃព្រះវិហារពិត នឹងមានភារកិច្ចពិសេស។ ពួកគេគឺជាអ្នកដែលនឹងជំរុញមនុស្សគ្រប់ទីកន្លែងឲ្យចូលរួម ថ្វាយបង្គំព្រះពិត ជាព្រះដែលបង្កើតផ្ទៃមេឃ ផែនដី និងសមុទ្រ ហើយនិងប្រភពទឹក។

ការថ្វាយបង្គំព្រះអទិករ មានន័យថា រក្សាថ្ងៃបរិសុទ្ធរបស់ទ្រង់ ជាថ្ងៃដែលទ្រង់បានញែកចេញពីថ្ងៃដទៃទៀត។ វាគឺជាសញ្ញា ជាទីសំគាល់និងជាត្រារបស់ទ្រង់។

ហេតុដូច្នេះហើយ បានជាលោកយ៉ូហាននិយាយបន្តទៀតថា "នេះហើយជាសេចក្តីអត់ធ្មត់របស់ពួកបរិសុទ្ធ ដែលកាន់តាមបញ្ញត្តរបស់ព្រះ ហើយមានសេចក្តីជំនឿដល់ព្រះយេស៊ូ" (វិវរណៈ ១៤:១២)។ តាមរយៈសេចក្តីជំនឿនៅក្នុងរង្វាន់របស់ព្រះយេស៊ូអំពីការអភ័យទោស និងសេចក្តីសុចរិតរបស់ទ្រង់ ប្រជារាស្ត្រនៅក្នុងព្រះវិហាររបស់ព្រះជាម្ចាស់អាចរក្សាបញ្ញត្តនៃសេចក្តីស្រឡាញ់របស់ទ្រង់បាន។

មិត្តអើយ ខ្ញុំជឿជាក់ថា បទទំនាយនេះគឺបានក្លាយជាការពិតហើយ ឥឡូវនេះ។ ខ្ញុំ គឺជាកម្មសិទ្ធិរបស់ព្រះវិហារដែលរក្សាបញ្ញត្តរបស់ព្រះ គឺព្រះវិហារសេវេនដេយ អាត់វេនទីស្ទ។ ខ្ញុំនៅទីនេះ និយាយជាមួយនឹងអ្នកអំពីព្រះវិហារពិតរបស់ព្រះ ហើយបានអញ្ជើញអ្នកឲ្យចូលរួមជាមួយនឹងខ្ញុំ ក្នុងការរក្សាថ្ងៃសាប្ប័តឲ្យបានបរិសុទ្ធ។ មានមនុស្សរាប់ពាន់នាក់ទៀត កំពុងតែធ្វើការងារនេះដូចគ្នា គឺជាច្រើនភាសានៅពាសពេញពិភពលោក។

ជារៀងរាល់ថ្ងៃ មុននឹងខ្ញុំចាប់ផ្តើមមេរៀនមួយក្នុងចំណោមមេរៀនទាំងនេះ ខ្ញុំសូមព្រះឲ្យបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមកជួយខ្ញុំ ឲ្យនិយាយតែអ្វីដែលទ្រង់ចង់ឲ្យខ្ញុំនិយាយតែប៉ុណ្ណោះ។ ខ្ញុំទូលសូមទ្រង់ឲ្យបញ្ជូនព្រះវិញ្ញាណបរិសុទ្ធឲ្យនិយាយទៅកាន់ចិត្តរបស់អ្នកខណៈពេលដែលខ្ញុំនិយាយឲ្យអ្នកស្តាប់។ មានសេចក្តីអធិស្ឋានមួយនៅក្នុងចិត្តរបស់ខ្ញុំនាពេលឥឡូវនេះ ដើម្បីឲ្យចិត្តគំនិតរបស់អ្នកនឹងបើកទទួលយកសារនេះ។

ខ្ញុំសុំសួរសំណួរមួយដល់អ្នក ៖ តើមានប៉ុន្មាននាក់យល់ថា ថ្ងៃសៅរ៍ជាថ្ងៃទី៧នៃសប្តាហ៍ គឺជាថ្ងៃដែលព្រះបានញែកចេញជាថ្ងៃបរិសុទ្ធរបស់ទ្រង់?
(សូមរង់ចាំចម្លើយតបមកវិញ)

ឥឡូវនេះ សូមលើកដៃឡើង បើសិនជាអ្នកយល់ថា តាមរយៈបទទំនាយនៅក្នុងព្រះគម្ពីរ ព្រះវិហារពិតរបស់ព្រះ គឺកើតពីរាស្ត្រដែលរក្សា បញ្ញត្តទាំងអស់របស់ទ្រង់ រួមទាំងបញ្ញត្តនៃថ្ងៃបរិសុទ្ធផង។ (សូមរង់ចាំ ចម្លើយតបវិញ)

សំណួរសំខាន់មួយទៀត ៖ តើមានប៉ុន្មាននាក់ដែលដឹងនៅក្នុងចិត្ត ក្នុងពេលឥឡូវនេះថាព្រះអម្ចាស់កំពុងតែហៅអ្នកឲ្យចូលរួមជាមួយនឹងខ្ញុំ ជាសមាជិកព្រះវិហារសេវេនដេយអាត់វេនទីស្ទ? (សូមរង់ចាំចម្លើយតបមកវិញ)។

សូមក្រោកឈរទាំងអស់គ្នា ហើយសង្រួមចិត្តអធិស្ឋានជាមួយគ្នា។

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ អរព្រះគុណទ្រង់ចំពោះសារដែលទ្រង់បានបញ្ជូនមកឲ្យពួកទូលបង្គំតាមរយៈហោរាព្រះគម្ពីរ។ អរព្រះគុណទ្រង់ចំពោះការបង្ហាញសេចក្តីពិតអំពីថ្ងៃបរិសុទ្ធរបស់ទ្រង់ ហើយនិងសេចក្តីពិតអំពីព្រះវិហាររបស់ទ្រង់។ ទ្រង់បានជ្រាបថា មានអ្នកខ្លះបានសម្រេចចិត្តចូលរួមជាមួយនឹងព្រះវិហាររបស់ផងទ្រង់រួចហើយ។ ហើយទ្រង់ជ្រាបដឹងពីចិត្តរបស់អស់អ្នកដែលមិនប្រាកដ ដោយសារតែពួកគេមិនបានចម្លើយអំពីសំណួររបស់ពួកគេឡើយ។ សូមទ្រង់ប្រទានពរដល់បុរស និងស្ត្រីទាំងនេះ។ ពួកគាត់ គឺជាបងប្អូនប្រុសស្រីរបស់ពួកទូលបង្គំ។ ពួកគេ គឺជាកូនចៅរបស់ផងទ្រង់។ សូមទ្រង់រុំពួកទូលបង្គំទាំងអស់គ្នានៅក្នុងក្តីស្រឡាញ់របស់ផងទ្រង់។ សូមទ្រង់ទាញពួកទូលបង្គំឲ្យខិតកាន់តែជិតទ្រង់។ អរព្រះគុណទ្រង់ ដែលបានបញ្ជូនព្រះយេស៊ូមកធ្វើជាព្រះអង្គសង្គ្រោះរបស់ពួកទូលបង្គំ។ សូមទ្រង់រៀបចំពួកទូលបង្គំទាំងអស់គ្នាមកធ្វើជាផ្នែកមួយនៃនគរដ៏អស់កល្បរបស់ផងទ្រង់។ ពួកទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ</u> ៖

| | | |
|---|---|---|
| អេសាយ ៥១:១៦ | អេម៉ុស ៣:៧ | កិច្ចការ ២០:២៨-៣០ |
| អេភេសូរ ៤:៤-៦ | អេសាយ ៥៥:២ | យ៉ូហាន ១០:១៦ |
| កូរិនថូសទី១ ១២:២៥ | យ៉ាកុប ៤:៤ | យេរេមា ៦:២ |
| យ៉ូហាន ១៣:១៧ | កូរិនថូសទី២ ១១:២ | វិវរណៈ ១៧:៣-៥ |
| យេរេមា ២៩:១៣ | យ៉ូហាន ១៧:២១ | ធីម៉ូថេទី១ ៣:១៦ |
| វិវរណៈ ១៨:៤ | អេសេគាល ៤:៦ | លូកា ១២:១៥ |
| អេភេសូរ ១:២០ | វិវរណៈ ១៩:១៥,១ | |

## លំនាំពិភាក្សា

**ជីវិតគឺរស់នៅក្នុងឈាម**

១. ហេតុអ្វីបានជាការមានឈាមដែលមានសុខភាពល្អ គឺជារឿងសំខាន់?

២. តើអ្វីដែលបណ្តាលឲ្យកើតជំងឺខ្វះឈាមក្រហម?

៣. ហេតុអ្វីបានជាស្ត្រីប្រឈមនឹងគ្រោះថ្នាក់ជាងគេ ក្នុងការកើតជំងឺខ្វះឈាមក្រហម ហើយតើត្រូវបង្កាកុំឲ្យជំងឺនេះកើតឡើងដោយរបៀបណា?

**ព្រះវិហារពិត (ភាគ១)**

១. ហោរាយ៉ូហានបានសុបិននិមិត្តឃើញស្ត្រីដែលរៀបនឹងសម្រាលកូន។ តើស្ត្រីតំណាងឲ្យអ្នកណា?

-វិវរណៈ ១២:១

២. គាត់បានឃើញសត្វនាគបម្រុងនឹងស៊ីកូនរបស់នាង។ តើសត្វនាគតំណាងឲ្យអ្វី?

-វិវរណៈ ១២:៩

៣. តើស្ត្រីនោះបានរត់គេចពីសត្វនាគទៅឯទីរហោស្ថានរយៈពេលយូរប៉ុណ្ណា?

-វិវរណៈ ១២:៦

៤. កូនចៅរបស់ស្ត្រី ដែលជាព្រះវិហាររបស់ព្រះ គឺត្រូវបានពន្យល់តាមលក្ខណៈពិសេសពីរយ៉ាង។ តើលក្ខណៈពិសេសទាំងពីរនោះគឺអ្វីខ្លះ?

-វិវរណៈ ១២:១៧

៥. លោកយ៉ូហានបានឃើញព្រះវិហារពិតរបស់ព្រះ តំណាងដោយទេវតាជាអ្នកនាំសារ។ តើសារពិសេសមួយក្នុង ចំណោមសារដទៃទៀត គឺអ្វី?

-វិវរណៈ ១៤:៦,៧

# មេរៀនសុខភាពទី២០ - ជំងឺបេះដូង គឺជាឃាតករលេខ១ក្នុងពិភពលោក



១. ពេលដែលមនុស្សផ្លាស់កន្លែងរស់នៅពីជនបទទៅក្នុងទីក្រុង ពួកគេជួបនៅជីវិតរស់នៅខុសៗគ្នា។ ផ្លូវសំបូរទៅយានយន្ត(ឡាន ម៉ូតូ) ដែលបំពុលខ្យល់។ ផ្ទះកកកុញ មានបំពង់ទឹកនៅក្នុងផ្ទះ។ វាររវល់ ហើយអ៊ូរអរ។ មានអាហារ និងគ្រឿងកំសាន្តច្រើនប្រភេទ ប៉ុន្តែភ័យខ្លាចអំពើហិងា្ស។ មិនសូវជាមានកន្លែងអាចទៅលំហែកាយ ហើយរីករាយជាមួយនឹងធម្មជាតិ។

រឿងទាំងអស់នេះហើយដែលជះឥទ្ធិពលទៅលើបេះដូង ហើយនាំឲ្យកើតជំងឺធ្ងន់ធ្ងរ ដូចជាជំងឺបេះដូង ជំងឺទឹកនោមផ្អែម ជំងឺមហារីក និងជំងឺបាក់ទឹកចិត្ត។

អាហារដែលព្រះបានប្រទានឲ្យមនុស្សញ៉ាំ នៅពេលដែលទ្រង់បានបង្កើតពួកគេ គឺនៅតែជាអាហារដែលល្អបំផុតសម្រាប់រក្សាសុខភាពរាងកាយឲ្យនៅល្អ។ អាហាររុក្ខជាតិ គឺជាអាហារដែលល្អសម្រាប់សុខភាពបេះដូង និងសរសៃឈាម។ សូម្បីតែនៅក្នុងពពួកសត្វ សត្វដែលស៊ីបន្លែពណ៌បៃតង និងគ្រាប់ធញ្ញជាតិនឹងធំលូតលាស់រឹងមាំ ហើយមានសុខភាពល្អ។ សាច់សត្វដែលមនុស្សញ៉ាំភាគច្រើន គឺជាសត្វដែលស៊ីរុក្ខជាតិ។

ប៉ុន្តែ មនុស្សជាច្រើននាពេលសព្វថ្ងៃនេះ មិនញ៉ាំអាហារដែលព្រះបានប្រទានឲ្យតាំងពីដើមមកទេ។ ការផ្លាស់ប្តូរពីអាហារដែលមិនចម្រាញ់ ដែលជាអាហាររុក្ខជាតិ ពីអាហារជនបទ ទៅជាអាហារបែបទីក្រុងបានបណ្តាលឲ្យសុខភាពចុះអន់ថយ។ អាហារនៅតាមទីក្រុង ឬក៏អាហារបែបអឺរ៉ុប គឺច្រើនជាអាហារកែច្នៃ។ គ្រាប់ធញ្ញជាតិត្រូវបានចម្រាញ់ ផ្លែឈើត្រូវបានគៀបយកទឹក សំបូររបស់ផ្អែមៗ (ស្ករគ្រាប់ នំចំណី) លក់ក្នុងតម្លៃថោក សាច់ក៏មានលក់ស្រាប់ ហើយភេសជ្ជៈដែលមានជាតិសូដាអាចរកទិញបាន គ្រប់ទីកន្លែង។

ការផ្លាស់ប្តូរទម្លាប់ពីការញ៉ាំអាហារបែបជនបទ ទៅជាអាហារបែបទីក្រុងអាចនាំឲ្យកើតជំងឺឃាតករទី១នៅក្នុងពិភពលោក គឺជំងឺបេះដូង និងជំងឺសរសៃឈាម។ លទ្ធផល គឺនាំឲ្យគាំងបេះដូង និងដាច់សរសៃឈាមខួរក្បាល។

.....................................................................................................................................

**២. ជីវិត គឺនៅក្នុងឈាម**

ជំងឺសរសៃបេះដូង គឺធ្វើឲ្យឈាមពិបាកហូរ បណ្តាលឲ្យមានដង្ហើមខ្លី ឈឺជើងនៅពេលដើរ ឬក៏ឈឺដើមទ្រូង។ ទាំងនេះ គឺជាសញ្ញាព្រមាន។ ជួនកាលគ្មានរោគសញ្ញាព្រមានឡើយ ហើយនោះគឺជារោគសញ្ញាដំបូងនៃជំងឺគាំងបេះដូង ឬដាច់សរសៃឈាមខួរក្បាល បន្ទាប់មកស្លាប់។ ជំងឺសរសៃឈាមបេះដូង បណ្តាលឲ្យបុរសស្លាប់នៅក្នុងវ័យក្មេងច្រើនជាងស្ត្រី។

មានកត្តានៃរបៀបរស់នៅជាច្រើនដែលធ្វើឲ្យបេះដូងខូច និងដំណើរឈាមរត់មិនល្អ៖

- ថ្នាំជក់ បំពុលឈាម ហើយបណ្តាលឲ្យសរសៃឈាមរួម ធ្វើឲ្យឈាមពិបាកធ្វើដំណើរ។
- រាងកាយគ្មានចលនា ធ្វើឲ្យសាច់ដុំបេះដូងចុះខ្សោយ ធ្វើឲ្យដំណើរឈាមរត់យឺតយ៉ាវ។

- ស្រា បំពុលកោសិកាបេះដូង ធ្វើឲ្យបេះដូងចុះខ្សោយ។
- ជំងឺទឹកនោមផ្អែមរំខានដល់ដំណើរឈាមរត់ និងបំផ្លាញទ្រង់ទ្រាយរបស់បេះដូង។
- ខ្យល់ពុលដែលចេញពីរោងចក្រ និងយានយន្ត(ម៉ូតូ និងឡាន)បំពុលដល់រាងកាយ ធ្វើឲ្យជំងឺគាំងបេះដូងកាន់តែកើនឡើង។
- ភាពតានតឹង ទុក្ខព្រួយ បាក់ទឹកចិត្ត និងកំហឹងប៉ះពាល់ដល់សុខភាពបេះដូង។
- អាហារដែលមិនល្អសម្រាប់សុខភាព ធ្វើឲ្យសុខភាពបេះដូង និងសរសៃឈាមចុះខ្សោយ។

……………………………………………………………………………………………………........

.

៣. ខឡេស្ទើរ៉ុល (ជាតិខ្លាញ់មិនល្អ)

ខឡេស្ទើរ៉ុល គឺជាសារធាតុដែលមានលក្ខណៈដូចជាក្រមួនខ្លាញ់ នៅក្នុងកោសិកានៃរាងកាយទាំងអស់។ វាមានមុខងារសំខាន់ពិសេសនៅក្នុងខួរក្បាល ក្នុងការផលិតវីតាមីន និងអរម៉ូន។ រាងកាយផលិតត្រឹមចំនួនដែលវាត្រូវការតែប៉ុណ្ណោះ អ្វីដែលលើសនាំឲ្យខូចខាត។ នៅពេលដែលញ៉ាំអាហារសាច់សត្វ គឺបានន័យថាញ៉ាំជាតិខឡេស្ទើរ៉ុលបន្ថែមទៀត។ វារត់នៅក្នុងចរន្តឈាម ហើយស្អិតជាប់នៅនឹងជញ្ជាំងសរសៃឈាម ធ្វើឲ្យស្ទះ និងរួមតូច។

កាលណាបន្ទះខ្លាញ់នេះធ្វើដំណើរទៅដល់សរសៃឈាមតូចៗ វាចុកសរសៃឈាមជិត ធ្វើឲ្យឈាមកកនិងឈាមឈប់ហូរ។ កោសិកាដែលមិនបានទទួលឈាមក៏ស្លាប់។ បញ្ហានេះអាចកើតឡើងនៅក្នុងសួតបេះដូង និងខួរក្បាល។ កាលណាវាកើតឡើងនៅក្នុងផ្នែកក្បាល វាធ្វើឲ្យដាច់សរសៃឈាមខួរក្បាល ដែលអាចនាំឲ្យបេះដូងឈប់ដំណើរការ នោះគឺគាំងបេះដូង។ បញ្ហាទាំងពីរប្រភេទនេះ អាចធ្វើឲ្យស្លាប់បាន។

……………………………………………………………………………………………………........

៤. អាហារចម្រាញ់

អាហារប៉ូវរាងកាយដែលបានមកពីអាហាររុក្ខជាតិទាំងស្រុងដែលបានកិនរំលាយ(មិនចម្រាញ់) ឆាប់ផ្តល់សារធាតុចិញ្ចឹមទៅក្នុងឈាមបានលឿន ផ្តល់អុកស៊ីហ្សែនទៅកោសិកាបានលឿន ព្រមទាំងផ្តល់កំលាំងថាមពលវីតាមីន និងសារធាតុសកម្មល្អៗនៅក្នុងរុក្ខជាតិ។ នៅពេលញ៉ាំអាហារចម្រាញ់ដែលមានជាតិសរសៃទាប ហើយមានជាតិស្ករខ្ពស់ ឈាមផ្ទុកលើសទម្ងន់ ហើយឡើងខាប់ និងធ្វើដំណើរយឺត។

ខ្លាញ់សត្វ និងខឡេស្ទើរ៉ុលចេញពីសាច់សត្វ បណ្តាលឲ្យមានបញ្ហាដូចគ្នា។ ដំណើរឈាមរត់យឺត ហើយកោសិកាទទួលបានអុកស៊ីហ្សែនតិច។ ខួរក្បាល បេះដូង ហើយនិងសរីរាង្គផ្សេងៗទៀតត្រូវការអាហារ និងអុកស៊ីហ្សែន ធ្វើឲ្យសម្ពាធឈាមឡើងខ្ពស់ ហើយនិងធ្វើឲ្យខូចខួរក្បាល និងកោសិកាសរសៃឈាមកាន់តែខ្លាំង។ បន្ទះខ្លាញ់កកកុញនៅលើជញ្ជាំងនៃសរសៃឈាម ហើយបញ្ហាយ៉ាប់យឺនកើតឡើងឥតឈប់ឈរ។

បញ្ហាលើសទម្ងន់ ឬជំងឺលើសទម្ងន់

អាហារទីក្រុងរួមជាមួយនឹងការមិនធ្វើលំហាត់ប្រាណ បានធ្វើមនុស្សជាច្រើនកើតជំងឺលើសទម្ងន់នៅពាសពេញពិភពលោក។ កាលណាមានខ្លាញ់នៅក្នុងខ្លួនបន្ថែម តម្រូវឲ្យសរសៃឈាមយឺតវែងថែមទៀតដែលជាហេតុធ្វើឲ្យបេះដូងធ្វើការបន្ថែមទៀត។ បញ្ហាលើសទម្ងន់ គឺជាបញ្ហាចំបងដែលនាំឲ្យកើតជំងឺដូចជាពិការដោយសារជំងឺទឹកនោមផ្អែម ជំងឺរលាកសន្លាក់ ជំងឺមហារីកជាច្រើនប្រភេទ មានបញ្ហាក្នុងការដកដង្ហើម និងបញ្ហាសរីរាង្គបន្តពូជ។

៥. អាហាររបស់ព្រះ

ព្រះជាម្ចាស់បានប្រទានអាហារឲ្យយើង សម្រាប់ឲ្យទម្ងន់ ដំណើរឈាមរត់ និងបេះដូងមានសុខភាពល្អ។ អាហាររបស់ទ្រង់នោះគឺ អាហាររុក្ខជាតិដែលមិនចម្រាញ់ មានផ្លែឈើ បន្លែ សណ្តែក គ្រាប់ផ្លែឈើ និង គ្រាប់ធញ្ញជាតិ។ ដើម្បីបំពេញឲ្យគ្រប់គម្រោងការរបស់ទ្រង់ ចាំបាច់ត្រូវតែហាត់ប្រាណ។

ព្រះជាម្ចាស់ចង់ជួយយើងកែប្រែពីទម្លាប់អាក្រក់ទៅជាទម្លាប់ដែលនាំឲ្យមានសុខភាពល្អ។ សូមអធិស្ឋាន និងសុំទ្រង់ឲ្យដឹកនាំការសម្រេចចិត្តរបស់អ្នក និងជួយអ្នកក្នុងការផ្តល់អាហារដែលមានសុខភាពល្អដល់ក្រុមគ្រួសាររបស់អ្នក។

"ទ្រង់ធ្វើឲ្យស្មៅដុះឡើងសម្រាប់សត្វ ហើយបន្លែសម្រាប់មនុស្ស ដើម្បីឲ្យទាំងពីរបានអាហារពីផែនដីមក ...ហើយអាហារផង សម្រាប់ចម្រើនកំលាំងចិត្តមនុស្ស" (ទំនុកតម្កើង ១០៤: ១៤,១៥)។

## ប្រាក់កាស និងទ្រព្យសម្បត្តិរបស់យើង



ឧបមាថា មានព្រឹកមួយអ្នកបានក្រោកឡើង ហើយនៅចំពីមុខអ្នកមានជាលមួយយ៉ាងធំមានពេញទៅដោយផ្លែឈើគ្រប់ប្រភេទ។ នៅក្នុងជាលនោះក៏មានផ្លែឈើដែលអ្នកចូលចិត្តដែរ។ ហើយក៏មានផ្លែឈើខ្លះដែលអ្នកមិនដែលធ្លាប់ឃើញពីមុនមកដែរ តែពេលអ្នកញុាំមួយម៉ាត់សាកមើល វាមានរសជាតិឆ្ងាញ់។ គ្រប់ចំណិត គឺថាឆ្ងាញ់អស្ចារ្យ។

តើជាលផ្លែឈើដ៏ល្អនោះ ទៅដល់ទីនោះបានដោយរបៀបណា? តើអ្នកគិតដូចម្តេច? តើវាជាវេទមន្ត ឬក៏សីល៍អ្វី? តើជាលនោះ ស្រាប់តែផុសចេញមកពីកន្លែងណាមួយឬ? ទេ។ ប្រាកដណាស់ មិនមែនទេ។ ការនោះមិនអាចកើតមានឡើងបានឡើយ។ ច្បាស់ជាមានអ្នកណាម្នាក់យកជាលនោះមកឲ្យអ្នកហើយ។

បើសិនអ្នកជាប្រភេទមនុស្សដែលចេះគិតគូរ ចេះគួរសម អ្នកនឹងព្យាយាមរកអ្នកដែលឲ្យអំណោយនោះដល់អ្នកមិនខាន។ ដូច្នេះ អ្នកសួរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតនៅក្នុងក្រុង "តើអ្នកមែនទេ ដែលឲ្យជាលមួយស្អាតមានផ្លែឈើនៅក្នុងនោះ?" ហើយពេលអ្នករកអ្នកដែលឲ្យឃើញ អ្នកនិយាយថា "អរគុណ! អរគុណចំពោះអំណោយដ៏ល្អនោះ។"

ហើយបន្ទាប់មក បើសិនអ្នកជាមនុស្សចិត្តល្អ អ្នកច្បាស់ជានិយាយមកកាន់ខ្លួនឯងថា "ខ្ញុំមិនដឹងថា តើខ្ញុំអាចធ្វើអ្វីសម្រាប់អ្នកដែលឲ្យផ្លែឈើខ្ញុំមួយជាលនោះទេ។ ច្បាស់ជាមានវិធីណាមួយ ដែលខ្ញុំអាចបង្ហាញពីការអរគុណរបស់ខ្ញុំជាមិនខាន។"

មិត្តទាំងឡាយ ជារៀងរាល់ថ្ងៃ យើងទទួលបានអំណោយល្អៗដែលងាយបំភ្លេច។ គ្រប់ដង្ហើមដែលយើងដកចូល។ គ្រប់ចង្វាក់ដែលបេះដូងលោត។ អំណោយទាំងនេះ គឺជាព្រះពរមកពីព្រះវរបិតារបស់យើងនៅឯនគរឋានសួគ៌។ ទ្រង់ គឺជាប្រភពនៃរឿងល្អគ្រប់យ៉ាងនៅក្នុងជីវិតរបស់យើង។ យើងនៅលើផែនដីនេះ ដោយសារទ្រង់។ នេះគឺជាការរំឭកមកពីព្រះគម្ពីរ៖

"ដ្បិត គឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់កម្រើក ហើយមាននៅផង ..." (កិច្ចការ ១៧:២៨)។

អំណោយដ៏ធំបំផុតដែលព្រះបានប្រទានឲ្យយើង គឺព្រះរាជបុត្រារបស់ទ្រង់ ដែលជាព្រះយេស៊ូ។ ព្រះវរបិតាបានបញ្ជូនទ្រង់ដើម្បីបង្ហាញយើងពីក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង។ ទ្រង់បានបញ្ជូនព្រះយេស៊ូមកលោះបាបរបស់យើង ដើម្បីឲ្យយើងអាចទទួលបាននូវការអភ័យទោស។ ទ្រង់បានបញ្ជូនព្រះរាជបុត្រាទ្រង់មកបង្រៀនយើងពីរបៀបរៀបចំសម្រាប់ជីវិតអស់កល្បនៅក្នុងនគររបស់ទ្រង់ដែលនឹងមកដល់នាពេលខាងមុខ។

មិត្តអើយ ខ្ញុំអរគុណខ្លាំងមែនទែនចំពោះអ្វីដែលទ្រង់បានធ្វើសម្រាប់ខ្ញុំ។ បើគ្មានទ្រង់ទេ ខ្ញុំនឹងក្លាយទៅជាអ្នកមានបាបដែលអស់សង្ឃឹម ដែលវង្វេងហើយ។ ឥឡូវនេះ ខ្ញុំមានសង្ឃឹម។ ជឿទុកចិត្តនៅក្នុងសេចក្តីសន្យារបស់ព្រះ ខ្ញុំសង្ឃឹមរង់ចាំទៅរស់នៅជាមួយនឹងទ្រង់ជារៀងរហូត។ វាអាចដូចគ្នាដែរសម្រាប់អ្នកម្នាក់ៗ។

អ្នកសរសេរព្រះគម្ពីរម្នាក់បានសួរថា “តើត្រូវឲ្យខ្ញុំយកអ្វីតបស្នងព្រះយេហូវ៉ា ចំពោះព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំទាំងប៉ុន្មាន?” (ទំនុកតម្កើង ១១៦:១២)។ តើយើងអាចធ្វើអ្វីដើម្បីបង្ហាញដល់ទ្រង់ឲ្យទ្រង់បានជ្រាបថា យើងដឹងគុណចំពោះ ទ្រង់នោះ?



នៅក្នុងសួនអេដែនដ៏ស្រស់ស្អាត ជាកន្លែងដែលឪពុកម្តាយដើមរបស់យើងអាចមើលឃើញព្រះទល់មុខនឹងមុខ។ ត្រឹមត្រូវហើយ។ មុនពេលដែលពួកគាត់បានប្រព្រឹត្តអំពើបាប ពួកគាត់មិនខ្លាចព្រះជាម្ចាស់ឡើយ។ ពួកគាត់អាចនិយាយ ជាមួយនឹងទ្រង់ដូចអ្នកនឹងខ្ញុំនិយាយលេងជាមួយគ្នាអញ្ចឹង។ ពួកគាត់អាចទូលប្រាប់ទ្រង់អំពីការដឹងគុណចំពោះអ្វីដែលទ្រង់បានធ្វើសម្រាប់ពួកគាត់ផ្ទាល់តែម្តង។ ពួកគាត់អាចទូលប្រាប់ទ្រង់ថា ពួកគាត់ស្រឡាញ់ទ្រង់ប៉ុណ្ណា។ ខ្ញុំចង់ធ្វើដូច្នោះដែរ ឥឡូវនេះ ចុះអ្នកវិញ?

សព្វថ្ងៃនេះ យើងអាចទៅជិតព្រះជិតបំផុត តាមរយៈការថ្វាយបង្គំទ្រង់។ អ្នកដឹងទេ យើងកំពុងតែធ្វើដូច្នោះហើយ ពេលនេះ។ នៅពេលដែលយើងមកជួបជុំគ្នានិយាយអំពីទ្រង់ នេះគឺជារបៀបថ្វាយបង្គំមួយប្រភេទ។ ការអធិស្ឋាន ក៏ជាការថ្វាយបង្គំមួយដែរ។ ការថ្វាយបង្គំ គឺជាវិធីមួយនៃការអរព្រះគុណទ្រង់ចំពោះអ្វីដែលទ្រង់បានធ្វើសម្រាប់យើងដែរ។

យើងក៏អាចបង្ហាញពីការអរគុណចំពោះព្រះ ដោយការស្តាប់បង្គាប់ទ្រង់។ ទ្រង់បានប្រទានឲ្យយើងនូវច្បាប់ទម្លាប់សម្រាប់ការរស់នៅដោយភាពរីករាយ និងមានក្តីសុខសាន្ត។ ដូចលោកអាដាម និងនាងអេវ៉ានៅក្នុងសួនអេដែនដែរ ព្រះបានផ្តល់សិទ្ធិសេរីភាពឲ្យយើងជ្រើសរើស យើងអាចស្តាប់បង្គាប់ទ្រង់។ ឬក៏យើងអាចសម្រេចចិត្ត មិនគោរពប្រតិបត្តិតាមច្បាប់របស់ទ្រង់។ ទ្រង់មិនបានបង្ខំយើងទេ។ តែទ្រង់បែរជាព្យាយាមបញ្ចុះបញ្ចូលយើងវិញ។ ទ្រង់ប្រទានពរឲ្យយើងពីមួយថ្ងៃទៅមួយថ្ងៃ បញ្ជាក់ប្រាប់យើងម្តងហើយម្តងទៀតថា ទ្រង់ស្រឡាញ់យើង។

ការស្តាប់បង្គាប់ព្រះជាម្ចាស់ មានន័យថា យើងស្រឡាញ់ និងជឿទុកចិត្តទ្រង់យ៉ាងខ្លាំង ដែលធ្វើឲ្យយើងចង់ដើរតាមគម្រោងការរបស់ទ្រង់សម្រាប់ជីវិតយើង។ ហើយមិត្តអើយ គ្មានសេចក្តីសុខណាធំជាងពេលដែលយើងដើរតាមគម្រោងការរបស់ទ្រង់។

គឺរាប់បញ្ចូលទាំងគ្រប់ផ្នែកនៃជីវិតរបស់យើង ក្រុមគ្រួសាររបស់យើង ហើយព្រមទាំងទ្រព្យសម្បត្តិរបស់យើង។

.



ប្រាកដណាស់ គ្រប់យ៉ាងគឺជាកម្មសិទ្ធិរបស់ព្រះ។ គ្រប់យ៉ាងដែលយើងមានជារបស់ផងទ្រង់។ ទ្រង់បានបង្កើតពិភពលោក និងរបស់សព្វសារពើដែលនៅក្នុងនោះ។ សូមស្តាប់នូវអ្វីដែលទ្រង់មានបន្ទូល ៖

"ដ្បិតអស់ទាំងសត្វនៅព្រៃសុទ្ធតែជារបស់អញ ព្រមទាំងហ្វូងសត្វទាំងប៉ុន្មាននៅលើភ្នំទាំងពាន់ផង។ អញស្គាល់អស់ទាំងសត្វស្លាបនៅលើភ្នំ ហើយសត្វព្រៃទាំងឡាយ ជារបស់ផងអញដែរ" (ទំនុកតម្កើង ៥០:១០,១១)។

អ្វីដែលយើងមាន ដែលយើងហៅថាជារបស់យើង គឺបានមកពីទ្រង់។ ព្រះគម្ពីរណែនាំយើង ៖

"ត្រូវឲ្យនឹកពីព្រះយេហូវ៉ាជាព្រះនៃឯងវិញ ដ្បិតគឺទ្រង់ហើយ ដែលប្រទានឲ្យឯងមានឥទ្ធិឫទ្ធិ ឲ្យបានទ្រព្យសម្បត្តិ..." (ចោទិយកថា ៨:១៨)។

ទ្រង់មានគម្រោងការជួយអ្នកឲ្យចងចាំរឿងនេះ។ នេះគឺជាគម្រោងការរបស់ទ្រង់ ៖

"ហើយផលពីដី១ភាគក្នុង១០ ទោះបើជាផលដែលកើតពីដី ឬជាផ្លែឈើ នោះជារបស់ផងព្រះយេហូវ៉ា ហើយត្រូវតែបានទុកជាបរិសុទ្ធសម្រាប់ទ្រង់។ ឯហ្វូងសត្វធំ ឬតូច១ភាគក្នុង១០ គឺសត្វណាក៏ដោយដែលចូលទៅក្រោមដំបង នោះត្រូវជាដង្វាយ១ភាគក្នុង១០ ទុកជាបរិសុទ្ធដល់ព្រះយេហូវ៉ា" (លេវីវិន័យ ២៧:៣០,៣២)។




ដង្វាយ១០ភាគរយ គឺ១ភាគក្នុង១០។ បើសិនជាសួនដំណាំរបស់យើងដុះបានពោត ១០ផ្លែ ពោតទាំងនោះគឺជាព្រះពរមកពីទ្រង់។ ទ្រង់សុំឲ្យយើងថ្វាយទៅទ្រង់វិញតែ១។ របស់មួយនោះ គឺជារបស់បរិសុទ្ធ។ គឺទុកសម្រាប់ទ្រង់ ហើយនិងការងារ របស់ទ្រង់។ វាដូចគ្នា បើសិនជាយើងលក់ពពែ១០ក្បាល។ លុយកាក់ដែលបានមកពីលក់ពពែ១ក្បាល ជារបស់ព្រះជាម្ចាស់។ វាជាប្រាក់កាសបរិសុទ្ធ។ ទ្រង់សន្យាប្រទានពរយើង នៅពេលដែលយើងចងចាំថ្វាយទៅទ្រង់វិញនូវដង្វាយមួយភាគដប់។

សូមស្តាប់ ៖

"ចូរនាំយកដង្វាយ១ភាគក្នុង១០ទាំងអស់មកដាក់ក្នុងឃ្លាំងចុះ ដើម្បីឲ្យមានស្បៀងអាហារនៅក្នុងដំណាក់នៃអញ ហើយល្បងលអញឥឡូវ បើអញមិនបើកទ្វារស្ថានសួគ៌ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបាន" (ម៉ាឡាគី ៣:១០)។

ការថ្វាយព្រះ១ភាគក្នុង១០ នូវអ្វីដែលយើងមាន មើលទៅហាក់ដូចជាច្រើនខ្លាំងជាពិសេសនៅពេលដែលយើងមិនមានច្រើននៅពេលចាប់ផ្តើមពីដំបូង។ ប៉ុន្តែ មានមនុស្សរាប់លាននាក់ ដូចអ្នកនិងខ្ញុំ បានដឹងថា ការថ្វាយទៅព្រះនូវដង្វាយ១ភាគ១០របស់ទ្រង់ នាំឲ្យពួកគេទទួលបានព្រះពររបស់ទ្រង់។

ប្រាកដណាស់ ព្រះជាម្ចាស់មិនត្រូវការលុយកាក់ ឬពោត ឬក៏ពពែរបស់យើងទេ។ ទ្រង់អាចបង្កើតភ្នំលុយ បើសិនជាទ្រង់ចង់។ ទ្រង់ចង់ឲ្យយើងថ្វាយដង្វាយ១ភាគ១០ទៅ

ទ្រង់វិញ ពីព្រោះទ្រង់ជ្រាបថា ការធ្វើបែបនោះគឺល្អសម្រាប់យើង។ វារំឭកដាស់តឿនយើងថា ទ្រង់គឺជាអ្នកផ្តល់ឲ្យនូវរបស់គ្រប់យ៉ាងដែលយើងមាន។ វាបង្ហាញថា យើងបានសម្រេចចិត្តស្រឡាញ់ទ្រង់ និងស្តាប់បង្គាប់ទ្រង់។ វាគឺជារបៀបនៃការនិយាយ "អរព្រះគុណទ្រង់" សម្រាប់គ្រប់យ៉ាងដែលទ្រង់បានធ្វើសម្រាប់យើង។



តើគេប្រើដង្វាយ១០ភាគរយដូចម្តេច? កាលនៅក្នុងសម័យព្រះគម្ពីរ មានសង្ឃជាច្រើន បានលះបង់ជីវិតរបស់ពួកទ្រង់ដើម្បីការងាររបស់ព្រះជាម្ចាស់នៅឯព្រះវិហារ។ ដង្វាយ១០ភាគរយ គឺត្រូវបានផ្តល់ឲ្យពួកទ្រង់សម្រាប់ផ្គត់ផ្គង់ក្រុមគ្រួសារ។ សព្វថ្ងៃនេះ ដង្វាយ១០ភាគរយ គឺប្រើស្រដៀងគ្នានេះដែរ។

យើងមិនមានសង្ឃធ្វើការនៅក្នុងព្រះវិហារ។ តែយើងមានគ្រូគង្វាលដែលជាអ្នកលះបង់ជីវិតដើម្បីបង្រៀន និងអធិប្បាយ ហើយជួយផ្គត់ផ្គង់ដល់សមាជិកព្រះវិហារ។ ពួកគាត់ទទួលបានប្រាក់ខែពីដង្វាយ១០ភាគរយ ដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគាត់។

នៅពេលដែលយើងថ្វាយដង្វាយ១០ភាគរយទៅព្រះជាម្ចាស់ គឺគ្រាន់តែជាការថ្វាយនូវរបស់ដែលជារបស់ទ្រង់រួចទៅហើយ។ វាគឺជាវិធីមួយដែលបង្ហាញអំពីការអរព្រះគុណទ្រង់។ វិធីមួយទៀត គឺជាការថ្វាយទៅទ្រង់វិញលើសពី១០ភាគរយ។ ចំនួនបន្ថែមនេះហៅថា "ដង្វាយសទ្ធា"។ ដង្វាយសទ្ធា ជួយការងារព្រះវិហារសម្រាប់ផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូ ហើយនិងនគរដែលនឹងមកដល់របស់ទ្រង់។ ព្រះបន្ទូលរបស់ទ្រង់ ចែងថា ៖

"ចូរឲ្យទៅគេ នោះនឹងបានមកអ្នកដែរ គេនឹងវាល់ឲ្យអ្នកយ៉ាងល្អ ទាំងញាត់ ទាំងរលាក់ ហើយដាក់ឲ្យហៀរ..." (លូកា ៦:៣៨)។

មិត្តអើយ យើងមិនអាចថ្វាយទៅព្រះច្រើនលើសជាងទ្រង់ផ្តល់ឲ្យយើងឡើយ។ កាលណាយើងថ្វាយទៅទ្រង់កាន់តែច្រើន ទ្រង់កាន់តែប្រទានពរដល់យើង។



ពិតណាស់ មានមនុស្សខ្លះដែលមិនចង់លះបង់លុយកាក់ ឬក៏ទ្រព្យសម្បត្តិ។ ព្រះយេស៊ូបានប្រាប់អំពីរឿងរបស់បុរសម្នាក់ដែលមានលក្ខណៈបែបនោះ។ គាត់គឺជាកសិករដែលខិតខំធ្វើការ ហើយទទួលបានផលច្រើន។ ជង្រុករបស់គាត់មិនធំល្មមគ្រប់គ្រាន់សម្រាប់ទុកដាក់គ្រាប់ពូជទាំងអស់នោះទេ។ តើគាត់គួរចែករំលែកផល ដែលគាត់ប្រមូលបានជាមួយនឹងអ្នកក្រីក្រ ដែរឬទេ? តើគាត់គួរតែថ្វាយដង្វាយ ១០ភាគរយ និងដង្វាយសទ្ធាបន្ថែមទៀត ដែរឬទេ? គាត់គិតចុះឡើងនៅក្នុងចិត្ត គំនិតរបស់គាត់។

នៅទីបំផុត កសិករនោះបាននិយាយថា "អត់ទេ។ ផលដែលប្រមូលបានយ៉ាងច្រើននេះជារបស់ខ្ញុំ ផលទាំងអស់គឺជារបស់ខ្ញុំ។ តើខ្ញុំមិនគិតគួរឲ្យបានត្រឹមត្រូវទេឬ? តើខ្ញុំមិនបានខំប្រឹងសម្រាប់ផលទាំងអស់នេះទេឬ?"

នេះគឺជាអ្វីដែលគាត់បានសម្រេចចិត្តធ្វើ ៖

"ទើបយល់ថា អញត្រូវធ្វើយ៉ាងនេះ គឺអញនឹងរុះជង្រុកអញ ពង្រីកឲ្យធំជាងទៅទៀត រួចប្រមូលផល នឹងទ្រព្យសម្បត្តិទៅផ្ទុកនៅទីនោះ។ នោះអញនឹងប្រាប់ ដល់ចិត្តថា ចិត្តអើយ ឯងមានទ្រព្យសម្បត្តិជាច្រើនល្មមទុកសម្រាប់ជាយូរឆ្នាំទៅមុខទៀតបានហើយ ចូរឯងឈប់សម្រាកទៅ ហើយស៊ីផឹកសប្បាយចុះ។"

ព្រះគម្ពីរប្រាប់ពីរបៀបដែលព្រះយេស៊ូបានបញ្ចប់រឿង ៖ "ប៉ុន្តែ ព្រះទ្រង់មានព្រះបន្ទូលទៅអ្នកនោះថា ឱមនុស្សល្ងីល្ងើអើយ នៅវេលាយប់នេះឯង អញនឹងដកយកព្រលឹងឯងទៅវិញ ដូច្នេះតើទ្រព្យសម្បត្តិទាំងប៉ុន្មានដែលឯងបានប្រមូលទុកនេះ នឹងទៅជារបស់អ្នកណាវិញ?"

"អ្នកណាដែលប្រមូលទ្រព្យសម្បត្តិ ទុកបម្រុងតែខ្លួនឯង តែឥតមានខាងឯព្រះសោះ នោះក៏ដូច្នោះដែរ" (លូកា ១២:១៨-២១)។

ព្រះយេស៊ូបានទូលសួរសាវ័ករបស់ទ្រង់អំពីសំណួរនេះ ៖ "ដ្បិតបើមនុស្សណានឹងបានលោកិយទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់ អ្នកនោះ ឬតើមនុស្សនឹងយកអ្វីទៅដូរឲ្យបានព្រលឹងខ្លួនវិញ?" (ម៉ាថាយ ១៦:២៦)។

---



ជីវិតរបស់យើង គឺជាអំណោយមកពីព្រះជាម្ចាស់។

សុខភាពរបស់យើង គឺជាអំណោយមកពីព្រះជាម្ចាស់។

គ្រប់ដង្ហើមដែលយើងដក ក៏ជាអំណោយមកពីព្រះជាម្ចាស់ដែរ។

អាហារដែលយើងញ៉ាំ សម្លៀកបំពាក់ដែលយើងស្លៀកពាក់ ផ្ទះដែលយើងរស់នៅ គឺជាអំណោយមកពីព្រះជាម្ចាស់។ គ្រប់យ៉ាងដែលយើងមាន គឺជាអំណោយមកពីព្រះ។

កាលណាយើងថ្វាយទៅទ្រង់វិញ យើងនិយាយថា "អរព្រះគុណព្រះជាម្ចាស់ នូវអ្វីដែលទ្រង់បានប្រទានឲ្យដល់ទូលបង្គំ។"

តើអ្នកចង់និយាយថា "ព្រះអម្ចាស់ អរព្រះគុណទ្រង់ចំពោះគ្រប់យ៉ាងដែលទ្រង់បានប្រទានឲ្យទូលបង្គំ" ដែរឬទេ? តើអ្នកនឹងសម្រេចចិត្តក្នុងពេលឥឡូវនេះ នៅត្រង់នេះ ថាថ្វាយដង្វាយ១០ភាគរយរបស់ទ្រង់ចេញពីផលដែលអ្នករក បានដែរឬទេ? បើសិន នោះជាការសម្រេចចិត្តរបស់អ្នក តើអ្នកនឹងលើកដៃឡើងជាមួយនឹងខ្ញុំ ពេលដែលយើងអធិស្ឋានដែរឬទេ?

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ ពួកទូលបង្គំសូមទទួលទ្រង់ជាព្រះអទិករដែលបង្កើតគ្រប់យ៉ាង ហើយជាព្រះដែលបានសុគតសម្រាប់អំពើបាបរបស់យើង។ គ្រប់យ៉ាងដែលយើងមាន គឺបានមកពីទ្រង់។ អរព្រះគុណទ្រង់! ពួកទូលបង្គំចង់យកដង្វាយ ១០ភាគរយរបស់ពួកទូលបង្គំ ហើយនិងដង្វាយសទ្ធាថ្វាយទៅទ្រង់ ហើយពួកទូលបង្គំចង់ថ្វាយពេលវេលា សមត្ថភាព កំលាំងថាមពល ហើយនិងសុខភាពទៅឯទ្រង់។ សូមទ្រង់ជួយពួកទូលបង្គំធ្វើជាអ្វីគ្រប់យ៉ាង ដែលទ្រង់ចង់ឲ្យពួកទូលបង្គំធ្វើ។ ពួកទូលបង្គំទូលសូមគ្រប់កិច្ចការនៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ ៖

លោកុប្បត្តិ ១:២៨,២៩
កិច្ចការ ១០:៣៨
ម៉ាថាយ ៦:៣១-៣៣
ម៉ាឡាគី ៣:៨,១០
លោកុប្បត្តិ ២៨:១២,២២
កូរិនថូសទី១ ៩:១៣,១៤
ទំនុកតម្កើង ២៤:១
លោកុប្បត្តិ ២:៨,១៥,១៦-១៧
រ៉ូម ១២:១
ម៉ាថាយ ១៦:២៦
ម៉ាថាយ ៤:៨,៩
ជនគណនា ១៨:២១
ម៉ាថាយ ៦:២១,២៦
ទំនុកតម្កើង ៩០:១២
លោកុប្បត្តិ ១៤:២០
កូរិនថូសទី១ ៤:២,៧
ម៉ាថាយ ២៣:២៣

## លំនាំពិភាក្សា

**ជំងឺបេះដូង គឺជាឃាតកររលេខ១ក្នុងពិភពលោក**

១. ការញុំាអាហារដែលមិនល្អ អាចធ្វើឲ្យបេះដូងរបស់អ្នកខូចបាន។ តើអាហារអ្វីខ្លះដែលមិនល្អចំពោះបេះដូង?
២. តើទម្លាប់រស់នៅដូចម្តេចដែលអាចធ្វើឲ្យបេះដូងខូច?
៣. តើអាហារអ្វីដែលជាអាហារដែលមានសុខភាពល្អរបស់ព្រះជាម្ចាស់?

**ប្រាក់កាស និងទ្រព្យសម្បត្តិរបស់យើង**

១. តើអំណោយល្អអស្ចារ្យអ្វីខ្លះដែលយើងទទួលបានមកពីព្រះអទិកររបស់យើងជារៀងរាល់ថ្ងៃ?
- កិច្ចការ ១៧:២៨ - យ៉ូហាន ៣:១៦

២. តើអ្វីៗគ្រប់យ៉ាងពិតជាកម្មសិទ្ធិរបស់យើងឬ?
- ទំនុកតម្កើង ៥:១០,១១ - ចោទិយកថា ៨:១៨

៣. តើគម្រោងការអ្វីរបស់ព្រះ ដើម្បីជួយយើងឲ្យចងចាំអំពីទ្រង់នៅក្នុងជីវិតរបស់យើង?
- លេវីវិន័យ ២៧:៣០ - ម៉ាឡាគី ៣:១០

៤. តើរង្វាន់អ្វីសម្រាប់អស់អ្នកដែលមានចិត្តសប្បុរសចំពោះព្រះជាម្ចាស់?
- លូកា ៦:៣៨

៥. តើអ្វីដែលល្អប្រសើរ ការសំចៃទុកទ្រព្យសម្បត្តិនៅទីនេះ ហើយបាត់បង់នគរឋានសួគ៌រួមជាមួយនឹងព្រះអម្ចាស់ ឬក៏ចែករំលែកឲ្យដោយចិត្តសប្បុរសនៅទីនេះ ហើយទទួលបានជីវិតអស់កល្បជាមួយនឹងព្រះជាម្ចាស់?
- ម៉ាថាយ ១៦:២៦

# មេរៀនសុខភាពទី២១ - ជំងឺដែលកើតឡើងដោយសារសត្វមូស




១. សត្វមូស គឺជាប្រភេទសត្វល្អិតដែលបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុតនៅក្នុងពិភពលោក។ ពួកវាគ្រោះថ្នាក់ជាងសត្វតោ ឆ្កែឆ្កួត និងហ្វូងដំរីទៅទៀត ហើយពួកវាពិបាកគ្រប់គ្រងណាស់។ នៅក្នុងចំណោមសត្វមូស៣០០០ប្រភេទ មាន ៣ប្រភេទដែលផ្ទុក និងចំលងជំងឺទៅមនុស្ស ធ្វើឲ្យមនុស្សរាប់លាននាក់ស្លាប់ជារៀងរាល់ឆ្នាំ។

សត្វមូសខាំ គឺពិតជាលើសពីខាំទៅទៀត។ ទ្រនិចម្ជុលរបស់វាមានពីរបណ្តាញ មួយគឺដើម្បីចាក់ទឹកមាត់ចូលទៅក្នុងស្បែក ហើយមួយទៀតជញ្ជក់បឺតឈាមរបស់អ្នក។ ពួកវាបឺតយកមេរោគបង្កជំងឺ នៅពេលដែលវាខាំ និងបឺតជញ្ជក់យកឈាមពីអ្នកជំងឺ។ បន្ទាប់មក វាក៏ចម្លងជំងឺនោះនៅពេលដែលវាចាក់បញ្ចូលទឹកមាត់របស់វាចូលទៅជនរងគ្រោះដែលវាខាំបន្ទាប់។

សត្វមូសអាចផ្ទុកជំងឺបានច្រើននៅក្នុងទឹកមាត់របស់វា ដូចជាគ្រុនឈឿង គ្រុនចាញ់ ឈីយុនហ្គូញ៉ាហ្វ៊ីកា គ្រុនវែស្ទណាល ហ្វីឡារ៉ាយអាស៊ីស អិនសេហ្វាលីធិស (រោគរលាកខួរក្បាល) និងជំងឺគ្រុនឈាម។ ជំងឺនីមួយៗនេះ គឺមានលក្ខណៈធ្ងន់ធ្ងរ ហើយអាចគ្រោះថ្នាក់ដល់ជីវិត ជាពិសេស ចំពោះកុមារ និងមនុស្សដែលមានវ័យចាស់ជរា។

តើជំងឺទាំងនេះអាចបង្កាបានដោយរបៀបណា? គួរឲ្យសោកស្តាយ គ្មានថ្នាំព្យាបាលធម្មជាតិបែបសាមញ្ញឡើយ។

ការចាក់ថ្នាំបង្កា គឺជាដំណោះស្រាយមួយចំណែក។ ថ្នាំបង្កាទាំងនោះមានសម្រាប់ ជំងឺគ្រុនឈឿង និងជំងឺគ្រុនឈាម។ មានថ្នាំបង្កាមួយទៀតដែលគេរំពឹងនឹងបានឆាប់ៗសម្រាប់ជំងឺឈីយុនហ្គូញ៉ា។ ថ្នាំ បង្កាសម្រាប់ជំងឺគ្រុនចាញ់ គឺត្រូវបានធ្វើតេស្តសាកល្បងនៅក្នុងទ្វីបអាហ្វ្រិក។ សូមសួរគ្រូពេទ្យរបស់អ្នក អំពីថ្នាំចាក់បង្កា ឬក៏ថ្នាំលេបការពារក្រុមគ្រួសាររបស់អ្នក បើសិនជាជំងឺទាំងនេះមាននៅក្នុងតំបន់របស់អស់លោកអ្នក។

…………………………………………………………………………………………………………………….........
.

២. **របៀបការពារប្រឆាំងនឹងសត្វមូស ៖**

វិធីបង្កាដែលល្អបំផុត គឺចៀសវាងកុំឲ្យមូសខាំ។ កាលណាវាខាំកាន់តែតិច ឱកាសកើតជំងឺកាន់តែតិច។

**នៅខាងក្រៅ – កំចាត់ និងគ្រប់គ្រងការបង្កាត់កូនរបស់វា**

សីតុណ្ហភាព និងភ្លៀងមានឥទ្ធិពលទៅលើសមត្ថភាពនៃការបង្កាត់ពូជរបស់មូស។ កន្លែងណាដែលទឹកនៅនឹង ជាកន្លែងសម្រាប់មូសបង្កាត់ពូជបង្កើតកូនចៅ។

- កំចាត់តំបន់ដែលមានទឹក ងាយសម្រាប់មូសបង្កាត់ពូជ
- លុបបំបាត់អន្លូង ឬក៏ស្រះដែលមានទឹកមិនហូរ ឬក៏ចាក់ប្រេងបន្តិចទៅលើផ្ទៃទឹក ដើម្បីឲ្យមូសមិនអាចរស់បាន។

- បង្ហូរទឹកចេញពីអន្លូង កំប៉ុង សំបក(កង់ ឡាន ម៉ូតូ) អ្វីដែលដក់ទឹកនៅជុំវិញផ្ទះរបស់អ្នកគ្រប់ពេល ដែលភ្លៀងរួចរាល់។ ត្រូវដកយកចេញ ឬក៏ចាក់ទឹកចេញដើម្បីកុំឲ្យមានទឹកដក់។
- ចាក់ដីខ្សាច់បំពេញនៅក្នុងបំពង់ឬស្សីដែលចំហ។

…………………………………………………………………………………………………………………………………………........
.

៣. - ពេលនៅខាងក្រៅ ចូរស្លៀកសម្លៀកបំពាក់ដែលគ្របជិតដៃ និងជើង ហើយប្រើថ្នាំកំចាត់មូស(មិនពុលដល់មនុស្ស)បាញ់នៅលើសម្លៀកបំពាក់ ការពារកុំឲ្យវាខាំ។

- សហការជាមួយនឹងអ្នកធ្វើការកំចាត់ជំងឺគ្រុនចាញ់ នៅពេលដែលពួកគេមកភូមិរបស់អ្នកដើម្បីបាញ់ថ្នាំ។ ចូរប្រាប់ពួកគេ បើសិនជាមានអ្នកណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកកើតជំងឺគ្រុនក្តៅ ហើយត្រូវធ្វើតេស្តឈាមរោគមេរោគគ្រុនចាញ់។ សូមលើកទឹកចិត្តដល់អ្នកជិតខាងរបស់អ្នកឲ្យធ្វើដូចគ្នា។

…………………………………………………………………………………………………………………………………………........
.

៤. នៅខាងក្នុងផ្ទះ – ការពារផ្ទះរបស់អ្នកពីសត្វមូស

- ដាក់កន្លែងគេង នៅត្រង់កន្លែងដែលគ្មានសត្វមូស។
- ប្រើមុងដែលមានថ្នាំកំចាត់សត្វមូសសម្រាប់គ្រួសារទាំងមូល។
- ត្រូវគ្របគ្រែកូនង៉ែតជាមួយនឹងក្រណាត់ស្តើង ឬក៏មុងគ្របនៅក្នុងពេលថ្ងៃ។
- ដាក់សំណាញ់នៅតាមបង្អួច និងទ្វារ ឬក៏សំណាញ់ជ្រលក់ថ្នាំកំចាត់មូស។

…………………………………………………………………………………………………………………………………………........

៥. - ដុតធូបមូសនៅពេលល្ងាច បិទទ្វារ ហើយចាំយ៉ាងហោចណាស់១ម៉ោង មុននឹងចូលទៅគេងនៅក្នុងបន្ទប់។

- រៀងរាល់យប់ មុននឹងគេង ត្រូវគោះ ឬរលាស់ក្រណាត់នៅក្រោមគ្រែ ក្រោមតុ និងទូ ជាកន្លែងដែលមូសពួនសំងំ។ ចូរដេញវាចេញ ហើយសម្លាប់វា!

- ចៀសវាងនៅខាងក្រៅផ្ទះពេលព្រលប់ ដល់ពេលព្រលឹម ព្រោះជាពេលដែលមូសចេញរកស៊ីច្រើនបំផុត។

វិធីព្យាបាលដែលល្អបំផុត គឺការការពារ ប៉ុន្តែ បើអ្នកឆ្លងជំងឺពីសត្វមូស ចូរព្យាបាល! រោគសញ្ញាភាគច្រើន គឺ គ្រុនក្តៅ រងារញាក់ ឈឺខ្លួន ឈឺក្បាល និងឈឺសន្លាក់។

…………………………………………………………………………………………………………………………………………........

៦. ជំងឺគ្រុនចាញ់

ជំងឺគ្រុនចាញ់ គឺជាជំងឺដែលបង្កដោយសត្វមូស សម្លាប់មនុស្សច្រើនជាងគេបំផុតនៅក្នុងពិភពលោក។ កុមារជាង១០០០នាក់ស្លាប់ជារៀងរាល់ថ្ងៃពីជំងឺគ្រុនចាញ់។ មនុស្សធំពេញវ័យដែលរស់នៅក្នុងតំបន់ដែលមានជំងឺគ្រុនចាញ់ អាចបង្កើតអង់ទីករដែលមានកម្រិតប្រឆាំងនឹងមេរោគគ្រុនចាញ់ ប៉ុន្តែ កុមារ និងកូនង៉ែតមិនអាចបង្កើតអង់ទីករបានទេ។ ជំងឺគ្រុនចាញ់ ធ្វើឲ្យស្ត្រីមានផ្ទៃពោះប្រឈមនឹងការកើតជំងឺខ្វះឈាមក្រហមខ្ពស់ កើតមុនពេលកំណត់ ឬក៏កើតកូនដែលស្លាប់។

ជំងឺគ្រុនចាញ់បំផ្លាញកោសិកាឈាមក្រហម ធ្វើឲ្យចំនួនអុកស៊ីហ្សែនដែលទ្រទ្រង់ជីវិត ដែលត្រូវនាំទៅកាន់កោសិកានោះថយចុះ។ លទ្ធផល គឺធ្វើឲ្យអ្នកជំងឺកើតជំងឺខ្វះឈាមក្រហម។ បើគ្មានអុកស៊ីហ្សែន កោសិការាងកាយមិនអាចធ្វើការបានល្អបំផុត។ ខួរក្បាលខ្វះអុកស៊ីហ្សែនដែលវាត្រូវការ ធ្វើឲ្យការចម្រើនលូតលាស់ ការគិត និងការរៀនសូត្រមានការលំបាក ជាពិសេស ចំពោះកុមារ។

រោគសញ្ញានៃជំងឺខ្វះឈាមមានដូចជា៖ ស្លេកអញ្ចាញធ្មេញ ក្រចកដៃ និងស្បែក ខ្សោយ និងអស់កំលាំង។ បើមានរោគសញ្ញាណាមួយលេចឡើងដំបូង ចាំបាច់ត្រូវព្យាបាលជាបន្ទាន់។ គ្រូពេទ្យ ឬអ្នកធ្វើការផ្នែកសុខភាព អាចផ្តល់ការព្យាបាលបង្ការកុំឲ្យកើតជំងឺ ដូចជាផ្តល់ថ្នាំប្រឆាំងនឹងមេរោគគ្រុនចាញ់ ហ្វូឡិក អាស៊ីត ថ្នាំជាតិដែក និងវីតាមីន ហើយនិងថ្នាំប្រឆាំងនឹងមេរោគគ្រុនចាញ់នៅក្នុងរដូវភ្លៀងធ្លាក់។

ដំណឹងល្អនោះគឺថា ជំងឺគ្រុនចាញ់ត្រូវបានគ្រប់គ្រង និងកំចាត់ចោលនៅតាមប្រទេសខ្លះ។ ជំងឺដ៏អាក្រក់នេះអាចព្យាបាលបាន ដោយការប្រើវិធីបង្ការ និងការព្យាបាលឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីបញ្ឈប់កុំឲ្យជំងឺនេះកើតឡើងវិញច្រំដែលៗ។

កាលសម័យនៃការបង្កើត ព្រះជាម្ចាស់បានមានព្រះបន្ទូលថា គ្រប់យ៉ាងដែលទ្រង់បានបង្កើត គឺសុទ្ធតែល្អ។ ប៉ុន្តែ អំពើបាបបានកែប្រែទាំងមនុស្ស ហើយនិងធម្មជាតិ។ ជំងឺ ហើយនិងក្តីទុក្ខលំបាកមិនមាននៅក្នុងសួនអេដែនឡើយ ហើយក៏មិនកើតមាននៅលើផែនដីថ្មីដែរ។ ព្រះជាម្ចាស់សន្យាថា ទ្រង់នឹងជូតទឹកភ្នែកចេញពីភ្នែកយើងទាំងអស់គ្នា ហើយនឹងគ្មានសេចក្តីស្លាប់ សេចក្តីសោកសង្រេង ឬក៏សេចក្តីទួញយំទៀតឡើយ។ នឹងគ្មានការឈឺចាប់ទៀតឡើយ ដ្បិតសេចក្តីទាំងអស់នេះ នឹងបានកន្លងបាត់ទៅជារៀងរហូត (វិវរណៈ ២១:៤)។ តើអ្នកមិនចង់ទៅទីនោះទេឬ?

## ព្រះវិញ្ញាណនៃបទទំនាយ



កាលឪពុកម្តាយដើមដំបូងរបស់យើងរស់នៅក្នុងសួនអេដែន ពួកគាត់គឺជាមនុស្សល្អ ហើយឥតខ្ចោះ និងជាមនុស្សស្អាតស្អំ។ ពួកគាត់អាចជួបព្រះទល់មុខនឹងមុខបាន ហើយអាចនិយាយជាមួយនឹងទ្រង់បាន ដូចអ្នកនឹងខ្ញុំអាចនិយាយជាមួយគ្នាបានដូច្នោះដែរ។ ពួកគេអាចសម្លឹងមើលព្រះនេត្រទ្រង់ ហើយស្តាប់ព្រះសូរសៀងរបស់ទ្រង់ប្រាប់ពួកគាត់ថា ទ្រង់ស្រឡាញ់ពួកគាត់ខ្លាំងប៉ុណ្ណា។

ព្រះគម្ពីរចែងថា "ដ្បិតព្រះនៃយើងរាល់គ្នា ទ្រង់ជាភ្លើងដែលឆេះបន្សុស" (ហេព្រើរ ១២:២៩)។

ប៉ុន្តែ មិនមែនសម្រាប់អាដាម និងអេវ៉ាទេ។ ពួកគាត់បរិសុទ្ធខ្លាំងណាស់ ដែលពួកគាត់អាចនៅក្នុងភ្លើងបន្សុសនោះ នៅក្បែរទ្រង់។ ពួកគាត់ចង់នៅក្នុងព្រះវត្តមានរបស់ទ្រង់នៅពេលដែលទ្រង់យាងមកលេងជាមួយនឹងពួកគាត់នៅក្នុងសួនអេដែនជារៀងរាល់ថ្ងៃ។

ការនេះមិនអាចទៅរួចចំពោះអ្នក ឬក៏ខ្ញុំឡើយ។ យើងមិនមែនមនុស្សបរិសុទ្ធ ឬក៏ស្អាតស្អំឡើយ តើមែនទេ? យើងមានបាបពីធម្មជាតិអញ្ចឹងហើយ យើងដូចជាស្មៅស្ងួតដែលអាចឆាប់ឆេះបាន។ បើសិនជាយើងសុំឲ្យព្រះអនុញ្ញាតឲ្យយើងមើលឃើញព្រះភ័ក្ត្រទ្រង់ ទ្រង់នឹងប្រាប់យើងដូចអ្វីដែលទ្រង់បានប្រាប់ហោរារបស់ទ្រង់ គឺលោកម៉ូសេដែរថា៖

“ឯងពុំអាចនឹងមើលមុខអញបានឡើយ ដ្បិតមនុស្សជាតិនឹងឃើញអញ ហើយរស់នៅមិនបានទេ” (និក្ខមនំ ៣៣:២០)។

.....................................................................................................................



តើមានអ្វីដែលបានប្រែប្រួល តាំងពីសម័យកាលដ៏ល្អនោះមក ពេលដែលអាដាម និងអេវ៉ាបានទៅរស់នៅក្នុងសួនអេដែន? ព្រះគម្ពីរចែងថា ៖

“គឺជាអំពើទុច្ចរិតរបស់ឯងរាល់គ្នា ដែលបានខណ្ឌជាកណ្ដាលឯង ហើយនឹងព្រះនៃឯងទេតើ” (អេសាយ ៥៩:២)។

នោះហើយ គឺជាហេតុការណ៍ដែលបានកើតឡើង។ អាដាម និងអេវ៉ាបានប្រព្រឹត្តអំពើបាប។ ពួកគាត់មិនស្ដាប់តាមការបង្គាប់របស់ព្រះជាម្ចាស់។ ពួកគាត់បានញ៉ាំផ្លែពីដើមដឹងខុសត្រូវ (ជាដើមដែលព្រះបានហាមឃាត់)។ អំពើបាបបានធ្វើឲ្យខូចអត្តចរិតរបស់ពួកគាត់។ ពួកគាត់លែងអាចរស់នៅក្នុងព្រះវត្តមានរបស់ព្រះបានតទៅទៀតហើយ។ ទ្រង់មិនបានប្រឆាំងជំទាស់នឹងពួកគាត់ទេ។ ពួកគាត់ទេដែលបានប្រឆាំងជំទាស់នឹងទ្រង់នោះ។

ខ្ញុំគិតថា ព្រះជាម្ចាស់ខូចព្រះទ័យ ដោយឃើញពួកគាត់ចាកចេញពីសួនទៅ។ ទ្រង់បានបង្កើតពួកគាត់ ដើម្បីប្រកបគ្នាជាមួយនឹងអង្គទ្រង់។ ទ្រង់ស្រឡាញ់ពួកគាត់។ ទ្រង់សព្វព្រះទ័យនឹងចំណាយពេលជាមួយនឹងពួកគាត់។ ឥឡូវ ពួកគាត់បានចេញទៅបាត់ហើយ។ ទ្រង់ពិតជាពិបាកព្រះទ័យខ្លាំងណាស់ហើយមើលទៅ ដែលឲ្យពួកគាត់ចេញទៅ។

.....................................................................................................................



ប៉ុន្តែ ទ្រង់មិនអាចឲ្យអំពើបាបកាត់ផ្ដាច់ទ្រង់ចេញពីកូនចៅជាមនុស្សរបស់ទ្រង់ទាំងស្រុងបានឡើយ។ ទោះបីជាទ្រង់មិនអាចទៅលេង ឬជួបពួកគាត់ផ្ទាល់ទល់មុខនឹងមុខក៏ដោយ ទ្រង់ក៏អាចទាក់ទងជាមួយនឹងពួកគាត់តាមរយៈពួកទេវតា តាមរយៈការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយក៏អាចតាមរយៈមនុស្សប្រុស និងមនុស្សស្រីដែលបរិសុទ្ធ ដែលជាហោរាបានដែរ។ សូមស្ដាប់ ៖

“ព្រះបានមានព្រះបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធរបស់ទ្រង់ តាំងពីបុរាណមក” (កិច្ចការ ៣:២១)។

ព្រះគម្ពីរចែងប្រាប់យើងពីរឿងនេះថា ៖

“ពិតប្រាកដជាព្រះយេហូវ៉ា ទ្រង់នឹងមិនធ្វើអ្វីដូច្នោះឡើយ លើកទ្រង់សំដែងឲ្យពួកហោរាជាអ្នកបម្រើទ្រង់ ឃើញគំនិតលាក់កំបាំងរបស់ទ្រង់ផង” (អេម៉ុស ៣:៧)។

ពួកហោរា មិនបានប្រឌិតសារឡើងដោយខ្លួនឯងនោះទេ។ សូមស្ដាប់ ៖

“ដ្បិតសេចក្ដីទំនាយមិនដែលមកដោយបំណងចិត្តមនុស្សទេ គឺជាមនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្ដាលវិញ” (ពេត្រុសទី២ ១:២១)។

តើសារអ្វីទៅ ដែលព្រះបានបញ្ជូនមកតាមរយៈពួកហោរានោះ? សូមស្តាប់អំពីរឿងនេះ ចេញពីព្រះគម្ពីរសញ្ញាចាស់នៃសៀវភៅហាកាយ ៖

“នោះហាកាយ ជាទូតរបស់ព្រះយេហូវ៉ា លោកប្រាប់ដល់បណ្ដាជនតាមព្រះបន្ទូលដែលព្រះយេហូវ៉ាទ្រង់បង្គាប់មក គឺព្រះយេហូវ៉ា ទ្រង់មានព្រះបន្ទូលថា អញនៅជាមួយនឹងឯងរាល់គ្នា” (ហាកាយ ១:១៣)។

តើអ្នកចង់ស្តាប់សារដូចនោះពីព្រះវរបិតារបស់អ្នកនៅឯនគរឋានសួគ៌ ដែរឬទេ?

ជួនកាលពួកហោរានាំសារព្រមានដាស់តឿនមកឲ្យ។ សូមស្តាប់ ៖

“ប៉ុន្តែ អញបានចាត់ពួកហោរាទាំងប៉ុន្មាន ជាអ្នកបម្រើរបស់អញឲ្យមក ឯងរាល់គ្នា គឺបានក្រោកពីព្រលឹមស្រាង ដើម្បីនឹងចាត់គេផង ដោយពាក្យថា ឱសូមកុំធ្វើការគួរខ្ពើមដែលអញស្អប់នេះឡើយ” (យេរេមា ៤៤:៤)។

ពួកហោរាផ្សេងទៀត ដូចជាលោកដានីយ៉ែល និងលោកយ៉ូហានបានសុបិននិមិត្ត ឃើញព្រឹត្តិការណ៍នាពេលអនាគត ដើម្បីឲ្យពួកគាត់អាចជួយយើង ឲ្យរៀបចំសម្រាប់អ្វីដែលកើតមានឡើងនាពេលខាងមុខ ហើយដើម្បីឲ្យយើងអាចមើលឃើញព្រះហស្តរបស់ព្រះធ្វើការពេញប្រវត្តិសាស្ត្ររបស់ពិភពលោកនេះ។

ថ្វីបើហោរាបាននិយាយដោយសំលេងផ្សេងៗគ្នាក៏ដោយ ក៏សារទាំងអស់ដែលព្រះបានប្រទានមកឲ្យពួកគាត់ត្រូវគ្នានឹងផ្ទៃរឿងដ៏ធំមួយ ៖ ក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះអ្នកមានបាប និងគម្រោងការរបស់ទ្រង់ជួយសង្គ្រោះពួកគាត់តាមរយៈការលះបង់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូគ្រីស្ទ។

---



ប្រាកដហើយ ព្រះយេស៊ូអង្គឯងក៏ជាហោរា ហើយលើសពីហោរាទៅទៀត។ ទ្រង់គឺជាអ្នកនាំសារដ៏ល្អឥតខ្ចោះមកពីព្រះវរបិតា។ ទ្រង់បានបង្ហាញក្តីស្រឡាញ់របស់ព្រះចំពោះអ្នកមានបាប ដែលគ្មានអ្នកណាអាចធ្វើបាន។ ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង គឺជាអ្វីដែលធ្វើឲ្យយើងអាចទទួលបានសេចក្តីសង្គ្រោះ។

កាលព្រះយេស៊ូបានយាងទៅកាន់នគរឋានសួគ៌ ទ្រង់បានទុកឲ្យក្រុមជំនុំរបស់ទ្រង់បន្តធ្វើការងារដែលទ្រង់បានចាប់ផ្តើមរួចហើយ។ ទ្រង់បានបញ្ជូនអំណោយនៃព្រះវិញ្ញាណរបស់ទ្រង់ ដើម្បីផ្តល់កំលាំងថាមពលដល់អ្នកដើរតាមទ្រង់ឲ្យធ្វើការងារ។ ព្រះវិញ្ញាណបានផ្តល់អំណោយខាងបទទំនាយទៅកាន់ក្រុមជំនុំ ដើម្បីឲ្យព្រះជាម្ចាស់អាចបន្តបញ្ជូនសាររបស់ទ្រង់ទៅកាន់កូនចៅរបស់ទ្រង់នៅឯផែនដី។

ជិតពីរពាន់ឆ្នាំបានកន្លងផុតទៅហើយ ចាប់តាំងពីពេលនោះមក។ យើងនឹងនៅតែមានសារដែលព្រះជាម្ចាស់បានបញ្ជូនមកតាមរយៈហោរារបស់ទ្រង់ពីសម័យបុរាណដដែល។ វាមាននៅក្នុងព្រះគម្ពីរនេះឯង។ សារនោះនៅតែពិតដល់សព្វថ្ងៃនេះ។

អ្នកមុខជាកំពុងតែឆ្ងល់ហើយ ថាតើព្រះឈប់បញ្ជូនសារមកតាមរយៈពួកហោរាឬ។ តើទ្រង់មិនមានអ្វីបន្ថែមទៀតដើម្បីនិយាយមកពួកយើងទេឬ? តើទ្រង់នៅតែស្រឡាញ់ពួកយើងដែរឬទេ? ឬក៏ទ្រង់បានបំភ្លេចពួកយើងហើយ?

សូមស្តាប់សារដែលទ្រង់បានផ្តល់ឲ្យតាមរយៈហោរារបស់ទ្រង់ គឺលោកយ៉ូអែល ៖

"ក្រោយគ្រានោះ អញនឹងចាក់វិញ្ញាណរបស់អញទៅលើគ្រប់ទាំងមនុស្ស នោះកូនប្រុសស្រីរបស់ឯងនឹងទាយ ពួកចាស់ៗរបស់ឯងនឹងយល់សប្តិឃើញ ហើយពួកកំលោះៗរបស់ឯងនឹងឃើញការជាក់ស្តែង" (យ៉ូអែល ២:២៨)។

នៅក្នុងសុបិននិមិត្តរបស់លោកយ៉ូហានអំពីសម័យចុងបញ្ចប់ គាត់បានឃើញសាតាំងដែលជាសត្វនាគវាយប្រហារទៅលើក្រុមជំនុំរបស់ព្រះ។

"នាគក៏ខឹងនឹងស្ត្រីនោះ ហើយចេញទៅច្បាំងនឹងសំណល់ពូជនាងទាំងប៉ុន្មាន ជាពួកអ្នកដែលកាន់តាមបញ្ញត្តព្រះ ហើយមានសេចក្តីបន្ទាល់ពីព្រះយេស៊ូ" (វិវរណៈ ១២:១៧)។

សំណល់ពូជរបស់ស្ត្រីគឺជាក្រុមជំនុំពិតនៅក្នុងសម័យចុងបញ្ចប់ គឺសម័យកាលរបស់យើង។ តើអ្វីទៅជា "ទីបន្ទាល់របស់ព្រះយេស៊ូគ្រីស្ទ"? មានទេវតាមួយរូបបានប្រាប់លោកយ៉ូហានថា៖

"ដ្បិតការធ្វើបន្ទាល់ពីព្រះយេស៊ូ នោះហើយជាវិញ្ញាណនៃសេចក្តីទំនាយ" (វិវរណៈ ១៩:១០)។

ដូច្នេះ ក្រុមជំនុំពិតរបស់ព្រះ គឺត្រូវបានស្គាល់ថាជាក្រុមជំនុំដែលរក្សាបញ្ញត្តរបស់ព្រះ ហើយជាក្រុមជំនុំដែលបានទទួលព្រះពរជាវិញ្ញាណនៃបទទំនាយ។

មានមនុស្សជាច្រើនបានតាំងខ្លួនជាហោរា។ ពួកគេបានអះអាងថានិយាយជួសឲ្យព្រះជាម្ចាស់។ ប៉ុន្តែ ចុះបើសិនជាពួកគេមិនមែនជាហោរាពិតនោះ។ ចុះបើសិនជាសាររបស់ពួកគេបានមកពីសាតាំងវិញនោះ?

ព្រះយេស៊ូបានព្រមានដាស់តឿនសាវ័ករបស់ទ្រង់អំពីរឿងនេះហើយ។ សូមស្តាប់៖

"ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយហោរាក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនិងការអស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឲ្យវង្វេងផង បើសិនជាបាន" (ម៉ាថាយ ២៤:២៤)។

ដោយសារតែយើងបានទទួលការព្រមានដាស់តឿនអំពីហោរាក្លែងក្លាយ យើងត្រូវតែដឹងអំពីភាពខុសគ្នារវាងហោរាក្លែងក្លាយ និងហោរាពិត។ ព្រះគម្ពីរចែងថា "កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹងជាមកពីព្រះ ឬមិនមែន ដ្បិតមានហោរាក្លែងក្លាយជាច្រើនកើតមកក្នុងលោកិយនេះហើយ" (យ៉ូហានទី១ ៤:១)។

តើយើង "ល្បងវិញ្ញាណ" យ៉ាងដូចម្តេចទៅ? ព្រះគម្ពីរចែងប្រាប់យើងថា៖

"យើងនឹងសំគាល់ព្រះវិញ្ញាណនៃព្រះបានដូច្នេះ គឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូគ្រីស្ទបានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយដែលមកពីព្រះ" (យ៉ូហានទី១ ៤:២)។

សារពិតរបស់ហោរា គឺត្រូវគ្នាជាមួយនឹងព្រះបន្ទូល ហើយនិងច្បាប់ ឬបញ្ញត្តរបស់ព្រះ។ (អេសាយ ៨:២០)

ការទស្សទាយរបស់ហោរាពិត ត្រូវតែបានបំពេញ (កើតឡើង)។ (យេរេមា ២៨:៩)

ការងាររបស់ហោរាពិត និងធ្វើឲ្យព្រះវិហាររីកចម្រើន។ (កូរិនថូសទី១ ១៤:៣,៤)

ជីវិតហោរាពិត នឹងផ្តល់ផលផ្លែល្អ។ (ម៉ាថាយ ៧:១៦)



ខ្ញុំសូមចែករំលែករឿងមួយជាមួយនឹងអ្នកអំពីរបៀបដែលព្រះបានប្រទានពរដល់ក្រុមជំនុំពិតរបស់ទ្រង់ដោយព្រះវិញ្ញាណនៃបទទំនាយនៅក្នុងសម័យកាលរបស់ពួកយើង។

មានការនិយមសាសនាមួយយ៉ាងធំ ដែលបានចាប់ផ្ដើមជិតពីរយឆ្នាំមុន នៅពេលសិស្សខ្លះដែលខិតខំប្រឹងប្រែងផ្ដោតអារម្មណ៍ទៅលើបទទំនាយរបស់លោកដានីញ៉ែល និងវិវរណៈ។ ពួកគាត់បានជឿជាក់ថា ការយាងមកជាលើកទី២របស់ព្រះយេស៊ូ គឺកាន់តែខិតជិតមកដល់ហើយ។ ការខិតខំសិក្សារៀនសូត្រយ៉ាងយកចិត្តទុកដាក់របស់ពួកគាត់បានធ្វើឲ្យពួកគាត់ជឿថា ព្រះយេស៊ូនឹងយាងមកជាមួយនឹងពពួកទេវតាជាច្រើននៅក្នុងឆ្នាំ១៨៤៤។

ពួកគាត់បានចាប់ផ្ដើមអធិប្បាយ និងបង្រៀនអំពីរឿងនេះ ហើយមានហ្វូងមនុស្សយ៉ាងច្រើនកុះករមកស្ដាប់។ មនុស្សរាប់ពាន់នាក់បានជឿលើសាររបស់ពួកគាត់ ហើយបានត្រៀមខ្លួនសម្រាប់ថ្ងៃដ៏អស្ចារ្យ នៅពេលដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញ។ ប៉ុន្តែ ពេលវេលាក៏បានមកដល់ ហើយក៏ហួសបាត់ទៅ ហើយព្រះយេស៊ូក៏មិនបានយាងមក។

អ្នកគិតទៅមើលថា អ្នកទាំងអស់នោះខកចិត្តខ្លាំងប៉ុណ្ណា។ ពួកគាត់ជឿជាក់យ៉ាងប្រាកដថា មិនយូរឡើយ ពួកគាត់នឹងបានទៅឯនគរឋានសួគ៌ជាមួយនឹងព្រះយេស៊ូ។ តែពួកគាត់បែរជានៅទីនេះដដែល គឺនៅក្នុងពិភពលោកដែលមានបាប។ អ្នកជិតខាងរបស់ពួកគាត់បានសើចចំអកឲ្យពួកគាត់ ហើយបានប្រាប់ពួកគាត់ថា ពួកគាត់ត្រូវបានចាញ់បោកឲ្យជឿថា ព្រះយេស៊ូពិតជានឹងយាងមកវិញ។

…………………………………………………………………………………………………….......



នៅក្នុងចំណោមអ្នកជឿដែលបានខកចិត្ត មានស្ត្រីវ័យក្មេងម្នាក់ឈ្មោះ អែលឡិន។ ព្រះជាម្ចាស់បានប្រទានសុបិននិមិត្តដើម្បីលើកទឹកចិត្តគាត់ ហើយនិងមនុស្សដទៃទៀតដែលបានជឿលើការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូ។ គាត់បានឃើញរាស្ត្ររបស់ព្រះដើរនៅក្នុងផ្លូវតូចចង្អៀតមួយ ខ្ពស់ពីលើលោកិយ។ ពួកគេកំពុងតែធ្វើដំណើរទៅកាន់នគរឋានសួគ៌។ នៅពីក្រោយ និងពីក្រោមពួកគេមានភាពងងឹត ប៉ុន្តែ ព្រះយេស៊ូអង្គឯងបានបំភ្លឺពន្លឺរបស់ទ្រង់នៅលើផ្លូវខាងមុខ។

អែលឡិនបានដឹងអំពីន័យនៅក្នុងសុបិននិមិត្តនេះ។ គាត់ ហើយនិងអ្នកជឿផ្សេងទៀត បានមកក្នុងសម័យកាលងងឹត។ ពួកគេស្ទើរតែបាក់ទឹកចិត្តដោយសារតែការខកចិត្ត។ ប៉ុន្តែ ព្រះយេស៊ូបានដឹកនាំពួកគេ។ បើសិនជាពួកគេនឹងដើរនៅក្នុងពន្លឺដែលទ្រង់ផ្ដល់ឲ្យ នោះទីបំផុត ពួកគេនឹងទៅដល់ដំណាក់ឋានសួគ៌របស់ពួកគេហើយ។

នៅពេលដែលអែលឡិន ចែករំលែកសុបិននិមិត្តរបស់គាត់ជាមួយនឹងអ្នកដទៃទៀត ពួកគេក៏មានទឹកចិត្តឡើងវិញ។ មនុស្សជាច្រើនបានយល់ថាព្រះជាម្ចាស់មិនបានបំភ្លេចពួកគេទេ។ ទ្រង់ស្រឡាញ់ពួកគេយ៉ាងខ្លាំង រហូតដល់ផ្ដល់ឲ្យពួកគេនូវព្រះវិញ្ញាណនៃបទទំនាយ។ អែលឡិន គឺជាអ្នកនាំសាររបស់ព្រះ ហើយពេញមួយជីវិតរបស់គាត់ ព្រះ

បានបញ្ជូនសុបិននិមិត្តឲ្យគាត់ជាបន្តបន្ទាប់ ដើម្បីចែករំលែកជាមួយនឹងរាស្ត្ររបស់ទ្រង់។

………………………………………………………………………………………………………………

.



គាត់បានរៀបការជាមួយនឹងសិស្សព្រះគម្ពីរវ័យក្មេងម្នាក់ឈ្មោះ ហ្សេមស៍ វ៉ាយថ៍ ហើយពួកគាត់បានរួបរួមជាមួយនឹងក្រុមតូចដទៃទៀតបង្កើតជាព្រះវិហារសេវេនដេយ អាត់វេនទីស្ទឡើង។ អស់រយៈពេលជាង៧០ឆ្នាំ ដែល អ្នកស្រីអ៊ែលឡិនបានផ្តល់ដំបូន្មានល្អៗ និងទិសដៅច្បាស់លាស់ទៅដល់អស់អ្នកដែលបានក្លាយជាមេដឹកនាំព្រះវិហារនេះ។ ពួកគេបានបោះពុម្ពសៀវភៅ ពួកគេបានផ្តល់ចំណេះដឹងដល់វេជ្ជបណ្ឌិត និងគ្រូពេទ្យ ពួកគេបាន បញ្ជូនបេសកជនទៅជុំវិញពិភពលោក ពួកគេបានសាងសង់សាលារៀន និង មន្ទីរពេទ្យទាំងអស់ គឺដោយសារតែដំបូន្មានដែលព្រះបានផ្តល់ឲ្យតាមរយៈអ្នកស្រីអ៊ែលឡិន វ៉ាយថ៍នេះឯង។

គាត់បានស្លាប់ជាង១០០ឆ្នាំមុន ប៉ុន្តែ ឥទ្ធិពលរបស់គាត់នៅតែមានជាបន្ត។ សំណេររបស់គាត់ត្រូវបានបោះពុម្ពចេញជាច្រើនភាសា។ តាមរយៈសៀវភៅរបស់គាត់ គាត់បានផ្សព្វផ្សាយទៅកាន់មនុស្សច្រើនជាងស្ត្រីផ្សេងៗទៀតនៅក្នុងប្រវត្តិសាស្ត្រ។ គាត់បានហៅសំណេររបស់គាត់ថា “ពន្លឺតូច” ចង្អុលបង្ហាញទៅរក “ពន្លឺដែលធំជាង” គឺព្រះគម្ពីរបរិសុទ្ធ។ ជីវិតរស់នៅរបស់គាត់តាមបែបផែនរបស់ព្រះ ការបង្រៀនដោយយកព្រះគម្ពីរជាគ្រឹះ ហើយនិងការទស្សទាយដែលត្រឹមត្រូវអំពីព្រឹត្តិការណ៍នាពេលអនាគត ទាំងអស់បញ្ជាក់ថា គាត់គឺជាហោរាពិត។

ការងាររបស់គាត់ ជាអ្នកនាំសាររបស់ព្រះជាម្ចាស់ ជួយបញ្ជាក់ថា ព្រះវិហារសេវេនដេយ អាត់វេនទីស្ទ គឺជាព្រះវិហាររបស់ព្រះពិតប្រាកដសម្រាប់សម័យកាលចុងក្រោយនេះ។ យើងបាននិយាយអំពីរឿងនេះនៅក្នុងមេរៀនមុនរបស់យើង។ តាមរយៈហោរាយ៉ូហាន ព្រះវិហារពិត គឺត្រូវបានចំណាំដោយសញ្ញាសំគាល់ពីរចំណុច គឺរក្សាបញ្ញត្តទាំងអស់របស់ព្រះជាម្ចាស់ ហើយនិងការមានទីបន្ទាល់របស់ព្រះយេស៊ូ ដែលជាព្រះវិញ្ញាណនៃបទទំនាយ។

ក្នុងនាមជាអ្នកសេវេនដេយ អាត់វេនទីស្ទ ខ្ញុំដឹងថាខ្ញុំបានព្រះពរយ៉ាងធំធេងតាមរយៈការងារផ្សព្វផ្សាយដំណឹងល្អរបស់អ្នកស្រីអ៊ែលឡិន វ៉ាយថ៍។ អ្នកក៏អាចចែករំលែកនៅក្នុងប្រយោជន៍ដែលបានមកតាមរយៈសារដែលព្រះបានបញ្ជូនមកព្រះវិហាររបស់ទ្រង់តាមរយៈហោរានៃសម័យចុងក្រោយរបស់ទ្រង់ដែរ។ សូមមេត្តាចូលរួមអធិស្ឋានជាមួយនឹងខ្ញុំ អរព្រះគុណដល់ព្រះជាម្ចាស់ ចំពោះអំណោយនៃបទទំនាយដ៏ល្អនេះ។

………………………………………………………………………………………………………………

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅឯនគរឋានសួគ៌ អរព្រះគុណទ្រង់ដែលស្រឡាញ់ពួកទូលបង្គំគ្រប់គ្រាន់នឹងនៅមានទំនាក់ទំនងជាមួយនឹងពួកទូលបង្គំ។ អរព្រះគុណទ្រង់ដែលបានផ្តល់នូវអំណោយទានដល់បុរស និងស្ត្រី ធ្វើជាហោរា ហើយតាមរយៈពួកគាត់ទ្រង់បានផ្តល់ព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ទ្រង់មកឲ្យពួកទូលបង្គំ។ ហើយក៏អរព្រះគុណទ្រង់

ដែលនៅក្នុងសម័យកាលចុងក្រោយនេះ ទ្រង់នៅតែមានសារសម្រាប់ពួកទូលបង្គំ ជាសារដែលអាចជួយពួកទូលបង្គំរស់នៅដោយរីករាយ មានសុខភាពល្អរស់នៅបានយូរអង្វែង ហើយមានជីវិតល្អប្រសើរ។

ដូច្នេះ ពួកទូលបង្គំសូមអរព្រះគុណទ្រង់ម្ដងទៀតចំពោះអំណោយនោះ។ ហើយពួកទូលបង្គំសូមអរព្រះគុណទ្រង់ចំពោះរបៀបដែលជួយឲ្យពួកទូលបង្គំដឹងអំពីចលនានៃសម័យចុងក្រោយរបស់ទ្រង់ផងដែរ។ អរព្រះគុណទ្រង់ដែលមានឱកាសដឹងអំពីសេចក្ដីពិតទាំងនេះ ហើយមានចំណែកចែករំលែកវាជាមួយនឹងពិភពលោក។

ព្រះវរបិតា ពួកទូលបង្គំស្រឡាញ់ទ្រង់ ហើយពួកទូលបង្គំចង់មានចំណែកជារាស្ត្រនៅក្នុងសម័យចុងក្រោយរបស់ទ្រង់។ សូមទ្រង់ផ្ដល់នូវព្រះគុណ និងកំលាំង ខណៈពេលដែលពួកទូលបង្គំបន្តរៀនសូត្រ និងបន្តរីកចម្រើននៅក្នុងសេចក្ដីពិតរបស់ទ្រង់គ្រប់កិច្ចការទាំងអស់នេះ ពួកទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូ អាម៉ែន។

………………………………………………………………………………………………………........

(រឿងអាចជ្រើសរើស)

(ត្រូវនិទានប្រាប់អំពីរឿងនេះ បើអាចធ្វើទៅបាន ជាជាងអានឲ្យស្ដាប់)

ជាច្រើនឆ្នាំមកហើយ នៅទីវាលរហោស្ថានដ៏ធំល្វឹងល្វើយនៃតំបន់ប៊ីយ៉ែនណាលែនដ៍នៃប្រទេសអាហ្វ្រិកខាងត្បូង មានមនុស្សព្រៃ ប្រុសម្នាក់ឈ្មោះថា ស៊ូយូបា។ គាត់បានរស់នៅដាច់ស្រយាលពីគេឯង ជាកុលសម្ព័ន្ធរបស់ប្រជាជនណូម៉ាឌីក។ មានយប់មួយនារដូវរងារ គាត់បានលូនចូលទៅក្នុងទីជម្រករបស់គាត់បម្រុងនឹងគេង។ ប៉ុន្តែ យប់ប្រែក្លាយទៅជាភ្លឺជាងពេលថ្ងៃ។ មានមនុស្សដែលមានពន្លឺបានលេចមកឯគាត់ ហើយប្រាប់គាត់ឲ្យទៅរកពួកមនុស្សដែលកាន់ "សៀវភៅ"។ គាត់ត្រូវតែទៅរកពួកមនុស្សដែលបានថ្វាយបង្គំព្រះជាម្ចាស់។

លោកស៊ូយូបា មិនយល់ទេថាមានន័យដូចម្ដេចនោះទេ។ តើជាសៀវភៅអ្វីទៅ? តើគាត់អានវាយ៉ាងម៉េចទៅ បើសិនជាគាត់រកវាឃើញ? ភាសារបស់មនុស្សព្រៃមានលក្ខណៈស្មុគស្មាញ ហើយបន្លឺសំលេងឡើងនៅបំពង់ក គឺខុសពីភាសាកុលសម្ព័ន្ធរបស់ជនជាតិអាហ្វ្រិកដទៃទៀត។ គេមិនដែលបានបង្កើតជាភាសាសរសេរនោះឡើយ។

ប៉ុន្តែ "រូបដែលមានពន្លឺចាំងចែង" ដូចដែលលោកស៊ូយូបា បានហៅថាជាទេវតាដែលបានលេចមកឯគាត់ បាននិយាយថា "សៀវភៅចេះនិយាយ។ អ្នកនឹងចេះអាន។" លោកស៊ូយូបា បានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃជាមួយនឹងក្រុមគ្រួសាររបស់គាត់ តាមស្វែងរកសៀវភៅនោះ។ គាត់បានធ្វើដំណើរទៅដល់ខ្ទមរបស់កសិករ កុលសម្ព័ន្ធ បាន់ធូរ ហើយបានសួរពួកគេ ក្រែងពួកគេស្គាល់ពួកមនុស្សដែលមាន សៀវភៅនោះ។

បុរសជនជាតិភាគតិច(កុលសម្ព័ន្ធ)ភ្ញាក់ព្រើតដែលបានឮមនុស្សព្រៃ ស្រាប់តែចេះនិយាយភាសា បានធូ របស់គាត់បាន។ គាត់ក៏បាននាំលោកស៊ូយូបាទៅជួបគ្រូគង្វាលរបស់គាត់ភ្លាម។ លោកគ្រូគង្វាលរំភើបចិត្តជាខ្លាំងពេលបានឮរឿងរបស់លោកស៊ូយូបា។ រួចគាត់បាននិយាយថា "ដំណើររបស់អ្នកត្រូវបានចប់ហើយ។" លោកស៊ូយូបាសប្បាយចិត្តជាខ្លាំង។ ប៉ុន្តែ នៅយប់នោះ រូបដែលមានពន្លឺចាំងចែងក៏បានលេចមកឯ

គាត់ម្តងទៀត។ គាត់បាននិយាយថា មនុស្សទាំងនេះ មិនមែនជាមនុស្សដែលគាត់ត្រូវតាមរកនោះទេ។ គាត់ត្រូវតាមរក "ព្រះវិហារដែលរក្សាថ្ងៃបរិសុទ្ធ ហើយនិងលោកគ្រូគង្វាលម៉យ។" លោកគ្រូគង្វាលម៉យ នឹងមានសៀវភៅ ហើយក៏មាន "សៀវភៅពណ៌ត្នោត៨ក្បាល ដែលតាមពិតទៅ៩ក្បាល។"

នៅថ្ងៃបន្ទាប់លោកស៊ូយូបា បានអធិស្ឋានសុំសញ្ញាតម្រុយ។ គាត់ត្រូវការការណែនាំខ្លះសម្រាប់ការធ្វើដំណើររបស់គាត់។ នៅពេលដែលគាត់បានអធិស្ឋាន ពពកក៏បានលេចមកនៅលើមេឃ។ លោកស៊ូយូបាន ក៏បានធ្វើដំណើរទៅតាមពពកនោះអស់រយៈពេលប្រាំពីរថ្ងៃ។ ពពកនោះក៏រសាត់បាត់ទៅនៅត្រង់ភូមិមួយ។

នៅទីនោះ លោកស៊ូយូបា បានសួររកលោកគ្រូគង្វាល ម៉យ ហើយគេក៏បាននាំគាត់ទៅរកផ្ទះគ្រូគង្វាលម៉យ ភ្លាម។

បន្ទាប់ពីលោកស៊ូយូបា បានប្រាប់រឿងរបស់គាត់ជាភាសាតំបន់នោះរួច លោកគ្រូគង្វាលម៉យ បានយកព្រះគម្ពីរចាស់សឹករេចរឹលនោះចេញមក។ លោកស៊ូយូបា បានលាន់មាត់ស្រែកថា "សៀវភៅនោះឯង!"។ "គឺសៀវភៅនោះឯង! ប៉ុន្តែ តើសៀវភៅទាំង៨ក្បាល ដែលតាមពិតទៅ៩ក្បាលនោះ នៅឯណា?"

តាមពិតទៅ ជាច្រើនឆ្នាំមុន អ្នកស្រីអ៊ែលឡិន វ៉ាយថ៍ បានសរសេរសៀវភៅអំពីសេចក្តីណែនាំទៅកាន់ក្រុមជំនុំរបស់ព្រះចំនួនប្រាំបួនក្បាល ដែលមានចំណងជើងថា ទីបន្ទាល់សម្រាប់ក្រុមជំនុំ។ នៅក្នុងការបោះពុម្ពមួយ សៀវភៅទាំងនេះត្រូវបានបង្រួមមកត្រឹមបួនក្បាល ហើយលោកគ្រូគង្វាលម៉យមានសៀវភៅទាំងនេះ!

ការស្វែងរករបស់លោកស៊ូយូបា ត្រូវបានបញ្ចប់។ គាត់បានរកឃើញពួកមនុស្សដែលមានសៀវភៅហើយ។ គាត់បានរកឃើញពួកមនុស្សដែលរក្សាថ្ងៃបរិសុទ្ធ ជាពួកមនុស្សដែលបានទទួលព្រះពរជាមួយនឹងអំណោយនៃបទទំនាយដែលបានទាយទុកមុន។ នៅទីបំផុត គាត់ និងក្រុមគ្រួសារបានទទួលយកព្រះគ្រីស្ទ ហើយបានធ្វើបុណ្យជ្រមុជទឹក។ គាត់បានក្លាយទៅជាអ្នកផ្សព្វផ្សាយដំណឹងល្អដល់ប្រជាជនរបស់គាត់។

សព្វថ្ងៃនេះ ព្រះបានធ្វើការតាមវិធីយ៉ាងអស្ចារ្យ ដើម្បីដឹកនាំបុរស និងស្ត្រីឆ្ពោះទៅរកសារនៅសម័យចុងក្រោយរបស់ទ្រង់។ ហេតុផលដែលអ្នកស្តាប់ឮរឿងនេះ គឺមិនមែនជារឿងចៃដន្យនោះទេ។ ដូចលោកស៊ូយូបា អ្នកកំពុងតែត្រូវបានដឹកនាំ។ ព្រះជាម្ចាស់ កំពុងតែដឹកនាំអ្នកទៅក្នុងសេចក្តីពិតរបស់ទ្រង់។ ព្រះជាម្ចាស់កំពុងតែផ្តល់ភាពក្លាហាន ឲ្យអ្នកប្រឈមនឹងអនាគតកាល។

អ្នកប្រហែលជាតាមស្វែងរកសេចក្តីពិតអស់ពេលជាច្រើនឆ្នាំហើយ។ ខ្ញុំជឿថា អ្នកត្រូវបានព្រះដឹកនាំមកកាន់គោលដៅនេះ។ អ្នកគឺដូចលោកស៊ូយូបាដែរ អាចលាន់មាត់ថា "គឺនេះហើយ! ជាសេចក្តីពិតរបស់ព្រះជាម្ចាស់!"

ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ ៖

| | | |
|---|---|---|
| លោកុប្បត្តិ ៣:២៨ | ដានីយ៉ែល ៨:១៩ | កូរិនថូសទី១ ១២:២៨ |
| ជនគណនា ១២:៦ | យ៉ូអែល ២:៣១ | អេភេសូរ ៤:៨ |
| របាក្សត្រទី២ ២០:២០ | ម៉ាថាយ ៧:១៨ | អេភេសូរ ៤:១១-១៥ |
| សុភាសិត ២៩:១៨ | កិច្ចការ ២១:៩ | យូដាស ១៤ |
| បរិទេវ ២:៩ | កូរិនថូសទី១ ១:៧ | វិវរណៈ ១៩:១២ |

## លំនាំពិភាក្សា

**សត្វមូស – ជាមេចំលងជំងឺ**

១. ហេតុអ្វីសត្វមូស ជាសត្វដែលគ្រោះថ្នាក់?
២. តើអ្នកអាចការពារមិនឲ្យសត្វមូសបង្កកំណើត ឬបន្តពូជនៅក្នុង ហើយនិងនៅក្បែរភូមិឋានរបស់អ្នកបានដោយរបៀបណា?
៣. តើអ្នកអាចការពារខ្លួន និងកូនចៅរបស់អ្នកពីសត្វមូសនៅក្នុងផ្ទះរបស់អ្នកដោយរបៀបណា?

**ព្រះវិញ្ញាណនៃបទទំនាយ**

១. កាលព្រះបានបង្កើតពួកគាត់ពីដំបូង អាដាម និងអេវ៉ា អាចជួប និងមើលព្រះជាម្ចាស់ទល់មុខ នឹងមុខបាន។ ហេតុអ្វីបានជាយើងមិនអាច?
- និក្ខមនំ ៣៣:២០ - អេសាយ ៥៩:២

២. ក្រោយអំពើបាប តើព្រះជាម្ចាស់ទាក់ទងជាមួយរាស្ត្ររបស់ទ្រង់ដោយរបៀបណា?
- កិច្ចការ ៣:២១ - អេម៉ុស ៣:៧

៣. តើសារអ្វីខ្លះ ដែលព្រះជាម្ចាស់បានបញ្ជូនមកតាមរយៈហោរារបស់ទ្រង់?
- ហាកាយ ១:១៣ - យេរេមា ៤៤:៤

៤. តើព្រះនឹងទំនាក់ទំនងជាមួយនឹងរាស្ត្ររបស់ទ្រង់តាមរបៀបនេះដែរឬទេ នៅក្នុងសម័យកាលរបស់យើង?
- យ៉ូអែល ២:២៨ -វិវរណៈ ១២:១៧

៥. តើអ្នកអាចដឹងដោយរបៀបណា ថាហោរាពិតជាហោរាមកពីព្រះជាម្ចាស់មែន ឬក៏ជាហោរាក្លែងក្លាយនោះ? តើឥឡូវនេះ យើងមានស្គាល់ហោរាណាទេ?
- ម៉ាថាយ ២៤:២៤ - យ៉ូហានទី១ ៤:១,២
- អេសាយ ៨:២០ - យេរេមា ២៨:៩
- កូរិនថូសទី១ ១៤:៣,៤ - ម៉ាថាយ ៧:១៦

# មេរៀនសុខភាពទី២២ - អនាម័យនៅតាមផ្ទះសម្បែង



១. ការប្រើប្រាស់ទឹកតាមរបៀបត្រឹមត្រូវ គឺល្អប្រសើរជាងការប្រើប្រាស់ថ្នាំដើម្បីបង្ការ ហើយនិងព្យាបាលជំងឺទៅទៀត។ ទឹកជួយដល់រាងកាយប្រយុទ្ធប្រឆាំងនឹងជំងឺ ឬមេរោគទាំងនៅខាងក្នុង និងខាងក្រៅរាងកាយ។ ការរក្សាអនាម័យ ជួយការពារប្រឆាំងនឹងមីក្រុប ឬមេរោគដែលបង្គ្រោះថ្នាក់កុំឲ្យចូលមកលុកលុយបាន។

ការលាងដៃ គឺជាវិធីដែលសំខាន់ជាងគេបំផុតដើម្បីបង្ការ ឬការពារការឆ្លងរាលដាលនៃជំងឺ។ ត្រូវលាងដៃឲ្យបានស្អាត មុននឹងធ្វើម្ហូបញ្ចាំ ឬក៏លាងរបួស ហើយនិងក្រោយពេលបត់ជើងរួច បន្ទាប់ពីប៉ះពាល់អ្នកជំងឺ សាច់ឆៅ ឬក៏សត្វ។

ត្រូវលាងដៃជាមួយនឹងសាប៊ូ ហើយដុសប្រអប់ដៃឲ្យសព្វកន្លែង ហើយដុសនៅតាមខ្នងប្រអប់ដៃរួចនៅតាមចន្លោះម្រាមដៃ បន្ទាប់មក លាងជំរះដៃជាមួយនឹងទឹកស្អាត។ សំអាតធូលីដីចេញពីក្រចក។ ត្រូវលាងជំរះជាមួយនឹងទឹកស្អាត ហើយសម្ងួតនឹងខ្យល់។

ចូរធ្វើតាមវិធីនេះ ទោះបីជាគ្មានសាប៊ូ ឬបើមិនសូវមានទឹកគ្រប់គ្រាន់។

---

**២. ការងូតទឹក**

ការងូតទឹកធ្វើឲ្យមានអារម្មណ៍ល្អ។ វាជំរះញើស និងមីក្រុប (មេរោគ) ការពារកុំឲ្យស្បែកមានដំបៅកន្ទួលរមាស់ និងក្លិនខ្លួន។

សាប៊ូដុសខ្លួនដែលមានសារធាតុសម្រាប់កំចាត់ចៃសាច់។ អាចប្រើសាប៊ូកក់កំចាត់ចៃ ប៉ុន្តែ សម្រាប់ពងចៃ និងចៃ ត្រូវតែប្រើស្និត ឬក្រាស់សិតចៃ។

កុមារត្រូវងូតទឹក ហើយស្លៀកសម្លៀកបំពាក់ដែលស្អាត (មិនប្រឡាក់ ឬកខ្វក់)ជារៀងរាល់ថ្ងៃ។ ត្រូវបង្រៀនពួកគេឲ្យចេះលាងដៃមុននឹងញុំអាហារ ឬនំចំណី ហើយនិងមុនពេលចូលគេង ហើយមិនត្រូវយកដៃទៅប៉ះពាល់ ឬលូកក្នុងមាត់ឡើយ។ ត្រូវរក្សាក្រចកដៃជើងពួកគេឲ្យនៅខ្លីជានិច្ច។ ត្រូវចងចាំថា កូនៗរៀនសូត្រដោយមើលតាមទង្វើរបស់ឪពុកម្តាយរបស់ពួកគេ។

បន្ទាប់ពីងូតទឹករួច ត្រូវស្លៀកសម្លៀកបំពាក់ដែលស្អាត (ស្ងួតបន្ទាប់ពីបោកហាលរួច)។ សម្លៀកបំពាក់កខ្វក់ផ្ទុកនូវកាកសំណល់ និងមេរោគដែលធ្វើឲ្យខូចស្បែកដែលស្អាត។

សម្លៀកបំពាក់ដែលបោករួច ត្រូវដាក់ហាលនៅក្រោមពន្លឺថ្ងៃដើម្បីសំលាប់មេរោគ។

**បង្គន់អនាម័យ**

ដើម្បីចៀសវាងពីជំងឺ គ្រប់ក្រុមគ្រួសារត្រូវមានបង្គន់អនាម័យ។ ត្រូវមានធុងទឹក កាបោយដងទឹក និង សាប៊ូនៅជិតបង្គន់ ដើម្បីលាងដៃ ក្រោយពេលបត់ជើងរួច។ សំភារៈអនាម័យ និងរបស់ប្រើប្រាស់ផ្ទាល់ខ្លួន គឺចាំបាច់សម្រាប់ក្មេងស្រី ហើយនិងស្ត្រី ពេលដែលមានរដូវប្រចាំខែ។

…………………………………………………………………………………………………........

**៣. ការលាងសំអាតផ្លែឈើ និងបន្លែ**

ផលដំណាំដែលដុះនៅជិតដី អាចងាយកើតជំងឺ មានមេរោគ និងព្រូន ជាពិសេស បើសិនជាកន្លែង ដែលដាំនោះមានសត្វ ឬក៏មនុស្សប្រើកន្លែងនោះសម្រាប់បត់ជើង ឬក៏គេប្រើលាមករបស់មនុស្សធ្វើជាជី។ ត្រូវលាងផលដំណាំនឹងទឹកស្អាត ហើយបើមានធូលីដីនៅជាប់ ត្រូវដុសវាចេញឲ្យជ្រះ។ ដើម្បីការពារកូន ង៉ែត និងកុមារតូចៗ ត្រូវបកសំបកផ្លែឈើ ឬបន្លែឲ្យបានស្អាត ឬក៏ចំអិនឲ្យបានឆ្អិនល្អ។ មេរោគនឹងស្លាប់ ពេលចំអិនបានឆ្អិនល្អ។ អាហារដែលទុក ត្រូវគ្របឲ្យជិត ដើម្បីការពារកុំឲ្យរុយរោម។

**ការកាប់ ហាន់សាច់ និងអាហារស្រស់**

ដើម្បីកាត់បន្ថយមេរោគដែលបំពុលអាហារ ត្រូវចិតផ្លែឈើ និងបន្លែស្រស់នៅលើជ្រុញផ្សេងពីជ្រុញ ដែលប្រើសម្រាប់កាប់ ឬហាន់សាច់។ បន្ទាប់ពីកាប់ ឬហាន់សាច់ និងចំអិនវារួចរាល់ហើយ ត្រូវលាងដៃ លាង កាំបិត ហើយ និងជ្រុញឲ្យបានស្អាត។ ត្រូវចំអិនសាច់ឲ្យបានឆ្អិនល្អ ដោយមិនត្រូវទុកផ្នែកណាមួយឲ្យនៅឆៅ ឬស្ទើរឆ្អិននោះឡើយ។

**ការលាងចាន**

ត្រូវលាងចានជាមួយនឹងទឹកសាប៊ូដែលក្តៅ ហើយត្រូវលាងជំរះឲ្យបានស្អាត។ គ្រឿងប្រដាប់ប្រដាប្រើ នៅក្នុងផ្ទះបាយ កាទឹក ឬក៏ចានក្បានដែលអ្នកជំងឺបានប្រើប្រាស់ ត្រូវស្ងោរក្នុងទឹកពុះរយៈពេល១នាទី។ កុំ សំងួតចានដោយប្រើក្រណាត់ តែត្រូវដាក់វាផ្កាប់ចុះក្រោមទៅនឹងរៀរ ឬធ្នើនៅក្រោមពន្លឺថ្ងៃ ឆ្ងាយពីសត្វនានា ហើយនិងធូលី។

…………………………………………………………………………………………………........

**៤. គ្របមាត់ពេលក្អក**

ការក្អក ចំលងមេរោគ។ អ្នកដែលក្អក ត្រូវគ្របមាត់របស់ខ្លួន ហើយលាងដៃឲ្យបានញឹកញាប់។ បើសិន ជាគ្មានក្រដាសអនាម័យទេ ត្រូវក្អកដាក់កន្លែងបត់នៃកែងដៃ។ អ្នកដែលឈឺ ត្រូវគេងឲ្យឆ្ងាយពីក្រុមគ្រួសារ ជាពិសេស គឺកូនតូចៗ។ បើសិនជាក្អកបណ្តាលមកពីជំងឺរបេង កូនតូចៗដែលនៅក្នុងគ្រួសារត្រូវចាក់ថ្នាំការ ពារ។

មិនត្រូវខាកស្តោះលើឥដ្ឋការ៉ូ ឬក្តារក្រាល ឬកម្រាលនៅក្នុងផ្ទះឡើយ។ ការខាកស្តោះ អាចចំលងជំងឺ ដូចជាជំងឺរបេងបាន។

…………………………………………………………………………………………………........

៥. ត្រូវសំអាតផ្ទះរបស់អ្នកឲ្យបានញឹកញាប់

ផ្ទះដែលមានអនាម័យ គឺជាផ្ទះដែលមានសុខភាពល្អ។ ត្រូវបោសសំអាតឥដ្ឋការ៉ូ ក្តារក្រាល ឬកម្រាលឲ្យបានស្អាត ហើយត្រូវលាងសំអាតជាមួយនឹងសាប៊ូ ឬក៏សាប៊ូសម្រាប់សំលាប់សត្វល្អិត ឬមេរោគ ដើម្បីបង្ការកុំឲ្យមានមេរោគ។ ត្រូវលុបប្រហោង និងកន្លែងដែលប្រេះ ជាកន្លែងដែលពពួកសត្វល្អិតអាចចូលបាន។ ត្រូវលោស់មុង ដើម្បីដេញមូស ហើយនិងសត្វល្អិតដទៃទៀត ហើយសំលាប់សត្វសង្កើច និងចៃ។

សត្វកណ្តុរ និងរុយចូលចិត្តរបស់អេតចាយ និងសម្រាមនៅជុំវិញផ្ទះ។ ត្រូវរើស ឬកើបវាទៅចាក់ចោលនៅកន្លែងចាក់សម្រាម ឬក៏ដុតវា។ ត្រូវដាក់កាកសំណល់អាហារនៅកន្លែងធ្វើជីរកំប៉ុស។ ត្រូវដាក់កាកសំណល់អាហារ និងរុក្ខជាតិជាស្រទាប់ៗ ដើម្បីធ្វើជាជីរកំប៉ុសដែលល្អសម្រាប់ដំណាំរបស់អ្នក។

៦. បរាសិតនៅខាងក្រៅ

មានបរាសិតដែលជញ្ជក់ឈាមច្រើនប្រភេទខុសៗគ្នា។ ពពួកចៃ និងពពួកសត្វល្អិត(ចៃ)ដែលកាត់ខោអាវ ដែលរស់នៅលើខ្លួនមនុស្ស នៅលើខ្លួនសត្វដើរដោយជើងទាំង៤ នៅលើខ្លួនសត្វស្លាប នៅលើសម្លៀកបំពាក់ ហើយនិងនៅក្នុងផ្ទះ។ សត្វសង្កើច និងសត្វចៃក្បាល និងចៃក្តាមមិនមានផ្ទុកមេរោគឡើយ ប៉ុន្តែ ការខាំរបស់វា ធ្វើឲ្យរមាស់ខ្លាំង។ សត្វចៃក្បាល ឆ្លងតាមរយៈភាពជិតស្និទ្ធ ឬក៏ប្រើស្និត ឬក្រាស់រួមគ្នា។ សត្វចៃក្តាម ឆ្លងតាមការរួមភេទ។

បរាសិតដែលជញ្ជក់ឈាមផ្សេងៗទៀត មានផ្ទុក និងជាភ្នាក់ងារចម្លងជំងឺ។ ចៃខ្លួន មានផ្ទុកជំងឺ គ្រុនរោល ដែលឆ្លងរាលដាលយ៉ាងខ្លាំង ហើយច្រើនតែបណ្តាលឲ្យអ្នកជំងឺស្លាប់។ គេអាចព្យាបាលជំងឺនេះជាមួយនឹងថ្នាំផ្សះ(អង់ទីប៊ីយ៉ូទិក)។ ចៃសម្លៀកបំពាក់ មានផ្ទុកមេរោគកមរមាស់ វារស់នៅលើស្បែក។ ចៃកកេរ មានផ្ទុកមេរោគ ដែលអាចបង្ការបានដោយការចាក់ថ្នាំការពារ។ ចៃឆ្មារ និងចៃឆ្កែ មានផ្ទុកតេនញ៉ា។

បរាសិតទាំងនេះ ចូលចិត្តពួនសំងំ ហើយបង្កាត់ពូជ និងបង្កើតកូនចៅនៅទីកន្លែងងងឹត កន្លែងស្ងួត ដូចជានៅតាមគ្រែ ពូក ក្រណាត់ ចន្លោះជញ្ជាំងប្រេះ ចន្លោះឥដ្ឋការ៉ូ ក្តារក្រាល ឬកម្រាល ហើយនិងគ្រឿងសង្ហារិម។

ដើម្បីកំចាត់សត្វចៃកកេរ ត្រូវកំចាត់កន្លែងដែលវាកកេរ ហើយនិងដាក់ថ្នាំកំចាត់វាចូលទៅក្នុងរូង ហើយនិងផ្លូវចូលរបស់វា។ រីឯសត្វចៃនៅលើសត្វចិញ្ចឹមវិញ ត្រូវប្រើថ្នាំកំចាត់វានៅលើសម្លៀកបំពាក់ ហើយនិងទៅលើរោមសត្វ។

របស់របរដែលដាក់សម្រាប់ឲ្យកូនតូចៗគេង ត្រូវស្ងោរសំលាប់មេរោគ តែមិនត្រូវប្រើថ្នាំកំចាត់សត្វល្អិតឡើយ។

ព្រះជាម្ចាស់បានផ្តល់ទឹកសម្រាប់ភពផែនដីរបស់យើង។ ចូរប្រើវាឲ្យបានត្រឹមត្រូវដើម្បីរក្សាយើងឲ្យមានសុខភាពល្អ។ វាគឺជាអំណោយទានមកពីព្រះ ហើយនិងទ្រង់សន្យា “ដ្បិតអញនឹងចាក់ទឹកទៅលើអ្នកណាដែលកំពុងស្រេក ព្រមទាំងបង្ហូរទឹកទៅលើដីហួតហែងផង អញនឹងចាក់វិញ្ញាណអញទៅលើពូជពង្សរបស់ឯង ហើយពររបស់អញ ទៅលើកូនចៅរបស់ឯង” (អេសាយ ៤៤:៣)។ ចូរអធិស្ឋានទៅទ្រង់ ហើយនិងទទួលយកសេចក្តីសន្យារបស់ទ្រង់។ ចូរសុំឲ្យទ្រង់ប្រទានពរដល់ក្រុមគ្រួសាររបស់អ្នក។

## ព្រះវិហារពិត (ភាគ២)



ហោរាយ៉ូហានបានឃើញសុបិននិមិត្តអំពីបុរសអ្នកជិះសេះបួននាក់ ជិះនៅលើសេះធំៗបួនក្បាល។ សេះទាំងនេះ ហើយនិងអ្នកជិះពីលើវា តំណាងឲ្យប្រវត្តិសាស្ត្រនៃព្រះវិហារគ្រីស្ទាន។ តាមរយៈការសិក្សាប្រវត្តិសាស្ត្រនេះ យើងអាចដឹងពីមូលហេតុដែលនាំឲ្យមានព្រះវិហារខុសៗគ្នា នាពេលសព្វថ្ងៃនេះ។

សេះទី១ មានពណ៌ស។ អ្នកជិះវាកាន់ធ្នូនៅនឹងដៃ ហើយពាក់មកុដ។

សេះទី២ មានពណ៌ក្រហមដូចភ្លើង ហើយអ្នកជិះកាន់ដាវ។

អ្នកជិះបន្ទាប់ កាន់ជញ្ជីញមួយគូ ដូចអ្នកលក់ឥវ៉ាន់ប្រើប្រាស់សម្រាប់ថ្លឹង។ គាត់ជិះសេះពណ៌ខ្មៅ។

សេះទី៤ ជាសេះដែលមានសម្រស់មិនស្អាត មានពណ៌ស្លេក ហើយអ្នកជិះវាឈ្មោះថា សេចក្តីស្លាប់។

តើសត្វសេះទាំងបួននេះ ហើយអ្នកជិះវាតំណាងឲ្យអ្វីខ្លះ? ទាំងសេះ ហើយនិងអ្នកជិះនីមួយៗប្រាប់យើងអំពីរឿងរ៉ាវខ្លះៗអំពីប្រវត្តិសាស្ត្ររបស់ព្រះវិហារគ្រីស្ទាន។ តោះយើងយកវាមកពិចារណាម្តងមួយៗ។

..................................................................................................................................

.



លោកយ៉ូហានបានសរសេរថា ៖

“ខ្ញុំក៏ក្រឡេកទៅឃើញសេះស១ ឯអ្នកដែលជិះក៏កាន់ធ្នូ ហើយមានគេឲ្យមកុដ ដល់អ្នកនោះ រួចអ្នកនោះចេញទៅទាំងមានជ័យជំនះ ហើយឲ្យបានឈ្នះតទៅ” (វិវរណៈ ៦:២)។

នេះតំណាងឲ្យព្រះវិហារ កាលពីវានៅថ្មីថ្មោង មិនទាន់ខូចខាត។ មេដឹកនាំរបស់វាបានស្គាល់ព្រះយេស៊ូផ្ទាល់។ ពួកគេបានឃើញព្រះយេស៊ូយាងទៅឯនគរឋានសួគ៌វិញដោយផ្ទាល់ភ្នែក។ ពួកគេបានជឿអស់ពីចិត្តថាទ្រង់នឹងបានយាងត្រឡប់មកវិញ។ ពួកគេមានជំនឿបរិសុទ្ធ ពីព្រោះពួកគេធ្លាប់នៅជាមួយនឹងព្រះយេស៊ូ។ ពួកគេបានជឿលើអ្វីដែលព្រះយេស៊ូបានជឿ។ ពួកគេបានបង្រៀននូវអ្វីដែលព្រះយេស៊ូបានបង្រៀន។

នោះគឺជាប្រភេទនៃជំនឿដូចគ្នាដែលយើងត្រូវការនាសព្វថ្ងៃនេះ ជាសេចក្តីជំនឿបរិសុទ្ធសាមញ្ញៗ ដែលទន្ទឹងរង់ចាំការយាងមកជាលើកទីពីររបស់ព្រះយេស៊ូគ្រីស្ទ។

ទីបន្ទាល់ផ្ទាល់នៃសាវ័ករបស់ព្រះយេស៊ូ គឺជាការលើកទឹកចិត្តដល់មនុស្សដទៃ ហើយនិងនាំអ្នកជឿរាប់ពាន់នាក់ចូលព្រះវិហារបន្ថែមទៀត។

មេដឹកនាំសាសនាយូដា ភ័យខ្លាចដោយឃើញព្រះវិហារគ្រីស្ទានរីកចម្រើនយ៉ាងខ្លាំង។ ពួកគេចាប់បង្ខំយកពួកសាវ័កខ្លះ ហើយដាក់ពួកគេនៅក្នុងគុក។ ពួកគេបញ្ជាឲ្យពួកសាវ័កឈប់អធិប្បាយ និងឈប់បង្រៀនអំពីព្រះយេស៊ូ។ នេះគឺជាចម្លើយដែលពួកសាវ័កបានឆ្លើយតប ៖

“ត្រូវតែស្តាប់បង្គាប់របស់ព្រះជាជាងមនុស្ស” (កិច្ចការ ៥:២៩)។

អ្នកអាចដឹងថា នៅសម័យនោះអ្នកជឿមានចិត្តមុតមាំក្នុងការធ្វើជាអ្នកផ្សព្វផ្សាយដំណឹងល្អ។ ពួកសាវ័កធ្វើតាមការបង្គាប់របស់ទ្រង់ យកដំណឹងល្អនៃសេចក្តីសង្គ្រោះទៅគ្រប់ទិសទីពេញពិភពលោក។ ព្រះវិហាររីកចម្រើនលូតលាស់ខ្លាំង លើសពីទឹកដីដើម ថែមទាំងចូលទៅដល់ទីក្រុងធំៗនៃអាណាចក្ររ៉ូម។

សូមស្តាប់របាយការណ៍ទាំងនេះ ដែលបានសរសេរឡើងដោយលោកលូកា ជាអ្នកផ្សព្វផ្សាយដំណឹងល្អដំបូងគេម្នាក់របស់គ្រីស្ទាន ៖

"ហើយពួកអ្នកដែលជឿដល់ព្រះអម្ចាស់ក៏បានចម្រើនកាន់តែច្រើនឡើង មានមនុស្សសន្ធឹក ទាំងប្រុសទាំងស្រី" (កិច្ចការ ៥:១៤)។

"ចំណែកព្រះអម្ចាស់ ទ្រង់ក៏បន្ថែមនូវអស់អ្នក ដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃទៅ" (កិច្ចការ ២:៤៧)។

………………………………………………………………………………………………



បន្ទាប់មករូបភាពផ្សេងក៏បានលេចមក។ សូមស្តាប់ ៖

"នោះមានសេះ១ទៀតចេញមក មានសម្បុរក្រហម ហើយគេឲ្យអ្នកដែលជិះ មានអំណាចអាចនឹងដកយកសេចក្តីសុខសាន្តពីផែនដីចេញ ឲ្យមនុស្សលោកបានសំលាប់គ្នា គេក៏ប្រគល់ដាវ១យ៉ាងធំដល់អ្នកនោះដែរ" (វិវរណៈ ៦:៤)។

កាលណាព្រះវិហាររីកលូតលាស់កាន់តែធំ វាប្រឈមនឹងការប្រឆាំងខ្លាំង ហើយនិងការប្រឆាំងបែបហិង្សាពីសំណាក់សាសនាបែបបុរាណដទៃទៀតនៅក្នុងអាណាចក្ររ៉ូម។ មន្ត្រីរដ្ឋាភិបាលដឹកនាំដោយអធិរាជ បានធ្វើទុក្ខបុកម្នេញដល់គ្រីស្ទាន។ ឥឡូវ ព្រះវិហារប្រឡាក់ដោយឈាម។ ហេតុដូច្នេះហើយបានជាសេះទីពីរមានពណ៌ក្រហម។

អ្នកដើរតាមព្រះយេស៊ូដោយស្មោះត្រង់ ត្រូវបានគេចាប់ ហើយបោះបញ្ចូលគុក។ ពួកគេត្រូវបានគេធ្វើទារុណកម្ម ហើយសំលាប់ចោល។ ពួកគេត្រូវបានគេយកធ្វើជាចំណីឲ្យដល់សត្វកំណាច ហើយត្រូវបានសំលាប់។ មនុស្សរាប់ពាន់នាក់បានបាត់បង់ជីវិត។ ពួកគេសុខចិត្តស្លាប់ជាជាងបោះបង់ជំនឿរបស់ពួកគេលើព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់ពួកគេ។

ប៉ុន្តែ ការធ្វើទុក្ខបុកម្នេញមិនបានបំផ្លាញព្រះវិហារឡើយ។ មើលទៅឈាមរបស់ពួកគ្រីស្ទានហាក់ដូចជាគ្រាប់ពូជដុះនៅកន្លែងណាដែលពួកគេបានស្លាប់។ កាលណាគ្រីស្ទានលះបង់ជីវិតរបស់ពួកគេដើម្បីព្រះយេស៊ូ មានមនុស្សកាន់តែច្រើនឡើងមកដើម្បីជំនួសកន្លែងរបស់ពួកគេ។

ការធ្វើទុក្ខបុកម្នេញ និងការបង្ហូរឈាមបន្តកើតមានឡើងរហូតដល់រជ្ជកាលអធិរាជរ៉ូម៉ាំងខុនស្ទិនធីន ជិត៣០០ឆ្នាំ ក្រោយសម័យកាលព្រះយេស៊ូ។

សេះក្រហមបានចាកចេញពីសុបិននិមិត្តរបស់លោកយ៉ូហាន ហើយក៏បានឃើញសេះទី៣ចូលមក។ សូមស្តាប់ ៖

………………………………………………………………………………………………



“... ខ្ញុំក៏ក្រឡេកទៅឃើញសេះខ្មៅ១ ឯអ្នកដែលជិះក៏កាន់ជញ្ជីង១នៅដៃ។ រួចខ្ញុំឮសំលេង១ ... ពោលដូច្នេះថា អង្ករស្រូវសាលី១នាលិ ថ្លៃ២កាក់ ហើយអង្ករស្រូវឱក៣នាលិ ថ្លៃ២កាក់ តែកុំឲ្យបង្ខូចព្រេង និងស្រាទំពាំងបាយជូរឡើយ” (វិវរណៈ ៦:៥,៦)។

តើអ្នកនៅចាំពីសេះទី១ទេ - គឺសេះពណ៌សនោះណា? គឺវាតំណាងឲ្យព្រះវិហារគ្រីស្ទានបរិសុទ្ធ។ ឥឡូវ យើងមានសេះពណ៌ខ្មៅ។ គឺគ្រាន់តែផ្ទុយពីពណ៌សប៉ុណ្ណោះ។ សេះពណ៌ខ្មៅប្រាប់យើងថា ព្រះវិហារបរិសុទ្ធត្រូវបានខូចឈ្មោះ។ វាជាប់ពាក់ព័ន្ធជាមួយនឹងរឿងលោកិយ ហើយលែងជាអំណាចខាងព្រលឹងវិញ្ញាណនៅក្នុងលោកិយទៀតហើយ។

លោក ប៉ុល ជាបេសកជនគ្រីស្ទានដំបូង បានផ្តល់សារព្រមានដាស់តឿនថា ៖

“ដ្បិតខ្ញុំដឹងថា ក្រោយដែលខ្ញុំទៅបាត់ នោះនឹងមានឆ្កែព្រៃដ៏សាហាវ ដែលមិនចេះប្រណីដល់ហ្វូង វានឹងចូលមកក្នុងពួកអ្នករាល់គ្នា។ ហើយក្នុងចំណោមអ្នករាល់គ្នា ក៏នឹងកើតមានមនុស្សដែលនឹងអធិប្បាយសេចក្តីទំនាស់ខុសដែរ ដើម្បីនឹងទាញនាំពួកសិស្សទៅតាមគេវិញ” (កិច្ចការ ២០:២៩,៣០)។

មានមេដឹកនាំគ្រីស្ទានជាច្រើនបានចេញពីសាសនាដទៃមកចូលរួមព្រះវិហារថ្មី។ ពួកគេបាននាំយកជំនឿចាស់ខ្លះរបស់ពួកគេមកជាមួយដែរ។ ការបង្រៀនព្រះគម្ពីរត្រូវបានដាក់ជំនួសដោយគោលលទ្ធិក្លែងក្លាយ។

ឧទាហរណ៍ រូបសំណាក ហើយនិងរូបផ្សេងៗទៀត ត្រូវបានគេនាំចូលមកក្នុងព្រះវិហារ សម្រាប់ធ្វើជាវត្ថុសម្រាប់ថ្វាយបង្គំ។ ការប្រតិបត្តិជំនឿបែបនេះ ត្រូវបានហាមឃាត់នៅក្នុងបញ្ញត្តដែលព្រះបានប្រទានឲ្យរាស្ត្ររបស់ទ្រង់កាលពីរាប់ពាន់ឆ្នាំមុនមកម្ល៉េះ។ សូមស្តាប់ ៖

“កុំឲ្យឆ្លាក់ធ្វើរូបណាសម្រាប់ឯងឲ្យសោះ ក៏កុំឲ្យធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង។ ក៏កុំឲ្យក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាម នោះឡើយ” (និក្ខមនំ ២០:៤,៥)។

នៅក្នុងកំឡុងពេលដដែលនោះ មេដឹកនាំព្រះវិហារបានឈររឹងមាំប្រឆាំងជាមួយនឹងបញ្ញត្តិរបស់ព្រះ១ទៀតផងដែរ។ ពួកគេចង់បានថ្ងៃអាទិត្យ ជាថ្ងៃទី១នៃសប្តាហ៍ ធ្វើជាថ្ងៃថ្វាយបង្គំ ជំនួសឲ្យថ្ងៃសៅរ៍ ដែលជាថ្ងៃទី៧។

ប៉ុន្តែ ព្រះជាម្ចាស់បានប្រាប់រាស្ត្ររបស់ទ្រង់ថា “ចូរឲ្យនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ។ ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ។ តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សម្រាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ។ នៅថ្ងៃនោះមិនត្រូវធ្វើអ្វីឲ្យសោះ ទោះខ្លួនឯងឬកូនប្រុស កូនស្រីឯងក្តី ទោះបាវប្រុស ឬបាវស្រីឯងក្តី ទោះសត្វរបស់ឯង ឬអ្នកដទៃ ដែលនៅផ្ទះឯងក្តី” (និក្ខមនំ ២០:៨-១០)។

នៅក្នុងសម័យកាលរបស់ព្រះវិហារសេះខ្មៅ មនុស្សត្រូវបានបង្រៀនថា សេចក្តីសង្គ្រោះរកបានដោយការគោរពប្រតិបត្តិច្បាប់សាសនា ដែលបង្កើតឡើងដោយពួកមេដឹកនាំយ៉ាងខ្ជាប់ខ្ជួន។ ប៉ុន្តែ ព្រះគម្ពីរបង្រៀនថា សេចក្តីសង្គ្រោះគឺជាអំណោយ។ យើងមិនអាចរកបានទេ។ យើងមិនអាចទិញបាន។ យើងមិនសមនឹងទទួលបានវាទេ ទោះបី

ជាខំគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ឬយើងលន់តួទោសអស់ពីចិត្តខ្លាំងយ៉ាងណា ក៏ដោយ ក៏មិនអាចទទួលបានដែរ។

ព្រះគម្ពីរបង្រៀនថា “ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន”(អេភេសូរ ២:៨,៩)។

ដើម្បីទទួលបានអំណោយនោះ អ្វីដែលយើងត្រូវធ្វើ គឺយាងព្រះយេស៊ូចូលមកក្នុងចិត្តរបស់យើង។ បន្ទាប់មក ទ្រង់អភ័យទោសគ្រប់អំពើបាបទាំងអស់របស់យើង។ ហើយបន្ទាប់មក ទ្រង់នឹងប្រទានអំណាចឲ្យយើងយកឈ្នះលើទម្លាប់នៃអំពើបាបរបស់យើង។ ទ្រង់នឹងផ្តល់អំណាចឲ្យយើងដើរនៅក្នុងគន្លងរបស់ទ្រង់។

ព្រះវិហារនៃសម័យសេះខ្មៅ តម្រូវឲ្យមនុស្សសារភាពអំពើបាបរបស់គេទៅសម្តេចសង្ឃ។ ហើយពួកគេត្រូវបង់លុយសម្រាប់ការអភ័យទោស។ ប៉ុន្តែ នោះមិនមែនជាអ្វីដែលព្រះគម្ពីរបង្រៀនឡើយ។ សូមស្តាប់៖

“បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាត ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង” (យ៉ូហានទី១ ១:៩)។

នេះក៏ជាព្រះវិហារដែលបានទទួលយកគោលលទ្ធិក្លែងក្លាយនៃព្រលឹងអមតៈ។ សមាជិកព្រះវិហារ ត្រូវបានបង្រៀនថា អស់អ្នកដែលបានស្លាប់ទៅ គឺមិនចំជាស្លាប់ទេ តែព្រលឹងរបស់ពួកគេបានចាកចេញពីរាងកាយរបស់ពួកគេ ហើយកំពុងរស់នៅឋានសួគ៌ ឬក៏នៅឋាននរក។

គោលលទ្ធិនេះ ចេញមកពីសាសនាដទៃ ហើយធ្វើឲ្យខូចដល់គោលលទ្ធិពិតប្រាកដរបស់ព្រះគម្ពីរ។ ចូរចងចាំ ព្រះគម្ពីរប្រាប់យើងថា ការស្លាប់គឺដូចជាការដេកលក់ ហើយគ្រីស្ទានទាំងឡាយដែលបានស្លាប់នឹងមិនរស់ឡើងវិញទេ រហូតទាល់តែដល់ព្រះគ្រីស្ទយាងមកជាលើកទីពីរ។

គោលលទ្ធិទាំងនេះ ហើយនិងការបង្រៀនក្លែងក្លាយពីសំណាក់ព្រះវិហារសម័យសេះខ្មៅ បានរៀបចំផ្លូវសម្រាប់សត្វសេះទី៤។ សូមស្តាប់ពាក្យរបស់ហោរាយ៉ូហាន៖

“ខ្ញុំក៏ក្រឡេកមើលទៅឃើញសេះ១សម្បុរស្លាំង ឯអ្នកដែលជិះមានឈ្មោះថា “សេចក្តីស្លាប់” ហើយស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏តាមអ្នកនោះទៅ”(វិវរណៈ ៦:៨)។

.



សម័យកាលរបស់សត្វសេះសម្បុរស្លាំង ជួនកាលហៅថា “សម័យងងឹត”។ ព្រះវិហារ ហើយនិងរដ្ឋាភិបាលរួមគ្នាគ្រប់គ្រងជីវិតមនុស្ស ហើយនិងបញ្ហាប្រទេសជាតិនានា។ សាសនាត្រូវបានគេគ្រប់គ្រងយ៉ាងតឹងរ៉ឹងបំផុត។ មានតែសម្តេចសង្ឃប៉ុណ្ណោះដែល មានសិទ្ធិបើកព្រះគម្ពីរ។ មនុស្សសាមញ្ញធម្មតា មិនមានសិទ្ធិអានវាដោយខ្លួនឯងបានទេ។ ព្រះវិហារជាអ្នកប្រាប់ពួកគេនូវអ្វីដែលត្រូវជឿ។

គោលលទ្ធិក្លែងក្លាយនៃព្រះវិហារសម័យសេះខ្មៅបានបន្តលើសពីនេះទៅទៀត។ ជីវិតរបស់ប្រជារាស្ត្រពោរពេញទៅដោយសេចក្តីភ័យខ្លាច ហើយនិងជំនឿឆ្វេង ហើយអ្វីដែលជាចំណេះដឹងពិតរបស់ព្រះជាម្ចាស់ គឺស្ទើរតែបាត់បង់អស់។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានឲ្យសេចក្តីពិតរបស់ទ្រង់រលត់សាបសូន្យទាំងស្រុងឡើយ។ នៅមានមនុស្សខ្លះ ដែលរក្សាសេចក្តីពិតឲ្យមានជីវិត។ ពួកគេ គឺជាពួកវ៉លដិនសីស៍។ ពួកគេរស់នៅតំបន់ភ្នំ នៅចុងភាគខាងជើងនៃប្រទេសអ៊ីតាលី។ ពួកគេមានព្រះគម្ពីរចម្លងដោយសរសេរដៃ។

ពួកគេយកសន្លឹកព្រះគម្ពីរខ្លះដេរភ្ជាប់នៅក្នុងហោប៉ៅសម្លៀកបំពាក់កូនរបស់ពួកគេ។ បន្ទាប់មក កូនៗរបស់ពួកគេធ្វើដំណើរទៅទីក្រុង ទៅសាលារៀន និងទៅតាមផ្សារ ហើយចែករំលែកសន្លឹកព្រះគម្ពីរនោះជាមួយនឹងមនុស្សដែល ពួកគេបានជួប។ តាមពិតទៅ វាជាការងារដែលគ្រោះថ្នាក់។ បើសិនជាគេរកឃើញ ពួកគេអាចត្រូវចាប់ខ្លួន ហើយធ្វើទារុណកម្មដោយដុតក្នុងភ្លើងឲ្យស្លាប់។

………………………………………………………………………………………………........

.



ពេលដែលសតវត្សរ៍នៃសម័យងងឹតបានកន្លងផុតទៅ មានមនុស្សខ្លះទៀត បានចាប់ផ្តើមស្តារចំណេះដឹងអំពីសេចក្តីពិតរបស់ព្រះគម្ពីរមកវិញ។ គឺមានតែ ពួកសម្តេចសង្ឃ ហើយនិងពួកអ្នកប្រាជ្ញតែប៉ុណ្ណោះដែលអាចអានព្រះគម្ពីរបរិសុទ្ធបាន។ ពួកគេបានឃើញថា ព្រះវិហារបង្រៀនគោលលទ្ធិក្លែងក្លាយ។

នេះនាំឲ្យមានការកែប្រែយ៉ាងធំធេង កាលពី៥០០ឆ្នាំមុន។ មនុស្សក្លាហានបានក្រោកឈរឡើងប្រឆាំងនឹងព្រះវិហាររ៉ូម៉ាំងកាតូលិក។ ពួកគេមិនព្រមទទួលយកឫទ្ធិអំណាចរបស់ស្តេចប៉ាបឡើយ។

ពួកគេបានបកប្រែព្រះគម្ពីរទៅជាភាសារបស់មនុស្សជាច្រើន។ កន្លែងបោះពុម្ពបានធ្វើឲ្យអាចបោះពុម្ពបានរាប់ពាន់ព្រះគម្ពីរ។ ចំណេះដឹងនៃព្រះបន្ទូលរបស់ព្រះបានកើនឡើង។

សកម្មជនដែលប្រឆាំងបានចាប់ផ្តើមបង្កើតព្រះវិហារថ្មី បែកចេញពីព្រះវិហាររ៉ូម៉ាំង។ ពួកគេបានស្តារគោលលទ្ធិព្រះគម្ពីរនៃសេចក្តីសង្គ្រោះតាមរយៈព្រះគ្រីស្ទតែមួយគត់។ ពួកគេបានបង្រៀនថា សមាជិកព្រះវិហារ ត្រូវលន់តួបាបទៅព្រះជាម្ចាស់ មិនមែនទៅសម្តេចសង្ឃខ្លះដែលជាមនុស្សនោះឡើយ។

សម័យងងឹតបានចប់។ សម័យនៃព្រះវិហាររបស់សត្វសេះសម្បុរស្លាំង បានកន្លងហួស។ ពន្លឺបានចែងចាំងចេញពីព្រះបន្ទូលរបស់ព្រះ គឺព្រះគម្ពីរ។ មនុស្សបានស្រាវជ្រាវរកសេចក្តីពិតចាស់។

………………………………………………………………………………………………........

.



បុរសម្នាក់នៅក្នុងចំណោមបុរសទាំងនោះ គឺលោកវីលៀម មីលឡឺរ កាលពីជិត ២០០ឆ្នាំមុន។ គាត់បានសិក្សាព្រះគម្ពីរដានីញ៉ែល និងព្រះគម្ពីរវិវរណៈ យ៉ាងយកចិត្តទុកដាក់។ គាត់ជឿថា បទទំនាយចង្អុលបង្ហាញទៅការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ហើយគាត់ក៏ជឿដែរថា វានឹងកើតឡើងឆាប់ៗ។

គាត់បានចាប់ផ្ដើមបង្រៀនអំពីវា ជម្រុញលើកទឹកចិត្តមនុស្សឲ្យរៀបចំត្រៀមខ្លួន។ មនុស្សដទៃទៀតបានចូលរួមជាមួយគាត់ មកពីព្រះវិហារផ្សេងៗគ្នា។ នោះហៅថា "ចលនានៃការយាងមករបស់ព្រះយេស៊ូ (The Advent Movement"។ ពាក្យ "អាត់វេន (Advent)" ក៏ជាពាក្យមួយទៀត ដែលសំដៅទៅលើការយាងមកវិញរបស់ព្រះយេស៊ូ។

មិត្តភក្តិរបស់លោកវីលៀម មីលឡឺរ បានធ្វើតាមគំរូរបស់គាត់ ដោយការសិក្សាព្រះគម្ពីរយ៉ាងយកចិត្តទុកដាក់។ នៅមានច្រើនដែលត្រូវរៀនសូត្រ។ មានសេចក្ដីពិតរបស់ព្រះគម្ពីរច្រើន ដែលត្រូវបានកប់នៅពីក្រោមគំនិតរបស់អ្នកដែលកាន់សាសនា គោរពរូបសំណាក ហើយនិងទំនៀមទម្លាប់ប្រពៃណីរបស់មនុស្ស។

វាដល់ពេលវេលាសម្រាប់ពួកគេស្វែងយល់ឲ្យបានស៊ីជម្រៅអំពីគម្រោងការរបស់ព្រះសម្រាប់គ្រួសាររបស់មនុស្សជាតិ។

ពួកគេដឹងថា សាច់ញាតិរបស់ពួកគេ ដែលបានស្លាប់ទៅហើយនោះ គឺមិនបានទៅនៅឋានសួគ៌ ឬឋាននរកឡើយ។ តែពួកគេដូចជាដេកលក់ រហូតទាល់តែដល់ថ្ងៃប្រោសឲ្យរស់ឡើងវិញ។ ពួកគេជឿពាក្យសម្ដីទាំងនេះមកពីព្រះគម្ពីរ។

"ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ ព្រះឱស្ឋទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង។ នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់" (ថែស្សាឡូនិចទី១ ៤:១៦)។

ពួកគេបានដឹងអំពីសេចក្ដីពិតដ៏សំខាន់មួយទៀតមកពីការសិក្សាព្រះបន្ទូលរបស់ពួកគេ ៖ ថ្ងៃថ្វាយបង្គំពិតប្រាកដរបស់គ្រីស្ទាន គឺថ្ងៃសៅរ៍ មិនមែនថ្ងៃអាទិត្យនោះទេ។ ការរក្សាថ្ងៃអាទិត្យ គឺជាទំនៀមទម្លាប់របស់មនុស្ស ដែលចាប់ផ្ដើមមកពីសាសនាដែលគោរពរូបសំណាក។ ពួកគេចងចាំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទាល់ ៖

"គេថ្វាយបង្គំអញជាឥតប្រយោជន៍ទេ ព្រោះគេបង្រៀនសេចក្ដីដែលជាបញ្ញត្តរបស់មនុស្សវិញ" (ម៉ាថាយ ១៥:៩)។

នៅលដែលគេរកឃើញសេចក្ដីពិតពិសេសនេះនៅក្នុងព្រះគម្ពីរ មនុស្សទាំងនេះ ជឿជាក់ថា ព្រះជាម្ចាស់បានត្រាស់ហៅពួកគេឲ្យជួយរៀបចំពិភពលោក សម្រាប់ការយាងមករបស់ព្រះយេស៊ូ។ ហេតុនោះហើយ បានជានៅទីបំផុត ពួកគេបានបង្កើតព្រះវិហារសេវេនដេយ អាត់វេនទីស្ទឡើង។

មិត្តអើយ ខ្ញុំជឿជាក់ថា ព្រះកំពុងតែត្រាស់ហៅអ្នក ដូចដែលទ្រង់បានត្រាស់ហៅអ្នកសេវេនដេយ អាត់វេនទីស្ទកាលពីដំបូងដែរ។ ការងារដែលពួកគេបានចាប់ផ្ដើម បានរីកចម្រើនពាសពេញពិភពលោក ប៉ុន្តែ នៅមិនទាន់ចប់សព្វគ្រប់នៅឡើយទេ។

ខ្ញុំជឿថា ព្រះចង់ឲ្យអ្នកធ្វើជាផ្នែកមួយនៃការងារនោះ។ ទ្រង់មានការងារឲ្យអ្នកធ្វើ។ មានមនុស្សដែលទ្រង់ចង់ឲ្យអ្នកចែករំលែកសេចក្ដីពិតជាមួយ។ វាគឺជារឿងសំខាន់នៃជីវិតអស់កល្បរបស់ពួកគេ។

ប្រហែលជាមិត្តភក្តិ ឬសមាជិកគ្រួសារដែលមិនអាចនៅទីនេះបាន។ អ្នកខ្លះអាចដឹងនៅក្នុងចិត្តក្នុងពេលឥឡូវនេះថា ព្រះជាម្ចាស់កំពុងតែហៅអ្នកឲ្យផ្សព្វផ្សាយដំណឹងល្អទៅកាន់អ្នកនោះ។

ព្រះជាម្ចាស់មានកន្លែងសម្រាប់អ្នកនៅក្នុងពេលនេះ ដូចដែលទ្រង់មានកន្លែងសម្រាប់អ្នកនៅក្នុងនគររបស់ទ្រង់។ តើអ្នកនឹងឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ទ្រង់ដែរឬទេ? តើអ្នកនឹងចូលរួមជាមួយនឹងព្រះវិហារពិតរបស់ទ្រង់ ហើយធ្វើជាផ្នែកមួយនៃគម្រោងការរបស់ទ្រង់ ដើម្បីផ្សព្វផ្សាយដំណឹងល្អទៅកាន់មនុស្សដទៃទៀតជាមួយនឹងដំណឹងល្អនៃសេចក្តីសង្គ្រោះ ដែរឬទេ? សូមមេត្តាទទួលយកការត្រាស់ហៅរបស់ទ្រង់ ហើយឈរជាមួយនឹងខ្ញុំ ពេលដែលយើងអធិស្ឋាន។

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់កំពុងតែមានបន្ទូលមកកាន់ចិត្តរបស់ពួកទូលបង្គំនាពេលនេះ កំពុងតែត្រាស់ហៅពួកទូលបង្គំម្នាក់ៗទៅកាន់កន្លែងនៅក្នុងព្រះវិហាររបស់ទ្រង់ ហើយនិងការងាររបស់ទ្រង់។ សូមជួយពួកទូលបង្គំឲ្យស្តាប់សំលេងរបស់ទ្រង់បានច្បាស់ ហើយឆ្លើយតបទៅនឹងការហៅរបស់ទ្រង់ដោយថ្វាយខ្លួនរបស់ពួកទូលបង្គំទៅក្នុងគម្រោងការរបស់ទ្រង់។ សូមបង្រៀន និងដឹកនាំពួកទូលបង្គំ ហើយប្រើពួកទូលបង្គំជួយសង្គ្រោះមនុស្សដទៃទៀត។ ពួកទូលបង្គំទូលសូមនៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ</u> ៖

| | | | |
|---|---|---|---|
| និក្ខមនំ ២០:១១ | អេម៉ុស ៣:៧ | កិច្ចការ ២:៤៧ | វិវរណៈ ៦:១ |
| ដានីញ៉ែល ៧:១៥ | ម៉ាថាយ ២៨:១៨,១៩ | រ៉ូម ៦:៣,៤ | វិវរណៈ ៦:៧,៨ |
| ដានីញ៉ែល ៨:១២ | យ៉ូហាន ១៦:១២ | កូឡុស ១:២៣ | វិវរណៈ ១៨:២ |

## លំនាំពិភាក្សា

**អនាម័យនៅតាមផ្ទះសម្បែង**

១. ហេតុអ្វីបានជាការលាងសំអាតដៃ ហើយនិងរាងកាយ គឺជារឿងសំខាន់?
២. ការក្អក និងការខាកស្តោះចំលងមេរោគ។ តើអ្នកអាចបង្ការវាកុំឲ្យកើតមានឡើងបានដោយរបៀបណា?
៣. តើសត្វល្អិតប្រភេទណាដែលមានផ្ទុកនូវជំងឺ? តើអ្នកអាចការពារកុំឲ្យឆ្លងជំងឺពីសត្វទាំងនោះបានដោយរបៀបណា?

**ព្រះវិហារពិត (ភាគ២)**

១. ហោរាយ៉ូហានបានសុបិននិមិត្តអំពីសត្វសេះបួនក្បាល។ តើសត្វសេះពណ៌សមានន័យដូចម្តេច?
- វិវរណៈ ៦:២ - កិច្ចការ ២:៤៧

២. តើសត្វសេះពណ៌ក្រហម មានន័យដូចម្ដេច?

-វិវរណៈ ៦:៤

៣. តើសត្វសេះពណ៌ខ្មៅមានន័យដូចម្ដេច?

-វិវរណៈ ៦:៥,៦ - កិច្ចការ ២០:២៩,៣០

៤. តើសត្វសេះដែលមានសម្បុរស្លេកមានន័យដូចម្ដេច?

-វិវរណៈ ៦:៨

៥. តើសារអ្វីដែលលោកវីលៀម មីលឡឺរ បានរកឃើញ ហើយបានចាប់ផ្ដើមបង្រៀន/អធិប្បាយ?

- ថៃស្សាឡូនិចទី១ ៤:១៦

# មេរៀនសុខភាពទី២៣ - ជំងឺទឹកនោមផ្អែម គឺជាជំងឺដែលបំផ្លាញ



១. ព្រះដែលជាអ្នកបង្កើត គឺជាព្រះដែលមានរបៀបរៀបរយ។ អ្នកអាចមើលឃើញផ្កាយនៅលើមេឃ នៅក្នុងធម្មជាតិ ហើយនិងនៅក្នុងការរចនារាងកាយរបស់មនុស្ស។ ទំនុកតម្កើង ១៣៩: ១៣,១៤ ចែងថា “ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ។ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់...។” កាលណាយើងយល់ពីគម្រោងបែបផែនជីវិតរស់នៅរបស់ព្រះជាម្ចាស់សម្រាប់យើងតាមលំដាប់លំដោយ ហើយសហការជាមួយនឹងវា ទ្រង់ប្រទានពរដល់យើងឲ្យមានសុខភាពល្អ និងមានសុភមង្គល។

វិធីមួយដែលយើងចូលរួមសហការ គឺតាមរយៈការញុំាអាហារដែលព្រះបានបង្កើត សម្រាប់ឲ្យមានសុខភាពល្អ។ អាហារដែលញុំាចូលទៅ ត្រូវបានកិនរំលាយ រលាយទៅជាសារធាតុចិញ្ចឹមតូចៗបំផុត ដើម្បីផ្គត់ផ្គង់ដល់កោសិការាងកាយ ជាមួយនឹងកំលាំងថាមពល ដើម្បីរក្សាម៉ាសុីនដ៏តូចរបស់វាឲ្យដំណើរការ។

ថាមពលទាំងនេះភាគច្រើនមានសណ្ឋានជាគ្លុយកូស ហើយមានឈ្មោះថា “ស្ករឈាម”។ ចំនួនស្ករគ្លុយកូសដែលបានកំណត់កម្រិត ធ្វើដំណើរនៅក្នុងឈាម។ គ្លុយកូស ត្រូវបានផ្ទុកនៅក្នុងសាច់ដុំ ហើយកោសិកាថ្លើមសម្រាប់ដាក់ចូលភ្លាមៗ នៅពេលដែលត្រូវការថាមពលសម្រាប់ការងារ ឬក៏លេង។

ខ្លាញ់ គឺជាសារធាតុចិញ្ចឹម បានមកពីអាហារដែលកិនរំលាយ។ ខ្លាញ់ខាប់ និងផ្ទុកថាមពលទ្វេរដងដូចជាតិម្សៅ ឬក៏ប្រូតេអុីន។ វាត្រូវបានប្រើប្រាស់ក្នុងការធ្វើការធ្ងន់ៗរយៈពេលយូរ ឬក៏ការហាត់ប្រាណខ្លាំងក្លា។ សូម្បីតែមនុស្សដែលស្គម ឬមាឌស្តើង ក៏បានរក្សាទុកខ្លាញ់នៃរាងកាយ ដើម្បីប្រើប្រាស់សម្រាប់ទ្រទ្រង់ការងារដែរ។ ថាមពលដែលនៅសេសសល់នៅក្នុងរាងកាយ គឺត្រូវបានត្រឡប់ទៅជាខ្លាញ់ ហើយត្រូវបានរក្សាទុកជាខ្លាញ់នៃរាងកាយដែរ។

ប្រូតេអុីន ខណៈពេលដែលវាអាចផ្គត់ផ្គង់ថាមពល ភាគច្រើនគឺសម្រាប់តែការលូតលាស់ និងការជួសជុលតែប៉ុណ្ណោះ។

…………………………………………………………………………………………………………………………………………………….

២. អាហាររុក្ខជាតិទាំងមូល (មិនកែច្នៃ) របៀបដែលព្រះបានបង្កើតពួកវាមក មានផ្ទុកអាហារជាតិសរសៃ ដែលមានសារសំខាន់បំផុត នៅក្នុងការសម្រួលដល់ការរំលាយអាហារ ហើយនិងគ្រប់គ្រងពេលវេលាសម្រាប់បញ្ចេញថាមពលចូលទៅក្នុងឈាម ហើយនិងកោសិកា។ អាហារមានចំណុះជាតិសរសៃខុសៗគ្នា៖

ក. ជាតិសរសៃខ្ពស់ - សណ្តែក ប៊ែរី បន្លែមើមដែលមិនបានបកសំបក។

ខ. ជាតិសរសៃមធ្យម - ផ្លែឈើ និងបន្លែ គ្រាប់ធញ្ញជាតិមិនទាន់ចម្រាញ់ គ្រាប់ផ្លែឈើ និងគ្រាប់ពូជ។

គ. ជាតិសរសៃទាប - គ្រាប់ធញ្ញជាតិដែលបានចម្រាញ់ នំប៉័ងពណ៌ស និងផាស្តា ទឹកបន្លែ/ផ្លែឈើ។

ឃ. គ្មានជាតិសរសៃ - ប្រេង ស្ករ កាហ្វេ តែ ភេសជ្ជៈដែលមានជាតិស្ករ ស្រា សាច់សត្វ ហើយនិងផលិតផលដែលធ្វើអំពីសាច់សត្វ។

លំពែង គឺជាសរីរាង្គដែលនៅបាំងពីក្រោយក្រពះ។ កាលណាញុាំអាហារចូលទៅ អ្នកផ្តល់ព័ត៌មានដែលកើតមកពីវីតាមីន សារធាតុរ៉ែខនិជ ហើយនិងសារធាតុគីមីរបស់រុក្ខជាតិ ត្រូវបានធ្វើឲ្យសកម្ម ហើយប្រាប់ដល់លំពែងឲ្យធ្វើការងាររបស់វា។ លំពែងបង្កើតអាំងស៊ុយលីន ជាអរម៉ូនដែលបើកសរសៃប្រសាទរបស់កោសិកាសាច់ដុំ ដើម្បីឲ្យថាមពលគ្លុយកូសចូលទៅក្នុងកោសិកាដើម្បីដុតយកថាមពល។ នៅពេលដែលមានខ្លាញ់ដែលមិនត្រូវការនៅក្នុងកោសិកា សរសៃប្រសាទសម្រាប់ទទួលអាំងស៊ុយលីនបិទ ហើយនឹងមិនបើកឡើយ បណ្តាលឲ្យកោសិកាទប់មិនឲ្យគ្លុយកូសចូលទៅបាន។ ថាមពលមិនអាចចូលទៅដល់កោសិកាបាន តែនៅនៅក្នុងឈាម នាំឲ្យមានគ្លុយកូសលើសចំនួន។

កាលណាឈាមមានគ្លុយកូសច្រើនលើសលុប កោសិកាខ្វះថាមពល ប៉ុន្តែ មិនព្រមឲ្យវាចូល។ លក្ខណៈបែបនេះហៅថា ជំងឺទឹកនោមផ្អែមប្រភេទទី២។ ខ្លាញ់ដែលលើសនៅក្នុងថ្លើម ហើយនិងកោសិកាសាច់ដុំបិទទ្វារកោសិកាសរសៃប្រសាទសម្រាប់ទទួល អាំងស៊ុយលីនមិនអាចយកថាមពលចូលបាន ហើយស្ករគ្លុយកូសកើនឡើងនៅក្នុងឈាម ធ្វើឲ្យវាផ្អែម ហើយស្អិត។ ឈាមស្អិត គឺជាឈាមដែលឈឺ។ វាហូរយឺត ហើយរាងកាយទាំងមូលរងទុក្ខ។

អស់អ្នកដែលងាយនឹងកើតជាជំងឺទឹកនោមផ្អែម គឺជាមនុស្សដែលមានសាច់ត្រគាកច្រើនហើយធំកណ្តាល ជាមនុស្សដែលធាត់លើសទម្ងន់ ហើយមិនហាត់ប្រាណ ឬក៏មានឪពុកម្តាយដែលកើតជំងឺទឹកនោមផ្អែម។

ជំងឺទឹកនោមផ្អែមមានពីរប្រភេទ។ រោគសញ្ញា និងអាការៈ គឺដូចគ្នា ប៉ុន្តែ មូលហេតុដែលបង្កឲ្យកើតជំងឺនេះគឺខុសគ្នា។ ជំងឺទឹកនោមផ្អែមប្រភេទទី២ អាចបង្កា និងព្យាបាលបានដោយការផ្លាស់ប្តូររបៀបរស់នៅ (របបអាហារ និងការរស់នៅ)។ ជំងឺទឹកនោមផ្អែមប្រភេទទី១ គឺបណ្តាលមកពីលំពែងខូច ហើយឈប់បង្កើតអាំងស៊ុយលីន។ ជំងឺនេះច្រើនកើតលើកុមារ ជាញឹកញាប់វាកកើតឡើងព្រមគ្នានឹងការផឹកទឹកដោះគោ។ ត្រូវផ្គត់ផ្គង់អាំងស៊ុយលីនតាមរយៈថ្នាំលេប ឬក៏ចាក់ថ្នាំពេញមួយជីវិត។

………………………………………………………………………………………………….......

៣. រោគសញ្ញា ឬអាការៈនៃជំងឺទឹកនោមផ្អែម

កាលណាកោសិការាងកាយស៊ាំ គ្លុយកូសក្នុងឈាមត្រូវការទឹកបន្ថែមទៀតដើម្បីពង្រាវវា ធ្វើឲ្យកាន់តែស្រេកទឹកខ្លាំង។ តម្រងនោមធ្វើការលើសម៉ោងដើម្បីច្រោះគ្លុយកូសដែលលើសចេញ ធ្វើឲ្យមានទឹកនោមច្រើនលើសលុបដែលមានជាតិផ្អែមបានមកពីជាតិស្ករក្នុងឈាម។ ភ្នែកប្រតិកម្មចំពោះគ្លុយកូសដែលមានលើសលុបត្រូវបានខូច ឬខ្វាក់។ ខួរក្បាលច្របូកច្របល់ ហើយការគិតមានការយឺតយ៉ាវ។ សរសៃរលាក បណ្តាលឲ្យជើង និងដៃឈឺចាក់ឆៀបៗ ស្ពឹក និងឈឺ។ បេះដូងធ្វើការធ្ងន់លើសកម្រិត ហើយសរសៃឈាមឡើងរឹង ធ្វើឲ្យសម្ពាធឈាមឡើងខ្ពស់ ដែលអាចនាំឲ្យកើតជំងឺគាំងបេះដូង។ ដំណើរឈាមរត់យឺត បណ្តាលឲ្យខូចអវៈយវៈចំពោះបុរស។

អស់អ្នកដែលមានអាការៈ ឬរោគសញ្ញាបែបនេះ ត្រូវធ្វើតេស្តរកជំងឺទឹកនោមផ្អែម ហើយព្យាបាលភ្លាមៗដោយគ្រូពេទ្យ។ ទឹកនោមរបស់អ្នកទឹកនោមផ្អែមមានរសជាតិផ្អែម។ នេះគឺជាវិធីសាស្ត្រមួយនៅក្នុងការវិនិច្ឆ័យជំងឺនេះ។ ជំងឺទឹកនោមផ្អែម គឺជាជំងឺដែលវេទនា ជាជំងឺដែលធ្វើឲ្យអស់កំលាំងល្វិតល្វៃ បណ្តាលឲ្យស្លាប់ទាំងនៅវ័យក្មេង ដោយយឺតៗ និងឈឺចាប់។

………………………………………………………………………………………………….......

៤. ការញ៉ាំអាហារដែលមានជាតិខ្លាញ់ខ្ពស់នៅក្នុងរយៈពេលបីម៉ោង ឈាមឡើងខាប់ កោសិកាធ្វើការប្រឆាំងបះបោរ ហើយក៏ស៊ាំ ហើយទ្វារនៃកោសិកាក៏បានបិទ។

កោសិកាស៊ាំ បណ្តាលមកពីរបបអាហារបីយ៉ាង៖

១. **អាហារដែលមានខ្លាញ់–ប្រេង** សាច់សត្វ ប្រហុកបារាំង និងអាហារដែលធ្វើមកពីទឹកដោះគោ គឺងាយប្រែក្លាយទៅខ្លាញ់នៃរាងកាយ។

២. **អាហារដែលគ្មានជាតិសរសៃ** ម្សៅ និងស្ករដែលចម្រាញ់ ដែលមិនបានយកទៅប្រើប្រាស់សម្រាប់បញ្ចេញថាមពល ត្រូវបានធ្វើឲ្យត្រឡប់ទៅជាខ្លាញ់របស់រាងកាយ។

៣. **ខ្លាញ់រាងកាយដែលលើសចំណុះ** កោសិកាខ្លាញ់រីកកាន់តែធំឡើង នៅពេលដែលវាស្តុកខ្លាញ់ដែលលើសចំណុះ ខ្លាញ់ដែលលើសនោះរត់នៅក្នុងឈាម ធ្វើឲ្យកោសិកាសាច់ដុំស៊ាំទៅនឹងថាមពលរបស់គ្លុយកូស។

…………………………………………………………………………………………………………………………........
.

៥. ការសម្របសម្រួលរបៀបរស់នៅឲ្យបានត្រឹមត្រូវ អាចជួយធ្វើឲ្យអ្នកកើតជំងឺទឹកនោមផ្អែមប្រភេទទី១ មានសុខភាពល្អប្រសើរ ហើយនិងអាចជួយឲ្យអ្នកកើតជំងឺទឹកនោមផ្អែមប្រភេទទី២ភាគច្រើនជាសះស្បើយបាន!!!

ក. ការហាត់ប្រាណ - វាសំអាតខ្លាញ់ចេញពីកោសិកាយ៉ាងមានប្រសិទ្ធភាព ហើយបើកទ្វារសរសៃប្រសាទឲ្យអាំងស៊ុយលីនចូល។

ខ. ចៀសវាងអាហារដែលគេយកខ្លាញ់សត្វមកប្រើប្រាស់ សាច់សត្វ ប្រហុកបារាំង(ធ្វើពីទឹកដោះគោ) ហើយនិងរបស់ញ៉ាំដែលធ្វើពីទឹកដោះគោ។

គ. ត្រូវញ៉ាំផ្លែឈើ និងបន្លែ សណ្តែក និងគ្រាប់ផ្លែឈើដែលមានជាតិសរសៃច្រើន។

ឃ. ត្រូវញ៉ាំគ្រាប់ធញ្ញជាតិដែលមិនចម្រាញ់។

ង. កុំញ៉ាំលើសកំណត់! ត្រូវដាក់បន្លែ និងសណ្តែកពាក់កណ្តាលចានរបស់អ្នក ហើយកុំញ៉ាំពោត បាយ ឬបន្លែមើមច្រើនហួសកំណត់។

ច. ចៀសវាងញ៉ាំភេសជ្ជៈដែលមានឧស្ម័ន(ហ្គាស) ហើយនិងអាហារដែលមានជាតិផ្អែម។ ព្រះគម្ពីរចែងថា "តើឯងរកបានឃ្មុំហើយឬ? ចូរបរិភោគតែល្មមសមគួរចុះ ក្រែងបរិភោគឆ្អែតទៅនឹងក្អួតចេញមកវិញ" (សុភាសិត ២៥:១៦)។

## គ្រោះកាចចង្រៃចុងក្រោយទាំង៧



ព្រះជាម្ចាស់បានត្រាស់ហៅគ្រួសារមួយឲ្យធ្វើជាអ្នកនាំសាររបស់ទ្រង់ទៅកាន់ពិភពលោក។ គ្រួសារដំបូងគេ គឺគ្រួសាររបស់លោកអាប្រាហាំ បន្ទាប់មកកូនរបស់គាត់ឈ្មោះអ៊ីសាក់ ហើយបន្ទាប់មក កូនប្រុសរបស់អ៊ីសាក់ ឈ្មោះយ៉ាកុប។ ព្រះជាម្ចាស់បានប្តូរឈ្មោះរបស់យ៉ាកុប ទៅជាអ៊ីស្រាអែល។ កូនប្រុសនីមួយៗរបស់អ៊ីស្រាអែលក្លាយទៅជាមេដឹកនាំនៃកុលសម្ព័ន្ធរបស់ខ្លួន។ ព្រះជាម្ចាស់បានសន្យាប្រទានពរដល់កុលសម្ព័ន្ធទាំង១២នេះ។ ព្រះគម្ពីរហៅមនុស្សនៃកុលសម្ព័ន្ធទាំងអស់នេះថា ជាកូនចៅរបស់លោកអុីស្រាអែល។

ពួកគេបានទៅរស់នៅក្នុងប្រទេសអេហ្សុីព ពីព្រោះមានគ្រោះអត់ឃ្លាននៅក្នុងប្រទេសរបស់ពួកគេ។ កាលពីដំបូង ពួកជនជាតិអេហ្ស៊ីព្សសរាយរាក់ទាក់ តែនៅទីបំផុត

ពួកគេក៏បានប្រែប្រួល។ មេដឹកនាំរបស់ប្រទេសអេហ្ស៊ីព បានងាកមកប្រឆាំងជាមួយនឹងពួកគេ ហើយបង្ខំពួកគេឲ្យធ្វើជាទាសករ។ ជាច្រើនឆ្នាំបានកន្លងផុតទៅ កូនចៅរបស់អ៊ីស្រាអែលបានរងទុក្ខវេទនានៅក្រោមចៅហ្វាយទាសករដ៏កាចសាហាវ។ ពួកគេបានស្រែកសុំព្រះឲ្យជួយ។ សូមស្តាប់ ៖

"នោះពួកកូនចៅអុ៊ីស្រាអែលគេថ្ងូរឡើង ដោយព្រោះការទុក្ខលំបាក ហើយក៏អំពាវនាវ ដល់ព្រះ ដោយព្រោះការទុក្ខលំបាករបស់ខ្លួន នោះទ្រង់ក៏ឮ។ ទ្រង់ឮដំងូររបស់គេ ហើយក៏នឹកចាំពីសេចក្តីសញ្ញាដែលទ្រង់បានតាំងនឹងអាប្រាហាំ និងអ៊ីសាក់ ហើយនិងយ៉ាកុប" (និក្ខមនំ ២:២៣,២៤)។

……………………………………………………………………………………………........

.



ព្រះបានជ្រើសតាំងបុរសម្នាក់ឈ្មោះម៉ូសេ ឲ្យទៅរំដោះកូនចៅអ៊ីស្រាអែលចេញពីអំពើទាសភាព ដើម្បីឲ្យពួកគេអាចចាកចេញពីអេហ្សុ៊ីព ហើយទៅកាន់ទឹកដីដែលព្រះបានសន្យាដល់ពួកគេ។ លោកម៉ូសេបានទៅគាល់ស្តេចផារ៉ោនជាមួយនឹងបងប្រុសរបស់គាត់ គឺលោកអ៊ើរ៉ុន។ ពួកគាត់បានទូលប្រាប់ទ្រង់អំពីការបញ្ជារបស់ព្រះជាម្ចាស់។

"ព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានព្រះបន្ទូលដូច្នេះថា ចូរឲ្យរាស្ត្រអញចេញទៅ" (និក្ខមនំ ៥:១)។

ស្តេចផារោនបានមានព្រះបន្ទូលតបថា ៖

"តើព្រះយេហូវ៉ាជាអ្នកណា ដែលអញត្រូវស្តាប់តាមទ្រង់ និងឲ្យសាសន៍អ៊ីស្រាអែលចេញទៅនោះ អញមិនស្គាល់ព្រះយេហូវ៉ាទេ ហើយក៏មិនព្រមឲ្យសាសន៍អ៊ីស្រាអែលចេញទៅឡើយ" (និក្ខមនំ ៥:២)។

ស្តេចផារោនមិនមានបំណងចង់បាត់បង់ទាសកររបស់ទ្រង់ឡើយ។ ទ្រង់បានបញ្ជាមេគ្រប់គ្រងពួកទាសករ ឲ្យដាក់ការងារឲ្យពួកទាសករធ្វើកាន់តែធ្ងន់ថែមទៀត។ ព្រះជាម្ចាស់បានបញ្ជូនលោកម៉ូសេ ហើយនិងលោកអ៊ើរ៉ុន ជាមួយនឹងសារទៅស្តេចផារ៉ោនផងសុំទ្រង់ម្តងទៀតឲ្យអនុញ្ញាតឲ្យកូនចៅអ៊ីស្រាអែលចេញទៅ។

"ឯព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា ស្តេចនឹងដឹងថា អញជាព្រះយេហូវ៉ាដោយសារការនេះ" (និក្ខមនំ ៧:១៧)។

ហើយបន្ទាប់មក ដើម្បីបង្ហាញពីអំណាចរបស់ព្រះជាម្ចាស់ លោកអ៊ើរ៉ុនបានលើកដំបងគាត់ដាក់ពីលើទឹកទន្លេ។ ទឹកក៏ប្រែទៅជាឈាម។ សូមស្តាប់ ៖

"ត្រីដែលនៅក្នុងទន្លេក៏ស្លាប់ ទឹកទន្លេក៏ធំក្លិនស្អុយ ហើយសាសន៍អេហ្ស៊ីពផឹកទឹកពីទន្លេមិនបាន ក៏មានឈាមនៅពេញក្នុងស្រុកអេហ្សុ៊ីពផង"(និក្ខមនំ ៧:២១)។

បើសិនជាអ្នក និងខ្ញុំបានទៅទីនោះ នៅកន្លែងរបស់ស្តេចផារ៉ោន ខ្ញុំគិតថាយើងច្បាស់ជានិយាយថា "បញ្ឈប់នូវគ្រោះកាចចង្រៃនេះទៅ! សូមកុំឲ្យមានទឹកពណ៌ឈាមទៀតអី! ចូរយកកូនចៅអ៊ីស្រាអែល ហើយចាកចេញពីប្រទេសអេហ្ស៊ីពភ្លាមទៅ!

ប៉ុន្តែ ស្តេចផារ៉ោនមិនធ្វើបែបនេះទេ។ អត់ទេ។ ព្រះទ័យរបស់ទ្រង់រឹងណាស់។ ទ្រង់បានសម្រេចព្រះទ័យហើយ។ ទ្រង់ចង់ទុកកូនចៅអ៊ីស្រាអែល ធ្វើជាទាសករ មិនថា មានរឿងអ្វីកើតឡើងក៏ដោយ។

ដូច្នេះ ព្រះជាម្ចាស់បានបញ្ជូនគ្រោះកាចចង្រៃបន្ថែមទៀតទៅលើស្តេចផារ៉ោន ហើយនិងរាស្ត្ររបស់ទ្រង់។ ទាំងអស់មានគ្រោះកាចចង្រៃចំនួន១០។ មុនរាល់គ្រោះកាចចង្រៃធ្លាក់មកដល់ លោកម៉ូសេ ហើយនិងលោកអ៊ើរ៉ុន បានព្រមានស្តេចផារ៉ោនអំពីការជំនុំជំរះដែលនឹងមកដល់ សង្ឃឹមថាទ្រង់នឹងសម្រេចព្រះទ័យដោះលែងកូនចៅអ៊ីស្រាអែល។ ប៉ុន្តែ រៀងរាល់ពេលដែលព្រះជាម្ចាស់បានផ្តល់ឱកាសឲ្យទ្រង់ផ្លាស់ប្តូរ ព្រះទ័យម្តងៗ ស្តេចផារ៉ោនបែរជាសម្រេចព្រះទ័យរឹងទទឹងកាន់តែខ្លាំង។

........................................................................................................................................

.



បន្ទាប់មក គ្រោះកាចចង្រៃជាសត្វកង្កែបមានពាសពេញទឹកដី។ មានច្រើនរាប់លាន! មាននៅក្នុងអាហារ នៅតាមគ្រែ មានគ្រប់ទីកន្លែង! ក្រោយមក គ្រោះកាចចង្រៃជាសត្វចៃ។ គ្រោះកាចចង្រៃបីបានកន្លងផុតទៅ។ គ្រប់គ្នានៅក្នុងទឹកដីនោះបានទទួលរងគ្រោះពីសត្វចៃនោះ។ សូម្បីតែកូនចៅអ៊ីស្រាអែលក៏ត្រូវទទួលរងពីវាដែរ។

ប៉ុន្តែ នៅក្នុងគ្រោះកាចចង្រៃចុងក្រោយទាំង៧ គឺសម្រាប់តែពួកអេហ្ស៊ីពប៉ុណ្ណោះ។ ព្រះជាម្ចាស់បានបញ្ជូនសារទៅស្តេចផារ៉ោន។

“អញនឹងញែកស្រុកកូសែនដែលរាស្ត្រអញនៅ ... អញនឹងផ្តាច់រាស្ត្រអញ និងរាស្ត្រឯងឲ្យដាច់ចេញពីគ្នា” (និក្ខមនំ ៨:២២,២៣)។

បន្ទាប់មក មានរុយចូលមកពេញទឹកដីអេហ្ស៊ីព លើកលែងតែកូសែន ជាកន្លែងដែលកូនចៅអ៊ីស្រាអែលរស់នៅ។ អ្នកស្រមៃមើលទៅ វាយ៉ាងម៉េចដែរ? សត្វរុយមាននៅគ្រប់ទីកន្លែង។ ពួកអេហ្ស៊ីពពិបាកនឹងបើកមាត់ណាស់ ព្រោះរុយហើរចូលមាត់។

បន្ទាប់មក ក៏មានជំងឺគួរឲ្យខ្លាចដែលបានសម្លាប់សត្វដែលគេចិញ្ចឹមស្តុកធ្វើជាអាហាររបស់ពួកអេហ្ស៊ីព។ សត្វសេះ សត្វលា សត្វគោ សត្វអូដ្ឋ ហើយថែមទាំងសត្វចៀម។ ប៉ុន្តែ គ្មានសត្វចិញ្ចឹមរបស់កូនចៅអ៊ីស្រាអែលណាត្រូវបានស្លាប់ឡើយ។

គ្រោះកាចចង្រៃទី៦ គឺធ្វើឲ្យមនុស្ស និងសត្វកើតបូស ប៉ុន្តែ ស្តេចដ៏ចចេសរឹងរូសនេះនៅតែមិនព្រមដោះលែងកូនចៅអ៊ីស្រាអែលដដែល។

មុនគ្រោះកាចចង្រៃទី៧ លោកម៉ូសេបានព្រមានដាស់តឿនជនជាតិអេហ្ស៊ីពឲ្យការពារខ្លួន។ វានឹងមានព្យុះព្រិលយ៉ាងខ្លាំងលាយឡំជាមួយនឹងផ្គររន្ទះផង។ អស់អ្នកដែលស្តាប់តាមការព្រមានដាស់តឿននឹងមានសុវត្ថិភាព តែ អស់អ្នកដែលមិនបានត្រៀមខ្លួនសម្រាប់ពេលនេះទេ នឹងត្រូវស្លាប់ដោយសារព្យុះ។

លោកម៉ូសេបានព្រមានដាស់តឿនស្តេចផារ៉ោនហើយថា បើសិនជាទ្រង់នៅតែមិនព្រមឲ្យកូនចៅអ៊ីស្រាអែលចាកចេញទេ គ្រោះកាចចង្រៃបន្ទាប់នឹងមានហ្វូងកណ្តូបច្រើន។ ទីប្រឹក្សារបស់ស្តេចផារ៉ោនបានទូលសុំអង្វរទ្រង់ឲ្យដោះលែងពួកទាសករទៅ ប៉ុន្តែ ស្តេចនៅតែមិនព្រម។ ព្រះជាម្ចាស់បានបញ្ជូនខ្យល់មកពីទិសខាងកើត ដែលនាំកណ្តូបយ៉ាងច្រើនពាសពេញមេឃមកក្នុងប្រទេសអេហ្ស៊ីព។

ព្រះគម្ពីរពិពណ៌នាវាតាមរបៀបនេះ៖
"ដ្បិតវាមកគ្របពេញពីលើដី ដល់ម្ល៉េះបានជាស្រុកត្រឡប់ទៅជាងងឹត វាក៏ស៊ីដំណាំទាំងអស់នៅក្នុងស្រុក ហើយនឹងអស់ទាំងផ្លែឈើ ដែលរួចអំពីព្រិលមក គ្មានសល់ស្លឹកខ្ចីណាមួយនៅដើមឈើ ឬស្មៅនៅវាលគ្រប់ក្នុងស្រុក អេហ្ស៊ីពឡើយ" (និក្ខមនំ ១០:១៥)។
បន្ទាប់មក គ្រោះកាចចង្រៃទី៩ក៏បានមកដល់ : មានភាពងងឹតខ្លាំងដែលអាចពាល់បាន ដល់ទៅ៣ថ្ងៃ។ ប៉ុន្តែ ស្តេចចោលម្សៀតផារ៉ោន នៅតែមិនព្រមចុះចាញ់ព្រះនៃនគរឋានសួគ៌។

………………………………………………………………………………………………………………........
.



លោកម៉ូសេបានព្រមានថា មានគ្រោះកាចចង្រៃមួយទៀតនឹងចាក់មកលើជនជាតិអេព។ ទេវតាដែលបំផ្លាញនឹងឆ្លងកាត់តាមទឹកដីនៅពាក់កណ្តាលអាធ្រាត ហើយនិងសំលាប់កូនដំបូងទាំងអស់នៅក្នុងប្រទេសអេហ្ស៊ីព ទាំងមនុស្ស ហើយនិងសត្វ។

ជាថ្មីម្តងទៀត កូនចៅអុីស្រាអែលក៏ត្រូវបានរក្សាទុក ប៉ុន្តែ លុះត្រាតែពួកគេធ្វើតាមការណែនាំរបស់ព្រះជាម្ចាស់។ គ្រួសារនីមួយៗ ត្រូវសំលាប់កូនចៀម ហើយប្រោះឈាមរបស់វាខ្លះនៅលើព្រំទ្វារតាមផ្ទះរបស់ពួកគេ។ នេះគឺជាសេចក្តីសន្យារបស់ព្រះជាម្ចាស់៖
"ផ្ទះណាអញឃើញឈាម នោះអញនឹងរំលងផុតពីឯងរាល់គ្នាទៅ ហើយនឹងគ្មានសេចក្តីវេទនាណាបំផ្លាញឯងរាល់គ្នា ក្នុងវេលាដែលអញវាយស្រុកអេហ្ស៊ីនោះឡើយ" (និក្ខមនំ ១២:១៣)។
ព្រះគម្ពីរបានកត់ត្រាទុកនូវអ្វីដែលបានកើតមានឡើងនៅយប់ដ៏គួរឲ្យខ្លាចនោះ៖ "រីឯនៅកណ្តាលអធ្រាត្រក្នុងយប់នោះ ព្រះយេហូវ៉ាទ្រង់ក៏វាយអស់ទាំងកូនច្បងនៅស្រុកអេហ្សុីព ចាប់តាំងពីបុត្រច្បងរបស់ផារ៉ោន ដែលគង់លើបល្ល័ង្ករាជ្យ រហូតដល់កូនច្បងរបស់អ្នកទោសនៅក្នុងគុក ព្រមទាំងកូនច្បងនៃអស់ទាំងសត្វផង" (និក្ខមនំ ១២:២៩)។
អ្នកអាចស្រមៃដឹងហើយថាវាយ៉ាងម៉េចនៅក្នុងប្រទេសអេហ្សុីពនោះ នៅពេលដែលព្រះអាទិត្យរះនៅពេលព្រឹកថ្ងៃបន្ទាប់។ ការស្លាប់បានវាយលុកពីមនុស្សដែលមានវណ្ណៈខ្ពង់ខ្ពស់ ចុះមកមនុស្សដែលមានវណ្ណៈទាបបំផុត។ គេឮសូរសម្រែករបស់អ្នកកាន់ទុក្ខពាសពេញទឹកដី។
នៅក្នុងផ្ទះដែលមានស្នាមឈាមប្រោះនៅលើព្រំទ្វារ គ្មានកូនច្បងដែលកើតដំបូងណាត្រូវបានប៉ះពាល់ឡើយ!
នៅទីបំផុត ស្តេចផារ៉ោនជ្រាបដឹងនូវកំហុសដ៏ធ្ងន់ធ្ងរដែលទ្រង់បានធ្វើ។ ទ្រង់បានចាត់គេឲ្យទៅរកលោកម៉ូសេ ហើយនិងអឺរ៉ុន ហើយជំរុញឲ្យពួកគេយកកូនចៅអ៊ីស្រាអែលចេញភ្លាមៗ។ រាស្ត្ររបស់ព្រះជាម្ចាស់ត្រូវបានរំដោះឲ្យមានសេរីភាព! ពួកគេធ្វើដំណើរទៅកាន់ទឹកដីដែលព្រះបានសន្យាចំពោះដូនតារបស់ពួកគេ!
មិត្តអើយ តើអ្នកមានអារម្មណ៍យ៉ាងណា បើសិនជាខ្ញុំប្រាប់អ្នកថា ព្រះនឹងប្រាប់អ្នកថានឹងបញ្ជូនគ្រោះកាចចង្រៃមកលើផែនដីម្តងទៀត? មិនមែនតែទៅលើប្រទេសអេហ្សុីពប៉ុណ្ណោះទេ ប៉ុន្តែ ទៅលើពិភពលោកទាំងមូល។ តើអ្នកនឹងជឿ ដែរឬទេ?

ព្រះគម្ពីរវិវរណៈទាយថា គ្រោះកាចចង្រៃចុងក្រោយទាំង៧នឹងធ្លាក់ទៅលើផែនដីមុននឹងព្រះយេស៊ូយាងត្រឡប់មកវិញ។ ដូចនៅក្នុងប្រទេសអេហ្ស៊ីពតាំងពីយូរមកហើយដែរ រាស្ត្ររបស់ព្រះនឹងត្រូវបានការពារ។



មុនហេតុការណ៍នោះកើតឡើង រាស្ត្ររបស់ព្រះនឹងបញ្ចប់ការងារដែលទ្រង់បានផ្តល់ឲ្យពួកគេធ្វើ។ ហោរាបានពិពណ៌នាពួកគេថា ជាទេវតានាំសារដែលព្រះជាម្ចាស់បានបញ្ជូនមកឲ្យរៀបចំពិភពលោកសម្រាប់ការយាងមករបស់ព្រះយេស៊ូ។ សូមស្តាប់៖

"ខ្ញុំក៏ឃើញទេវតា១ទៀត កំពុងហោះកាត់កណ្តាលមេឃ ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សម្រាប់នឹងថ្លែងប្រាប់ដល់មនុស្សនៅផែនដី គឺដល់គ្រប់អស់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងគ្រួសារដែរ" (វិវរណៈ ១៤:៦)។

"មានទេវតា១ទៀតមកតាមក្រោយប្រាប់ថា ក្រុងបាប៊ីឡូនដ៏ជាធំ បានរលំហើយ..." (វិវរណៈ ១៤:៨)។

នៅក្នុងបទទំនាយនេះ បាប៊ីឡូន គឺជាសញ្ញានៃសាសនាក្លែងក្លាយរបស់ពិភពលោក។

នៅមានទៀត។ សូមស្តាប់៖ "រួចមានទេវតាទី៣មកតាមក្រោយទៀត ទាំងបន្លឺសំលេងយ៉ាងខ្លាំងថា បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ហើយទទួលទីសំគាល់វា ... អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តីឃោរឃៅរបស់ព្រះ"
(វិវរណៈ ១៤:៩,១០)។

ពិតណាស់ "ស្រាផងសេចក្តីឃោរឃៅរបស់ព្រះ" គឺគ្រាន់តែជាភាសាតំណាង។ គឺសំដៅទៅលើការដាក់ទោសយ៉ាងធ្ងន់ធ្ងរ ដែលនឹងធ្លាក់ទៅលើអ្នកទាំងឡាយណា ដែលមានលក្ខណៈដូចជាស្តេចផារ៉ោន ដែលមិនព្រមទទួលសាររបស់ព្រះ ហើយមិនខ្វល់អំពីការព្រមានដាស់តឿនរបស់ទ្រង់។ សម្រាប់អ្នកទាំងអស់នោះ នឹងគ្មានការព្រមាន ដាស់តឿន គ្មានការហៅឲ្យទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់ពួកគេទៀតឡើយ។ សម្រាប់ពួកគេ ទ្វារនៃសេចក្តីមេត្តានឹងត្រូវបិទជារៀងរហូត។

ចុះអំពីរាស្ត្ររបស់ព្រះនៅក្នុងកំឡុងពេលដែលយ៉ាប់យ៉ឺននោះ? ពួកគេនឹងនៅលើផែនដីនេះ រហូតដល់ទីបញ្ចប់! ពួកគេនឹងត្រូវបានការពារនៅក្នុងកំឡុងពេលមានគ្រោះកាចចង្រៃ ប៉ុន្តែ ពួកគេនឹងមិនគេចរួចពីទុក្ខលំបាក ហើយនិងការឈឺចាប់ឡើយ។ គ្រប់គ្នានឹងជួបបញ្ហានៅក្នុងពេលណាមួយ។



នេះគឺជាអ្វីដែលហោរាបានសរសេរ៖

"ខ្ញុំក៏ឃើញទីសំគាល់១ទៀត ដែលធំហើយអស្ចារ្យនៅលើមេឃ គឺមានទេវតា៧ ដែលកាន់សេចក្តីវេទនាទាំង៧ក្រោយបង្អស់ ដ្បិតសេចក្តីឃោរឃៅរបស់ព្រះបានសម្រេច ដោយសេចក្តីវេទនាទាំងនោះ" (វិវរណៈ ១៥:១)។

"ខ្ញុំក៏ឮសំឡេង១យ៉ាងខ្លាំងចេញពីព្រះវិហារ ប្រាប់ទៅទេវតាទាំង៧ថា ចូរចាក់សេចក្តីឃោរឃៅរបស់ព្រះ ដែលនៅក្នុងចានទាំង៧ ទៅលើផែនដីទៅ។"
(វិរណៈ ១៦:១)

“ទេវតាទី១ក៏ចេញទៅ ចាក់ពីចានខ្លួន ទៅលើផែនដី នោះមនុស្សដែលមានទីសំគាល់របស់សត្វ និងអស់ពួកអ្នកដែលក្រាបថ្វាយបង្គំដល់រូបវា គេក៏កើតដំបៅកាចអាក្រក់” (វិវរណៈ ១៦:២)។

“ទេវតាទី២ ក៏ចាក់ពីចានខ្លួន ទៅក្នុងសមុទ្រ រួចសមុទ្រត្រឡប់ទៅជាឈាម ដូចជាសមុទ្រខ្មោច ហើយគ្រប់ទាំងសត្វនៅក្នុងសមុទ្រក៏ស្លាប់អស់” (វិវរណៈ ១៦:៣)។

“ទេវតាទី៣ ក៏ចាក់ពីចានខ្លួន ទៅក្នុងទន្លេ និងរន្ធទឹកទាំងប៉ុន្មាន នោះក៏ប្រែទៅជាឈាមទាំងអស់ដែរ” (វិវរណៈ ១៦:៤)។

នេះមិនល្អទាល់តែសោះ មែនទេ? ប៉ុន្តែ ទេវតាបរិសុទ្ធមើលឃើញថាព្រះជាម្ចាស់ទ្រង់យុត្តិធម៌គ្រប់ទាំងអស់។ ហោរាបានឮទេវតាមួយរូបនិយាយដូច្នេះថា៖

“ ឱព្រះដ៏គង់នៅ ហើយបានគង់នៅតាំងពីដើមរៀងមកអើយ ដែលទ្រង់បានជំនុំជំរះកាត់ទោសដូច្នេះ នោះសុចរិតហើយ។ ដ្បិតគេបានកំចាយឈាមនៃពួកបរិសុទ្ធ និងពួកហោរា ហើយទ្រង់បានប្រទានឈាមឲ្យគេផឹក” (វិវរណៈ ១៦:៥,៦)។

សាច់រឿងបន្តទៅទៀត៖

“ទេវតាទី៤ក៏ចាក់ពីចានខ្លួន ទៅលើព្រះអាទិត្យរួចព្រះអាទិត្យបានអំណាចនឹងធ្វើឲ្យមនុស្សត្រូវខ្លោច ដោយសារភ្លើង។ មនុស្សលោកក៏ត្រូវខ្លោចទៅ ដោយអំណាចក្តៅជាខ្លាំង តែគេមិនបានប្រែចិត្តដើម្បីនឹងលើកសរសើរដល់សិរីល្អនៃព្រះទេ គឺគេប្រមាថដល់ព្រះនាមព្រះ...” (វិវរណៈ ១៦:៨,៩)។

“ឯទេវតាទី៥ ក៏ចាក់ពីចានខ្លួន ទៅលើបល្ល័ង្ករបស់សត្វនោះ រួចនគរវាត្រឡប់ទៅជាងងឹតសូន្យសុង ហើយគេខាំអណ្តាត ដោយមានសេចក្តីទុក្ខលំបាក” (វិវរណៈ ១៦:១០)។

“ទេវតាទី៦ ក៏ចាក់ពីចានខ្លួន ទៅលើទន្លេធំ គឺជាទន្លេអើប្រាត រួចទឹកទន្លេនោះក៏រីងទៅ ដើម្បីឲ្យបានរៀបចំផ្លូវរបស់ពួកស្តេចពីទិសខាងថ្ងៃរះ។ រួចខ្ញុំឃើញវិញ្ញាណអសោច ៣ ដូចជាកង្កែប ...ដែលចេញទៅឯអស់ទាំងស្តេច នៅផែនដីទាំងមូល ទាំងធ្វើទីសំគាល់ដើម្បីនឹងប្រមូលស្តេចទាំងនោះមកក្នុងចំបាំង នៅថ្ងៃដ៏ធំរបស់ព្រះដ៏មានព្រះចេស្តាបំផុត” (វិវរណៈ ១៦:១២-១៤)។

ជាមួយនឹងពាក្យសម្តីទាំងនោះ ហោរាបានមើលដឹងនូវគ្រប់ឥទ្ធិពលអាក្រក់នៃការប្រមូលផ្តុំរបស់ពិភពលោក ដើម្បីប្រយុទ្ធប្រឆាំងជាមួយនឹងព្រះជាម្ចាស់ ហើយនិងរាស្ត្ររបស់ទ្រង់។ ឆាករឿងត្រូវបានរៀបចំ សម្រាប់គ្រោះកាចចង្រៃចុងក្រោយ។

“ទេវតាទី៧ ក៏ចាក់ពីចានខ្លួន ទៅក្នុងអាកាស រួចមានឮសំលេងខ្លាំងចេញពីបល្ល័ង្កក្នុងព្រះវិហារនៅស្ថានសួគ៌មកថា ស្រេចហើយ!”

“រួចមានផ្លេកបន្ទោរ សូរសំលេង និងផ្គរលាន់ ហើយមានកក្រើកដីជាខ្លាំងដែរ...។ នោះគ្រប់ទាំងកោះក៏បាត់ទៅ ហើយមិនឃើញមានភ្នំណាទៀតសោះឡើយ។”

“ក៏មានព្រិលយ៉ាងធំៗ គ្រាប់១ទម្ងន់១ហាប ធ្លាក់ចុះពីផ្ទៃមេឃមកលើមនុស្ស...ហើយមនុស្សលោកក៏ប្រមាថដល់ព្រះ ដោយព្រោះសេចក្តីវេទនានឹងព្រិលនោះ ពីព្រោះសេចក្តីវេទនានោះជាខ្លាំងក្រៃលែង” (វិវរណៈ ១៦:១៧,១៨, ២០,២១)។

សំលេងនិយាយចេញពីបល្ល័ង្កមកថា “ស្រេចហើយ!” ពាក្យសម្តីទាំងនោះមានន័យថានៅទីបំផុតអាណាចក្រ និងនគរនៃពិភពលោកនេះ គឺត្រូវបានចប់ហើយ។ គឺជារឿង

ហេតុ។ ព្រះយេស៊ូយាងមកវិញដើម្បីរាស្ត្ររបស់ទ្រង់ ហើយនគររបស់ទ្រង់នឹងមិនដែលចប់ឡើយ។

……………………………………………………………………………………………………........

.



មិត្តអើយ តើអ្នកចង់ច្បាស់អំពីការការពាររបស់ព្រះជាម្ចាស់ នៅពេលដែលពេលទុក្ខវេទនាដ៏ធំមកដល់ ដែរឬទេ? មានផ្លូវតែមួយប៉ុណ្ណោះ។

ចូរចងចាំ នៅពេលដែលគ្រោះកាចចង្រៃដ៏អាក្រក់ចុងក្រោយបានធ្លាក់ទៅលើប្រជាជនអេហ្ស៊ីព។ កូនប្រុសច្បងដែលកើតដំបូងត្រូវបានសំលាប់ពាសពេញផ្ទៃប្រទេស។ ប៉ុន្តែ មិនមែននៅក្នុងផ្ទះរបស់អ្នកដែលមានឈាមប្រោះនៅលើព្រំទ្វារនោះឡើយ។ ផ្ទះទាំងអស់នោះត្រូវបានការពារ។

នៅសម័យចុងក្រោយ គឺជាឈាមរបស់កូនចៀមដែលនឹងការពារយើង។ ព្រះយេស៊ូដែលជាកូនចៀមរបស់ព្រះជាម្ចាស់ បានលះបង់ព្រះជន្មទ្រង់ដើម្បីសង្គ្រោះយើង។ នៅពេលដែលយើងទទួលយកទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើង ព្រះលោហិតរបស់ទ្រង់លាងសំអាតយើងចេញពីអំពើបាប។ ព្រះវរបិតាទទួលយកយើងជាកូនចៅរបស់ទ្រង់។ យើងអាចទទួលយកសេចក្តីសន្យានៃព្រះបន្ទូលរបស់ទ្រង់។ សូមស្តាប់៖

"ឯងនឹងមិនភ័យខ្លាចអ្វីឡើយ ទោះទាំងសេចក្តីស្ញែងខ្លាចនៅពេលយប់ឬព្រួញដែលហើរនៅពេលថ្ងៃ ឬសេចក្តីវេទនាដែលតែងមាននៅក្នុងទីងងឹត ឬសេចក្តីហិនវិនាស ដែលបំផ្លាញនៅពេលថ្ងៃត្រង់ផង នឹងមានមនុស្ស១ពាន់នាក់ដួលស្លាប់នៅក្បែរឯង ហើយ១ម៉ឺននាក់នៅខាងដៃស្តាំឯងដែរ តែសេចក្តីនោះនឹងមិនមកជិតឯងឡើយ ឯងនឹងបានក្រឡេកឃើញការតបស្នងដល់ពួកមនុស្សអាក្រក់ដោយភ្នែកតែប៉ុណ្ណោះទេ ពីព្រោះឯងបានថា ព្រះយេហូវ៉ាជាទីពឹងជ្រកនៃឯងគឺបានយកព្រះដ៏ខ្ពស់បំផុត ជាទីលំនៅរបស់ឯង យ៉ាងនោះនឹងគ្មានសេចក្តីអាក្រក់ណាកើតឡើងដល់ឯងឡើយ ក៏គ្មានវេទនាណាមកជិតទីលំនៅរបស់ឯងដែរ ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់ ពីដំណើរឯងឲ្យបានថែរក្សាឯង ក្នុងគ្រប់ទាំងផ្លូវរបស់ឯង"(ទំនុកតម្កើង ៩១:៥-១១)។

ឥឡូវ គឺជាពេលវេលាសម្រាប់យើងម្នាក់ៗ ដើម្បីបញ្ជាក់ថាយើងមានសុវត្ថិនៅក្នុងព្រះយេស៊ូ។ សូមទ្រង់ធ្វើជាព្រះអង្គសង្គ្រោះរបស់អ្នកចុះ។ ទូលសូមព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ឲ្យយាងចូលក្នុងចិត្តរបស់អ្នក។ ទ្រង់នឹងបង្ហាញអ្នកនូវអំពើបាបរបស់អ្នក ហើយផ្តល់ឲ្យអ្នកនូវក្តីសោកសៅចំពោះពួកវា។ ទ្រង់នឹងដឹកនាំអ្នកឲ្យទៅលន់តួ ហើយទ្រង់នឹងអភ័យទោសឲ្យអ្នក និងផ្តល់ឲ្យអ្នកនូវចិត្ត និងគំនិតស្អាតស្អំ។ ដោយសារអំណាចរបស់ទ្រង់ អ្នកនឹងបំបាត់ចោលនូវទម្លាប់អាក្រក់ ហើយរស់នៅជីវិតថ្មី។

ពេលដែលអ្នកឃើញព្រះកែប្រែចិត្តរបស់អ្នក អ្នកនឹងកាន់តែស្រឡាញ់ទ្រង់ថែមទៀត។ អ្នកនឹងជឿទុកចិត្តលើទ្រង់ ហើយមានទំនុកចិត្តនៅក្នុងអំពើល្អរបស់ទ្រង់។ អ្នកនឹងចង់ប្រាប់គ្រប់គ្នា នូវអ្វីដែលទ្រង់បានធ្វើដើម្បីអ្នក នោះហើយគឺជាព្រះអង្គសង្គ្រោះដ៏អស្ចារ្យ!

បើសិនជាអ្នកចង់បានបទពិសោធនោះនៅថ្ងៃនេះ តើអ្នកអាចឈរជាមួយនឹងខ្ញុំដើម្បីអធិស្ឋាន ដែរឬទេ?

(សំណើអធិស្ឋាន)

ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ អរព្រះគុណទ្រង់ដែលបានផ្តល់នូវការពារតាមសន្យា នៅពេលដែលបញ្ហាធំមកកាន់ពិភពលោកនេះ។ ទូលបង្គំចង់ប្រាកដថា គ្មានអំពើបាបនៅក្នុងជីវិតទូលបង្គំដែលអាចនឹងញែកពួកទូលបង្គំចេញពីទ្រង់ឡើយ។ សូមទ្រង់ផ្តល់ឲ្យពួកទូលបង្គំនូវជ័យជំនះលើអំពើបាប។ សូមទ្រង់ជួយទូលបង្គំទាំងអស់គ្នា ថ្វាយខ្លួនទាំងស្រុងចំពោះគម្រោងការ និងព្រះហឫទ័យរបស់ទ្រង់សម្រាប់យើងម្នាក់ៗ។

សូមបង្កើនសេចក្តីជំនឿ និងសេចក្តីទុកចិត្តរបស់ពួកទូលបង្គំនៅក្នុងព្រះយេស៊ូ ជាព្រះអង្គសង្គ្រោះរបស់ពួកទូលបង្គំ។ សូមឲ្យពួកទូលបង្គំម្នាក់ៗស្វែងរកការការពារនៅក្នុងការរក្សាមិត្តភាពជាមួយនឹងទ្រង់។ នេះគឺជាការអធិស្ឋានរបស់ពួកទូលបង្គំ នៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ</u>

| | | |
|---|---|---|
| និក្ខមនំ ៧:២២ | អេសាយ ៣៣:១៦ | វិវរណៈ ១៦:១១ |
| វិវរណៈ ១៩:១៤-១៥ | និក្ខមនំ ៩:៧ | យេរេមា ៨:២០ |
| វិវរណៈ ១៦:១៦ | វិវរណៈ ២២:១១ | ទំនុកតម្កើង ៩១:១,៤ |
| ដានីញ៉ែល ១២:១ | វិវរណៈ ១៩:១១ | |

## លំនាំពិភាក្សា

**ជំងឺទឹកនោមផ្អែម គឺជាជំងឺដែលបំផ្លាញ**

១. តើឥទ្ធិពលអ្វីខ្លះដែលជំងឺទឹកនោមផ្អែមមានទៅលើរាងកាយ?
២. តើអ្វីដែលធ្វើឲ្យមនុស្សងាយនឹងកើតជំងឺទឹកនោមផ្អែម?
៣. តើជំងឺទឹកនោមផ្អែមអាចជាដែរឬទេ? បើដូច្នោះមែន តើដោយរបៀបណា?

**គ្រោះកាចចង្រៃចុងក្រោយទាំង៧**

៤. នៅពេលដែលស្តេចអេហ្ស៊ីបដិសេធមិនព្រមធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់បានបញ្ជូនគ្រោះកាចចង្រៃទាំងដប់មកលើទឹកដីនោះតាមរយៈលោកម៉ូសេ។ តើគ្រោះកាចចង្រៃមួយចំនួនមានអ្វីខ្លះ?
- និក្ខមនំ ៧:២១

៥. តើមានគ្រោះកាចចង្រៃប៉ុន្មានដែលប៉ះពាល់ទៅលើប្រទេសអេហ្ស៊ីបតែមួយគត់ ប៉ុន្តែ
មិនប៉ះពាល់ដល់កូសែន
ជាកន្លែងដែលពួកអ៊ីស្រាអែលរស់នៅ?
- និក្ខមនំ ៨:២២,២៣

៦. ក្រោយគ្រោះកាចចង្រៃទី១០ តើមានរឿងអ្វីកើតឡើងចំពោះស្តេច ហើយតើមានរឿងអ្វីកើតឡើងចំពោះអ៊ីស្រាអែល?
- និក្ខមនំ ១២:២៩

៧. ព្រះជាម្ចាស់បានបញ្ជូនទេវតាអ្នកនាំសារមកព្រមានរាស្រ្តដែលនៅផែនដីអំពីគ្រោះកាចចង្រៃជាច្រើនទៀត ដែលនឹងមកដល់។ តើមានគ្រោះកាចចង្រៃប៉ុន្មានទៀតដែលនឹងមកដល់ តើវាមានលក្ខណៈដូចម្តេច?

-វិវរណៈ ១៦:១-២១

៨. តើអ្នកអាចការពារកុំឲ្យទទួលបានគ្រោះកាចចង្រៃទាំងនោះបានដោយរបៀបណា?

- ទំនុកតម្កើង ៩១

# មេរៀនសុខភាពទី២៥: អាហារជាតិម្សៅ - អាហារដែលមានថាមពលខ្ពស់



១. មានរុក្ខជាតិដែលអាចញ៉ាំជាអាហារបានចំនួនជាង៥០០០០ប្រភេទ ប៉ុន្តែ មានអាហារធម្មជាតិតែ១៥មុខប៉ុណ្ណោះ ដែលផ្តល់នូវថាមពលខ្ពស់ ដែលកោសិកាពងកាយរបស់យើងត្រូវការ។ រុក្ខជាតិដែលគេនិយមញ៉ាំច្រើនជាងគេ គឺ ៖ ស្រូវ ស្រូវសាឡី ពោត ស្រូវមីយេ ស្រូវសរហ្គឹម មើម(ដំឡូងបារាំង ដំឡូងឈើ/គោ ដំឡូងផ្សេងៗ និងត្រាវ) ហើយនិងពពួកសណ្តែក។

គ្រាប់ធញ្ញជាតិសម្រូប គឺស្ថិតនៅលើលំដាប់ដំបូងគេ។ គ្រាប់ធញ្ញជាតិដែលគេប្រើប្រាស់ច្រើនជាងគេ គឺ ស្រូវ ស្រូវសាឡី និងពោត។

គ្រាប់ទាំងមូលនៃគ្រាប់ធញ្ញជាតិទាំងនេះ គឺដាំដើម្បីចិញ្ចឹមជីវិត ហើយព្រះជាម្ចាស់បានបង្កើតរាងកាយយើងឲ្យប្រើប្រាស់គ្រាប់ធញ្ញជាតិសំរូប ដើម្បីឲ្យយើងមានជីវិត និងមានសុខភាពល្អ។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ១:២៩ និង៣:១៨ ព្រះជាម្ចាស់បានដាស់តឿនរំឭកយើងថា ទ្រង់បានផ្តល់ឲ្យយើងនូវរុក្ខជាតិដែលផ្តល់គ្រាប់ពូជនៅលើផ្ទៃផែនដីទាំងមូល និងដើមឈើដែលផ្តល់ផ្លែដែលមានគ្រាប់នៅក្នុងផ្លែ ហើយនិងដើមរុក្ខជាតិនៅតាមទីវាលទុកសម្រាប់ជាអាហាររបស់យើង។

……………………………………………………………………………………………………………………

២. នៅក្នុងគ្រាប់ស្រូវសាឡីនេះ អ្នកអាចមើលឃើញ៤ផ្នែកធំៗ (គ្រាប់ធញ្ញជាតិដទៃទៀត មានលក្ខណៈស្រដៀងគ្នា) ៖

ក. សំបក - ស្រោបគ្រាប់ ជាផ្នែកដែលរឹងមិនអាចញ៉ាំបាន។

ខ. កន្ទក់ - ជាស្រទាប់ខាងក្រៅនៃគ្រាប់ សំបូរជាតិសរសៃ វីតាមីន និងសារធាតុគីមីល្អ និងមានសារធាតុវ៉ៃខនិជ។

គ. អង់ដូស្ពែម - ស្ថិតនៅកណ្តាល ជាស្រទាប់ធំជាងគេបង្អស់ ភាគច្រើនជាកាបូអ៊ីដ្រាត (ជាតិម្សៅ) ជាមួយនឹងជាតិប្រូតេអ៊ីនខ្លះ។

ឃ. សាច់គ្រាប់ - ផ្នែកខាងក្នុង ជាផ្នែកដែលល្អ មានផ្ទុកសារធាតុខ្លាញ់ដែលល្អ មានវីតាមីន និងសារធាតុគីមីល្អ។

គ្រាប់ធញ្ញជាតិមួយ គឺជាកញ្ចប់អាហារដែលមានជីវជាតិល្អបំផុត ដើម្បីជួយដល់ការលូតលាស់ និងធ្វើឲ្យមានសុខភាពល្អ។ កាលណាចម្រាញ់វា ជាតិកន្ទក់ និងសាច់គ្រាប់របស់វាត្រូវជំរះចេញអស់ ជំរុះអស់ជាតិប្រូតេអ៊ីន ជាតិសរសៃ វីតាមីន សារធាតុវ៉ៃខនិជ ហើយនិងសារធាតុគីមីល្អនៅក្នុងរុក្ខជាតិដែលផ្តល់ពណ៌ និងរសជាតិពី២៥-៩០%។ ស្រូវសាលីបាត់បង់អស់សារធាតុចិញ្ចឹមច្រើនជាងស្រូវធម្មតា រីឯពោតបាត់បង់ជាងពាក់កណ្តាល។ ផ្នែកដែលមានសារធាតុចិញ្ចឹមទាំងនេះ ដែលមនុស្សគ្រប់គ្នា ជាពិសេសកុមារដែលកំពុងតែនៅក្នុង

វែយលូតលាស់ ត្រូវការបង្ការកុំឲ្យកើតជំងឺខ្វះអាហាររូបត្ថម្ភ ហើយនិងជំងឺនានា គឺត្រូវបានគេយកទៅធ្វើជាចំណីដាក់ឲ្យសត្វមាន់ និងសត្វដទៃទៀត។

អ្វីដែលនៅសេសសល់ គឺជាតិម្សៅអង់ដូស្ពែមដែលមានពណ៌ស ដែលមានជាតិសរសៃតិចតួច ដើម្បីចិញ្ចឹមមីក្រុប(មេរោគ)ដែលល្អនៅក្នុងពោះវៀន ហើយនិងរក្សាជញ្ជាំងពោះវៀនឲ្យមានសុខភាពល្អ។

ជាតិសរសៃជួយចំរែត និងជួយអ្នកកុំឲ្យឆាប់ឃ្លាន និងកុំឲ្យញាំហួសកម្រិត ដែលអាចនាំឲ្យលើសទម្ងន់។ វាជួយបង្ការកុំ ឲ្យកើតជំងឺផ្តេសផ្តាស ឬជំងឺបស្ទឹមប្រទេសដូចជាជំងឺមហារីក ជំងឺទឹកនោមផ្អែម និងជំងឺបេះដូងដែលកើតចេញមកពីអាហាររុក្ខជាតិដែលមានជាតិសរសៃទាប ហើយនិងអាហារសាច់សត្វ ទឹកដោះសត្វ(គោ និងពពែ) ហើយ និងស៊ុត(ពង)បក្សី (ទា មាន់។ល។)។

៣. អ្នកច្បាស់ជាឆ្ងល់ហើយថា ហេតុអ្វីបានជាមនុស្សញាំគ្រាប់ធញ្ញជាតិចម្រាញ់ បើវាមិនជួយធ្វើឲ្យមានសុខភាពល្អផងនោះ?

  ក. គេអាចរក្សាវាទុកបានយូរ មិនងាយខូច ពីព្រោះពពួកសត្វល្អិត និងសត្វកណ្តុរមិនចូលចិត្តវា។ ក្រុមហ៊ុនអាហារចូលចិត្តបែបនោះ។

  ខ. គ្រាប់ធញ្ញជាតិចម្រាញ់ ច្រើនមានរសជាតិឆ្ងាញ់ ដោយគ្រាន់តែលាយជាមួយនឹងអំបិល ស្ករ និងខ្លាញ់ ឬប្រេង (ប្រេងល្ង សណ្តែក...។ល។)។ ប៉ុន្តែ ការលាយបញ្ចូលគ្នាបែបនេះ គឺមានគ្រោះថ្នាក់ចំពោះសុខភាពណាស់។ វានាំឲ្យខូចធ្មេញ(ដង្កូវស៊ីធ្មេញ) លើសទម្ងន់ ហើយនិងកើតជំងឺជាច្រើនទៀត។ អាហារចម្រាញ់ទាំងនេះ រួមជាមួយនឹងអាហារដែលមានជាតិខ្លាញ់ច្រើន វាធ្វើឲ្យឈាមនៅក្នុងរាងកាយរត់យឺត ដែលជាហេតុនាំឲ្យកើតជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺដាច់សរសៃឈាមខួរក្បាល និងជំងឺមហារីក។

  គ. គ្រាប់ធញ្ញជាតិសំរូប ត្រូវបានគេជឿថា ជាអាហាររបស់ប្រជាជនដែលរស់នៅក្នុងប្រទេសក្រីក្រ តែទោះជាយ៉ាងណាក្តី ក៏មានអ្នកមានបំផុតខ្លះ ដែលមានចំណេះដឹងជ្រៅជ្រះនៅក្នុងពិភពលោកចូលចិត្តធញ្ញជាតិសំរូបច្រើន ដោយសារពួកគេយល់អំពីគុណតម្លៃនៃសារធាតុចិញ្ចឹមល្អៗនៅក្នុងធញ្ញជាតិនោះ។

  ឃ. គ្រាប់ធញ្ញជាតិចម្រាញ់អាចមានតម្លៃថោក ពីព្រោះចំអិនឆាប់ឆ្អិនជាងគ្រាប់ធញ្ញជាតិសំរូប អាចកាត់បន្ថយការចំណាយទៅលើអុស ភ្លើងអគ្គិសនី ឬហ្គាសដើម្បីចំអិន។ បញ្ហានេះអាចដោះស្រាយបានដោយការលីងនឹងខ្ទះ ឬក៏ចំហុយស្រូវ។ ការត្រាំគ្រាប់ធញ្ញជាតិពេញមួយយប់ ជួយកាត់បន្ថយពេលវេលាចំអិន ហើយបង្កើនការរំលាយអាហារបានស្រួល។ វាក៏ជួយបង្កើនការស្រូបយកជាតិប្រូតេអ៊ីនវីតាមីន ដែក និងជាតិស័ង្កសី។ ភ្លើងអាចសន្សំបានដោយការគ្របឆ្នាំងពេលដែលកំពុងចំអិន។ ចង្ក្រានដែលស៊ីភ្លើងតិចអាចសន្សំភ្លើងបាន ៖ ដាក់ឆ្នាំងដែលកំពុងតែពុះខ្លាំង មានគ្របបិទជិតទៅក្នុងធុង ហើយដាក់ពីលើទ្រនាប់ធ្វើអំពីរុក្ខជាតិស្ងួត។

............................................................................................................................

៤. វិធីចំអិនពោត

ពោត មុននឹងចំអិន ត្រូវតែត្រាំជានិច្ច។ ដាក់ផេះដែលបានមកពីឈើខ្លឹមបន្តិចបន្តួច ឬក៏សំបកពោត១គីឡូក្រាម ដាក់កាល់ស្យូមអុកស៊ីតកិនចំនួន១ស្លាបព្រាបាយទៅក្នុងទឹកក្តៅ១ពែង។ កូរ។ ដាក់ទឹកកំពុងពុះ២លីតចូល ហើយចំអិនរយៈពេល២០នាទី។ បិទភ្លើង ហើយត្រាំវាមួយយប់ លាងជំរះ ហើយចំអិននៅក្នុងទឹកស្អាត។ ការត្រាំក៏ជួយកំចាត់ជាតិពុលដែលបង្កគ្រោះថ្នាក់ បណ្តាលមកពីផ្សិត ដែលចម្លងទៅដំណាំពោត។ ការចំអិនពោតបែបនេះ ហៅថាពោតកំបោរ។

**វិធីចំអិនបាយ**

បើសិនជាអ្នកមានសំណាងបានដាំស្រូវដោយខ្លួនឯង សូមកុំបោកប្រាស់ខ្លួនឯងអី។ ចូរជំរះតែសំបកទៅ។ ចូរញ៉ាំគ្រាប់ទាំងមូល ហើយរក្សាជីវិតដែលមាននៅក្នុងគ្រាប់ស្រូវ ដែលមានវីតាមីន សារធាតុរ៉ែខនិជល្អៗ សារធាតុគីមីល្អៗ និងជាតិសរសៃដែលនឹងជួយធ្វើឲ្យក្រុមគ្រួសារមានសុខភាពល្អ ហើយរក្សាខ្លួនឲ្យមានសុខភាពល្អជានិច្ច។

---

៥. បើសិនជាគ្រួសាររបស់អ្នកស៊ាំជាមួយនឹងគ្រាប់ធញ្ញជាតិដែលចម្រាញ់/បាយស ពួកគេត្រូវការការលើកទឹកចិត្តខ្លះ ឲ្យព្យាយាមសាកល្បងញ៉ាំគ្រាប់ធញ្ញជាតិសំរូប/បាយសំរូប។ អ្នកអាចចាប់ផ្តើមជាមួយនឹងការចំហុយគ្រាប់ធញ្ញជាតិជាមុនសិន។ ចំហុយគ្រាប់ស្រូវទាំងមូលសិន មុនពេលខាត់ ជម្រុញសារធាតុចិញ្ចឹមចូលជ្រៅទៅក្នុងគ្រាប់។ បន្ទាប់មក នៅពេលដែលកន្ទក់ និងសាច់គ្រាប់ត្រូវបានជំរុះចេញ នោះសារធាតុចិញ្ចឹមនៅសល់ច្រើននៅ ក្នុងគ្រាប់ស្រូវពណ៌ស។

ជំហានគោលដើម្បីចំហុយស្រូវរបស់អ្នក គឺត្រាំ ចំហុយ និងសំងួត។

ត្រូវប្រើស្រូវស្អាត ដែលនៅក្នុងសំបក

១. ត្រាំនៅក្នុងទឹកត្រជាក់ចំនួន ៣៦-៣៨ម៉ោង
២. ដាក់វាចូលទៅក្នុងថាសចំហុយជាមួយនឹងទឹកត្រជាក់ ហើយស្អាត
៣. ដាំឲ្យពុះរហូតទាល់តែគ្រាប់ស្រូវចាប់ផ្តើមប្រេះ
៤. ដាក់ឲ្យត្រជាក់ និងហាលឲ្យស្ងួតនៅលើកន្ទេល
៥. កិនដោយដៃ ឬម៉ាសុ៊ីន (យកសំបកខាងក្រៅចេញ)

ជំហានទាំងនេះជួយជំរុញឲ្យមានសារធាតុចិញ្ចឹមរបស់គ្រាប់ធញ្ញជាតិ/គ្រាប់ស្រូវកាន់តែច្រើនឡើង ធ្វើឲ្យវាកាន់តែស្ងួត និងត្រសុសល្អពេលចំអិន។

## រយៈពេល១០០០ឆ្នាំ (សហស្សវត្សរ៍)



ខ្ញុំមិនដែលនឿយហត់ ឬធុញពីការប្រាប់អ្នកអំពីគម្រោងការរបស់ព្រះជាម្ចាស់រំលំនគរទាំងអស់នៃពិភពលោកនេះ ហើយដាក់នគរអស់កល្បរបស់ទ្រង់មកជំនួសវិញនោះទេ។ ដល់ពេលនោះ រាស្ត្ររបស់ទ្រង់ដែលបានទទួលយកព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូ ជាព្រះអង្គសង្គ្រោះ នឹងបានរស់នៅជាមួយនឹងទ្រង់ជារៀងរហូត។ ខ្ញុំចង់រស់នៅក្នុងនគរនោះ ចុះអ្នកវិញ?

សព្វថ្ងៃនេះ យើងនឹងឃើញពីរបៀបដែលព្រះគម្ពីរពិពណ៌នាអំពីចុងបំផុតនៃពិភពលោកដែលមានបាបនេះ។ វាគួរឲ្យខ្លាច ប៉ុន្តែ វាគឺជារូបភាពដ៏អស្ចារ្យដែលត្រូវគិតគូរ។ បើសិនជាយើងពិតជាផ្នែកមួយនៃគ្រួសាររបស់ព្រះនៅលើផែនដីនេះមែន នោះយើងគ្មានអ្វីដែលគួរត្រូវខ្លាចនោះឡើយ។

នៅពេលដែលទ្រង់បានចាកចេញពីសាវ័ករបស់ទ្រង់ ហើយយាងត្រឡប់ទៅឋានសួគ៌វិញ ទេវតាពីរូបបានផ្តល់សារលើកទឹកចិត្ត។ សូមស្តាប់៖

"ព្រះយេស៊ូនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នាឡើងទៅលើស្ថានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែល ដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ" (កិច្ចការ ១:១១)។

លោក ប៉ុល ជាបេសកជនដ៏ល្អនៃព្រះវិហារសម័យមុន បានសរសេរអំពីការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូតាមរបៀបនេះ ៖

"ពីព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំលេងមហាទេវតា និងត្រែរបស់ព្រះផង" (ថែស្សាឡូនិចទី១ ៤:១៦)។

(ចូរចង្អុលទៅផ្ទាំងគំនូរ)រូបភាពដ៏ស្អាតនេះ បានមកពីគំនិតច្នៃប្រឌិតរបស់ជាងគំនូរ ប៉ុន្តែ ព្រឹត្តិការណ៍ពិតប្រាកដគឺលើសពីការគិតរបស់មនុស្ស។ សូមស្តាប់ ៖

" ... ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង ហើយលោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង" (ម៉ាថាយ ២៤:៣០,៣១)។

នេះ គឺនៅពេលដែលការប្រោសឲ្យរស់ឡើងវិញជាលើកដំបូងកើតឡើង។ មែនហើយ។ គឺការប្រោសឲ្យរស់ឡើងវិញជាលើកដំបូង។ យើងនឹងនិយាយអំពីការប្រោសឲ្យរស់ឡើងវិញមួយទៀតនៅក្នុងរយៈពេលបន្តិចទៀតនេះ។ ឥឡូវនេះ សូមយើងស្តាប់ពាក្យសម្តីរបស់លោកប៉ុល ៖

"នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស" (ថែស្សាឡូនិចទី១ ៤: ១៦,១៧)។

នៅពេលនោះ កូនចៅទាំងអស់របស់ព្រះដែលត្រូវបានប្រោសលោះ ចាប់ពីសម័យកាលរបស់អាដាមចុះមកដល់ទីបញ្ចប់ គឺនៅជុំគ្នា។ ពួកគេបានឡើងទៅឯអាកាស ដើម្បីចូលរួមជាមួយនឹងព្រះយេស៊ូ ហើយនិងពពួកទេវតា នៅក្នុងពពកដ៏មានសិរីល្អអស្ចារ្យ។ ផែនដីត្រូវបានទុកចោលឲ្យនៅឆ្ងាយ ពេលដែលពួកគេហោះទៅឯ ឋានសួគ៌ជាមួយនឹងព្រះយេស៊ូ។ បែបនេះនឹងបំពេញសេចក្តីសន្យាដែលទ្រង់បាន ធ្វើជាមួយនឹងសាវ័ករបស់ទ្រង់។ សូមស្តាប់ ៖

"ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា។ បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅទីនោះដែរ" (យ៉ូហាន ១៤:២,៣)។

តាមរយៈហោរាយ៉ូហាន "អ្នកទាំងនោះនឹងធ្វើជាពួកសង្ឃនៃព្រះ និងព្រះគ្រីស្ទ ហើយនិងសោយរាជ្យជាមួយនឹងទ្រង់អស់១ពាន់ឆ្នាំ" (វិវរណៈ ២០:៦)។

អ្នកមុខជាឆ្ងល់នូវអ្វីដែលនឹងកើតមានឡើងចំពោះលោកិយនេះ នៅពេលដែលព្រះយេស៊ូយករាស្ត្ររបស់ទ្រង់ទៅឯឋានសួគ៌។ ខ្ញុំសូមប្រាប់អ្នក។

ដំបូង ត្រូវចងចាំថា មានតែ "អ្នកស្លាប់នៅក្នុងព្រះគ្រីស្ទ" ប៉ុណ្ណោះ ដែលត្រូវបានប្រោសឲ្យរស់ឡើងវិញនៅក្នុងការប្រោសលោះឲ្យរស់ឡើងវិញលើកដំបូង។ លោកយ៉ូហានប្រាប់យើងថា "តែមនុស្សស្លាប់ឯទៀតមិនបានរស់វិញទេ ទាល់តែផុតពី១ពាន់

ឆ្នាំនោះទៅ" (វិវរណៈ ២០:៥)។ ដូច្នេះ ពួកគេនៅតែស្លាប់ដដែល ពេលដែលរាស្ត្ររបស់ព្រះជាម្ចាស់នៅជាមួយព្រះយេស៊ូនៅឯឋានសួគ៌។



ចុះ សត្រូវរបស់ព្រះជាម្ចាស់ដែលរស់នៅចាំមើលការយាងមកជាលើកទី២របស់ព្រះយេស៊ូវិញនោះ? តើមានអ្វីកើតឡើងចំពោះពួកគេទៅ? លោកយ៉ូហានប្រាប់យើងថា៖

"ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ និងព្រះអង្គដែលគង់លើវាទ្រង់មានព្រះនាមថា ស្មោះត្រង់ ហើយពិតប្រាកដ ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត។ ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង ហើយនៅលើព្រះសិរសាមានមកុដជាច្រើន។ មានដាវយ៉ាងមុតចេញពីព្រះឱស្ឋទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍" (វិវរណៈ ១៩:១១,១២,១៥)។

លោកយ៉ូហាននិយាយប្រាប់យើងបន្តទៅទៀតអំពីការប្រយុទ្ធយ៉ាងធំ នៅពេលដែលពលបរិវាររបស់អំពើអាក្រក់ប្រយុទ្ធប្រឆាំងនឹងព្រះយេស៊ូ ជាព្រះដែលមានព្រះនាមថា "ស្មោះត្រង់ និងពិតប្រាកដ"។ សត្វកំណាចដ៏ធំ ហើយនិងសម្ព័ន្ធមិត្តរបស់វាត្រូវបានចាប់ ហើយនិងបំផ្លាញចោល។ លោកយ៉ូហានបានសរសេរ "ហើយពួកដែលសល់នៅ ក៏ត្រូវស្លាប់ដោយដាវព្រះអង្គ ដែលគង់លើសេះ" (វិវរណៈ ១៩:២១)។

សូមយើងគិតស្រមៃថា តើពិភពលោកនេះនឹងមានសភាពបែបណា នៅក្នុងកំឡុងពេល១០០០ឆ្នាំ ខណៈពេលរាស្ត្ររបស់ព្រះដែលត្រូវបានប្រោសលោះនៅឯនគរឋានសួគ៌។

ដំបូង គ្មានមនុស្សណានៅទីនេះមានជីវិតទេ។ ផែនដីនឹងក្លាយទៅជាទីវាលកប់សពយ៉ាងធំល្វឹងល្វើយ។

បន្ទាប់មក ភាពសុីវីល័យដ៏អស្ចារ្យរបស់មនុស្ស នឹងត្រូវវិនាសឋិនហោច។ តើចងចាំអំពីគ្រោះកាចចង្រៃចុងក្រោយទាំង៧ ដែរឬទេ? រញ្ជួយដី និងព្រិលធំៗរបស់គ្រោះកាចចង្រៃទី៧នឹងត្រឡប់ផ្ទៃផែនដីទៅជាឆេះខ្មៅខ្មីរ។

ប៉ុន្តែ មានរឿងសំខាន់មួយទៀតនិយាយអំពីអ្វីដែលពិភពលោកនេះនឹងមានសភាពបែបណានៅក្នុងកំឡុងរយៈពេល១០០០ឆ្នាំ។ សូមស្តាប់ពាក្យសម្តីរបស់ហោរា៖



"ខ្ញុំក៏ឃើញទេវតា១ ចុះពីស្ថានលើមក ទាំងកាន់កូនសោរជង្ហុកធំ និងច្រវាក់១យ៉ាងធំនៅដៃ។ ទេវតានោះក៏ចាប់នាគចងវាទុក១ពាន់ឆ្នាំ គឺជាពស់ពីចាស់បុរាណ ដែលជាអារក្សឈ្មោះថាសាតាំង ក៏បោះវាចោលទៅក្នុងជង្ហុកធំ ទាំងខ្ទប់ ហើយបិទត្រាពីលើ ដើម្បីកុំឲ្យវានាំអស់ទាំងសាសន៍ឲ្យវង្វេងទៀត ទាល់តែផុតពី១ពាន់ឆ្នាំនោះទៅ ក្រោយនោះត្រូវតែស្រាយវាលែងបន្តិច" (វិវរណៈ ២០:១-៣)។

"ជង្ហុកធំ (អន្លង់គ្មានបាត)" គឺជាពាក្យតំណាងឲ្យពិភពលោកនេះ ដែលស្ថិតនៅក្នុងសភាពខ្មៅខ្មីរ បន្ទាប់ពីគ្រោះកាចចង្រៃ ហើយនិងការយាងត្រឡប់មកជាលើកទី២របស់ព្រះយេស៊ូ។ ផែនដីនឹងក្លាយជាគុករបស់សាតាំងចំនួន១០០០ឆ្នាំ។ ដោយគ្មានមនុស្សមានជីវិតរស់នៅទីនេះ វានឹងគ្មានអ្នកណាដែលអាចបោកប្រាស់ ឬល្បួង ឬក៏ធ្វើបាប

បាន។ វារួមជាមួយនឹងទេវតាអាក្រក់របស់វា នឹងត្រូវជាប់ជាឈ្លើយនៅទីនេះ។វានឹងត្រូវឆ្លងកាត់ពេលវេលានេះដោយក្តីវេទនារង់ចាំដល់ពេលកាត់ក្តីជាលើកចុងក្រោយ។ ក្នុងកំឡុងពេលនោះ រាស្ត្ររបស់ព្រះជាម្ចាស់នឹងនៅឯនគរឋានសួគ៌។



តើអ្នកឆ្ងល់ឬ ថាពួកគេនឹងធ្វើអ្វីនៅទីនោះ? ក្រៅពីក្តីអំណរហួសថ្លែងនៃការជួបជុំជាមួយនឹងព្រះគ្រីស្ទ ហើយនិងអ្នកដើរតាមទ្រង់ លោកយ៉ូហានមានរឿងប្រាប់យើងបន្ថែមទៀត។ សូមស្តាប់ ៖

"ខ្ញុំក៏ឃើញបល្ល័ង្កជាច្រើន និងពួកអ្នកដែលអង្គុយលើ ហើយមានអំណាចបានប្រគល់ដល់អ្នកទាំងនោះឲ្យជំនុំជំរះ" (វិវរណៈ ២០:៤)។

ព្រះជាម្ចាស់ដែលឆ្លាតវៃ និងមានអំណាចខ្លាំងក្លានៃសកលលោកនេះ បានបញ្ចូលបុរស និងស្ត្រីទន់ខ្សោយទៅក្នុងការងារដ៏សំខាន់ គឺការជំនុំជំរះពួកទេវតាអាក្រក់ ហើយនិងអ្នកដែលមិនត្រូវបានសង្គ្រោះ។

លោកប៉ុល ជាអ្នកសរសេរព្រះគម្ពីរដ៏ឆ្នើម សួរសំណួរថា ៖

"តើមិនដឹងថា ពួកបរិសុទ្ធនឹងជំនុំជំរះលោកិយដែរទេឬ?... តើមិនដឹងថា យើងរាល់គ្នានឹងជំនុំជំរះ ដល់ទាំងពួកទេវតាផងទេឬអី?" (កូរិនថូសទី១ ៦:២,៣)។

អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ សាតាំងបានអះអាងថា ព្រះជាម្ចាស់មិនយុត្តិធម៌ មិនមានក្តីស្រឡាញ់ ហើយនិងមិនស្មោះត្រង់។ នៅក្នុងកំឡុងពេល១០០០ឆ្នាំ យើងទាំងអស់គ្នានឹងមានឱកាសមើលដឹងថា ព្រះជាម្ចាស់យុត្តិធម៌ និងមានក្តីស្រឡាញ់ ហើយស្មោះត្រង់។

ប៉ុន្តែ ហេតុអ្វីបានជាយើងត្រូវជំនុំជំរះពួកទេវតាអាក្រក់ ហើយនិងអ្នកមានបាបដែលអាក្រក់? តើពួកគេមិនត្រូវបានជំនុំជំរះមុនពេលព្រះគ្រីស្ទយាងមកទេឬ?

ពិតហើយ ប៉ុន្តែ តើអ្នកមានដែលឆ្ងល់ទេ ថាអ្នកអាចមានប្រតិកម្មអ្វីខ្លះ បើអ្នកស្វែងរកនរណាម្នាក់នៅឯឋានសួគ៌ ដែលអ្នករំពឹងថាជួបនៅទីនោះ មានតែដឹងដំណឹងថា គេត្រូវបានបាត់បង់ជារៀងរហូត? អ្នកអាចឆ្ងល់អំពីភាពយុត្តិធម៌នៃតុលាការរបស់ព្រះជាមិនខាន។

នៅក្នុងកំឡុងពេល១០០០ឆ្នាំ បញ្ជីនៃអ្នកដែលបាត់បង់នឹងត្រូវបានបើកចំហ។ អាថ៌កំបាំង និងហេតុផលនីមួយៗនឹងត្រូវបានលាតត្រដាង។ នៅទីបំផុត នឹងលែងមានចំងល់អំពីសេចក្តីស្រឡាញ់ និងភាពយុត្តិធម៌របស់ព្រះទៀតហើយ។ យើងទាំងអស់គ្នានឹងទទួលបានការឆ្លើយតបដូចគ្នា ៖ "ឱព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ សេចក្តីជំនុំជំរះរបស់ទ្រង់សុទ្ធតែសុចរិត ហើយពិតត្រង់ទាំងអស់" (វិវរណៈ ១៦:៧)។



នៅចុងបំផុតនៃរយៈពេល១០០០ឆ្នាំ មានរឿងអស្ចារ្យកើតឡើង។ សូមស្តាប់ ៖

"ហើយយ៉ូហានខ្ញុំក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ តាក់តែងដូចជាប្រពន្ធថ្មោងថ្មី តែងខ្លួនទទួលប្តី" (វិវរណៈ ២១:២)។

ព្រះយេស៊ូ និងរាស្ត្រដែលទ្រង់បានប្រោសលោះ នឹងវិលត្រឡប់មកកាន់ ផែនដីវិញ បន្ទាប់ពីរយៈពេល១០០០ឆ្នាំ។ ទីក្រុងដ៏រុងរឿងរបស់ទ្រង់ គឺទីក្រុងយេរូសាឡិមថ្មី នឹងមកដល់ទីនេះ។ លោកយ៉ូហានបានឮសំលេងនិយាយថា “មើលរោងឧបោសថរបស់ព្រះបាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់” (វិវរណៈ ២១:៣)។

ប៉ុន្តែ មានរឿងផ្សេងទៀត ដែលមិនសូវល្អកើតមានឡើង។ ហោរាប្រាប់យើងថា ៖

“...ទ្រង់នឹងស្រាយអារក្សសាតាំងលែងពីគុកចេញ នោះវានឹងចេញទៅ ខំនាំអស់ទាំងសាសន៍ដែលនៅផែនដីទាំង៤ទិសឲ្យវង្វេង គឺទាំងសាសន៍កុក និងសាសន៍ម៉ាកុក ដើម្បីនឹងប្រមូលគេមកច្បាំង ចំនួនគេដូចជាខ្សាច់នៃសមុទ្រ”(វិវរណៈ ២០:៧,៨)។

នេះគឺជាពេលដ៏អាក្រក់នៃការប្រោសឲ្យរស់ឡើងវិញជាលើកទី២។ អ្នកមានបាប និងអ្នកដែលវង្វេងនៃផែនដីនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ។ គ្មាននគរឋានសួគ៌ សម្រាប់ពួកគេឡើយ។ ពួកគេបានធ្វើការសម្រេចចិត្តរួចជាយូរមកហើយ ហើយក៏បានដាក់ខ្លួននៅក្រោមទង់របស់សាតាំងដែរ។ គ្រប់ការស្អប់ខ្ពើម ហើយនិងគំនិតអាក្រក់នឹងត្រូវលាយបញ្ចូលគ្នា ដើម្បីគាំទ្រដល់គម្រោងការរបស់សាតាំង។ វានឹងមានសេរីភាពដើរបោកបញ្ឆោតគេឯងម្តងទៀត។ ដោយមានវាជាមេដឹកនាំ ពួកគេនឹងរៀបចំការប្រយុទ្ធចុងក្រោយប្រឆាំងនឹងព្រះជាម្ចាស់។ នេះគឺជាការយល់ឃើញរបស់ហោរាអំពីរឿងនោះ ៖



“នោះគេក៏ឡើងទៅពេញពាសលើផែនដី ទាំងឡោមព័ទ្ធទីដំឡើងត្រសាលរបស់ពួកបរិសុទ្ធ ហើយនិងទីក្រុងស្ងួនភ្ងាដែរ តែមានភ្លើងធ្លាក់ពីលើមេឃមកអំពីព្រះ បញ្ឆេះគេទាំងអស់ទៅ” (វិវរណៈ ២០:៩)។

សង្គ្រាមក៏បានចប់! ពិតជាគួរឲ្យសោកស្តាយ នៅពេលដែលវាគួរតែល្អប្រសើរជាងនេះ! តើមានអ្វីកើតឡើងចំពោះអារក្ស? ព្រះគម្ពីរប្រាប់យើងថា ៖

“រួចអារក្សដែលនាំឲ្យគេវង្វេង បានត្រូវបោះទៅក្នុងបឹង ដែលឆេះជាភ្លើង និងស្ពាន់ធ័រ ...។ បើអ្នកណាគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត អ្នកនោះត្រូវបោះទៅក្នុងបឹងភ្លើង” (វិវរណៈ ២០:១០,១៤,១៥)។

ដល់ពេលនោះ សាតាំង និងទេវតាអាក្រក់របស់វា ហើយនិងអ្នកមានបាប ត្រូវបាត់បង់ជារៀងរហូត! យើងអាចមានសាច់ញាតិ មិត្តភក្តិ ឬអ្នកស្គាល់ ជិតដិត ដែលយើងស្រឡាញ់យ៉ាងខ្លាំង ដែលត្រូវបាត់បង់ជារៀងរហូត។ ប្រាកដហើយ យើងនឹងយំសោក។ បើមិនដូច្នោះទេ របៀបណាផ្សេងទៀតម៉េចត្រូវ?

ប៉ុន្តែ នេះគឺជាដំណឹងល្អខ្លះៗ ៖

“ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ។ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ” (វិវរណៈ ២១:៤)។

.



ខួរក្បាលយើងតូចហួសនឹងគិតអំពីសិរីល្អ និងសម្រស់នៃឋានសួគ៌ដែលព្រះជាម្ចាស់កំពុងរៀបចំសម្រាប់អស់អ្នកដែលស្រឡាញ់ទ្រង់ ហើយនិងសុខចិត្តដើរតាមទ្រង់! ហើយគិតបន្តិចថា របស់ទាំងអស់នេះ ដែលពួកអាក្រក់គួរតែបានសប្បាយជាមួយនឹង ប៉ុន្តែ តម្លៃវាហាក់ដូចជាខ្ពស់ពេក! ពួកគេមិនព្រមជ្រើសយកព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះ និងជាព្រះរបស់ពួកគេឡើយ។

តើអ្នកនឹងនៅទីណា ពេលដែលថ្ងៃនោះមកដល់? អ្នកមិនអាចរង់ចាំដល់ពេលនោះទើបសម្រេចចិត្តនោះទេ។ ផ្លូវតែមួយដែលអាចដឹងច្បាស់បានថា អ្នកអាចនៅជាមួយនឹងព្រះយេស៊ូនៅក្នុងនគរដ៏អស់កល្បរបស់ទ្រង់ គឺត្រូវថ្វាយចិត្ត និងជីវិតរបស់អ្នកទៅឯទ្រង់ពេលឥឡូវនេះ នៅថ្ងៃនេះ! តើមានអ្វីនៅក្នុងពិភពលោកនេះសំខាន់ជាងរឿងនោះទេ?

ឥឡូវនេះ តើព្រះវិញ្ញាណរបស់ព្រះមានបន្ទូលទៅកាន់ចិត្តរបស់អ្នកដែរឬទេ? ប្រហែលជាមានរឿងអ្វីមួយនៅក្នុងជីវិតរបស់អ្នក ទប់ស្កាត់អ្នកមិនឲ្យជ្រើសរើសយកព្រះយេស៊ូហើយ។ ប៉ុន្តែ ឥឡូវនេះពេលដែលអ្នកគិតអំពីសេចក្ដីអំណរនៃភាពអស់កល្ប នៅក្នុងពិភពលោកដ៏ល្អឥតខ្ចោះ អ្នកដឹងនៅក្នុងចិត្តរបស់ខ្លួនថា អ្នកចង់ថ្វាយខ្លួនទៅឯទ្រង់។ បើសិននោះគឺជាអ្វីដែលអ្នកចង់បាន សូមមក ហើយឈរជាមួយនឹងខ្ញុំ។ ថ្ងៃនេះ ខ្ញុំចង់អធិស្ឋានពិសេសសម្រាប់អស់អ្នកដែលកំពុងធ្វើការសម្រេចចិត្ត។ អ្នកខ្លះសម្រេចចិត្តថ្វាយជីវិតទៅឯព្រះយេស៊ូ ហើយបានធ្វើបុណ្យជ្រមុជទឹក។ ខ្ញុំចង់អធិស្ឋានឲ្យអ្នកនៅខាងមុខនេះ។

បើអ្នកបានឮសំលេងព្រះត្រាស់ហៅឲ្យអ្នកដើរតាមទ្រង់រហូតឈានដល់ការធ្វើបុណ្យជ្រមុជទឹកតាមព្រះគម្ពីរ សូមមកចូលរួមជាមួយនឹងខ្ញុំនៅទីនេះ មុននឹងយើងអធិស្ឋាន។ សូមកុំពន្យារពេលធ្វើការសម្រេចចិត្តដ៏សំខាន់នេះអី។ ឥឡូវដល់ពេលជ្រើសរើសទីកន្លែងណាដែលយើងត្រូវនៅ នៅក្នុងកំឡុងពេល១០០០ឆ្នាំ។ នៅក្នុងផ្ទះរបស់យើង ឬក៏នៅនគរឋានសួគ៌ជាមួយនឹងព្រះយេស៊ូ។

នៅពេលដែលយើងសម្រេចចិត្តដើរតាមព្រះគ្រីស្ទ យើងនិយាយថា “ព្រះយេស៊ូ ទូលបង្គំជារបស់ផងទ្រង់។ ព្រះយេស៊ូ ទូលបង្គំចង់ដើរតាមទ្រង់។ ព្រះយេស៊ូ ទូលបង្គំស្រឡាញ់ទ្រង់អស់អំពីចិត្តរបស់ទូលបង្គំ។ ទូលបង្គំចង់មានចំណែកធ្វើជាអ្នកដែលរក្សាបញ្ញត្ត និងជាអ្នករក្សាថ្ងៃបរិសុទ្ធរបស់ផងទ្រង់។ ទូលបង្គំចង់រួបរួមជាមួយនឹងមនុស្សជុំវិញពិភពលោក ដែលបានធ្វើការសម្រេចចិត្តនេះ។ ព្រះជាម្ចាស់ នេះគឺជាសេចក្ដីប្រាថ្នារបស់ទូលបង្គំ នេះគឺជាសម្រែកនៃចិត្តរបស់ទូលបង្គំ នេះគឺជាការអង្វររបស់ទូលបង្គំ។”

ខ្ញុំជឿជាក់ថា មានអ្នកខ្លះនៅទីនេះដែលគិតអំពីការសម្រេចចិត្តនេះ។ វាគឺជាការសម្រេចចិត្តដែលអ្នកប្រយុទ្ធជាមួយ។ អ្នកដឹងថាព្រះជាម្ចាស់ដឹកនាំអ្នក ប៉ុន្តែ វាពិបាកនឹងឈានចេញ។ បើសិនជាអ្នកមិនទាន់បានត្រៀមខ្លួនធ្វើការសម្រេចចិត្តស្រួលបួលទេ ប៉ុន្តែ អ្នកចង់ឲ្យខ្ញុំអធិស្ឋានឲ្យអ្នក នោះចូរមកខាងមុខ។

មានអ្នកខ្លះដែលមានបញ្ហានៅក្នុងជីវិត វាធំហួស ហើយអ្នកមិនដឹងថាដោះស្រាយវាយ៉ាងណា។ អ្នកមុខជាដឹងថាបញ្ហានេះ ឈរនៅចន្លោះអ្នក ហើយនិងការសម្រេចចិត្តដែលអ្នកដឹងថា ជាការសម្រេចចិត្តដែលត្រឹមត្រូវ។ ខ្ញុំចង់អធិស្ឋានឲ្យអ្នកនៅពេលយប់នេះ។ សូមមកខាងមុខ ហើយចូលរួមអធិស្ឋានជាមួយនឹងពួកយើង។

(សំណើអធិស្ឋាន)

ឱព្រះវរបិតានៅឯនគរឋានសួគ៌ ទូលបង្គំមកឯទ្រង់នៅថ្ងៃនេះ ដោយបើកចំហចិត្ត ទទួលយកព្រះវិញ្ញាណរបស់ទ្រង់។ មានអ្នកខ្លះនៅទីនេះ ដែលបានធ្វើការសម្រេចចិត្ត ថ្វាយចិត្តទៅតាមបំណងព្រះហឫទ័យទ្រង់ ហើយធ្វើបុណ្យជ្រមុជទឹក។ ពួកគេបាន សម្រេចចិត្តចូលរួមនៅក្នុងព្រះវិហាររបស់ទ្រង់ រក្សាបញ្ញត្ត និងថ្ងៃបរិសុទ្ធរបស់ទ្រង់។ ឱព្រះបិតាអើយ សូមទ្រង់ប្រទានពរពួកគេឲ្យមានសេចក្តីសុខសាន្តនៅក្នុងចិត្ត និងមាន កំលាំងពលំនៅក្នុងការធ្វើតាមការសម្រេចចិត្តរបស់ពួកគេ។

អាចមានអ្នកខ្លះដែលកំពុងតែប្រយុទ្ធជាមួយនឹងឧបសគ្គ ដែលរារាំងពួកគេពីទ្រង់។ ប្រហែលជាមានអំពើបាបដែលពួកគេចូលចិត្តនៅក្នុងជីវិត។ ប្រហែលជាមានមន្ទិល សង្ស័យខ្លះ ឬក៏សេចក្តីភ័យខ្លាច។ ប្រហែលជាមានអ្នកខ្លះនៅទីនេះ ថែមទាំងយល់ថា អំពើបាបរបស់ពួកគេធំខ្លាំងពេក ឬក៏ចិត្តរបស់ពួកគេអាក្រក់ហួសពេក ធ្វើឲ្យទ្រង់មិនអាច ឬក៏នឹងមិនអភ័យទោសឲ្យពួកគេបាន។ ព្រះបិតា សូមបញ្ជូនព្រះវិញ្ញាណរបស់ព្រះ ចូល ទៅក្នុងចិត្តរបស់ពួកគេ ជាមួយនឹងសារនៃក្តីសង្ឃឹម។ សូមឲ្យពួកគេដឹងថា គ្មានអំពើបាប ណាធំហួស ហើយក៏គ្មានចិត្តណាដែលអាក្រក់ខ្លាំងនោះឡើយ។ សូមជួយឲ្យពួកគេ ឃើញថា ទ្រង់ស្រឡាញ់ពួកគេ។ សូមប្រាប់ពួកគេថា ព្រះយេស៊ូយកគ្រប់អំពើបាប និង សេចក្តីអាក្រក់ទាំងអស់របស់ពួកគេដាក់នៅលើអង្គទ្រង់។ ទ្រង់បានសុគតជួសពួកគេនៅ លើឈើឆ្កាង។

ព្រះអម្ចាស់ សូមទ្រង់បន្ទន់ចិត្តអស់អ្នកដែលមិនព្រមទទួលការត្រាស់ហៅរបស់ទ្រង់។ ទូលបង្គំដឹងថា ទ្រង់ចង់ឲ្យគ្រប់គ្នាដែលនៅទីនេះ បាននៅជាមួយនឹងទ្រង់នៅឯនគរឋាន សួគ៌ នៅក្នុងកំឡុងពេល១០០០ឆ្នាំ។ ទ្រង់ចង់ឲ្យ ពួកទូលបង្គំគ្រប់គ្នាមានចំណែកនៅក្នុង នគរដ៏អស់កល្បរបស់ទ្រង់។ សូមទ្រង់ ជួយជំរុញចិត្តរបស់ពួកទូលបង្គំ។ សូមដាស់ចិត្ត គំនិតពួកទូលបង្គំ។ សូមទាញ ពួកទូលបង្គំម្នាក់ៗឲ្យខិតកាន់តែជិតទ្រង់។ ទូលបង្គំ ទូល សូមគ្រប់កិច្ចការនេះនៅក្នុងព្រះនាមជាទីស្រឡាញ់របស់ព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ</u> ៖

| | | |
|---|---|---|
| យេរេមា ៤:២៣-២៦ | យ៉ូហាន ៥:២៥ | យេរេមា ២៥:៣៣ |
| យ៉ូហាន ៥:២៨,២៩ | អេសាយ ២៦:១៩ | យ៉ូហាន ១១:២៥ |
| ម៉ាថាយ ២៥:៣១ | ពេត្រុសទី២ ៣:១០ | |

## លំនាំពិភាក្សា

**អាហារជាតិម្សៅ – អាហារដែលមានថាមពលខ្ពស់**

១. តើបួនផ្នែកនៃគ្រាប់ធញ្ញជាតិ គឺអ្វីខ្លះ?

២. ហេតុអ្វីបានជាគ្រាប់ធញ្ញជាតិដែលចម្រាញ់ មិនមែនជាអាហារដែលល្អបំផុត?

៣. តើប្រជាជននៅក្នុងភូមិរបស់អ្នកចូលចិត្តគ្រាប់ធញ្ញជាតិពណ៌ស(ចម្រាញ់)? តើអ្នកយល់ព្រមសាកល្បងគ្រាប់ធញ្ញជាតិសំរូបដែរឬទេ?

**រយៈពេល១០០០ឆ្នាំ (សហស្សវត្សរ៍)**

១. នៅពេលដែលព្រះយេស៊ូបានយាងត្រឡប់ទៅឋានសួគ៌វិញ ទ្រង់បានផ្តល់ដំណឹងទៅកាន់អ្នកដើរតាមទ្រង់។ តើជាដំណឹងអ្វី?

- កិច្ចការ ១:១១ - យ៉ូហាន ១៤:២,៣

២. តើការយាងមករបស់ព្រះយេស៊ូមានសភាពបែបណា?

- ថែស្សាឡូនិចទី១ ៤:១៦,១៧ - ម៉ាថាយ ២៤:៣០,៣១

៣. តើផែនដីនឹងសម្រាករយៈពេលយូរប៉ុណ្ណា ហើយអ្នកបរិសុទ្ធជំនុំជំរះ បន្ទាប់ពីព្រះយេស៊ូយករាស្ត្ររបស់ទ្រង់ទៅនគរឋានសួគ៌?

-វិវរណៈ ២០:៥,៦

៤. តើសាតាំង ហើយនិងអ្នកដែលបានសង្គ្រោះចំណាយពេលនៅក្នុងកំឡុងពេល១០០០ឆ្នាំ ធ្វើអ្វីខ្លះ?

-វិវរណៈ ២០:១-៤ - កូរិនថូសទី១ ៦:២,៣ -វិវរណៈ ១៦:៧

៥. តើមានរឿងអ្វីកើតឡើងនៅទីបញ្ចប់នៃរយៈពេល១០០០ឆ្នាំ?

-វិវរណៈ ២១:៣,៤ -វិវរណៈ ២០:៧-១៥

# មេរៀនសុខភាពទី២៥ - ជំងឺបាក់ទឹកចិត្ត (អន្លង់ជ្រៅ)



១. តើអ្នក ឬក៏មានអ្នកណាដែលអ្នកស្គាល់ មានអារម្មណ៍សោកសង្រេង បាក់ទឹកចិត្តខ្លាំង ឬយល់ថាខ្លួនឯងគ្មានតម្លៃដែរឬទេ? តើអ្នកស្អុគស្អាញនឹងជីវិតឬ? តើអ្នកហត់នឿយខ្លាំង ហើយមិនមានកំលាំងឬ? តើចង់គេច ហើយគេងរហូតឬ? តើមានអារម្មណ៍ថា ខួរក្បាលដើរយឺត ភ្លេច ឬក៏ច្របូកច្របល់ឬ? តើលែងចាប់អារម្មណ៍នឹងការងារនៃជីវិតឬ? តើមានគំនិតចង់បញ្ចប់ជីវិតខ្លួនឯងដែរឬទេ?

អារម្មណ៍បែបនេះអាចជារឿងធម្មតានៅពេលដែលជួបនឹងវិបត្តិ(បញ្ហា)។ ប៉ុន្តែ វានឹងរសាត់បាត់អស់ទៅ នៅពេលដែលបញ្ហានោះកន្លងហួសទៅ។ បើសិនជាអារម្មណ៍បែបនេះនៅតែមានខ្លះៗ នៅពេលដែលគ្មានវិបត្តិ ឬបញ្ហា ហើយនៅតែកើតមានអារម្មណ៍បែបនេះលើសពី២សប្តាហ៍ នោះគេហៅថា ជំងឺបាក់ទឹកចិត្ត។ ជំងឺបាក់ទឹកចិត្តអាចកើតមានឡើងនៅគ្រប់អាយុកាល សូម្បីតែនៅក្នុងវ័យកុមារក៏អាចកើតមានបានដែរ។

…………………………………………………………………………………………………........

២. ជំងឺបាក់ទឹកចិត្ត គឺជាជំងឺខួរក្បាល។ ផ្នែកខាងមុខនៃខួក្បាលចុះអន់ថយ ហើយរួម ដោយសារតែគ្មានសកម្មភាព។ ការនេះប៉ះពាល់ដល់ការចងចាំ និងការវិនិច្ឆ័យ និងអារម្មណ៍ទាក់ទងជាមួយនឹងចំណាប់អារម្មណ៍ផ្លូវភេទ ប្រតិកម្មនឹងភាពតានតឹង ការខឹងសម្បារ និងការភ័យខ្លាច។ កាលណាខួរក្បាលឈឺ ប្រព័ន្ធការពារចុះខ្សោយ ប្រឈមនឹងការកើតជំងឺ ហើយនិងឆាប់ស្លាប់មុនអាយុកាល។

ជំងឺបាក់ទឹកចិត្ត ច្រើនកើតឡើងចំពោះមនុស្សដែលកើតនៅក្នុងគ្រួសារដែលមានជំងឺបាក់ទឹកចិត្ត។ វាច្រើនកើតមាននៅក្នុងចំណោមអស់អ្នកដែលចម្រើនលូតលាស់នៅក្នុងគ្រួសារដែលមិនមានក្តីស្រឡាញ់ នៅក្នុងក្រុមគ្រួសារដែលមានតែម្តាយ ឬឪពុក ឬក៏ទៅលើអ្នកដែលទទួលរងការរំលោភបំពានផ្លូវភេទ។ កត្តាទាំងនេះមិនអាចកែប្រែអតីតកាលបានឡើយ ប៉ុន្តែ ជម្រើសនៃការរស់នៅក្នុងពេលបច្ចុប្បន្នអាចជួយព្យាបាលឲ្យជាពីជំងឺបាក់ទឹកចិត្ត ហើយនិងធ្វើឲ្យជីវិតល្អប្រសើរបាន។

ខួរក្បាលតែងតែប្រែប្រួលជានិច្ច។ ទម្លាប់ផ្លូវដើរចាស់ អាចកំចាត់ចោលបាន កោសិកាថ្មីអាចលូតលាស់ ហើយខួរក្បាលអាចជាសះស្បើយបាន។ មានកត្តាជាច្រើនធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់ ឬក៏ចំផ្លាញកោសិកាខួរក្បាល អាចកែប្រែខួរក្បាលឲ្យល្អប្រសើរ ឬក៏កាន់តែយ៉ាប់យ៉ឺនក៏បាន។ វាប្រើពេលអស់ប្រាំខែដើម្បីឲ្យខួរក្បាលផ្លាស់ប្តូរជាស្ថាពរ ប៉ុន្តែ បន្ទាប់ពីការផ្លាស់ប្តូរជីវិតរស់នៅតែមួយសប្តាហ៍ប៉ុណ្ណោះ មនុស្សអាចចាប់ផ្តើមមានអារម្មណ៍ល្អប្រសើរហើយ។

អាកប្បកិរិយានៃរបៀបរស់នៅ ដែលអាចព្យាបាលខួរក្បាលឲ្យជាបាន គឺត្រូវបានចែករំលែកនៅក្នុងមេរៀនលំហាត់ប្រាណ ហើយនិងមេរៀនផ្សេងទៀត។ សូមរៀនពីវា យកវាទៅអនុវត្តនៅក្នុងជីវិតរបស់អ្នក នោះអ្នកនឹងអាចបង្កា ហើយនិងយកឈ្នះលើជំងឺបាក់ទឹកចិត្តបានជាមិនខាន។

…………………………………………………………………………………………………........

### ៣. កត្តាទី១: ធម្មជាតិជាអ្នកជួយព្យាបាល

អុកស៊ីហ៊្សែន ព្យាបាលខួរក្បាល។

ឈរឲ្យត្រង់ខ្លួន : ដកដង្ហើមឲ្យវែង។ ដកដង្ហើមចូលដោយយឺតៗ ទប់ដង្ហើមរាប់ដល់៥។ ដកដង្ហើមចេញយឺតៗ។ ដកដង្ហើមរបៀបនេះចំនួន១៥នាទី ៣ដងក្នុង១ថ្ងៃ។

**ការហាត់ប្រាណនៅខាងក្រៅជួយព្យាបាលខួរក្បាល។**

ប្រចាំថ្ងៃ : ហាត់ប្រាណឲ្យរហ័សរហួនចំនួន១នាទី ធ្វើឲ្យបេះដូងរបស់អ្នកលោតញាប់។ បន្ទាប់មក ហាត់ប្រាណដោយថ្នមៗចំនួនកន្លះនាទី។ ធ្វើដដែលៗ រហូតទាល់តែអ្នកនឿយហត់។ ការធ្វើបែបនេះ វាជួយបន្សុទ្ធអុកស៊ីហ៊្សែននាំចូលទៅក្នុងឈាមរបស់អ្នក ជួយពង្រឹងបេះដូង សួត និងខួរក្បាលរបស់អ្នក។ បើសិនជាជំងឺបាក់ទឹកចិត្ត វាធ្វើឲ្យអ្នកមិនចង់បញ្ចេញចលនា ត្រូវហៅមិត្តភក្តិឲ្យចូលរួមហាត់ប្រាណជាមួយអ្នក។

**ពន្លឺថ្ងៃ និងការគេងជួយព្យាបាលខួរក្បាល។**

ការហាត់ប្រាណនៅក្រោមពន្លឺព្រះអាទិត្យនៅពេលព្រឹកព្រលឹម ហើយនិងពេលល្ងាច វាធ្វើឲ្យសារធាតុគីមីនៅក្នុងខួរក្បាលផ្លាស់ប្តូរ។ វាជួយបំបាត់ជំងឺគេងមិនលក់ ជួយឲ្យគេងលក់បានស្កប់ស្កល់ ហើយបង្កាមិនឲ្យឆាប់ក្រោកពីដំណេកពីព្រលឹមពេក។

………………………………………………………………………………………………………………........

### ៤. កត្តាទី២: អាកប្បកិរិយា ជួយព្យាបាលបាន

អ្វីដែលអ្នកគិត វាធ្វើឲ្យខួរក្បាលរបស់អ្នកប្រែប្រួលបាន។ ការគិតវិជ្ជមាន ជាមួយនឹងគំនិតត្រឹមត្រូវ អាចកែប្រែអាកប្បកិរិយាអវិជ្ជមាន(មិនល្អ)បាន។

នេះគឺជាយោបល់ខ្លះៗ ៖

ទី១ - ជារៀងរាល់ថ្ងៃ ត្រូវរាប់ព្រះពរដែលអ្នកទទួលបាន។ ត្រូវដឹងគុណ ទោះបីជារឿងតូចតាចក៏ដោយ។ គ្មានអ្វីដែលជួយឲ្យរាងកាយ និងព្រលឹងមានសុខភាពល្អជាងការចេះដឹងគុណ និងការសរសើរតម្កើងនោះឡើយ។

ទី២ - មិនត្រូវរិះគន់ចំនួន២សប្តាហ៍។ បើសិនជាអ្នកនៅតែរិះគន់ ត្រូវចាប់ផ្តើមឈប់រិះគន់ចំនួន២សប្តាហ៍ជាថ្មី។ អ្នកអាចឃុំគ្រងខួរក្បាលរបស់អ្នកជាមួយនឹងទម្លាប់នៃការគិតវិជ្ជមានបែបថ្មី។

ទី៣ - ចូរធ្វើអំពើល្អចំពោះអ្នកណាម្នាក់ដោយមិនបាច់គិតទុកជាមុន។ “គួរតែឲ្យយើងរាល់គ្នា ដែលមានកំលាំងបានទ្រាំទ្រនឹងសេចក្តីកំសោយរបស់ពួកអ្នកដែលគ្មានកំលាំងវិញ ឥតបំពេញចិត្តខ្លួនយើងឡើយ” (រ៉ូម ១៥:១)។ ការបម្រើអ្នកដទៃ គឺជាវិធីព្យាបាលរបស់ព្រះជាម្ចាស់។

ទី៤ - រស់នៅដោយចំណាយពេលគិតអំពីព្រះយេស៊ូ ហើយនិងជីវិតរបស់ទ្រង់ ជាជាងគិតអំពីបញ្ហារបស់អ្នក។ ព្រះយេស៊ូបានមានបន្ទូលថា “ដែលឲ្យ នោះបានពរជាជាងទទួល” (កិច្ចការ ២០:៣៥)។

………………………………………………………………………………………………………………........

### ៥. កត្តាទី៣ – អាហារដែលមានជីវជាតិ ជួយព្យាបាលបាន

អាហារដែលល្អសម្រាប់រាងកាយរបស់អ្នក គឺល្អសម្រាប់ខួរក្បាលរបស់អ្នក។ អាហាររុក្ខជាតិ ព្យាបាលខួរក្បាល ហើយនិងផ្តល់ឲ្យវានូវសារធាតុចិញ្ចឹមនិងជីវជាតិដ៏ល្អ។ ផ្លែឈើពពួកប៊ីរី និងបន្លែដែលមានពណ៌ចំរុះ

ជាពិសេស បន្លែដែលមានស្លឹកពណ៌បៃតង និងសណ្តែក សំបូរទៅដោយជាតិវីតាមីនប៊ី៩ (ហ្វូឡេត) ហើយនិងវីតាមីនស៊ី ដែលបង្ការមិនឲ្យអស់កំលាំង ច្របូកច្របល់ និងបាត់បង់ការចងចាំ។ គ្រាប់ហ្លិក្ស(គ្រាប់លីន) ឬក៏គ្រាប់ឈា កិន ឬគ្រាំ បង្កា និងកាត់បន្ថយជំងឺបាក់ទឹកចិត្ត។ ចូរប្រើ១ស្លាបព្រាបាយសម្រាប់បង្កាជំងឺបាក់ទឹកចិត្ត និង៤ស្លាបព្រាបាយសម្រាប់ព្យាបាលវា។

ខ្លាញ់សត្វ និងខលេស្ទឺរ៉ូល វាធ្វើឲ្យសរសៃឈាមចុក(ស្ទះ) ហើយកាត់បន្ថយអុកស៊ីហ្សែន នាំឲ្យកើតជំងឺបាក់ទឹកចិត្ត។

ស្ករ និងគ្រាប់ធញ្ញជាតិចម្រាញ់ ខ្វះ “អរម៉ូនដែលនាំឲ្យមានក្តីរីករាយ” សារធាតុចិញ្ចឹមដែលមានវីតាមីនប៊ីដែលសំបូរនៅក្នុងធញ្ញជាតិសុំរូប សណ្តែក និងបន្លែពណ៌បៃតង។

ថ្នាំវីតាមីប៊ី១២ ជួយបង្កាជំងឺបាក់ទឹកចិត្ត ហើយរក្សាការចងចាំ ហើយនិងសមត្ថភាពនៅក្នុងការគិត។

…………………………………………………………………………………………………………………………........

៦. កត្តាទី៤ – ជាតិពុលៈ ជាសារធាតុដែលបំផ្លាញ

ថ្នាំជក់ ថ្នាំដែលខុសច្បាប់ និងកាហ្វេអ៊ីន នៅក្នុងការហ្វេ តែពណ៌ខ្មៅ និងភេសជ្ជៈកូឡា ធ្វើឲ្យខួរក្បាលដើរហួសកម្រិត ពោរពេញទៅដោយជាតិពុល ហើយកាត់បន្ថយអុកស៊ីហ្សែនទៅកាន់កោសិកា បណ្តាលឲ្យកើតជំងឺរសាប់រសល់ និងច្របូកច្របល់។ ជំងឺបាក់ទឹកចិត្តច្រើនកើតទៅលើអ្នកជក់ថ្នាំជក់(បារី) និងកញ្ឆា។

ស្រា វាធ្វើឲ្យខួរក្បាលស្ពឹក ឬវង្វេង បំផ្លាញកោសិកា ហើយធ្វើឲ្យសមត្ថភាពនៃការគិតច្បាស់លាស់ថយចុះ ធ្វើឲ្យមនុស្សបាក់ទឹកចិត្ត ហើយចង់ផឹកថែមទៀត។

ជាតិគីមី ដូចជាអារសេនិក ថ្នាំសំលាប់សត្វល្អិត និងប្រេងកាតឆៅ ហើយនិងជាតិបារ៉ែតដែលមានលក្ខណៈដូចដែក ហើយនិងសំណ បំផ្លាញកោសិកាខួរក្បាល។ ជាតិគីមីទាំងនេះពិបាកនឹងកំចាត់ចេញពីរាងកាយណាស់។

ត្រូវចៀសវាងប្រើប្រាស់សារធាតុទាំងនេះ។ វាគ្រោះថ្នាក់ចំពោះកុមារ ហើយអាចធ្វើឲ្យបាត់បង់សមត្ថភាពនៅក្នុង ការរៀនសូត្រ មានភាពសោកសង្រេងខ្លាំង ហើយមានបញ្ហាផ្នែកអត្តចរិតផងដែរ។

វិធីការពារដ៏ល្អបំផុតប្រឆាំងនឹងជំងឺបាក់ទឹកចិត្ត គឺខួរក្បាលផ្នែកខាងមុខមានសុខភាពល្អ។ ខួរក្បាលផ្នែកខាងមុខ គឺជាផ្នែកនៃខួរក្បាលដែលសម្រេចនូវការដឹងខុសត្រូវ ដែលជួយឲ្យធ្វើការវិនិច្ឆ័យបានល្អ និងជួយនៅក្នុងការធ្វើផែនការ និងគម្រោង ហើយនិងធ្វើការ។ វាគឺជាផ្នែកមួយនៃខួរក្បាលរបស់អ្នក ដែលធ្វើទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់នៅក្នុងពេលអធិស្ឋាន និងសិក្សាព្រះគម្ពីរ។ ជំងឺបាក់ទឹកចិត្តអាចធ្វើឲ្យខួរក្បាលរួមបាន ប៉ុន្តែ ការផ្លាស់ប្តូរ របៀបរស់នៅ និងរបបអាហារ ហើយមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់អាចជួយព្យាបាលវាបាន។

## ផែនដីថ្មី



នៅក្នុងមេរៀនមុន យើងបាននិយាយអំពីពេលវេលា១០០០ឆ្នាំ នៅពេលអស់អ្នកដែលត្រូវបានសង្គ្រោះនឹងនៅជាមួយនឹងព្រះយេស៊ូនៅឯឋានសួគ៌។ យើងបាននិយាយអំពីការងារដែលពួកគេនឹងត្រូវធ្វើ រៀបចំសម្រាប់ការជំនុំជំរះចុងក្រោយចំពោះអស់អ្នក

ដែលប្រឆាំងនឹងព្រះជាម្ចាស់។ យើងបាននិយាយអំពីការបំផ្លាញសាតាំង ហើយនិង គ្រប់គ្នាដែលនៅខាងវា។

ថ្ងៃនេះ យើងនឹងដាក់រឿងទាំងនោះមួយឡែក ហើយមើលទៅឲ្យកាន់តែជ្រៅទៅពេលអនាគត។ យើងនឹងត្រូវប្រើប្រាស់ការស្រមើស្រមៃរបស់យើង ដើម្បីរកឲ្យឃើញថា ជីវិតនឹងមានលក្ខណៈបែបណានៅក្នុងនគរដ៏អស់កល្បរបស់ព្រះជាម្ចាស់។ ហោរា យ៉ូហានបានឮសំលេងរបស់ព្រះជាម្ចាស់។ សូមស្ដាប់៖

“មើល អញធ្វើទាំងអស់ឡើងជាថ្មី” (វិវរណៈ ២១:៥)។

នេះគឺជាអ្វីដែលលោកប៉ុលបានសរសេរអំពីវា៖

“សេចក្ដីដែលភ្នែកមើលមិនឃើញ ត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្ដីនោះឯងដែលព្រះបានរៀបចំទុកសម្រាប់ពួកអ្នកដែលស្រឡាញ់ទ្រង់” (កូរិនថូសទី១ ២:៩)។

(លើកព្រះគម្ពីរឡើង) ថ្ងៃនេះ យើងនឹងឲ្យព្រះគម្ពីរធ្វើជាអ្នកដឹកនាំយើង។ វានឹងផាត់រូបភាពពាក្យដ៏អស្ចារ្យនៃវត្ថុដែលនឹងល្អហួសថ្លែង។ យើងចាប់ផ្ដើមជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់អង្គឯង ដែលទ្រង់មានបន្ទូលតាមរយៈហោរាអេសាយ៖

“ដ្បិតមើល អញនឹងបង្កើតផ្ទៃមេឃថ្មី ហើយនិងផែនដីថ្មី ឯរបស់ពីមុនៗ នោះនឹងគ្មានអ្នកណានឹកចាំទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ”(អេសាយ ៦៥:១៧)។

.................................................................................................................................

.



លោកយ៉ូហានបានឃើញបទទំនាយរបស់ហោរាអេសាយត្រូវបានបំពេញ។

“រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ទៅហើយ ក៏គ្មានសមុទ្រទៀតឡើយ។ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ តាក់តែងដូចជាប្រពន្ធថ្មោងថ្មី តែងខ្លួនទទួលប្ដី” (វិវរណៈ ២១:១,២)។

តើអ្នកអាចស្រមៃពីរូបភាពនោះនៅក្នុងចិត្តគំនិតរបស់អ្នក? ផែនដីរបស់យើងនឹងត្រូវបានធ្វើថ្មីឡើងវិញដោយព្រះអទិករអង្គឯង។ គ្រប់ដាននៃជាតិសាសន៍របស់មនុស្សនឹងត្រូវបាត់បង់អស់។ នឹងមិនមានអ្វីដែលអំពើបាបប៉ះពាល់បានឡើយ។ នឹងគ្មានសញ្ញានៃអំពើអាក្រក់។ ពិភពលោកថ្មីនឹងមានលក្ខណៈល្អឥតខ្ចោះ ដែលនឹងធ្វើឲ្យពិភពលោកចាស់ត្រូវបានបំភ្លេចចោល។

ទីក្រុងបរិសុទ្ធ យេរូសាឡិមថ្មី នឹងហោះចុះរហូតមកដល់ខាងក្រោម ឆ្លងកាត់ផ្កាយ ហើយនឹងចតនៅលើពិភពលោកយើងនេះ។ ជាងគំនូរបានព្យាយាមគូររូបភាពនោះយ៉ាងស្អាត ប៉ុន្តែ វានឹងអស្ចារ្យ ហើយនិងល្អជាងការស្មានរបស់ពួកគេទៅទៀត។ វានឹងក្លាយជារាជធានីនៃសកលលោកទាំងមូល។

.................................................................................................................................

.



នេះគឺជាការពិពណ៌នាអំពីរាជធានីនោះរបស់ហោរា ៖

“ឯទេវតា ដែលនិយាយមកខ្ញុំ នោះក៏មានកាន់រង្វាស់មាស ដើម្បីនឹងវាស់ទីក្រុង និងទ្វារ ហើយកំផែងក្រុងដែរ។ ទីក្រុងនោះ មានរាង៤ជ្រុង បណ្តោយនិងទទឹងស្មើគ្នា ទេវតាក៏យករង្វាស់ទៅវាស់ទីក្រុង ឃើញមាន១២ ពាន់ស្តាដ ឯបណ្តោយ ទទឹង ហើយកំពស់ក៏ស្មើគ្នាទាំងអស់” (វិវរណៈ ២១: ១៥,១៦)។

១២ពាន់ស្តាដ គឺជិតស្មើនឹង២៤០០គីឡូម៉ែតជុំវិញកំផែងខាងក្រៅ។ ទីក្រុងយេរូសាឡិមថ្មី គឺធំខ្លាំងណាស់!

នៅមានទៀត ៖

“ហើយពន្លឺរស្មីរបស់ទីក្រុងនោះ ក៏ដូចជាត្បូងមានតម្លៃថ្លៃវិសេស គឺដូចជាត្បូងមណីជោតិ ហើយថ្លាដូចកែវចរណៃ” (វិវរណៈ ២១:១១)។

“ទ្វារទាំង១២ ជាកែវមុក្តា១២ គឺទ្វារ១ធ្វើពីកែវមុក្តា១ ហើយផ្លូវក្រុងក៏ធ្វើពីមាសសុទ្ធថ្លាដូចជាកែវ” (វិវរណៈ ២១:២១)។

“ក្រុងនោះមិនត្រូវការនឹងព្រះអាទិត្យ ឬព្រះចន្ទ សម្រាប់នឹងបំភ្លឺទេ ដ្បិតសិរីល្អនៃព្រះបានបំភ្លឺហើយ ឯកូនចៀមក៏ជាចង្កៀងនៃក្រុងនោះដែរ” (វិវរណៈ ២១:២៣)។

“ទេវតាក៏បង្ហាញ ឲ្យខ្ញុំឃើញទន្លេទឹកជីវិត ថ្លាដូចជាកែវចរណៃ ដែលហូរចេញពីបល្ល័ង្កនៃព្រះ និងកូនចៀម។ ឯនៅកណ្តាលផ្លូវក្រុងនោះ ហើយនៅមាត់ទន្លេទាំងសងខាង នោះមានដើមជីវិតដែលបង្កើតផ្លែ១២ដង គឺ១ខែម្តងៗ ហើយស្លឹកឈើនោះក៏សម្រាប់ នឹងមើលអស់ទាំងសាសន៍ឲ្យជា” (វិវរណៈ ២២:១,២)។

“ក៏នឹងឥតមានយប់ទៀតឡើយ” (វិវរណៈ ២២:៥)។

“ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ” (វិវរណៈ ២១:៤)។

ហោរាអេសាយបានផ្តល់ព័ត៌មានលំអិតឲ្យយើងបន្ថែមទៀត ៖

“នៅក្នុងស្រុកឯងនឹងមិនដែលឮនិយាយពីសេចក្តីច្រឡោតទៀត ឬពីការរឹបជាន់ ឬពីការបំផ្លាញនៅក្នុងព្រំដែនឯងឡើយ” (អេសាយ ៦០:១៨)។

នៅក្នុងផែនដីថ្មី នឹងមិនមានសង្គ្រាម ហើយមិនមានបទឧក្រិដ្ឋណាមួយឡើយ។ គ្រប់គ្នានឹងមានក្តីសុខជាមួយគ្នា។ នឹងមិនចាំបាច់មានអាវុធ ឬមានប៉ូលីស ឬក៏មានទ័ពឡើយ។

………………………………………………………………………………………………………........

.



ប៉ុន្តែ ហោរាប្រាប់យើងនៅមិនទាន់អស់ទេ។ សូមស្តាប់ ៖

“នៅគ្រានោះ ឆ្កែព្រៃនឹងនៅជាមួយនឹងកូនចៀម ឯខ្លារខិន នឹងដេកនៅជាមួយនឹងកូនពពែ ឯកូនគោ និងសិង្ហស្ទាវព្រមទាំងសត្វបំប៉នយ៉ាងធាត់នឹង នៅជាមួយគ្នា ហើយក្មេងតូចៗជាអ្នកគង្វាលវា”(អេសាយ ១១:៦)។

ដូច្នេះ ក៏នឹងមានក្តីសុខសាន្តនៅក្នុងពូជអំបូររបស់សត្វដែរ។

គ្រប់គ្នានៅក្នុងផែនដីថ្មីនឹងមានសុខភាពល្អជានិច្ច។ សូមស្តាប់ ៖

“ឯពួកអ្នកដែលនៅក្នុងក្រុង គេនឹងមិនថាខ្ញុំឈឺទៀតឡើយ” (អេសាយ ៣៣:២៤)។

“គ្រានោះ ភ្នែករបស់មនុស្សខ្វាក់ នឹងបានភ្លឺឡើង ហើយត្រចៀករបស់មនុស្សថ្លង់នឹងឮបាន។ គ្រានោះ ពួកមនុស្សខ្វិននឹងលោតដូចជាប្រើស ហើយអណ្តាតរបស់មនុស្សគនឹងច្រៀងឡើង” (អេសាយ ៣៥: ៥,៦)។

សូម្បីតែ ផ្ទៃនៃផែនដីថ្មីនឹងត្រូវបានផ្លាស់ប្រែ។

“ទីរហោស្ថាន ហើយទីហួតហែង នឹងមានសេចក្តីអំណរ ឯសមុទ្រខ្សាច់ នឹងរីករាយ ហើយផ្កាឡើងដូចជាកុលាប” (អេសាយ ៣៥:១)។

ផែនដីថ្មីនឹងក្លាយទៅជាកន្លែងដ៏ស្រស់ស្អាត! តើយើងនឹងធ្វើអ្វីខ្លះ នៅលើពិភពលោកដែលល្អឥតខ្ចោះនោះ? សូមស្តាប់៖

“គ្រានោះមនុស្សនឹងសង់ផ្ទះ ហើយនិងអាស្រ័យនៅផង ក៏នឹងដាំចំការទំពាំងបាយជូរ ហើយនិងបរិភោគផលដែរ។ គេនឹងមិនសង់ រួចមានម្នាក់ទៀតអាស្រ័យនៅ ឬដាំ រួចមានម្នាក់ទៀតបរិភោគផលនោះឡើយ។...ហើយពួករើសតាំងរបស់អញនឹងប្រើប្រាស់ការដែលដៃគេធ្វើជាយឺនយូរទៅ” (អេសាយ ៦៥:២១,២២)។

.



ផែនដីថ្មី នឹងក្លាយជាកន្លែងដែលសប្បាយរីករាយ។

“ឯពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះ គេនឹងវិលមកវិញ គេនឹងមកដល់ក្រុងស៊ីយ៉ូនដោយច្រៀង ហើយនិងមានសេចក្តីអំណរដ៏នៅអស់កល្បជានិច្ច ពាក់នៅលើក្បាលគេ គេនឹងបានសេចក្តីត្រេកអរ និងសេចក្តីរីករាយ ឯអស់ទាំងសេចក្តីទុក្ខព្រួយ និងដំងូរទាំងប៉ុន្មាន នោះនឹងរត់បាត់ទៅ” (អេសាយ ៣៥:១០)។

“គ្រានោះនឹងកើតមានដូច្នេះថា ចាប់តាំងពីថ្ងៃចូលខែ១ ដរាបដល់ថ្ងៃចូលខែ១ទៀត ហើយពីថ្ងៃឈប់សម្រាក១ ដរាបដល់ថ្ងៃឈប់សម្រាក១ទៀត នោះគ្រប់មនុស្សទាំងអស់នឹងមកក្រាបថ្វាយបង្គំនៅចំពោះអញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា” (អេសាយ ៦៦:២៣)។

វាគឺជាការធ្វើពិធីដើម្បីសម្តែងសេចក្តីត្រេកអរដ៏រីករាយអស្ចារ្យជារៀងរាល់ថ្ងៃបរិសុទ្ធ ពេលដែលរាស្ត្ររបស់ព្រះជាម្ចាស់មកថ្វាយបង្គំទ្រង់ផ្ទាល់។ ពិតហើយ ព្រះជាម្ចាស់ អង្គឯងនឹងគង់នៅទីនោះ។ សូមស្តាប់ពាក្យសម្តីរបស់លោកយ៉ូហាន៖

“ខ្ញុំមានឮសំលេង១យ៉ាងខ្លាំង ចេញពីស្ថានសួគ៌មកថា មើលរោងឧបោសថរបស់ព្រះបាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ” (វិវរណៈ ២១:៣)។



មិត្តអើយ នេះគឺជាអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យចង់បាន កាលទ្រង់បានបង្កើតអាដាម និងអេវ៉ា។ ទ្រង់សព្វព្រះទ័យនឹងនៅជាមួយពួកគេ ដើរ ហើយមានបន្ទូលជាមួយពួកគេ។ ទ្រង់ចង់ធ្វើជាមិត្តដ៏ជិតស្និទ្ធ និងល្អបំផុតរបស់ពួកគេជារៀងរហូត។ ពេលដែលពួកគេបានបែរចេញឆ្ងាយពីទ្រង់ ទ្រង់ខូចព្រះទ័យ។ ទ្រង់លែងបានជួបទាក់ទងជាមួយនឹងពួកគេទល់មុខនឹងមុខទៀតហើយ។

អំពើបាបបានញែកពួកគេចេញពីទ្រង់ ហើយប្លន់ជីវិតអស់កល្បពីពួកគេ។ គម្រោងនៃសេចក្តីសង្គ្រោះរបស់ទ្រង់ គឺសុទ្ធតែអំពីការស្តារមិត្តភាពរវាងអង្គទ្រង់ ជាមួយនឹងកូនចៅមនុស្សជាតិរបស់ទ្រង់ ដើម្បីឲ្យទ្រង់អាចផ្តល់ជីវិតអស់កល្បឲ្យដល់ពួកគេ។

តើមានអ្វីដែលអាចប្រសើរជាការរស់នៅក្នុងពិភពលោកដ៏ល្អឥតខ្ចោះជារៀងរហូតទៅ? ព្រះយេស៊ូ ជាព្រះអង្គសង្គ្រោះរបស់យើង នឹងគង់នៅទីនោះ។ ទ្រង់នឹងយាងដើរ ហើយមានបន្ទូលជាមួយនឹងយើង ដូចដែលទ្រង់ធ្លាប់បានធ្វើជាមួយនឹងអាដាម ហើយនិងអេវ៉ា នៅសួនអេដែនដែរ។ ខ្ញុំដឹងថា ខ្ញុំចង់នៅទីនោះ។ ចុះអ្នកវិញ? ខ្ញុំប្រាកដថា មានកន្លែងសម្រាប់អ្នកនៅទីនោះ។

ព្រះយេស៊ូនឹងនៅទីនោះ ដើម្បីបើកបង្ហាញឲ្យយើងដឹងពីអាថ៌កំបាំងនៃការបង្កើត។ យើងនឹងរៀនអំពីអ្វីដែលថ្មីៗជានិច្ច។ យើងនឹងអាចធ្វើដំណើរ តាមពេលវេលាដែលយើងចង់។ យើងនឹងមានពេលនៅជាមួយមិត្តភក្តិយើង ហើយនិងញាតិជាទីស្រឡាញ់របស់យើង។ ហើយរាល់ថ្ងៃបរិសុទ្ធ យើងនឹងសរសើរតម្កើងព្រះ ហើយច្រៀងជាមួយនឹងពពួកទេវតា ហើយនិងព្រះយេស៊ូ ពេលវេលាពិសេសរបស់យើងដើម្បីធ្វើទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់នៃយើង។

ខ្ញុំដឹងថា ខ្ញុំចង់នៅទីនោះ។ ចុះអ្នកវិញ? ខ្ញុំប្រាកដថា មានកន្លែងសម្រាប់អ្នកនៅទីនោះ។

---



អ្នកមុខជាចង់និយាយថា “បរពិត្រព្រះអម្ចាស់ ទូលបង្គំចង់នៅជាមួយនឹងទ្រង់។ ទូលបង្គំចង់នៅជាមួយនឹងទ្រង់ជារៀងរហូត!”

អ្នកអាចធ្វើជាផ្នែកមួយនៃអនាគតអស់កល្បដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ចូរទទួលយកព្រះយេស៊ូធ្វើជាព្រះអង្គសង្គ្រោះរបស់អ្នកនៅថ្ងៃនេះ។ សូមយាងព្រះវិញ្ញាណទ្រង់ចូលទៅក្នុងចិត្តរបស់អ្នក។ នោះអ្នកអាចប្រាកដថា មានផ្ទះនៅលើផែនដីថ្មី ជាកន្លែងដែលនឹងមានសេចក្តីសុខសាន្ត សេចក្តីស្រឡាញ់ និងសេចក្តីអំណរជារៀងរហូត។

មុននឹងយើងអធិស្ឋានជុំគ្នា ខ្ញុំសុំសួរសំណួរសំខាន់មួយដល់អ្នក៖ តើព្រះវិញ្ញាណរបស់ព្រះមានបន្ទូលទៅកាន់ចិត្តអ្នកដែរឬទេ? អ្នកប្រហែលជាធ្លាប់ស្ទាក់ស្ទើរ មិនចង់ហ៊ានសម្រេចចិត្តទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់អ្នក។ ប្រហែលជាអ្នកកំពុងតែគិតអំពីពិធីបុណ្យជ្រមុជទឹក ហើយព្រះជាម្ចាស់កំពុងតែហៅអ្នកឲ្យធ្វើការសម្រេចចិត្តនៅថ្ងៃនេះ។ អ្នកប្រហែលជាកំពុងស្ទាក់ស្ទើរ ពីព្រោះមានអំពើបាបខ្លះនៅក្នុងជីវិតរបស់អ្នក ដែលអ្នកមិនចង់បោះបង់ចោល។

ឥឡូវនេះ គឺជាពេលវេលាសំខាន់។ ជីវិតអស់កល្បរបស់អ្នកអាចអាស្រ័យទៅលើអ្វីដែលអ្នកសម្រេចនៅទីនេះ នាថ្ងៃនេះ។ បើសិនជាអ្នកបានសម្រេចចិត្តដើរតាមព្រះយេស៊ូ ហើយចង់ធ្វើបុណ្យជ្រមុជទឹក ហើយអ្នកចង់ធ្វើពិធីបុណ្យជ្រមុជទឹកក្នុងពេលឆាប់ៗ ខ្ញុំក៏ចង់អធិស្ឋានសម្រាប់អ្នកផងដែរ។ បើសិនជាអ្នកកំពុងទន្ទឹងរង់ចាំ ចង់ធ្វើពិធីបុណ្យជ្រមុជទឹកក្នុងពេលឆាប់ៗនេះ គ្រាន់តែលើកដៃឡើងនៅនឹងកន្លែងទៅបានហើយ។ (ពេលដែលដៃត្រូវបានលើកឡើង ចូរនិយាយថា “ព្រះប្រទានពរអ្នក ព្រះទតឃើញដៃរបស់អ្នក”)។

អ្នកប្រហែលជាពិបាកធ្វើការសម្រេចចិត្តទទួលយកព្រះយេស៊ូគ្រីស្ទជាព្រះអង្គសង្គ្រោះ។ សូមមេត្តាកុំពន្យារពេលអី។ ឥឡូវ គឺជាពេលដែលត្រូវនិយាយថា "ព្រះអម្ចាស់យេស៊ូ ទូលបង្គំបានសម្រេចចិត្តហើយ។ ទូលបង្គំត្រូវការទ្រង់នៅក្នុងជីវិតរបស់ទូលបង្គំ។ សូមទ្រង់មេត្តាអភ័យទោសបាបរបស់ទូលបង្គំ ហើយទទួលយកទូលបង្គំ ចូលទៅក្នុងនគររបស់ទ្រង់។" បើសិននោះ ជាអ្វីដែលចិត្តអ្នកប្រាថ្នាចង់បាននៅថ្ងៃនេះ សូមលើកដៃឡើង ឥឡូវនេះ។

ខ្ញុំដឹងថា អាចមានអ្នកខ្លះដែលនៅទីនេះ ដែលមានទម្លាប់ ឬអំពើបាបខ្លះនៅក្នុងជីវិតរបស់អ្នក ដែលរារាំងអ្នក ហើយអ្នកចង់និយាយថា "ព្រះអម្ចាស់ ទូលបង្គំចង់បោះបង់វាចោល។ ទូលបង្គំសុខចិត្តឲ្យទ្រង់ធ្វើឲ្យទូលបង្គំយល់ព្រមបោះបង់វាចោល។ ទូលបង្គំទូលសូមឲ្យទ្រង់យកវាចេញពីទូលបង្គំ ពីព្រោះទូលបង្គំមិនអាចឲ្យវាបានទេ។

"ទូលបង្គំត្រូវការទ្រង់ឲ្យទូលបង្គំមានចិត្តថ្មី ពីព្រោះទូលបង្គំមិនអាចបោះបង់ទម្លាប់ចាស់ចោលដោយខ្លួនឯងបានទេ។ ទូលបង្គំជារបស់ផងទ្រង់។ សូមទ្រង់ធ្វើឲ្យទូលបង្គំក្លាយទៅជាប្រភេទមនុស្សដែលទ្រង់ចង់បាន។ ទូលបង្គំចង់រស់នៅក្នុងផែនដីថ្មីជាមួយនឹងទ្រង់។" គ្រាន់តែលើកដៃរបស់អ្នកឡើង ទៅបានហើយ។ ព្រះប្រទានពរឲ្យអ្នក គ្រប់គ្នា។ ព្រះទ្រង់ទតឃើញដៃគ្រប់គ្នា ព្រះទ្រង់ទតឃើញចិត្តរបស់មនុស្សម្នាក់ៗ។ ឥឡូវនេះ សូមអធិស្ឋានជាមួយគ្នា។

(សំណើអធិស្ឋាន)

"ឱព្រះវរបិតាដែលគង់នៅនគរឋានសួគ៌ អរព្រះគុណទ្រង់ចំពោះព្រះយេស៊ូ អរព្រះគុណទ្រង់ចំពោះសេចក្តីស្រឡាញ់របស់ទ្រង់ អរព្រះគុណទ្រង់ចំពោះព្រះគុណរបស់ទ្រង់ អរព្រះគុណទ្រង់ចំពោះអំណាចរបស់ទ្រង់។ ពួកទូលបង្គំចង់និយាយនៅវេលាយប់នេះថា ពួកទូលបង្គំស្រឡាញ់ទ្រង់។ ពួកទូលបង្គំចង់នៅជាមួយនឹងទ្រង់នៅក្នុងនគរដ៏អស់កល្បរបស់ទ្រង់។

ព្រះវរបិតាអើយ សូមទ្រង់បណ្តាលចិត្តទូលបង្គំឲ្យបានជ្រាលជ្រៅនៅវេលាយប់នេះ។ សូមជួយបើកចិត្តពួកទូលបង្គំ ឲ្យទទួលយកក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់។ សូមជួយពួកទូលបង្គំឲ្យថ្វាយចិត្តរបស់ពួកទូលបង្គំទាំងស្រុងទៅឯទ្រង់។ ពួកទូលបង្គំទន្ទឹងរង់ចាំទៅរស់នៅជាមួយនឹងទ្រង់ជារៀងរហូត។ សូមកុំឲ្យពួកទូលបង្គំបាត់បង់អ្នកណាម្នាក់ឡើយ។ ពួកទូលបង្គំទូលសូមនៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។

<u>ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ៖</u>

| | | |
|---|---|---|
| លោកុប្បត្តិ ៣:១៥ | ម៉ាថាយ ៥:៥ | ពេត្រុសទី២ ១:១៩ |
| វិវរណៈ ២២:៣ | លោកុប្បត្តិ ៦:៥ | ម៉ាថាយ ៦:១០ |
| ហេព្រើរ ១១:៩-១០ | វិវរណៈ ២២:១៧ | លោកុប្បត្តិ ១២:១-២ |
| កាឡាទី ៣:២៩ | ហេព្រើរ ១១:១៣,១៦ | អេសាយ ៦០:១៨ |
| រ៉ូម ៦:១៦ | វិវរណៈ ៣:២០-២១ | អេសាយ ៦៦:២២ |
| កូរិនថូសទី១ ២:១០ | វិវរណៈ ២១:១២,១៧ | |

# លំនាំពិភាក្សា

**ជំងឺបាក់ទឹកចិត្ត**

១. តើវិធីអ្វីខ្លះដែលធម្មជាតិអាចជួយព្យាបាលជំងឺបាក់ទឹកចិត្តបាន?
២. ចូរប្រាប់ឈ្មោះអាហារខ្លះៗដែលល្អសម្រាប់ខួរក្បាលរបស់អ្នក?
៣. តើវិធីការពារប្រឆាំងនឹងជំងឺបាក់ទឹកចិត្តដែលល្អបំផុត គឺជាអ្វី?

**ផែនដីថ្មី**

១. តើហោរាយ៉ូហានបានឃើញអ្វីចុះមកពីឋានសួគ៌?
-វិវរណៈ ២១:១,២
២. ទីក្រុងបរិសុទ្ធមានទំហំធំណាស់!វាក៏ស្អាតដែរ! តើទ្វារទីក្រុង និងផ្លូវធ្វើអំពីអ្វី?
-វិវរណៈ ២១:១១,២១
៣. តើយើងនឹងញុំាអ្វីនៅទីនោះ?
-វិវរណៈ ២២:១,២
៤. តើរឿងអស្ចារ្យអ្វីខ្លះដែលអ្នក ហើយនិងខ្ញុំទន្ទឹងរង់ចាំនៅក្នុងផែនដីថ្មី?

| | |
|---|---|
| -វិវរណៈ ២១:៣,៤ | - អេសាយ ៦០:១៨ |
| - អេសាយ ១១:៦ | - អេសាយ ៣៣:២៤ |
| - អេសាយ ៣៥:១,៥,៦,១០ | - អេសាយ ៦៦:២៣ |

# មេរៀនសុខភាពទី២៦: ដានីញ៉ែល - របៀបរស់នៅរបស់ព្រះសម្រាប់សុខភាពល្អ



១. ឧបមាថា ថ្ងៃមួយអ្នកឮសំលេងទាហានដើរជាក្បួនឆ្ពោះទៅកាន់ភូមិរបស់អ្នក។ ពួកគេសម្រុកចូលទៅក្នុងផ្ទះ ហើយចាប់ក្មេងៗ ចងដៃពួកគេទៅនឹងខ្សែ ហើយនាំពួកគេដើរទៅទឹកដីផ្សេងដែលមិនធ្លាប់ស្គាល់។ គ្មានអ្នកណាអាចបញ្ឈប់ពួកគេបានឡើយ។ តើអ្នកអាចស្រម៉ៃឃើញរឿងគួរឲ្យខ្លាច និងឈឺចាប់ដែរឬទេ?

ព្រះគម្ពីរដានីញ៉ែលប្រាប់យើងថា ហេតុការណ៍នេះបានកើតឡើងចំពោះទីក្រុងយេរូសាឡិម។ នេប៊ូក្នេសារជាស្តេចនៃក្រុងបាប៊ីឡូន បានច្បាំងដណ្តើមយកអុីស្រាអែល ហើយនិងចាប់យកយុវវ័យដែលល្អបំផុត ដែលឆ្លាតបំផុត ខ្លាំងបំផុត និងយុវជនរាជ ដើម្បីធ្វើជាបាវបម្រើផ្ទាល់ខ្លួនរបស់ទ្រង់។

នៅក្នុងចំណោមអ្នកដែលត្រូវបានចាប់យកទៅ មានដានីញ៉ែល ហើយនិងមិត្តភក្តិជិតដិតរបស់គាត់៣នាក់។ ពួកគាត់មកពីក្រុមគ្រួសារដែលស្រឡាញ់ និងគោរពដល់ព្រះជាម្ចាស់ ហើយនិងព្រះបន្ទូលរបស់ផងទ្រង់។ ក្មេងប្រុសទាំងនេះត្រូវបានបង្រៀនឲ្យចេះស្រឡាញ់ព្រះជាម្ចាស់ ហើយនិងចេះដឹងគុណ មានចិត្តសប្បុរស និងចេះស្តាប់បង្គាប់នៅគ្រប់កាលៈទេសៈ។ ពួកគេមានទម្លាប់ធ្វើតាមព្រះបន្ទូលរបស់ព្រះ ហើយពួកគាត់មិនព្រមផ្លាស់ប្តូរជំនឿរបស់ពួកគាត់ឡើយ។ នៅក្នុងទឹកដីដែលគេចាប់ពួកគាត់ទៅធ្វើជាឈ្លើយ ពួកគាត់គោរពព្រះជាម្ចាស់ ហើយ បានរស់នៅតាមរបៀបរបស់ទ្រង់។ ព្រះជាម្ចាស់ក៏បានតបវិញ ដោយផ្តល់កិត្តិយសដល់ពួកគាត់វិញដែរ។

……………………………………………………………………………………………………........

២. ទីក្រុងបាប៊ីឡូននោះរុងរឿង ទីក្រុងដែលសម្បូរ ពោរពេញទៅដោយភាពស្រស់បំព្រង និងមានការល្បួង។ ស្តេចចង់យកឈ្លើយធ្វើជាបាវបម្រើស្មោះត្រង់របស់ទ្រង់ ដូច្នេះ ទ្រង់បានទាក់ទាញពួកគាត់ដោយចំណាប់អារម្មណ៍ និងជំនួយពិសេសនៅក្នុងទីធ្លាយ៉ាងប្រណិតដែលបានមកពីអំពើពុករលួយ។ ពួកគាត់ត្រូវបានផ្តល់ឲ្យនូវអាហារល្អៗពីលើតុរបស់ទ្រង់ ហើយនិងស្រាល្អៗបំផុត។

នេះគឺជាការសាកល្បងដ៏សំខាន់។ លោកដានីញ៉ែល ហើយនិងមិត្តភក្តិរបស់គាត់ចងចាំមេរៀនពីផ្ទះ ហើយបានធ្វើសំណើពិសេស។ ពួកគាត់ស្នើសុំអាហារធ្វើអំពីបន្លែរុក្ខជាតិ ហើយនិងទឹកសុទ្ធធម្មតាញ៉ាំជំនួសអាហារធ្វើអំពីសាច់សត្វ និងស្រាវិញ។ នេះគឺជាសំណើប្លែក ប៉ុន្តែ ដោយសារអត្តចរិតល្អ និងភាពឆ្លាតវៃរបស់ពួកគាត់ ទ្រង់ក៏បានយល់ព្រម។ ព្រះជាម្ចាស់ការពារ ហើយផ្តល់ឲ្យពួកគាត់។

ព្រះជាម្ចាស់បានប្រទានពរដល់ភាពស្មោះត្រង់របស់ពួកគាត់ ហើយបន្ទាប់ពីការញ៉ាំតាមរបៀបព្រះជាម្ចាស់ចំនួន១០ថ្ងៃ កំលោះទាំងបីកាន់តែមានសុខភាពល្អ ហើយស្បែកមានពណ៌ល្អប្រសើរ ហើយមានខួរក្បាលឆ្លាតវៃជាងឈ្លើយវ័យក្មេងដទៃទៀត។ ពួកគាត់ត្រូវបានអនុញ្ញាតឲ្យញ៉ាំអាហាររុក្ខជាតិសម្រាប់បីឆ្នាំបន្ទាប់ទៀត ពេលដែលពួកគាត់បានរៀនសូត្រនៅក្នុងសាលារៀនរបស់ស្តេចជាមួយនឹងពួកឈ្លើយដទៃទៀត។

……………………………………………………………………………………………………........

៣. ការសិក្សាអប់រំរបស់ស្តេចរាប់បញ្ចូលការសិក្សាខ្ពស់ផ្នែកវិទ្យាសាស្ត្រ គណិត ប្រវត្តិសាស្ត្រ ភាសា និងរដ្ឋាភិបាល។ នៅចុងបំផុតនៃមេរៀន ស្តេចបានត្រាស់ហៅសិស្សធ្វើតេស្ត។ លោកដានីញ៉ែល និងមិត្តភក្តិរបស់ពួកគាត់ គឺឆ្លាតជាងសិស្សដទៃទៀតដប់ដង។ ព្រះគម្ពីរចែងថា “ដ្បិតអស់អ្នកណាដែលលើកតម្កើងអញ នោះអញនឹងតម្កើងអ្នកនោះឡើងដែរ” (សាំយ៉ូអែលទី១ ២:៣០) នោះគឺជារឿងដែលបានកើតឡើង។ ព្រះជាម្ចាស់បានប្រទានពរពួកគេ ហើយផ្តល់ចំណេះដឹង ហើយនិងជំនាញនៅគ្រប់ការរៀនសូត្រ។

មនុស្សដែលសំខាន់បំផុតនៅក្នុងប្រទេស គឺមិនមានចំណេះដឹង ការយល់ដឹងខ្ពង់ខ្ពស់ ការគិតច្បាស់លាស់ ការអង្គុយ ឬឈរត្រង់ខ្លួន រាងកាយរឹងមាំ ហើយនិងអំណោយទានពីធម្មជាតិដូចលោកដានីញ៉ែល ហើយនិងមិត្តទាំងបីរបស់ពួកគាត់។ ស្តេចជ្រាបថា ព្រះអម្ចាស់ធ្លាប់បានធ្វើជាគ្រូបង្រៀនដល់ពួកគាត់ ហើយទ្រង់បានផ្តល់កិត្តិយសឲ្យអ្នកទាំងបួននូវតំណែងខ្ពង់ខ្ពស់នៅក្នុងរដ្ឋាភិបាលរបស់ទ្រង់ ដែលពួកគាត់បានបម្រើការងារយ៉ាងស្មោះត្រង់អស់រយៈពេលជាច្រើនទសវត្សរ៍។

………………………………………………………………………………………………

៤. រឿងព្រះគម្ពីរចែងប្រាប់ពីរឿងអតីតកាល ប៉ុន្តែ រឿងទាំងនោះក៏បានបង្រៀនអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតយើងនាសព្វថ្ងៃនេះដែរ។ ព្រះទ្រង់ចង់ប្រទានពរឲ្យយើងនាពេលឥឡូវនេះខ្លាំងណាស់ គឺដូចនៅក្នុងសម័យកាលរបស់លោកដានីញ៉ែល និងមិត្តភក្តិរបស់គាត់ដូច្នោះដែរ។ នៅក្នុងមេរៀនសុខភាពដែលមានជាបន្តបន្ទាប់មកនេះ យើងបានរៀននូវអ្វីដែលវិទ្យាសាស្ត្រ និងព្រះគម្ពីរបានបង្រៀនអំពីសុខភាពល្អ។ គោលការណ៍ដែលលោកដានីញ៉ែល និងមិត្តភក្តិបានធ្វើតាម ក៏នឹងផ្តល់ឲ្យយើង និងកូនចៅរបស់យើងមានរាងកាយរឹងមាំ គំនិតជ្រះថ្លា និងចិត្តស្រឡាញ់ព្រះជាម្ចាស់។

គោះ រំឭកមេរៀនព្រះគម្ពីរអំពីជម្រើសនៃការរស់នៅដែលជួយឲ្យមានសុខភាពល្អតាមបែបរបស់ព្រះជាម្ចាស់។

………………………………………………………………………………………………

**៥. អាហារដែលមានជីវជាតិ ឬសារធាតុចិញ្ចឹម ៖**

អាហារដែលមានជីវជាតិ ឬសារធាតុចិញ្ចឹម ត្រូវមានអាហារធ្វើអំពីរុក្ខជាតិ ស្រស់ៗមកពីសួនដំណាំពីធម្មជាតិទាំងស្រុង មិនចម្រាញ់ ហើយក៏គ្មានបន្ថែមជាតិស្ករ ឬក៏ខ្លាញ់។ ការបំបៅកូនដែត គឺជាជម្រើសដែលល្អបំផុតសម្រាប់កំឡុងពេល២ឆ្នាំដំបូង ត្រូវបន្ថែមអាហារបន្លែ បន្ទាប់ពីកូនដែតមានអាយុ៦ខែ។

អាហារសាច់សត្វ និងផលិតផលធ្វើអំពីសាច់សត្វ មិនមែនជាអាហារដែលល្អបំផុតសម្រាប់មនុស្សឡើយ។ អាហារទាំងនោះអាចបង្កជាជំងឺ ហើយនាំឲ្យមានសុខភាពមិនល្អ។

**ភេសជ្ជៈ ៖**

ភេសជ្ជៈដែលល្អបំផុត គឺទឹកសុទ្ធ ដែលស្អាត។ ទឹកសំអាតជាតិពុលចេញពីឈាម ហើយជួយរក្សារាងកាយ និងខួរក្បាលឲ្យធ្វើការបានយ៉ាងល្អបំផុត។ ស្រាបៀរ ស្រា ភេសជ្ជៈដែលមានជាតិសូដា កាហ្វេ និងតែពណ៌ខ្មៅធ្វើឲ្យរាងកាយខូច ហើយប្រើប្រាស់វីតាមីន និងសារធាតុខនិជដែលត្រូវការសម្រាប់ការលូតលាស់ និងសុខភាពល្អ។

**ខ្យល់បរិសុទ្ធ ពន្លឺថ្ងៃ និងការហាត់ប្រាណ ៖**

ជីវិត គឺនៅក្នុងឈាម។ ព្រះជាម្ចាស់ផ្តល់អំណោយនៃខ្យល់បរិសុទ្ធ ពន្លឺថ្ងៃ ហើយនិងការហាត់ប្រាណ ដើម្បីសំអាតឈាម និងធ្វើឲ្យប្រព័ន្ធការពាររាងកាយរឹងមាំ ដែលអាចប្រយុទ្ធ និងយកឈ្នះលើជំងឺនានា។ អំណោយទាំងនេះ គឺ មិនគិតថ្លៃទេ ហើយត្រូវប្រើប្រាស់វាជារៀងរាល់ថ្ងៃ។ វាផ្តល់សុខភាពល្អទៅឲ្យរាងកាយ និងជួយផលិតសារធាតុគីមី ឲ្យខួរក្បាល ដែលធ្វើឲ្យយើងសប្បាយរីករាយ ហើយនិងជួយឲ្យគេងលក់ស្រួល។

**អនាម័យ និងភាពស្អាតស្អំ៖**

រាងកាយ ផ្ទះ និងបរិស្ថានដែលស្អាតស្អំកាត់បន្ថយចំនួនមេរោគដែលធ្វើឲ្យមានគ្រោះថ្នាក់ ពពួកព្រូន និងបរាសិតដែលនាំឲ្យកើតជំងឺនានា។ ភាពស្អាតស្អំជួយការពាររាងកាយពីជំងឺនានា។

**ជាតិពុល៖**

សាតាំង គឺជាមេអន្ទាក់ទាក់ចិត្តគំនិតរបស់មនុស្ស។ វិធីមួយដែលមានប្រសិទ្ធភាពបំផុតរបស់វា គឺជាតិពុលដែលមាននៅក្នុងថ្នាំជក់ ស្រា និងថ្នាំញៀន។ វត្ថុទាំងនេះ គឺជាមេបំផ្លាញ ហើយត្រូវតែចៀសវាងវា។ វាបំផ្លាញសុខភាពខួរក្បាល និងរាងកាយ វានាំទុក្ខវេទនាឲ្យអ្នកដែលប្រើប្រាស់វា ហើយនាំភាពអាប់យសដល់ព្រះជាម្ចាស់។ ដោយមានជំនួយពីព្រះជាម្ចាស់ អ្នកអាចនិយាយថាទេ ចំពោះជាតិពុលទាំងនេះបាន។ ចូរទូលសុំទ្រង់ទៅ។

……………………………………………………………………………………………………………..........

៦. សេចក្តីស្រឡាញ់ និងគ្រួសារ៖

កាលពីដំបូងឡើយ ព្រះជាម្ចាស់បានបង្កើតបុរស និងស្ត្រី ដើម្បីជួយបន្ថែមគ្នាទៅវិញទៅមកនៅក្នុងការបំពេញចំណងអាពាហ៍ពិពាហ៍។ ប៉ុន្តែ ជាញឹកញយច្រើនតែមានភាពអាត្មានិយម និងខ្វះការគ្រប់គ្រង មករំខានដល់ចំណងអាពាហ៍ពិពាហ៍ ហើយនាំឲ្យមានជំងឺ និងទុក្ខវេទនាដល់ក្រុមគ្រួសារទាំងមូល។ តាមរយៈក្តីស្រឡាញ់ចំពោះព្រះយេស៊ូ ហើយនិងភក្តីភាពចំពោះទ្រង់ គ្រួសារអាចទទួលបានព្រះពរពិសេសរបស់ព្រះជាម្ចាស់ សមាជិកម្នាក់ៗផ្តល់ឲ្យហើយនិងទទួលបានក្តីស្រឡាញ់។

ពេលដែលអ្នកសម្រេចចិត្តដើរតាមព្រះយេស៊ូតាមរបៀបរស់នៅរបស់អ្នក ព្រះពរដែលបានផ្តល់ឲ្យទៅលោកដានីញ៉ែល ក៏នឹងអាចជារបស់អ្នកផងដែរ។ ព្រះជាម្ចាស់មានបន្ទូលថា “អ្នកស្ងួនភ្ងាអើយ ខ្ញុំប្រាថ្នាចង់ឲ្យអ្នកបានចម្រើនឡើងគ្រប់ជំពូក ហើយឲ្យបានសុខសប្បាយខាងរូបសាច់ ដូចជាព្រលឹងអ្នកបានចម្រើនឡើងដែរ” (យ៉ូហានទី៣ ១:២)។

## សហរដ្ឋអាមេរិកស្ថិតនៅក្នុងបទទំនាយ



ថ្ងៃនេះ ខ្ញុំចង់និយាយទៅកាន់អ្នកអំពីសត្វកំណាចធំៗចំនួន៣។ ពួកវា ពិតជាបិសាច។ មួយមកពីលើមេឃ មួយមកពីសមុទ្រ ហើយមួយទៀតមកពីដីគោក។ សត្វកំណាចទាំងបីនេះរួមគ្នា តំណាងឲ្យសត្រូវរបស់ព្រះពិតរួមជាមួយនឹងអស់អ្នកដែលជឿទុកចិត្តព្រះបន្ទូលរបស់ទ្រង់ផង។

អ្នកបានជួបបិសាចទាំងបីនេះពីមុនរួចមកហើយ នៅក្នុងមេរៀនរបស់យើង ប៉ុន្តែថ្ងៃនេះ អ្នកនឹងឃើញពួកវានៅក្នុងពន្លឺថ្មី។ អ្នកនឹងឃើញពួកវាទាំងអស់មានគោលបំណងដូចគ្នា៖ ពួកវាចង់ឲ្យមនុស្សគ្រប់គ្នានៅលើផែនដីទទួលយកសាសនាក្លែងក្លាយ ហើយនិងថ្វាយបង្គំព្រះក្លែងក្លាយ។ រឿងរបស់ពួកវា គឺនិយាយអំពីការថ្វាយបង្គំ។

សត្វកំណាចមកពីលើមេឃ នោះគឺពិតជាសត្វនាគហើយ។ សូមស្តាប់៖

“ឃើញមានទីសំគាល់១ទៀត នៅលើមេឃ គឺនាគដ៏ធំ មានសម្បុរក្រហម ដែលមានក្បាល៧ ស្នែង១០ ឯនៅលើក្បាលវា មានមកុដ៧” (វិវរណៈ ១២:៣)។

ខ្ញុំគិតថា អ្នកច្បាស់ជាចងចាំថា សត្វនាគនោះ គឺជាសាតាំងនោះឯង។ វា ហើយនិងទេវតារបស់វា ដែលបានដើរតាមវា ត្រូវបានបណ្តេញចេញពីឋានសួគ៌មក។ ពួកវាជាអ្នកដែលបង្កឲ្យមានបញ្ហាទាំងអស់នៅលើផែនដីនេះ។

ហោរាបានឃើញស្ត្រីស្អាតម្នាក់ដែលបានស្លៀកពាក់ពន្លឺនៃព្រះអាទិត្យ។ នាង គឺជាសញ្ញាតំណាងឲ្យរាស្ត្រដែលស្មោះត្រង់របស់ព្រះជាម្ចាស់។ សូមស្តាប់៖

"នាងមានគភ៌ ក៏ស្រែកដោយរៀបនឹងសម្រាលចេញ ទាំងឈឺចាប់នឹងបង្កើតកូនមក" (វិវរណៈ ១២:២)។

សត្វនាគបានដឹងថា កូនរបស់ស្ត្រីនោះ គឺព្រះយេស៊ូ ជាព្រះរាជបុត្រារបស់ព្រះ។ ហោរាប្រាប់យើងពីហេតុការណ៍ដែលបានកើតឡើងថា៖

"នាគនោះក៏ស្ថិតនៅត្រង់មុខស្ត្រីដែលរៀបនឹងសម្រាលកូននោះ ដើម្បីនឹងលេបកូននាង ក្នុងកាលដែលសម្រាលចេញមក" (វិវរណៈ ១២:៤)។

សាតាំង ដែលជាសត្វនាគមកពីលើមេឃ គឺជាមេរបស់ទេវតាអាក្រក់។ វាតែងតែប្រើមនុស្សឲ្យធ្វើការងារវា។ វាស្ថិតនៅពីក្រោយសាសនាក្លែងក្លាយរបស់អាណាចក្ររ៉ូម៉ាំង។ វាជម្រុញទឹកចិត្តអធិរាជរ៉ូម៉ាំងឲ្យសំលាប់គ្រីស្ទានកាលពីសម័យមុន។

គោលដៅសំខាន់បំផុតរបស់វា គឺព្រះជាម្ចាស់យេស៊ូរបស់យើងនោះឯង។ មិនយូរប៉ុន្មាន បន្ទាប់ពីទ្រង់បានប្រសូត សត្វនាគបានជំរុញទឹកចិត្តមន្ត្រីរ៉ូម៉ាំងឲ្យព្យាយាមតាមធ្វើគត់ទ្រង់។ ព្រះជាម្ចាស់បានបញ្ជូនទេវតាមកព្រមានដាស់តឿនឪពុកម្តាយរបស់ព្រះយេស៊ូ ឲ្យភៀសខ្លួនចេញទៅប្រទេសអេហ្ស៊ីព ជាកន្លែងដែលព្រះបុត្រាអាចមានសុវត្ថិភាពបាន។

---



ក្រោយមក នៅពេលដែលព្រះយេស៊ូរៀបនឹងចាប់ផ្តើមការបង្រៀន ហើយនិងការងារព្យាបាលរបស់ទ្រង់ សត្វនាគបានព្យាយាមប្រើវិធីសាស្ត្រមួយទៀត។ វាចង់បោកបញ្ឆោតព្រះយេស៊ូឲ្យថ្វាយបង្គំព្រះក្លែងក្លាយ។ សូមស្តាប់៖

"...អារក្សបាននាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ ក៏បង្ហាញអស់ទាំងនគរក្នុងលោកិយ និងសិរីលំអរបស់នគរទាំងនោះថ្វាយទ្រង់ទត។ រួចទូលថា បើសិនជាអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះខ្ញុំនឹងឲ្យរបស់ទាំងនេះដល់អ្នក" (ម៉ាថាយ ៤:៨,៩)។

មិត្តអើយ សព្វថ្ងៃសាតាំងវាធ្វើបែបនេះដាក់យើងដូចគ្នា។ វាព្យាយាមបញ្ចុះបញ្ចូលយើងឲ្យងាកចេញពីព្រះជាម្ចាស់ ហើយមកបម្រើវាវិញ។ យើងត្រូវធ្វើនូវអ្វីដែល ព្រះយេស៊ូបានធ្វើ។

"នោះព្រះយេស៊ូមានព្រះបន្ទូលតបថា នែសាតាំង ចូរឯងថយចេញពីអញទៅ ដ្បិតមានសេចក្តីចែងទុកមកថា ឯងត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែមួយព្រះអង្គប៉ុណ្ណោះ" (ម៉ាថាយ ៤:១០)។

ការវាយប្រហារចុងក្រោយរបស់សាតាំងជំទាស់នឹងព្រះយេស៊ូ គឺនៅលើឈើឆ្កាង។ ព្រះយេស៊ូបានសុគតនៅលើឈើឆ្កាង នៅក្រោមអំណាចនៃរាជាធិរាជរ៉ូម៉ាំង។ មើលទៅហាក់ដូចជាសត្វនាគនោះបានឈ្នះសង្គ្រាមប្រឆាំងនឹងព្រះយ៉ាងធំធេង។ ប៉ុន្តែ នៅពេល

ដែលព្រះយេស៊ូបានរស់ពីសុគតឡើងវិញ បានធ្វើឲ្យអំណាចរបស់សត្វនាគបែកខ្ចាយអស់។

បន្ទាប់ពីព្រះយេស៊ូយាងទៅកាន់ឋានសួគ៌វិញ សត្វនាគក៏បែរការអារម្មណ៍ទៅរកអស់អ្នកដែលជឿព្រះយេស៊ូ ហើយនិងអ្នកដែលនាំសាររបស់ទ្រង់ទៅកាន់មនុស្សនៅក្នុងពិភពលោក។ ជាថ្មីម្តងទៀត សត្វនាគបានធ្វើការតាមរយៈអ្នកកាន់សាសនាក្លែងក្លាយរបស់អាណាចក្ររ៉ូម៉ាំង។

នេះគឺជារឿងសំខាន់ដែលអ្នកគួរដឹងអំពីពួករ៉ូម៉ាំង៖ សម្រាប់ពួកគេ សាសនា គឺជាផ្នែកមួយរបស់រដ្ឋាភិបាល។ ទាំងពីរនេះ គឺមិនអាចញែកចេញពីគ្នាបានឡើយ។ ព្រះវិហារ និងរដ្ឋ គឺរួមគ្នា។ ការថ្វាយបង្គំព្រះរបស់ពួករ៉ូម៉ាំង គឺជាផ្នែកមួយនៃការធ្វើជាពលរដ្ឋល្អ។

ដូច្នេះ វាងាយស្រួលយល់អំពីមូលហេតុដែលទីក្រុងរ៉ូមមានបញ្ហាជាមួយនឹងគ្រីស្ទាន ដែលជ្រើសរើសថ្វាយបង្គំព្រះជាម្ចាស់នៃនគរឋានសួគ៌។ ពួកអធិរាជបានបង្ខំពួកគេឲ្យទទួលយកសាសនារបស់រដ្ឋនៃទីក្រុងរ៉ូម។ មានមនុស្សជាច្រើនបានបដិសេធ ហើយត្រូវបាត់បង់ជីវិត។ នេះគឺជាការងាររបស់សត្វនាគ។

ដូចអាណាចក្រធំៗដទៃទៀតនៅក្នុងពិភពលោកដែរ នៅទីបំផុតអាណាចក្ររ៉ូម៉ាំងបានបែកបាក់។ វាគឺជាការស្លាប់ដ៏យូរ និងយឺត ហើយនៅក្នុងដំណើរការនោះ មានអធិរាជ ខ្លះបានសម្រេចចិត្តយកសាសនាគ្រីស្ទជាសាសនាផ្លូវការ។

ដំបូងនេះ មើលទៅហាក់ដូចជាជ័យជំនះដ៏ធំសម្រាប់ព្រះវិហាររបស់ព្រះជាម្ចាស់។ ប៉ុន្តែ អត់ទេ! ពួកគេបានបញ្ចូលគ្រីស្ទសាសនា លាយជាមួយនឹងសាសនាក្លែងក្លាយ ហើយសាសនាពិតត្រូវបានធ្វើឲ្យខុសពីភាពដើម។ សាតាំង ដែលជាសត្វនាគដ៏ធំ គឺមិនត្រូវបានបញ្ចប់ទេ។

………………………………………………………………………………………………………........

.



នេះ គឺជាឈុតឆាករបស់សត្វកំណាចទី២ចូលមកក្នុងរូបភាពរបស់យើង។ សូមស្តាប់ពាក្យសម្តីរបស់ហោរាយ៉ូហាន៖

“ហើយខ្ញុំឃើញសត្វសាហាវ១ឡើងចេញពីសមុទ្រមក ដែលមានស្នែង១០ និងក្បាល៧ ...ហើយនៅលើក្បាលទាំងប៉ុន្មាន នោះមានឈ្មោះជាពាក្យប្រមាថ” (វិវរណៈ ១៣:១)។

នៅក្នុងបទទំនាយព្រះគម្ពីរ សមុទ្រតំណាងឲ្យ “ប្រជាជន មនុស្សផងទាំងឡាយ គ្រប់សាសន៍ គ្រប់ភាសា” (វិវរណៈ ១៧:១៥)។ ដូច្នេះ សត្វកំណាចសមុទ្រនេះ មិនមែនតំណាងឲ្យអ្វីដែលថ្មីទាំងស្រុងនោះឡើយ។ វាដើបចេញពីក្នុងចំណោមប្រទេសដែលមានពីមុនមក។ ភិនភាគរបស់វាប្រាប់យើងថា វាពាក់ព័ន្ធទៅនឹងសត្វនាគ។ ពួកវាទាំង២មានក្បាល៧ និងមានស្នែង១០។ សូមស្តាប់រឿងនេះចុះ៖

“នាគក៏ឲ្យឫទ្ធិ និងបល្ល័ង្ករបស់វាដល់សត្វនោះ ព្រមទាំងអំណាចយ៉ាងធំដែរ” (វិវរណៈ ១៣:២)។

ដូច្នេះ សត្វកំណាចសមុទ្រតំណាងឲ្យអាណាចក្ររ៉ូមប្រភេទថ្មី។ វាគឺជាអាណាចក្រសាសនា ដែលយើងស្គាល់ថាជាព្រះវិហាររ៉ូម ឬក៏ព្រះវិហាររ៉ូម៉ាំងកាតូលិក។ អាណាចក្រ

សាសនានេះ ដែលជាសាសនារ៉ូម៉ាំងកាតូលិក បានជំនួសអាណាចក្រសាសនាក្លែងក្លាយរបស់រ៉ូម។ “ឈ្មោះប្រមាថ” របស់វា បញ្ជាក់ថា វាជាសាសនាក្លែងក្លាយ ប្រឆាំងនឹងព្រះពិត។

ហោរាបានសរសេរថា ៖

“ហើយផែនដីក៏អស្ចារ្យនឹងសត្វនោះ គេក្រាបថ្វាយបង្គំដល់នាគ ដែលឲ្យសត្វនោះមានអំណាច ព្រមទាំងក្រាបថ្វាយបង្គំដល់សត្វនោះដែរ ដោយនិយាយថា តើមានអ្នកណាដូចសត្វនេះ? មានអ្នកឯណាដែលអាចច្បាំងនឹងវាបាន?” (វិវរណៈ ១៣:៣,៤)។

ចរិតលក្ខណៈពិតរបស់សត្វកំណាចសមុទ្រ គឺត្រូវបានបង្ហាញនៅក្នុងពាក្យពីរ ដែលខ្ញុំទើបតែបានអាន។ “ថ្វាយបង្គំ” និង “សង្គ្រាម”។ ដូចសាសនាក្លែងក្លាយរបស់អាណាចក្ររ៉ូមនៅពីមុន វាបានបង្រួមសាសនា និងរដ្ឋាភិបាលជាមួយគ្នា។ ព្រះវិហារ និងរដ្ឋ។ មេដឹកនាំនៃអាណាចក្រថ្មីនេះ គឺជាសង្ឃនាយករបស់ទីក្រុងរ៉ូម ដែលម្យ៉ាងទៀត ហៅថាស្តេចប៉ាប។ ទ្រង់មានអំណាចទាំងខាងសាសនា និងខាងនយោបាយ។

មិត្តទាំងឡាយអើយ នៅពេលដែលព្រះវិហារ និងរដ្ឋបានរួបរួមគ្នា រឿងអាក្រក់អាចកើតឡើងបាន។ សាសនាក្លែងក្លាយរបស់រ៉ូមបានធ្វើទុក្ខបុកម្នេញ ហើយត្រូវបានសំលាប់អ្នកជឿគ្រីស្ទសាសនាអស់រាប់ពាន់នាក់ ដែលមិនព្រមថ្វាយបង្គំព្រះរបស់ពួកអធិរាជ។ ឥឡូវ អាណាចក្រសត្វកំណាចសមុទ្រទទួលបានប្រព័ន្ធព្រះវិហាររដ្ឋមកពីសត្វនាគ។

ហោរាប្រាប់យើងថា សត្វកំណាចសមុទ្រ “ក៏ឲ្យមានអំណាចនឹងធ្វើការវាក្នុងរវាង ៤២ខែ” (វិវរណៈ ១៣:៥)។

“ក៏មានអំណាចបានប្រគល់ដល់វា ឲ្យច្បាំងឈ្នះពួកបរិសុទ្ធ ហើយនិងអំណាចលើគ្រប់ទាំងពូជមនុស្ស” (វិវរណៈ ១៣:៧)។

នៅក្នុងមេរៀនមុន យើងបាននិយាយអំពីរយៈពេលនៃ៤២ខែនេះ។ គឺដូចគ្នាទៅនឹង ៣ឆ្នាំកន្លះ ឬក៏១២៦០ថ្ងៃ នៅក្នុងពេលវេលានៃការទោះទាយទុកមុន។ នៅក្នុងបទទំនាយថ្ងៃនីមួយៗតំណាងឲ្យ១ឆ្នាំនៅក្នុងពេលវេលាពិត។ នេះប្រាប់យើងថា សត្វកំណាចសមុទ្រមានអំណាចធ្វើទុក្ខបុកម្នេញពួកបរិសុទ្ធ ជារាស្ត្ររបស់ព្រះជាម្ចាស់ចំនួន១២៦០ឆ្នាំ។



ព្រះវិហាររ៉ូម តំណាងដោយសត្វសមុទ្រកំណាច ទទួលបានតំបន់ត្រួតត្រាពីអាណាចក្ររ៉ូម៉ាំង។ ហើយដូចអាណាចក្ររ៉ូម៉ាំង វាបានធ្វើការរបស់សត្វនាគដ៏អស្ចារ្យ គឺសាតាំង។ មេដឹកនាំព្រះវិហារមានអំណាចយ៉ាងធំខាងនយោបាយ។ ពួកគេអាចធ្វើសង្គ្រាមនៅក្នុងនាមសាសនា។ ពួកគេអាចបង្ខំមនុស្សឲ្យធ្វើតាមសង្ឃរបស់ពួកវា។ ពួកគេអាចធ្វើទារុណកម្មដល់មនុស្សដែលបានបដិសេធមិនព្រមជឿគោលលទ្ធិរបស់វា។

បន្ទាប់ពីអាណាចក្ររ៉ូមុ៊ាំងបានដួលរលំ ព្រះវិហាររ៉ូម៉ាំងបានធ្វើទុក្ខបុកម្នេញ ដល់គ្រីស្ទានដែលគោរពកោតខ្លាចព្រះ ដែលបដិសេធមិនទទួលយកអំណាចរបស់នាយកសង្ឃកាតូលិក និងស្តេចប៉ាប។ បញ្ហាបែបនេះបន្តកើតមានជាច្រើនសតវត្សរ៍។ ព្រះវិហារបានបញ្ជូនទ័ពទៅប្រយុទ្ធប្រឆាំងនឹងមនុស្សដែលមានចិត្តស្មោះត្រង់ ជាមនុស្សដែលមិន

យល់ស្របជាមួយនឹងការបង្រៀនរបស់ព្រះវិហាររ៉ូម៉ាំង។ វាគឺជាពេលវេលា ដែលសោកសៅ អាក្រក់ ហើយនិងមានការកាប់សំលាប់។

រយៈពេល១២៦០ឆ្នាំនៃការគ្រប់គ្រងរបស់ព្រះវិហារបានមកដល់ទីបញ្ចប់នៅក្នុងឆ្នាំ ១៧៩៨ ពេលដែលស្តេចប៉ាបនៃទីក្រុងរ៉ូម ត្រូវបានចាប់ខ្លួន ហើយត្រូវបាននិរទេសខ្លួនចេញ។ ចំពោះសត្វកំណាចសមុទ្រនៃបទទំនាយ នោះគឺជារបួសដល់ស្លាប់។ សូមស្តាប់ពាក្យសម្តីរបស់ហោរា ៖

“ខ្ញុំឃើញក្បាលវា១ដូចជាបានកាប់សំលាប់ហើយ តែរបួសដល់ស្លាប់នោះ បានសះជាឡើងវិញ” (វិវរណៈ ១៣:៣)។



ឥឡូវដល់ពេល ត្រូវមើលទៅសត្វកំណាចចុងក្រោយ។ សូមស្តាប់ ៖

“ខ្ញុំក៏ឃើញសត្វសាហាវ១ទៀត ឡើងចេញពីដីមក វាមានស្នែង២ ដូចជាកូនចៀម តែពោលពាក្យដូចនាគវិញ” (វិវរណៈ ១៣:១១)។

សត្វកំណាចដីគោកនេះ តំណាងឲ្យអំណាចពិភពលោក ដែលមានជីវិតរស់នៅចុងឆ្នាំ១២៦០ឆ្នាំនៃការគ្រប់គ្រងរបស់រ៉ូម៉ាំងកាតូលិក។ វាងើបឡើងឆ្ងាយពី “ប្រជាជនមនុស្សផងទាំងឡាយ គ្រប់សាសន៍ គ្រប់ភាសា” នៃអាណាចក្រមុនៗ។ ភិនភាគរបស់វាបានរំឭកហោរាអំពីកូនចៀមតូច។ ប៉ុន្តែ នៅពេលដែលសត្វកំណាចនិយាយ វាមានសំលេងរបស់សត្វនាគ។

ប្រវត្តិសាស្ត្រប្រាប់យើងថាមានតែប្រទេស១យ៉ាងធំដែលត្រូវទៅនឹងការពិពណ៌នានោះ។ គឺមានតែសហរដ្ឋអាមេរិកនោះហើយ។ វាត្រូវបានតាំងនៅក្នុងតំបន់ដែលគេចាត់ទុកថាជា “ពិភពលោកថ្មី”។

អ្នកដែលរកឃើញសហរដ្ឋអាមេរិក ចង់មានសេរីភាព។ ពួកគេបានឃើញ និងជួបការឈឺចាប់ច្រើនពេក បង្កឡើងដោយអ្នកដែលគ្មានសេរីភាពខាងសាសនា។ ពួកគេចង់ធ្វើតាមមនសិការរបស់ខ្លួនឯង។

ពួកគេបង្កើតរដ្ឋាភិបាលដោយផ្អែកទៅលើគោលការណ៍នៃការបំបែកព្រះវិហារ និងរដ្ឋចេញពីគ្នា។ ពួកគេជឿថា សាសនាគួរតែជារឿងផ្ទាល់ខ្លួន មិនមែនជារឿងរបស់ច្បាប់ទេ។ សហរដ្ឋអាមេរិក ត្រូវបានគេស្គាល់ថាជា “ទឹកដីនៃសេរីភាព”។

មកដល់សព្វថ្ងៃនេះ យើងបាននិយាយអំពីបទទំនាយដែលបានបំពេញរួចហើយ។ ប្រវត្តិសាស្ត្របានបញ្ជាក់ថា បទទំនាយទាំងនេះគឺជាការពិត។ ប៉ុន្តែ ឥឡូវយើងនឹងមើលអំពីអនាគត អំពីតួនាទីរបស់សហរដ្ឋអាមេរិកដែលវានឹងធ្វើនៅក្នុងបញ្ហាគួរឲ្យចាប់អារម្មណ៍ចុងក្រោយ មុនការយាងត្រឡប់មកជាលើកទី២របស់ព្រះយេស៊ូ។



សូមស្តាប់នូវអ្វីដែលហោរាបានសរសេរអំពីសត្វដែលចេញពីដីគោកដ៏កំណាចនោះ គឺសត្វកំណាចដែលមានស្នែង២ដូចកូនចៀម និងសំលេងដូចសត្វនាគ ៖

“ក៏ប្រព្រឹត្តដោយនូវគ្រប់ទាំងអំណាចរបស់សត្វទី១ នៅមុខនាគនោះ ទាំងបណ្តាលឲ្យផែនដី និងអស់អ្នកដែលនៅផែនដីបានក្រាបថ្វាយបង្គំដល់សត្វទី១ដែលមានរបួសដល់ស្លាប់នោះ តែបានសះជាវិញនោះផង” (វិវរណៈ ១៣:១២)។

តាមរយៈរឿងនេះ សត្វកំណាចដីគោក ដែលជាសហរដ្ឋអាមេរិក នឹងទទួលយកអំណាច និងការងាររបស់សត្វកំណាចសមុទ្រ ជាអំណាចរបស់សាសនាកាតូលិក។ វានឹងដាក់ច្បាប់ដែលដាក់កំរិតលើសេរីភាពខាងផ្នែកសាសនា។ សហរដ្ឋអាមេរិក ជាប្រទេសដែលមានអំណាចខ្លាំងក្លាបំផុតនៅលើផែនដី នឹងបង្ខំមនុស្សឲ្យគោរពសាសនាក្លែងក្លាយ។

តាមរយៈហោរា សាសនាក្លែងក្លាយនោះនឹងធ្វើជាគំរូអំពីសាសនានៃសត្វកំណាចសមុទ្រ ដែលជាព្រះវិហាររ៉ូម៉ាំង។ សូមស្តាប់ ៖

“វាបញ្ឆោតពួកមនុស្សនៅផែនដី … ក៏ប្រាប់ដល់ពួកអ្នកនៅផែនដី ឲ្យធ្វើរូបសត្វនោះដែលត្រូវរបួសនឹងដាវ តែបានរស់វិញដែរ” (វិវរណៈ ១៣:១៤)។

ខ្ញុំសុំសួរអ្នកនូវរឿងមួយ ៖ តើអ្នកគិតថា ពិភពលោកនឹងក្លាយជាកន្លែងដែលល្អប្រសើរដែរឬទេ បើសិនជាគ្រប់គ្នាមានសាសនាដូចគ្នា? បើសិនជាគ្រប់គ្នា ទាំងតូចទាំងធំ ទាំងមានទាំងក្រ ជាក្រុមជំនុំនៅក្នុងព្រះវិហារតែមួយ?

តើនោះនឹងដោះស្រាយបញ្ហារបស់ពិភពលោកឬ?(រង់ចាំពីរឬបីវិនាទី ខណៈពេលដែលមនុស្សគិត)

វាពិបាកនឹងឆ្លើយសំណួរនោះ តើមែនទេ? ចម្លើយគឺអាស្រ័យទៅលើប្រភេទសាសនា ឬប្រភេទនៃព្រះវិហារអ្វីដែលយើងនិយាយនោះ។ តើខ្ញុំនិយាយត្រូវដែរឬទេ?

បទទំនាយនេះប្រាប់យើងថា សហរដ្ឋអាមេរិក នឹងនាំមុខគេនៅក្នុងការរៀបចំសាសនាសម្រាប់ពិភពលោកទាំងមូល។ សាសនានេះ នឹងមានរូបភាព ឬក៏មានភិនភាគដូចជាសត្វកំណាចសមុទ្រ។ វាគឺជាសាសនារបស់សត្វនាគ។ វាគឺជាសាសនានៃអំណាច។ វាគឺជាសាសនាដែលមិនឲ្យមនុស្សម្នាក់ៗមានសេរីភាពខាងមនសិការឡើយ។

សូមស្តាប់បន្ថែមទៀត អំពីសត្វកំណាចដីគោក ៖

“ក៏មានអំណាចបានប្រគល់ឲ្យវា នឹងធ្វើឲ្យរូបសត្វនោះមានខ្យល់ដង្ហើម ដើម្បីឲ្យបានចេះនិយាយ ហើយអំណាចនឹងធ្វើឲ្យពួកអ្នកដែលមិនព្រមក្រាបថ្វាយបង្គំសត្វនោះ ត្រូវស្លាប់ផង” (វិវរណៈ ១៣:១៥)។

មិត្តអើយ តើនោះជាប្រភេទសាសនាដែលនឹងធ្វើឲ្យពិភពលោកក្លាយទៅជាកន្លែងដ៏ល្អប្រសើរឬ? ខ្ញុំគិតថា មិនអញ្ចឹងទេ។

ខ្ញុំសូមរំឭកនូវអ្វីដែលយើងបានរៀនអំពីសត្វកំណាចដីគោកនេះ ដែលជានិមិត្តសញ្ញានៃបទទំនាយសម្រាប់សហរដ្ឋអាមេរិក។

យើងដឹងថា វាមានជីវិតនៅចុងបញ្ចប់នៃ១២៦០ឆ្នាំនៃការគ្រប់គ្រងរបស់រ៉ូម៉ាំងកាតូលិក។

យើងដឹងថា វាមិនផុសចេញនៅក្នុងចំណោមប្រទេសដទៃឡើយ ប៉ុន្តែ នៅក្នុងផ្នែកនៃពិភពលោកថ្មី។

រឿងទាំងអស់នេះ យើងដឹងពីប្រវត្តិសាស្ត្រ។ ឥឡូវ នេះគឺជាអ្វីដែលយើងរំពឹងថានឹងកើតមានឡើងឆាប់ៗ៖

ថ្វីបើសហរដ្ឋអាមេរិកបានផ្តល់សេរីភាពខាងសាសនាដល់មនុស្សពីដើមដំបូងក៏ពិតមែន នៅពេលអនាគត ការនោះនឹងប្រែប្រួល។

យើងរំពឹងថា វានឹងនិយាយក្នុងនាមជាសត្វនាគ ជាមួយនឹងអំណាចសិទ្ធអំណាចខាងសាសនានៃសត្វកំណាចសមុទ្រដែលបានទៅមុនវា។

សហរដ្ឋអាមេរិកនឹងកោះហៅឲ្យពិភពលោកទាំងមូលចូលរួមគោរពសាសនាតែមួយផ្អែកទៅលើគោលការណ៍របស់ព្រះវិហាររ៉ូម។

សព្វថ្ងៃនេះ គ្មានចម្ងល់អំពីអំណាច និងឥទ្ធិពលរបស់សហរដ្ឋអាមេរិកទេ។ វាគឺជាប្រទេសដ៏ធំធេង ហើយវាបានធ្វើអំពើល្អយ៉ាងច្រើននៅក្នុងពិភពលោកយើងនេះ។ ប៉ុន្តែខ្ញុំជឿថា អំណាចនោះអាច ហើយនឹងត្រូវបានប្រើប្រាស់ក្នុងបំណងអាក្រក់។

បើសិនជាប្រទេសទាំងអស់នៅលើពិភពលោកចូលរួមជាមួយនឹងសហរដ្ឋអាមេរិកនៅក្នុងការបង្កើតសាសនាតែមួយសម្រាប់ពិភពលោក តើអ្នកនឹងធ្វើដូចម្តេច?

បើសិនជាសាសនាតែមួយរបស់ពិភពលោកលុបបំបាត់បញ្ញត្តិ១០ប្រការ តើអ្នកនឹងធ្វើដូចម្តេច?

បើសិនជាវាលុបបំបាត់ថ្ងៃបរិសុទ្ធនៃបញ្ញត្តិទី៤ ហើយតម្រូវឲ្យអ្នកថ្វាយបង្គំនៅថ្ងៃផ្សេង តើអ្នកនឹងធ្វើដូចម្តេច?

មិត្តអើយ សត្រូវដ៏ធំរបស់យើង គឺសត្វនាគ ហៅសាតាំង។ វាចង់ឲ្យព្រះយេស៊ូ ក្រាបថ្វាយបង្គំវា វាចង់បានពីយើងបែបនោះដែរ។ វាបានប្រើអំណាច និងទ័ព ព្រះវិហារ ស្តេចប៉ាប និងសង្ឃនាយក ដើម្បីបង្វែរយើងចេញពីសេចក្តីពិត ទៅរកសេចក្តីមិនពិត ហើយពីព្រះជាម្ចាស់ទៅខ្លួនវា។



ការសាកល្បងចុងក្រោយសម្រាប់រាស្ត្ររបស់ព្រះជាម្ចាស់ គឺជាការសាកល្បង អំពីការជឿទុកចិត្ត។ តើយើងនឹងជឿទុកចិត្តលើព្រះវរបិតានៃនគរឋានសួគ៌របស់យើង ឲ្យទ្រង់មើលថែយើង ការពារយើងពីអំណាចរបស់សត្វនាគ សត្វកំណាចសមុទ្រ ហើយនិងសត្វកំណាចដីគោកដែរឬទេ? បើសិនជាយើងជឿទុកចិត្តលើទ្រង់ទាំងស្រុង យើងអាចស្ថិតនៅក្នុងចំណោមពួកអ្នកដែលត្រូវបានប្រោសលោះគ្រប់សម័យកាល ដែលនឹងទទួលស្វាគមន៍ព្រះយេស៊ូ នៅពេលដែលទ្រង់យាងមកម្តងទៀត។ យើងប្រាកដ ជាមានកន្លែងនៅក្នុងនគរអស់កល្បរបស់ផងទ្រង់ជាមិនខាន។

ថ្ងៃនេះ តើអ្នកសុខចិត្តដាក់ខ្លួន ហើយនិងក្រុមគ្រួសាររបស់អ្នកនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ដែរឬទេ? តើអ្នកទុកចិត្តឲ្យទ្រង់មើលថែអ្នកនៅក្នុងជីវិតនេះ ហើយនិងជីវិតនាពេលខាងមុខ ដែរឬទេ? បើសិនជាអ្នកសុខចិត្ត សូមមេត្តាឈរជាមួយនឹងខ្ញុំ ពេលដែលយើងអធិស្ឋាន។

ឱព្រះវរបិតានៅឯនគរឋានសួគ៌ ពេលដែលពួកទូលបង្គំអានព្រះបន្ទូលរបស់ទ្រង់នៅថ្ងៃនេះ ពួកទូលបង្គំបានឃើញពីរបៀបដែលសត្រូវដ៏ធំរបស់ទ្រង់បានធ្វើការទៅលើមនុស្សគ្រប់សម័យកាល។ ពួកទូលបង្គំអាចមើលដឹងថា ពួកទូលបង្គំកំពុងតែរស់នៅក្នុង

ទីបញ្ចប់នៃរឿងដ៏វែងអន្លាយនោះហើយ។ ក្នុងពេលឆាប់ៗ ពួកទូលបង្គំនឹងឃើញប្រទេសទាំងឡាយនៅលើផែនដីមករួមគ្នាគោរពសាសនាក្លែងក្លាយតែមួយ។ ប៉ុន្តែ ពួកទូលបង្គំចង់ថ្វាយបង្គំទ្រង់តែមួយអង្គគត់។ នឹងមានពេលវេលាលំបាកនៅពេលខាងមុខសម្រាប់អស់អ្នកដែលឈរនៅទីនេះនៅថ្ងៃនេះ។ ព្រះបិតាអើយ សូមជួយផ្តល់កំលាំង និងការពារពួកទូលបង្គំ។ សូមជួយឲ្យពួកទូលបង្គំជឿទៅលើទ្រង់ទាំងស្រុង។ សូមឲ្យជីវិតពួកទូលបង្គំបានភ្លឺ ដោយពរនៃសេចក្តីសង្ឃឹមនៃការយាងត្រឡប់មកវិញរបស់ព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូ។ ពួកទូលបង្គំទូលសូមនៅក្នុងព្រះនាមរបស់ទ្រង់។ អាម៉ែន។

ខព្រះគម្ពីរបន្ថែមសម្រាប់ប្រធានបទនេះ

ថែស្សាឡូនិចទី១ ២:៤ | វិវរណៈ ១៤:៩-១២ | វិវរណៈ ១៣:៨
វិវរណៈ ១៥:២-៣ | វិវរណៈ ១៣:១៤ | វិវរណៈ ១៨:៤
វិវរណៈ ១៣:១៦-១៧

## លំនាំពិភាក្សា

**ដានីញ៉ែលៈ របៀបរស់នៅរបស់ព្រះសម្រាប់សុខភាពល្អ**

១. តើអាហារអ្វីដែលគេបានឲ្យលោកដានីញ៉ែល និងមិត្តភក្តិរបស់គាត់?

២. តើព្រះប្រទានពរចំពោះភាពស្មោះត្រង់របស់ពួកគាត់ដែលបានគោរពប្រតិបត្តិតាមផ្លូវរបស់ទ្រង់ដោយរបៀបណា?

៣. តើស្តេចផ្តល់កិត្តិយសឲ្យលោកដានីញ៉ែល ហើយនិងមិត្តភក្តិរបស់គាត់ដោយរបៀបណា?

**សហរដ្ឋអាមេរិកស្ថិតនៅក្នុងបទទំនាយ**

១. តើនរណាជាសត្វនាគនៃព្រះគម្ពីរវិវរណៈ ជំពូក១២?

- វិវរណៈ ១២:៣

២. តើសត្វនាគបានព្យាយាមបំផ្លាញពូជរបស់ស្ត្រី-ព្រះយេស៊ូ?

- វិវរណៈ ១២:៤
- ម៉ាថាយ ៩:៨-១០

៣. តើអ្នកណាដែលតំណាងដោយសត្វកំណាចពីសមុទ្រ? តើវាមានអំណាចរយៈពេលយូរប៉ុណ្ណា ហើយតើវាបាត់បង់អំណាចទៅវិញដោយរបៀបណា?

- វិវរណៈ ១៣:២-៧

៤. សត្វកំណាចដែលផុសចេញពីផែនដី បន្ទាប់ពីសត្វកំណាចសមុទ្រ មានសិទ្ធិអំណាចលើសត្វកំណាចសមុទ្រ។ តើសត្វកំណាចនេះតំណាងឲ្យប្រទេសណា ហើយតើវានឹងបង្កើតច្បាប់អ្វី?

- វិវរណៈ ១៣:១៤

៥. តើមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់មានសុវត្ថិភាពពីការធ្វើទុក្ខបុកម្នេញ ឬក៏ការសំលាប់ ដោយសារតែសេចក្តីជំនឿរបស់ពួកគេ ដែរឬទេ?

- វិវរណៈ ១៣:១៥